**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០៤/០៧-០៩-២០០៩-អវតក/កសចស(អបជ ៦១) |
| **ដាក់ទៅ** | ៖ | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | ៖ | ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ |
| **ភាគីអ្នកដាក់** | ៖ | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | ៖ | អង់គ្លេស |

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Jan-2020, 13:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖** សម្ងាត់ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់ចំនួន៣

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖** សម្ងាត់/Confidential

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ៖**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ៖**

**ហត្ថលេខា៖**

---

# បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ
# ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (D381)

---

**អ្នកដាក់ឯកសារ៖**
លោកស្រី Brenda J. Hollis
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន៖**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ផុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហមេធាវីការពារក្តី យឹម ទិត្យ**
លោក សូ ម៉ូសេ្សនី
លោកស្រី Suzana TOMANOVIĆ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
**ទាំងអស់ក្នុងសំណុំរឿង០០៤**

# មាតិកា

**I. សេចក្តីផ្តើម** ..... 5

**II. ប្រវត្តិនីតិវិធី** ..... 6

**III. ច្បាប់ជាធរមាន** ..... 6

ក. បទដ្ឋាននៃការពិនិត្យឡើងវិញចំពោះសេចក្តីសម្រេចលើយុត្តាធិការបុគ្គល ..... 6

ខ. បទដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម ..... 9

គ. លក្ខខណ្ឌតម្រូវឱ្យមានការស៊ើបសួរ និងចេញសេចក្តីសម្រេចលើអង្គហេតុនានា ដែលស្ថិតក្រោមវិសាលភាពនៃរឿងក្តីនេះ ..... 11

ឃ. លក្ខខណ្ឌតម្រូវចំពោះសេចក្តីសម្រេចដែលមានសំអាងហេតុ រួមមានការសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទ ..... 13

ង. បទដ្ឋាននៃភស្តុតាងសម្រាប់ការបញ្ជូនរឿងទៅជំនុំជម្រះ ..... 15

**IV. សារណាបណ្តឹងឧទ្ធរណ៍** ..... 16

ក. ដីកាសម្រេចលើកលែងការចោទប្រកាន់ មានកំហុសអង្គច្បាប់ ដោយសារតែការសម្រេចថា ឌុច គឺជាជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" តែម្នាក់គត់ ..... 17

១. ការសម្រេចផ្ទុយទៅនឹងដីកាដំណោះស្រាយលើសំណុំរឿង ០០៤/១ និងដីកាសម្រេចលើកលែងការចោទប្រកាន់លើសំណុំរឿង ០០៤/២ ..... 18

២. ការសម្រេចផ្ទុយនឹងភាសាដ៏ច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ..... 18

៣. ការសម្រេចនេះពុំស្របនឹងការយល់ឃើញរបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ទៅលើយុត្តាធិការបុគ្គល នៅពេលបង្កើត អ.វ.ត.ក នោះទេ ..... 19

ខ. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ដោយខកខានច្រើនដងក្នុងការចេញសេចក្តីសម្រេចដែលមានសំអាងហេតុ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងលទ្ធភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ យឹម ទិត្យ ..... 27

១. ការគ្មានសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់ទាក់ទងថាតើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តស្ថិតក្នុង យុត្តាធិការនៃ អ.វ.ត.ក និងថាតើ យឹម ទិត្យ ទំនងជាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះដែរឬទេ ........ 27

២. ការខកខានមិនបានវាយតម្លៃទៅលើភ័ស្តុតាង និងបង្កើតសំអាងហេតុ ទាក់ទងនឹងតួនាទី និងអំណាច តាមព្រឹត្តហេតុ របស់ យឹម ទិត្យ ........ 33

៣. ការដកទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍មួយចំនួន ដោយមិនត្រឹមត្រូវចេញពីការពិចារណា..... 40

៤. ការមិនបានពិចារណាលើលទ្ធភាពនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះអំពើប្រល័យពូជសាសន៍ក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល ........ 42

៥.ការមិនពិចារណាពីជនរងគ្រោះផ្សេងទៀតក្រៅពីជនទាំងឡាយណាដែលត្រូវបានសម្លាប់ នៅពេលវាយតម្លៃទៅលើយុត្តាធិការបុគ្គល ........ 49

គ. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសផ្នែកអង្គច្បាប់ តាមរយៈការពិចារណាពីបញ្ហារបស់ថ្នាក់លើ និងការបង្ខិតបង្ខំ នៅពេលវាយតម្លៃលើយុត្តាធិការបុគ្គល........ 51

១. ការពឹងផ្អែកលើបញ្ហារបស់ថ្នាក់លើក្នុងការវិភាគពីយុត្តាធិការបុគ្គល ........ 51

២. ការពឹងផ្អែកលើការបង្ខិតបង្ខំក្នុងការវិភាគពីយុត្តាធិការបុគ្គល ........ 56

៣. ការពិចារណាលើបញ្ហាថ្នាក់លើ និងការបង្ខិតបង្ខំ តាមរបៀបផ្សេងគ្នា ក្នុងសំណុំរឿង ០០១ និង ០០៤........ 62

ឃ. ដីកាលើកលែងការចោទប្រកាន់មានកំហុសនៅក្នុងការពិចារណាលើទម្រង់នៃការចូលរួម និងភាពនៅជិតឧក្រិដ្ឋកម្មរបស់ យឹម ទិត្យ នៅពេលកំណត់លើកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ........ 66

១. ការផ្តល់ទម្ងន់ជ្រុលហួសលើ "ការចូលរួមផ្ទាល់" នៅក្នុង និងភាពនៅជិតឧក្រិដ្ឋកម្មនៅក្នុងការវិភាគលើយុត្តាធិការបុគ្គល ........ 66

២. ការខកខានពិចារណាលើការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម នៅពេលធ្វើការវាយតម្លៃលើយុត្តាធិការបុគ្គល ........ 72

ង. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុស ដោយបានការធ្វើការសន្និដ្ឋានផ្នែកអង្គហេតុដែលនាំឲ្យមានការខុសឆ្គោយរបស់តុលាការ ........ 82

១. ការរកឃើញថា មានតែកម្មាភិបាល ប.ក.ក មួយចំនួនប៉ុណ្ណោះ មានសិទ្ធិអំណាចធ្វើការសម្រេចចិត្តអំពីការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ .............. 82

២. ការរកឃើញថា យឹម ទិត្យ អាចមានមុខនាទីក្នុងភូមិភាគមួយ ក្នុងរយៈពេលណាមួយ .......... 92

៣. ការរកឃើញដែលថា តួនាទីតែមួយគត់របស់ យឹម ទិត្យ នៅថ្នាក់ភូមិភាគពាយ័ព្យ គឺត្រឹមថ្នាក់សមាជិកគណៈកម្មាធិការ............................................................................ 93

៤. ការរកឃើញដែលថា យឹម ទិត្យ មិនមានអ្នកក្រោមបង្គាប់.............................................. 94

៥. ការរកឃើញដែលថា ការសម្លាប់បានធ្លាក់ចុះក្រោយសេចក្តីប្រកាសរបស់ ខៀវ សំផន ដែលត្រូវបានអះអាងនៅពាក់កណ្តាលឆ្នាំ ១៩៧៨............................................................................ 97

ច. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយផ្តល់ទម្ងន់លើអង្គហេតុដែលមានភាពពាក់ព័ន្ធតិចតួច ......................................................................................... 100

១. ការរកឃើញថា យឹម ទិត្យ មិនមែនជាសមាជិកម្នាក់នៃសភាតំណាងប្រជាជន................. 100

២. ការសន្និដ្ឋានថា យឹម ទិត្យ មិនមានតួនាទីក្នុងកងទ័ព ........................................ 101

៣. ការសន្និដ្ឋានដែលថា យឹម ទិត្យ មិនជាប់ពាក់ព័ន្ធក្នុងការរៀបចំការផ្ទេរកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ ......................................................................... 103

៤. ការសន្និដ្ឋានដែលថា ការបោសសម្អាតបានចាប់ផ្តើមមួយផ្នែករួចទៅហើយ និងទីតាំងឧក្រិដ្ឋកម្មខ្លះបានដំណើរការរួចហើយមុនការមកដល់ភូមិភាគពាយ័ព្យរបស់ យឹម ទិត្យ.......................... 104

៥. ការសន្និដ្ឋានដែលថា មានកម្មាភិបាលប្រមាណ ១០០នាក់ ដែលបានបម្រើការនៅថ្នាក់តំបន់ និងថ្នាក់ភូមិភាគ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ................................................ 104

៦. ការសន្និដ្ឋានដែលថា សាក្សីមួយចំនួនមិនបានឮអំពី យឹម ទិត្យ .................................. 105

**V. ផលវិបាកផ្នែកច្បាប់នៃដីកាដំណោះស្រាយខ្វែងគ្នា ..................................................107**

**VI. សេចក្តីសន្និដ្ឋាន .........................................................................................113**

# I. សេចក្ដីផ្ដើម

1. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយមួយ លើកលែងចោទប្រកាន់ យឹម ទិត្យ ("ដីកាសម្រេចលើកលែងចោទប្រកាន់") ដោយផ្អែកលើមូលដ្ឋានថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ ឡើយ[1]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ចោទប្រកាន់ យឹម ទិត្យ ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ការរំលោភទៅលើក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[2]។

2. ដីកាសម្រេចលើកលែងចោទប្រកាន់ ផ្អែកលើការសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតនៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានា និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ឡើយ។ យ៉ាងណាក៏ដោយ ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់នេះ ផ្អែកលើកំហុសឆ្គងផ្នែកអង្គច្បាប់ និងអង្គហេតុជាច្រើន ដែលកំហុសនីមួយៗ ឬជារួម ធ្វើឱ្យដីកាសម្រេចលើកលែងចោទប្រកាន់នេះគ្មានសុពលភាព និង/ឬបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ និងជាកត្តាកំណត់យ៉ាងសំខាន់នៃសេចក្ដីសន្និដ្ឋានលើយុត្តាធិការបុគ្គល។ ការបន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ របស់ យឹម ទិត្យ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ជាចម្បង បណ្ដាលមកពីការបកស្រាយមិនត្រឹមត្រូវលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ការខកខានដដែលៗក្នុងការចេញសេចក្ដីសម្រេចដែលមានសំអាងហេតុ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង និងភវនីយភាពនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ការពឹងផ្អែកមិនត្រឹមត្រូវទៅលើបញ្ជារបស់ថ្នាក់លើ និងការបង្ខិតបង្ខំ ការផ្ដល់ទម្ងន់យ៉ាងលើសលប់ចំពោះ "ការចូលរួមដោយផ្ទាល់" នៅក្នុង និងភាពនៅកៀកកិតនឹងឧក្រិដ្ឋកម្ម ខណៈដែលបដិសេធពុំពិចារណាទៅលើទម្រង់

---

[1] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ ថ្ងៃទី ២៨ខែ មិថុនា ឆ្នាំ ២០១៩ ("ដីកាសម្រេចលើកលែងចោទប្រកាន់") កថាខណ្ឌ ៦៨៦។ ដីកាសម្រេចលើកលែងចោទប្រកាន់ ទទួលស្គាល់ថាមានការយល់ឃើញថា យឹម ទិត្យ ពុំស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់អ.វ.ត.កឡើយ នៅមុនថ្ងៃទី ៩ ខែធ្នូ ឆ្នាំ២០១៥ ក្នុងអំឡុងពេលកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដែលពុំបានជូនដំណឹងថាកិច្ចស៊ើបសួរនឹងត្រូវបញ្ចប់មិនឱ្យហួសថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧។ *សូមមើល* **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤, ១៦, ៤៦-៤៧។

[2] ឯកសារ **D382** ដីកាដំណោះស្រាយ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

នៃការទទួលខុសត្រូវផ្សេងៗទៀត កំហុសអង្គហេតុបន្ថែមជាច្រើនអំពីបញ្ហានានាដែលមានសារៈសំខាន់ចំពោះការវិភាគលើយុត្តាធិការបុគ្គល និងការពិចារណា មិនសមស្របទៅលើកត្តានានាដែលមានភាពពាក់ព័ន្ធបន្តិចបន្តួចមិនសំខាន់។

3. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ឥឡូវនេះ ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ដោយអនុលោមតាមវិធាន៦៧(៥) និង៧៤(២)[3] នៃវិធានផ្ទៃក្នុង។ ស.ព.អ សូមស្នើឱ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") បដិសេធដីកាសម្រេចលើកលែងចោទប្រកាន់នេះ ដោយសារកំហុសនានានៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ និងសម្រេចបញ្ជូនសំណុំរឿងប្រឆាំងនឹង យឹម ទិត្យ ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចេញដោយ ស.ច.ស.អ[4]។

## II. ប្រវត្តិនីតិវិធី

4. **ឧបសម្ព័ន្ធ ១** បង្ហាញពីប្រវត្តិនីតិវិធីដែលពាក់ព័ន្ធក្នុងរឿងក្ដីនេះ។

## III. ច្បាប់ជាធរមាន

### ក. បទដ្ឋាននៃការពិនិត្យឡើងវិញចំពោះសេចក្ដីសម្រេចលើយុត្តាធិការបុគ្គល

5. អង្គបុរេជំនុំជម្រះ បានសម្រេចថាឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ក្នុងការកំណត់ថាតើជនសង្ស័យស្ថិតនៅក្នុងប្រភេទជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ "មិនមែនគ្មានព្រំដែននោះទេ" ហើយ "មិនអនុញ្ញាតឱ្យបំពេញកិច្ចតាម

---

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី៩) ដែលបានកែប្រែ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") ឬ ("វិធាន")។

[4] សំណើសុំឱ្យមានដំណោះស្រាយនេះធ្វើឡើង ដោយសារតែស្ថានភាពមានដីកាដំណោះស្រាយពីរផ្ទុយគ្នា ពោលគឺ ដីកាដំណោះស្រាយមួយ គឺជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមួយទៀត គឺជាដីកាសម្រេចលើកលែងចោទប្រកាន់ នៅក្នុងសំណុំរឿងតែមួយ ដែលត្រូវយកមក ពិចារណាជាមួយគ្នា។ សំណើសុំឱ្យមានដំណោះស្រាយនេះ ផ្អែកលើការសន្មតថាបណ្ដឹងឧទ្ធរណ៍ណាក៏ដោយ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានតម្កល់ទេ។ នៅក្នុងស្ថានភាពនេះ កាលណាមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព វិធាន៧៧(១៣)(ខ) តម្រូវឱ្យ អ.ប.ជ ប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ។ *សូមមើលខាងក្រោម* ផ្នែកទី៤។

អំពើចិត្តទេ”[5]។ ដូច្នេះហើយ អ.ប.ជ អាចពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចនៃដីកាសម្រេចលើកលែងចោទប្រកាន់ ពាក់ព័ន្ធនឹងបញ្ហានេះ[6]។

6. នាពេលថ្មីៗនេះ អង្គបុរេជំនុំជម្រះ បានសម្រេចជាឯកច្ឆ័ន្ទថា៖

> សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិមួយអាចត្រូវបានបដិសេធចោល ក្នុងករណីដែលសេចក្តីសម្រេចនោះ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (*គឺ* កំហុសអង្គច្បាប់) ដែលនាំឲ្យសេចក្តីសម្រេចនោះគ្មានសុពលភាព [ឬ] (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវច្បាស់ក្រឡែត (*គឺ* កំហុសអង្គហេតុ) ដែលបណ្តាលឲ្យមានភាពមិនយុត្តិធម៌ [.] […]។ អាចនិយាយម្យ៉ាងទៀតថា ត្រូវបង្ហាញឲ្យឃើញថាមានកំហុស […] ដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[7]។

7. អង្គបុរេជំនុំជម្រះ បានសម្រេចជា៖

> គេបានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងច្បាប់យុត្តិសាស្ត្រអន្តរជាតិថា ចំពោះបណ្តឹងឧទ្ធរណ៍ ការភ័ន្តច្រឡំអង្គច្បាប់ដែលបានលើកឡើងត្រូវបានពិនិត្យមើល *ជាថ្មី* ដើម្បីសម្រេច ថាសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ និងការភ័ន្តច្រឡំអង្គហេតុត្រូវ បានពិនិត្យមើលស្របតាមបទដ្ឋានស្តីពីភាពសមស្របដើម្បី

[5] សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ (“សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម”) កថាខណ្ឌ ២០ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។ *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើបណ្តឹងសាទុក្ខ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ (“សាលដីការបស់ ឌុច”) កថាខណ្ឌ ៦៣-៧៤, ៧៩។

[6] សំណុំរឿង០០៤/១-ឯកសារ D308/3/1/20 សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ២០ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។

[7] សំណុំរឿង០០៤/១-ឯកសារ D308/3/1/20 សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ២១ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។

សម្រេចថា តើពុំមានអ្នកវិនិច្ឆ័យឥតលម្អៀងបានធ្វើសំអាងផ្អែកអង្គហេតុដែលបាន លើកឡើងដែរឬទេ[8]។

8. លើសពីនេះទៀត យុត្តិសាស្ត្រ អ.វ.ត.ក និងច្បាប់អន្តរជាតិ បានចែងយ៉ាងច្បាស់ថា នៅពេលមាន ភស្តុតាងបង្ហាញថាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិមួយ ពឹងផ្អែកលើសំអាងហេតុ និងសំអាងច្បាប់ ខុស អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ត្រូវធ្វើមោឃៈភាពសេចក្តីសម្រេចនោះ ដោយត្រូវបញ្ជូនត្រលប់ ទៅតុលាការកម្រិតទាបវិញ ដើម្បីឱ្យអនុវត្តបទដ្ឋានត្រឹមត្រូវ ឬចេញសេចក្តីសម្រេចផ្ទាល់ខ្លួនលើ បញ្ហានេះ[9]។

[8] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកា ដំណោះស្រាយ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ (“សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកា ដំណោះស្រាយ”) កថាខណ្ឌ ១១៣។

[9] អ.វ.ត.ក៖ សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើ ករណីឌុច ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ (“សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី” កថាខណ្ឌ ៤០,៤២ ។ សំណុំរឿង០០២-ឯកសារ **D300/1/7** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអំពីការណែនាំឲ្យពិចារណាឡើងវិញលើសំណើ D153, D172, D173, D174, D178 និង D284 ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ១៩,២៦ *ក្នុងចំណោមនោះ យោងទៅលើ* សំណុំរឿង០០២-ឯកសារ **D365/2/17** សាល ដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើប អង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវ ចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ៦៧,៨១។ សំណុំរឿង០០២- សំណុំរឿង០០២- ឯកសារ **D310/1/3** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេច បដិសេធសំណើសុំ សម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយ បង្ខំ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ១៥-១៦។ អន្តរជាតិ៖ សេចក្តីសម្រេចបន្ទាន់បង្ខំក្នុងរឿងក្តី *S. Milošević* កថាខណ្ឌ១០ *ដកស្រង់*ក្នុងឯកសារ **D260.1.2** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរក ភស្តុតាង ដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួមថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ២៥។ សេចក្តីសម្រេចបន្ទាន់បង្ខំក្នុងរឿងក្តី *S. Milošević* កថាខណ្ឌ ៥-៦។ សេចក្តីសម្រេចបន្ទាន់បង្ខំក្នុងរឿងក្តី *Karemera* កថាខណ្ឌ ៥។ សេចក្តីសម្រេចបន្ទាន់បង្ខំ ក្នុងរឿងក្តី *Uwinkindi* កថាខណ្ឌ៦។ សេចក្តីសម្រេចលើវិធានការតឹងរឹងក្នុងរឿងក្តី *Katanga* កថាខណ្ឌ១, ៤១-៤៣។

## ខ. បទដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម

9. ការកំណត់អត្តសញ្ញាណមន្ត្រីខ្មែរក្រហមទាំងអស់នោះ "ដែលទទួលខុសត្រូវខ្ពស់បំផុត" [10] ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការ អ.វ.ត.ក តម្រូវឲ្យមានការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[11]។ ការវាយតម្លៃនេះ ត្រូវតែធ្វើឡើង "ផ្អែកទាំងស្រុងលើអង្គសេចក្ដីនៃរឿងក្ដីនីមួយៗ[12]"។ សហចៅក្រមស៊ើបអង្កេតទាំងពីរ បានទទួលស្គាល់នាពេលថ្មីៗនេះថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មិនមានកិច្ចព្រមព្រៀងគ្នាណាមួយដែលថាមានតែបុគ្គលមានឈ្មោះមួយចំនួនប៉ុណ្ណោះដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការឡើយ[13]។

10. កត្តាដែលពាក់ព័ន្ធនឹងការវាយតម្លៃភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត រួមមាន (១) ចំនួនជនរងគ្រោះ[14] (២) វិសាលភាពភូមិសាស្ត្រ និងពេលវេលានៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ [15](៣)

---

[10] សំណុំរឿង០០១-ឯកសារ **F28** សាលដីការបស់ *ឌុច* កថាខណ្ឌ ៥២, ៦១។

[11] សំណុំរឿង០០១-ឯកសារ **F28** សាលដីការបស់ ឌុច កថាខណ្ឌ ៧១, ៨០។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រមថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រមរបស់ឌុច") កថាខណ្ឌ ២២។ សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ ("សំអាងហេតុ") ក្នុងសំណុំរឿង០០៤/១,ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ("ដីកាដំណោះស្រាយលើករណី អ៊ឹម ចែម") កថាខណ្ឌ៣៨-៤១ ជើងទំព័រ ៧៣៥។ *សូមមើលផងដែរ* សំណុំរឿង០០៣-ឯកសារ **D266** ដីកា លើកលែង ចោទប្រកាន់ មាស មុត ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ("ដីកាលើកលែងចោទប្រកាន់ មាស មុត") កថាខណ្ឌ៣,៣៦៥-៣៦៧។ សំណុំរឿង ០០៣-ឯកសារ **D359** ដីកាលើកលែងចោទប្រកាន់ អោម អាន, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាលើកលែង ចោទប្រកាន់ អោម អាន") កថាខណ្ឌ ៤២៤-៤២៥។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណា លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, យោបល់របស់ចៅក្រម Baik និង Beauvallet ("យោបល់របស់ចៅក្រមអន្តរជាតិ") កថាខណ្ឌ៣២១។ សេចក្ដីសម្រេចបញ្ជូនបន្តក្នុងរឿងក្ដី *Lukić & Lukić* កថាខណ្ឌ២៦-២៨។

[12] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយលើករណី *អ៊ឹម ចែម* កថាខណ្ឌ៣៧។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣២១។

[13] សំណុំរឿង០០៤/១-ឯកសារ**D308/3** ដីកាដំណោះស្រាយលើករណី អ៊ឹម ចែម កថាខណ្ឌ៣៧-៣៨។

[14] ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ត្រូវបានកំណត់ជាផ្នែកយោងទៅលើភាពងាយរងគ្រោះនៃជនរងគ្រោះទាំងនោះ។ *សូមមើលផងដែរ* សំណុំរឿង០០១-ឯកសារ **F28** សាលដីការបស់ *ឌុច* កថាខណ្ឌ ៣៧៥។

[15] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយលើករណី អ៊ឹម ចែម កថាខណ្ឌ៣១៧។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២២។។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ៣២៧។ សេចក្ដី

របៀបដែលឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តតាមការចោទប្រកាន់[16] និងចំនួននៃអង្គហេតុនីមួយៗដែលកើតមានឡើង[17]។

11. កត្តាពាក់ព័ន្ធនឹងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ រួមមាន (១) កម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្ម រួមទាំងកម្រិតនៃការចូលរួមក្នុងការបង្កើតគោលនយោបាយ និង/ឬការអនុវត្តគោលនយោបាយ (២) ឋានន្តរស័ក្តិ ឬមុខតំណែង តាមឋានានុក្រមរបស់ជនជាប់ចោទ រួមទាំងចំនួនអ្នកនៅក្រោមបង្គាប់ និងថ្នាក់ឋានានុក្រមនៅពីលើគាត់ និងមុខតំណែងអចិន្ត្រៃយ៍[18] (៣) សិទ្ធិអំណាចជាក់ស្តែង[19] និងលទ្ធភាពក្នុងការចេញបញ្ជា[20] និង (៤) វិសាលភាពពេលវេលា នៃ

សម្រេចបញ្ជូនបន្តក្នុងរឿងក្តី *Janković* កថាខណ្ឌ១៩។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការបញ្ជូនបន្តក្នុងរឿងក្តី *Todović* កថាខណ្ឌ ១៣, ១៦។

[16] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយលើករណី អ៊ឹម ចែម កថាខណ្ឌ៣១៧។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២២។។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ៣២៧។ សំណុំរឿង០០១-ឯកសារ **F28** សាលដីការបស់ *ឌុច* កថាខណ្ឌ ៣៧៥។ សាលដីការបស់ *Tolimir* កថាខណ្ឌ ៦៣៣។

[17] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយលើករណី អ៊ឹម ចែម កថាខណ្ឌ៣១៧។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២២។។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ៣២៧។ សំណុំរឿង០០១-ឯកសារ **F28** សាលដីការបស់ *ឌុច* កថាខណ្ឌ ៣៧៥។ សាលដីការបស់ *Tolimir* កថាខណ្ឌ ៦៣៣។

[18] សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ២២។ សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយលើករណី អ៊ឹម ចែម កថាខណ្ឌ៣៩-៤១។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣៣២, ៣៣៥។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ៣៧៥។ សាលដីការបស់ *Tolimir* កថាខណ្ឌ ៦៣៣។ សំណុំរឿង០០២-**D427** ដីកាដំណោះស្រាយ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ("ដីកាដំណោះស្រាយ") កថាខណ្ឌ ១៣២៨។ សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *Ademi* កថាខណ្ឌ២៩។ សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *Kovačević* កថាខណ្ឌ២០។ សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *D. Milošević* កថាខណ្ឌ២៣។ សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *Kovačević* កថាខណ្ឌ២០។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ *Lukić* កថាខណ្ឌ ២១។

[19] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ *Lukić & Lukić* កថាខណ្ឌ ២១។ សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *Ademi* កថាខណ្ឌ ២៩។

[20] សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *Ademi* កថាខណ្ឌ២៩។

ការគ្រប់គ្រង[21]។ មុខងារជាក់លាក់របស់បុគ្គលម្នាក់ មិនត្រូវវាយតម្លៃតែឯង ឬត្រូវបានកំណត់ជាមុនដោយផ្អែកខ្លាំងពេកទៅលើផ្នែកផ្លូវការនោះទេ[22]។

12. ការអនុវត្តលក្ខណៈវិនិច្ឆ័យជាគន្លឹះ រួមមានភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសមិនតម្រូវឱ្យមានការប្រៀបធៀប និងការចាត់ចំណាត់ថ្នាក់ទៅលើការទទួលខុសត្រូវរបស់អ្នកដែលអាចជាចារីទាំងអស់នោះទេ[23] ប៉ុន្តែត្រូវគិតគូរទៅលើរឿងក្តីផ្សេងៗដែលតុលាការ បានជំនុំជម្រះ និង កាលៈទេសៈ និងបរិបទដោយឡែកដែលឧក្រិដ្ឋកម្មត្រូវបានបានប្រព្រឹត្ត[24]។ មិនត្រូវផ្តល់ទម្ងន់មិនត្រឹមត្រូវទៅលើលក្ខណៈឧក្រិដ្ឋកម្មនៅមូលដ្ឋាននោះទេ ដោយហេតុថា មេដឹកនាំថ្នាក់មូលដ្ឋានអាចមានឥទ្ធិពលសំខាន់ និង/ឬដើរតួសំខាន់ក្នុងការអនុវត្តគោលនយោបាយទូទាំងប្រទេស ដែលត្រូវដាក់គាត់ទៅក្នុងប្រភេទនៃ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត[25]"។

## គ. លក្ខខណ្ឌតម្រូវឲ្យមានការស៊ើបសួរ និងចេញសេចក្តីសម្រេចលើអង្គហេតុនានា ដែលស្ថិតក្រោមវិសាលភាពនៃរឿងក្តីនេះ

13. អនុលោមតាមវិធាន៥៥ (២) ស.ច.ស មានកាតព្វកិច្ចធ្វើការស៊ើបសួរឱ្យបានពេញលេញ និងត្រឹមត្រូវ *តាមផ្លូវច្បាប់* អង្គហេតុសំខាន់ៗ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូន

---

[21] សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *D. Milošević* កថាខណ្ឌ២៣។

[22] សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើដីកាចាប់ខ្លួន *Ntaganda* កថាខណ្ឌ ៧៦។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយ លើករណីរបស់ អ៊ឹម ចែម, យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣២១, ៣៣៤។

[23] សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ៦២។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២៤។

[24] សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *Ademi* កថាខណ្ឌ២៨។

[25] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ *Lukić* កថាខណ្ឌ២៨។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, យោបល់របស់ចៅក្រម អន្តរជាតិ កថាខណ្ឌ ៣២៩, ៣៣៥-៣៣៦។ Guéry & Chambon, *Droit et Pratique de l'Instruction Préparatoire* (7th edition), 2010-2011, pp. 157-158, s. 51.02 *ដកស្រង់* រឿងក្តី Cass. Crim. ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៨៧, No. 86-90.769 ["Attendu que, […] le juge d'instruction n'est autorisé à rendre une ordonannce disant qu'il n'y a lieu à informer que si, pour des causes affectant l'action publique elle-même, les faits ne peuvent légalement comporter une poursuite ou si, à supposer les faits démontrés, ils ne peuvent admettre une qualification pénale." បកប្រែក្រៅផ្លូវការ៖ [កាលណាចៅក្រមស៊ើបអង្កេតមានសិទ្ធិចេញដីកាបដិសេធស៊ើបអង្កេត តែនៅពេលដែលចំពោះហេតុផលនានាដែលប៉ះពាល់ដល់ការចោទប្រកាន់ខ្លួនវា អង្គហេតុមិនអាចត្រូវបានចោទប្រកាន់ ឬនៅពេលណាដែលអង្គហេតុត្រូវបានបង្កើតឡើង មិនមានការបទឧក្រិដ្ឋណាមួយឡើយ។]

រឿងឱ្យស៊ើបសួរ និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[26]។ ស.ច.ស មានកាតព្វកិច្ចបន្ថែមទៀតក្នុងការធ្វើសេចក្ដីសម្រេចនៅក្នុងដីកាដំណោះស្រាយ ថាតើជាដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ[27] លើអង្គហេតុនីមួយៗដែលចៅក្រមស៊ើបសួរបានទទួលបណ្ដឹងយ៉ាងត្រឹមត្រូវនោះ[28]។

---

[26] វិធាន៥៣, ៥៥(១),៥៥(២)។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា) មាត្រា ១២៥។ សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច កថាខណ្ឌ៣៥។ ឯកសារ **D365/3/1/5** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចលើសំណុំសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ កថាខណ្ឌ៣៩។ *សូមអានផងដែរ* ឯកសារ **D378/2.1.14** ដីកាសម្រេចរបស់សហព្រះរាជអាជ្ញាសុំឱ្យបំភ្លឺអំពីបទចោទ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ("ដីកាសម្រេចរបស់ ក.ស.ច.ស") កថាខណ្ឌ៦, កំណត់សម្គាល់សម្គាល់ជើងទំព័រលេខ១។ Cass. Crim. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ លេខ ៧៦-៩១-៤៤២។ ["le juge d'instruction est tenu d'informer sur tous les faits dont il a été régulièrement saisi"។ ការបកប្រែក្រៅផ្លូវការ៖ "សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចក្នុងការស៊ើបអង្កេតទាំងអស់ ដែលគាត់ត្រូវបានប្ដឹងយ៉ាងត្រឹមត្រូវ"]។

[27] ដីកាសម្រេចលើកលែងចោទប្រកាន់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងពីរនេះគឺជាដីកាដំណោះស្រាយ និងមានលក្ខខណ្ឌតម្រូវខាងនីតិវិធីដូចគ្នា។ *សូមអាន* វិធានផ្ទៃក្នុង៦៧(១) ["[ស.ច.ស] ត្រូវបញ្ចប់កិច្ចស៊ើបសួរដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនរងគ្រោះទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"]។ វិធានផ្ទៃក្នុង ៦៧(៤) ["ដីកានេះ អាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាសម្រេចលើកលែង ចោទប្រកាន់ចំពោះករណីដទៃទៀត"]។ សទ្ទានុក្រម [កំណត់និយមន័យ "ដីកាដំណោះស្រាយ" និង "ដីកាសម្រេចលើកលែងចោទប្រកាន់"]។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា) មាត្រា ២៤៧។

[28] សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច កថាខណ្ឌ២៩, ៣៣, ៣៧-៣៨, ១១៥។ សំណុំរឿង០០២-ឯកសារ **D198/1** ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ១០។ Cass. Crim. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ លេខ៧៦-៩១។៤៤២ ["Le juge d'instruction avait l'obligation d'instruire, puis de statuer par une ordonnance de règlement sur l'ensemble des faits" […] "Le juge est tenu de statuer par ordonnance du règlement sur tous les faits dont il a été régulièrement saisi"។ ការបកប្រែក្រៅផ្លូវការ៖ "ចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចស៊ើបអង្កេត ហើយបន្ទាប់មក ត្រូវចេញដីកាមួយ គ្របដណ្ដប់លើអង្គហេតុទាំងអស់។ […] ចៅក្រមនេះត្រូវមានកាតព្វកិច្ចប្រកាសគ្រប់អង្គហេតុទាំងអស់ដែលគាត់ត្រូវបានប្ដឹងយ៉ាងត្រឹមត្រូវ"។ Cass. Crim. ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៤ លេខ០៣-៨៥.៩៨៣ ["le juge d'instruction n'a pas statué, comme il en a le devoir, dans son ordonnance de renvoi, sur tous les faits dont il est saisi". ការបកប្រែក្រៅផ្លូវការ៖ "ចៅក្រមស៊ើបអង្កេត មិនវិនិច្ឆ័យនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ដូចដែលគាត់មានកាតព្វកិច្ចនោះទេ ទៅលើគ្រប់អង្គហេតុទាំងអស់ដែលគាត់ត្រូវបានប្ដឹង"។ *សូមអានផងដែរ* សំណុំរឿង០០៤/១- ឯកសារ**D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ ស្ដីពីដីកាដំណោះស្រាយលើករណីអ៊ឹម ចែម កថាខណ្ឌ១១៦, ១២៩, យោបល់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១១, ១២៩។

## ឃ. លក្ខខណ្ឌតម្រូវចំពោះសេចក្តីសម្រេចដែលមានសំអាងហេតុ រួមមានការសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងតទនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទ

14. អនុលោមតាមបទដ្ឋានអន្តរជាតិដែលថាសេចក្តីសម្រេចទាំងអស់នៃអង្គភាពតុលាការ ត្រូវតែមានសំអាងហេតុនោះ[29] "សេចក្តីសម្រេចរបស់ [ស.ច.ស] *ក្នុងការលើកលែងការចោទប្រកាន់ចំពោះអំពើទាំងឡាយ ឬបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ* ត្រូវផ្តល់សំអាងហេតុ ដូចមានចែងច្បាស់នៅក្នុងវិធាន៦៧(៤) នៃវិធានផ្ទៃក្នុង[30]"។ ហេតុដូច្នេះ ដីកាដំណោះស្រាយត្រូវតែ "ជាអប្បបរមា... [...] ត្រូវផ្តល់សំអាងហេតុ ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួនពាក់ព័ន្ធនឹងការពិចារណាដ៏សំខាន់ទាក់ទងនឹងសេចក្តីសម្រេចរបស់ខ្លួន[31]"។

15. ដោយហេតុថាការកំណត់ថាតើជនជាប់ចោទម្នាក់ស្ថិតនៅក្នុងចំណោមជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការ អ.វ.ត.ក តម្រូវឲ្យមានការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និង កម្រិតនៃការទទួលខុសត្រូវរបស់

---

[29] ឯកសារ **D344.1.2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ២១ (និងយុត្តិសាស្ត្រនៅក្នុងនោះ) ["អង្គបុរេជំនុំជម្រះយល់ឃើញថា "សេចក្តីសម្រេចទាំងអស់របស់តុលាការ តម្រូវឲ្យផ្តល់សំអាងហេតុ ដោយសារវាជាបទដ្ឋានអន្តរជាតិ។""] សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច កថាខណ្ឌ៣៨។ សំណុំរឿង០០២-ឯកសារ **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការបន្ទាន់ តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ២៥។ សំណុំរឿង០០២-ឯកសារ **E50** សេចក្តីសម្រេចលើសំណុំសុំដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ២៣-២៧ (និងយុត្តិសាស្ត្រនៅក្នុងនោះ)។ *សូមអានផងដែរ* ឧទាហរណ៍ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រឿងក្តី *Milutinović* កថាខណ្ឌ២២។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រឿងក្តី *Lubanga* កថាខណ្ឌ២០។

[30] សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច កថាខណ្ឌ៣៨ (គូសបញ្ជាក់បន្ថែម)។ *សូមអានផងដែរ* វិធាន៦៧(៤) នៃវិធានផ្ទៃក្នុង ["ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ"]។ សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច កថាខណ្ឌ១១៥។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧ ["ដីកាដំណោះស្រាយ អាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ [...] "។ ដីកាដំណោះស្រាយជានិច្ចជាកាលត្រូវតែមានសំអាងហេតុ"]។

[31] សេចក្តីសម្រេចបន្ទាន់បង្គំក្នុងរឿងក្តី *Milutinović* កថាខណ្ឌ១១។ *សូមអានផងដែរ* សាលដីកាស្តីពីការកោសលុបក្នុងរឿងក្តី *Lubanga* កថាខណ្ឌ២០។

ជនសង្ស័យ[32] ផ្អែកលើអង្គហេតុទាំងអស់ដែលស.ច.ស ត្រូវបានប្តឹងនោះ[33] ការសម្រេចលើកលែងការចោទប្រកាន់រឿងក្តីមួយ ដោយពុំមានយុត្តិធិការបុគ្គល ត្រូវមានការសន្និដ្ឋានផ្នែកអង្គហេតុ និងអង្គច្បាប់ ដែលចាំបាច់ដើម្បីធ្វើសេចក្តីសម្រេចនោះ។

16. តាមពិតទៅ អង្គបុរេជំនុំជម្រះ បានសម្រេចជាឯកច្ឆន្ទថា តម្រូវឱ្យមានសេចក្តីសន្និដ្ឋានទៅលើភាពធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្មដែលត្រូវចោទ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ។ ដើម្បីអនុវត្តអំណាចរបស់ខ្លួនដោយត្រឹមត្រូវ ក្នុងការពិនិត្យមើលឡើងវិញទៅលើសេចក្តីសម្រេចលើយុត្តាធិការបុគ្គល អង្គបុរេជំនុំជម្រះ "*ប្រាកដជា* អាចពិនិត្យមើលលើសេចក្តីសន្និដ្ឋាននានាដែលនាំឱ្យមានការសម្រេចបែបនេះ រួមទាំង សេចក្តីសន្និដ្ឋានទាំងឡាយណាពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ [ជនសង្ស័យ][34]"។ ប្រការនេះរួមបញ្ចូលទាំង "ការសម្រេចចុងក្រោយរបស់ ស.ច.ស ពាក់ព័ន្ធនឹងការកំណត់ប្រភេទបទល្មើសនៃអំពើនានា ដែលបានចោទប្រកាន់ដោយសហព្រះរាជ អាជ្ញា និង [...] សម្រេចថា តើអំពើទាំងនេះ ត្រូវចាត់ទុកជាបទឧក្រិដ្ឋនានា ដែលស្ថិតនៅក្នុង យុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ"[35]។

17. ជាងនេះទៅទៀត ត្រូវតែច្បាស់លាស់ថាតើ ស.ច.ស វាយតម្លៃភស្តុតាងដោយរបៀបណា ដើម្បីមានការសន្និដ្ឋានផ្នែកអង្គហេតុ រួមទាំងការបង្ហាញពីភស្តុតាងណាដែលត្រូវបានទទួលយកជា

---

[32] *សូមអានខាងលើ* ផ្នែកទី III (ខ)។

[33] *សូមអានខាងលើ* ផ្នែកទី III (គ)។

[34] សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយ លើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ២៦ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ) (គូសបញ្ជាក់បន្ថែម)។ *សូមអានផងដែរ* សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច កថាខណ្ឌ១១៥។

[35] សំណុំរឿង០០៤/១-ឯកសារ **D306/3.1.35** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ៧៩។ *សូមអានផងដែរ* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយ លើករណីរបស់ អ៊ឹម ចែម យោបល់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣២១-៣៤០ ។ សាលដីកាស្តីពីការកោសលុបក្នុងករណី *Lubanga* កថាខណ្ឌ២០ សេចក្តីសម្រេចត្រូវតែកំណត់អត្តសញ្ញាណ ថាតើអង្គហេតុ មួយណាត្រូវបានរកឃើញថា មានជាប់ទាក់ទងនឹងការបានឈានទៅដល់សេចក្តីសន្និដ្ឋាន របស់ខ្លួននេះ។ រហូតមកដល់ពេលនេះ ដីកាដំណោះស្រាយនីមួយៗដែលបានចេញនៅ អ.វ.ត.ក លើកលែងតែដីកាសម្រេច លើកលែងចោទប្រកាន់ សំណុំរឿង០០៤/២-ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត និងសំណុំរឿង០០៤/២-ឯកសារ **D359** ដីកាសម្រេចលើកលែង ចោទប្រកាន់ អោ អាន មានសេចក្តីសន្និដ្ឋានទាំងនេះ។

ភស្តុតាងនៃធាតុផ្សំទាំងអស់របស់ឧក្រិកម្មដែលត្រូវបានចោទប្រកាន់[36]។ តាមការសន្មត ស.ច.ស បានវាយតម្លៃយ៉ាងត្រឹមត្រូវលើភស្តុតាងទាំងអស់ដែលមាននៅចំពោះមុខពួកគាត់ ដរាបណា មិនមានការបង្ហាញថា ពួកគាត់មិនបានយកចិត្តទុកដាក់ទៅលើភស្តុតាងជាក់លាក់នោះ[37]។ សូម្បីតែក្នុងករណីដែលការវិភាគខ្លួនឯង ត្រូវមានសំអាងហេតុក៏ដោយ "ការវិភាគដែលត្រូវបានកម្រិតចំពោះតែផ្នែកដែលបានជ្រើសរើសមួយនៃកំណត់ត្រាភស្តុតាងដែលពាក់ព័ន្ធ គឺមិនគ្រប់គ្រាន់ចាំបាច់ ដើម្បីបង្កើតជាទស្សនៈមួយដែលមានសំអាងនោះទេ[38]"។

## ខ. បទដ្ឋាននៃភស្តុតាងសម្រាប់ការបញ្ជូនរឿងទៅជំនុំជម្រះ

18. អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុងចែងថា ត្រូវមាន "ភស្តុតាងគ្រប់គ្រាន់ [...] នៃបទចោទ ដើម្បីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងជនត្រូវចោទ[39]។ ស.ច.ស និងអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ចំណុចនេះតម្រូវឲ្យមាន "ភវនីយភាព" នៃពិរុទ្ធភាពដែលលើសពី "គ្រាន់តែអាចកើតមាន" ប៉ុន្តែ តិចជាងបទដ្ឋាន "ហួសពីវិមតិសង្ស័យ" ដែលបានប្រើប្រាស់នៅពេលជំនុំជម្រះ[40]។ លើសពីនេះទៀត "ភស្តុតាងនៅក្នុងសំណុំរឿងត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឲ្យមានតម្លៃជាភស្តុតាងបន្ទាល់"[41]។

---

[36] *សូមអាន ឧទា.* សាលដីការឿងក្តី *Bemba* កថាខណ្ឌ ៥២។ សាលដីការឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៣៨៥។ សាលដីការឿងក្តី *Kunarac* កថាខណ្ឌ ៤១។

[37] សំណុំរឿង ០០២/១-ឯកសារ **F36** សាលដីកា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សាលដីកាលើសំណុំរឿង ០០២/១") កថាខណ្ឌ ៣០៤ (ការដកស្រង់នៅក្នុងនោះ)។ *សូមមើលផងដែរ* សាលដីកា *Perišić* កថាខណ្ឌ ៩២។

[38] សាលដីកាលរឿងក្តី *Perišić* កថាខណ្ឌ ៩៥។

[39] ស.ច.ស បានអនុវត្តបទដ្ឋាននេះនៅក្នុងសំណុំរឿង ០០២។ *សូមមើល* សំណុំរឿង ០០១ ឯកសារ **D99** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ *ហៅ* *ឌុច* ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ("ដីកាដំណោះស្រាយលើករណី ឌុច") កថាខណ្ឌ ១៣០។ សំណុំរឿង ០០២ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២១។

[40] សំណុំរឿង ០០២ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងករណី *អ៊ឹម ចែម* កថាខណ្ឌ ៦០-៦២ (សេចក្តីសម្រេចជាឯកច្ឆន្ទ)។

[41] សំណុំរឿង ០០២ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។

## IV. សារណាបណ្តឹងឧទ្ធរណ៍

19. នៅក្នុងការវាយតម្លៃអំពីយុត្តាធិការបុគ្គល ដីកាសម្រេចលើកលែងការចោទប្រកាន់ មានកំហុសអង្គច្បាប់ និងអង្គហេតុមួយចំនួន ដែលកំហុសនីមួយៗ[42] ឬជារួម[43] បានបណ្តាលឱ្យដីកាសម្រេចលើកលែងការចោទប្រកាន់គ្មានសុពលភាព និង/ឬ បានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និងជាកត្តាកំណត់យ៉ាងសំខាន់នៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។ កំហុសទាំងនេះរួមមាន (១) ការសម្រេចថា *តាមការប៉ាន់ប្រមាណ* និងជាបញ្ហាអង្គច្បាប់ ប្រភេទនៃ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" អាចអនុវត្តបានចំពោះតែ ឌុច ម្នាក់គត់ប៉ុណ្ណោះ (២) ការបដិសេធពុំព្រមធ្វើការកំណត់បទចោទ និងទម្រង់នៃការទទួលខុសត្រូវ ដោយផ្អែកលើអង្គហេតុ ដែល ស.ច.ស បានទទួលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[44] ដូច្នេះហើយ ខកខានពុំបានចេញសេចក្តីសម្រេចដែលមានសំអាងហេតុ (៣) ការពិចារណា និងការវិភាគខុសចំពោះបញ្ហាថ្នាក់លើ និងការគាបសង្កត់ នៅក្នុងការវាយតម្លៃអំពីយុត្តាធិការបុគ្គល (៤) ការផ្តល់ទម្ងន់ហួសហេតុទៅលើ "ការចូលរួមដោយផ្ទាល់" នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម តែបែរជាមិនអើពើចំពោះទម្រង់នៃការទទួលខុសត្រូវដែលជាប់ពាក់ព័ន្ធច្រើនជាងនេះទៅវិញ (៥) ការសម្រេចដែលពុំមានមូលដ្ឋានអង្គហេតុ និង/ឬ ដែលផ្ទុយយ៉ាងច្បាស់ក្រឡែតទៅនឹងភស្តុតាង និង (៦) ការផ្តល់ទម្ងន់ទៅលើកត្តានានាដែលមានភាពជាប់ពាក់ព័ន្ធតិចតួចបំផុត នៅពេលធ្វើការវាយតម្លៃយុត្តាធិការបុគ្គល។

---

[42] កំហុសដូចខាងក្រោមនេះ គឺជាការកំណត់ដោយឡែកៗពីគ្នា៖ IV(ក), IV(ខ)(១)-(៣), (៥), IV(គ), IV(ឃ), IV(ង)(១)-(២), (៤), IV(ច)(៥)។

[43] កំហុសដូចខាងក្រោមនេះ គឺជាការកំណត់សរុបរួមគ្នា៖ IV(ខ)(៤), (៦), IV(ង)(៣), (៥), IV(ច)(១)-(៤), (៦)។

[44] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងទៅនឹងតំបន់១ និងខ្មែរក្រោម")។ ឯកសារ **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ")។ ឯកសារ **D196/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤។ ឯកសារ **D272/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ("ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ")។

## ក. ដីកាសម្រេចលើកលែងការចោទប្រកាន់ មានកំហុសអង្គច្បាប់ ដោយសារតែការសម្រេចថា ឌុច គឺជាជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" តែម្នាក់គត់

20. ដីកាសម្រេចលើកលែងការចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយការសម្រេចថា យឹម ទិត្យ ស្ថិតនៅក្រៅយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ពីព្រោះថា *តាមការប៉ាន់ប្រមាណ* និងជាបញ្ហាអង្គច្បាប់ ប្រភេទនៃ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" អាចអនុវត្តបានចំពោះតែ ឌុច ម្នាក់គត់ប៉ុណ្ណោះ។ ដោយការពិនិត្យឡើងវិញទៅលើប្រវត្តិចរចាបង្កើតច្បាប់ស្តីពី អ.វ.ត.ក[45] ដីកាសម្រេចលើកលែងការចោទប្រកាន់បានលើកឡើងយ៉ាងច្បាស់ក្រឡែតថា "មុខសញ្ញា" របស់ អ.វ.ត.ក "គឺមេដឹកនាំជាន់ខ្ពស់ និង ឌុច ដែលជាបុគ្គល *ម្នាក់តែប៉ុណ្ណោះ* ដែលជាជនទទួលខុសត្រូវខ្ពស់បំផុត"[46]។ កំហុសនេះបានបណ្តាលឲ្យដីកាសម្រេចលើកលែងការចោទប្រកាន់គ្មានសុពលភាព។

21. ការបញ្ជាក់អះអាងនៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់ ថា ឌុច គឺជាបុគ្គលតែម្នាក់គត់ ដែលស្ថិតនៅក្នុងប្រភេទនៃ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺពុំត្រឹមត្រូវ" ដោយសារមូលហេតុយ៉ាងតិចចំនួនបី៖ (១) ដីកាសម្រេចលើកលែងការចោទប្រកាន់ផ្ទុយទៅនឹងសេចក្តីថ្លែងការណ៍មុនៗ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយលើសំណុំរឿង ០០៤/១ និងដីកាដំណោះស្រាយលើសំណុំរឿង ០០៤/២ ដែលលើកឡើងថា វាពុំមានប្រយោជន៍អ្វីចំពោះការជំទាស់តវ៉ាថា យុត្តាធិការបុគ្គលមានចេតនាកម្រិតតែចំពោះបុគ្គលមានឈ្មោះមួយចំនួននោះទេ (២) ដីកាសម្រេចនេះផ្ទុយនឹងភាសាដ៏ច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក[47] និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង (៣) ដីកាសម្រេចនេះពុំស្របនឹងការយល់ឃើញច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជាផង និងរបស់ អ.ស.ប ផងទៅលើបញ្ហាយុត្តាធិការបុគ្គល នៅពេលបង្កើត អ.វ.ត.ក។

---

[45] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ")។

[46] ឯកសារ **D381** ដីកាសម្រេចលើកលែងការចោទប្រកាន់ កថាខណ្ឌ ៦៣៨ (មានបញ្ជាក់សេចក្តីបន្ថែម)។

[47] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

## ១. ការសម្រេចផ្ទុយទៅនឹងដីកាដំណោះស្រាយលើសំណុំរឿង ០០៤/១ និងដីកាសម្រេចលើកលែងការចោទប្រកាន់លើសំណុំរឿង ០០៤/២

22. ការអះអាងនៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់ថា ឌុច ជាជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" តែម្នាក់គត់នោះ គឺផ្ទុយនឹងដីកាសម្រេចលើកលែងការចោទប្រកាន់លើងសំណុំរឿង ០០៤/២ និងដីកាដំណោះស្រាយលើសំណុំរឿង ០០៤/១ ដែលទទួលស្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចយ៉ាងច្បាស់នៅក្នុងសំណុំរឿង ០០១ ថា៖

> វាពុំមានប្រយោជន៍អ្វីត្រូវអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាជុំវិញការបង្កើត អ.វ.ត.ក នាំឲ្យយល់ឃើញតាមផ្លូវច្បាប់ជារួមថា មានតែបុគ្គល(មានឈ្មោះ)មួយចំនួនប៉ុណ្ណោះ ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់តុលាការពោលគឺការជ្រើសរើសយកបុគ្គលមួយចំនួនមកធ្វើការស៊ើបអង្កេត និងចោទប្រកាន់បញ្ជូនទៅជំនុំជម្រះកន្លងមក និងបច្ចុប្បន្នជាបញ្ហាឆន្ទានិសិទ្ធិរបស់ ក.ស.ព និង ក.ស.ច.ស ហើយបានផ្អែកសុទ្ធសាធលើអង្គហេតុនៃរឿងក្តីនីមួយៗ[48]។

## ២. ការសម្រេចផ្ទុយនឹងភាសាដ៏ច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

23. យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក រវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ដែលត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា តាមរយៈច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ច្បាប់ទាំងពីរនេះចែងថា យុត្តាធិការត្រូវបានកំណត់ចំពោះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់[49]។

24. ហេតុដូច្នេះ ការសម្រេចនៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់ថា មានតែ ឌុច ម្នាក់គត់ដែលត្រូវបានចាត់ទុកថាស្ថិតនៅក្នុងប្រភេទ "*ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*"[50]

---

[48] សំណុំរឿង ០០៤/២ ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន កថាខណ្ឌ ៤៦១។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ ឯកសារ **D308/3** ដីកាដំណោះស្រាយប្រឆាំងនឹង អ៊ឹម ចែម កថាខណ្ឌ ៣៧។

[49] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។ ច្បាប់បង្កើត អ.វ.ត.ក មាត្រា ១ និងមាត្រា ២ថ្មី។

[50] ភាសាជាពហុវចនៈនេះមានទាំងបីភាសា (អង់គ្លេស បារាំង និងខ្មែរ) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់បង្កើត អ.វ.ត.ក។ អត្ថបទភាសាបារាំងនិយាយសំដៅ "les principaux responsables" ហើយអត្ថបទភាសាខ្មែរបញ្ជាក់ច្បាស់លាស់ថា "ជន

គឺផ្ទុយទៅនឹងភាសាច្បាស់ក្រឡែតនៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលត្រូវបានសរសេរជាទម្រង់ពហុវចនៈ និងបញ្ជាក់យ៉ាងច្បាស់សំដៅទៅមនុស្សមួយប្រភេទ គឺមិនមែនសំដៅតែបុគ្គលម្នាក់នោះឡើយ[51]។ ភាសាដូចគ្នានេះក៏មាននៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[52]។ ឯកសារច្បាប់ទាំងពីរនេះបង្ហាញយ៉ាងច្បាស់ថា ការបកស្រាយដែលបានលើកឡើងនៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់ ពុំត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ។

## ៣. ការសម្រេចនេះពុំស្របនឹងការយល់ឃើញរបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ទៅលើយុត្តាធិការបុគ្គល នៅពេលបង្កើត អ.វ.ត.ក នោះទេ

### *ក) រាជរដ្ឋាភិបាលកម្ពុជា*

---

ទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។

[51] កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា ["ដោយហេតុថា អាជ្ញាធរកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្ដី [...] និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"] មាត្រា ១, ២(១) ៥(៣) និង៦(៣)។ កិច្ចព្រមព្រៀង អ.វ.ត.ក ត្រូវបានចាត់ទុកថាជាការសម្ដែងចេតនាច្បាស់លាស់របស់ភាគីនៃកិច្ចព្រមព្រៀងនេះ គឺរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប។ អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់នៃសន្ធិសញ្ញា ទីក្រុងវីយែន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩, 1155 UNTS 331 ("អនុសញ្ញាទីក្រុងវីយែន") មាត្រា ៣១(១) ចែងថា ["ត្រូវតែបកស្រាយសន្ធិសញ្ញាដោយសុទ្ធចិត្តឲ្យស្របនឹងអត្ថន័យធម្មតាដែលបានកំណត់ចំពោះពាក្យពេចន៍នៃសន្ធិសញ្ញានេះ ទៅតាមបរិបទរបស់ពាក្យពេចន៍ទាំងនេះ និងដោយយោងទៅលើកម្មវត្ថុ និងគោលបំណងរបស់សន្ធិសញ្ញានេះ"]។ ភាគីទាំងពីរបានយល់ព្រមយ៉ាងច្បាស់លាស់ថា អនុសញ្ញាទីក្រុងវីយែនអនុវត្តចំពោះកិច្ចព្រមព្រៀង អ.វ.ត.ក។ *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(២)។ *សូមមើលផងដែរ វិវាទលើបូរណភាពដែនដី (ប្រទេស Libyan Arab Jamahiriya ទល់នឹង ប្រទេសឆាត)* សាលក្រម ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៤ របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ១៩៩៤ ទំព័រ ៦ កថាខណ្ឌ ៤១ ["ការបកស្រាយត្រូវតែសំអាងលើអត្ថបទនៃសន្ធិសញ្ញាទាំងស្រុង"]។ *នីត្យានុកូលភាពនៃការប្រើប្រាស់កម្លាំង (ប្រទេសស៊ែប៊ី និងម៉ុងតេណេហ្គ្រោ ទល់នឹង ប្រទេសបែលហ្ស៊ិក)* បញ្ហាបឋម សាលក្រម ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៤ របាយការណ៍ ICJ ២០០៤ ទំព័រ ២៧៩ កថាខណ្ឌ ១០០។ ការបកស្រាយសន្ធិសញ្ញាសន្តិភាព (ដំណាក់កាលទី២) យោបល់ប្រឹក្សា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៥០ របាយការណ៍ ICJ ១៩៥០ ទំព័រ ២២៩ ["វាជាកាតព្វកិច្ចរបស់តុលាការក្នុងការបកស្រាយសន្ធិសញ្ញានានា មិនមែនកែប្រែសន្ធិសញ្ញាទាំងនោះឡើងវិញទេ"]។ មាត្រាទាំងឡាយនៃសេចក្ដីព្រាងច្បាប់របស់ ILC ស្ដីពីច្បាប់នៃសន្ធិសញ្ញាដោយមានសេចក្ដីអត្ថាធិប្បាយផង សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ឆ្នាំ១៩៦៦ វ៉ុល II ទំព័រ ២២០-២២១ កថាខណ្ឌ ១១ ["សេចក្ដីអត្ថាធិប្បាយចំពោះមាត្រា ២៧ [...] [មាត្រា ២៧ (បច្ចុប្បន្នជាមាត្រា ៣១ ដូចដែលបានបញ្ជាក់រួចហើយ គឺសំអាងទៅលើទស្សនៈយល់ឃើញថា អត្ថបទច្បាប់ត្រូវសន្មតថា ជាការសម្ដែងចេតនាច្បាស់លាស់របស់ភាគី ហើយជាលទ្ធផល ចំណុចចាប់ផ្ដើមនៃការបកស្រាយគឺជាភាពច្បាស់លាស់នៃអត្ថន័យរបស់អត្ថបទនោះ មិនមែនជា*ការចាប់ផ្ដើម*ស្រាវជ្រាវទៅលើចេតនារបស់ភាគីរបស់ភាគីនោះទេ។ វិទ្យាស្ថានច្បាប់អន្តរជាតិប្រើប្រាស់វិធីសាស្ត្រនេះសម្រាប់ការបកស្រាយសន្ធិសញ្ញា"]។

[52] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ១, មាត្រា ២ថ្មី។

25. ការអះអាងនៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់ថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" តែម្នាក់ប៉ុណ្ណោះ ក៏ផ្ទុយផងដែរទៅនឹងចេតនាយ៉ាងច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា នៅពេលធ្វើការអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ការថ្លែងបង្ហាញនៅចំពោះមុខរដ្ឋសភាជាតិ ធ្វើឡើងដោយឧបនាយករដ្ឋមន្ត្រី សុខ អាន ប្រធានក្រុមចរចារបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងជំនួបពិភាក្សាជាមួយ អ.ស.ប គឺជាភស្តុតាងដ៏ប្រពៃបំផុតបង្ហាញអំពីបំណងរបស់រដ្ឋាភិបាលកម្ពុជា នៅពេលបង្កើតកិច្ចព្រមព្រៀង អ.វ.ត.ក។ សុខ អាន បានថ្លែងយ៉ាងស៊ីសង្វាក់គ្នាថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រភេទមានកម្រិត ប៉ុន្តែបើកចំហ។

26. ថ្លែងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ គឺរយៈពេលជាង ១៨ ខែ ក្រោយពីការចាប់ខ្លួន ឌុច និងនៅមុនពេលអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅក្នុងឆ្នាំ២០០១ តែបន្តិច[53] សុខ អាន បានថ្លែងដោយពុំបានសំដៅលើ ឌុច ឡើយៈ

> ក្របខណ្ឌសមត្ថកិច្ចផ្អែកទៅលើទិដ្ឋភាពផ្លូវច្បាប់ធំៗចំនួនបីៈ ទីមួយ គឺអ្វីដែលយើងហៅថា ទិដ្ឋភាពសមត្ថកិច្ចបុគ្គល ("La compétence personnelle") ដែលត្រូវកំណត់គោលដៅដែលជាកម្មវត្ថុនៃការជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញ។ ដូច្នេះ ទិដ្ឋភាពមួយនេះបញ្ជាក់យ៉ាងច្បាស់ថា មានតែមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះ [បទឧក្រិដ្ឋកម្ម] ប៉ុណ្ណោះ ដែលនឹងត្រូវយកមកជំនុំជម្រះ[54]។

27. នៅក្នុងអំឡុងពេលពិភាក្សាដេញដោលនៅក្នុងរដ្ឋសភាជាតិកម្ពុជាកាលពីខែតុលា ឆ្នាំ២០០៤ ស្តីពីវិសោធនកម្មច្បាប់ អ.វ.ត.ក ឲ្យស្របនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀង អ.វ.ត.ក សមាជិកសភាមួយចំនួនបានស្នើឲ្យមានការបញ្ជាក់បំភ្លឺថា តើអ្នកធ្វើសេចក្តីព្រាងមានន័យយ៉ាងដូចម្តេចចំពោះឃ្លាថា

---

[53] ច្បាប់ស្តីពីកាបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានអនុម័តកាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១១ និងបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០១ (នស/រកម/០៨០១/១២) បោះពុម្ពផ្សាយឡើងវិញនៅក្នុងឯកសារ *ស្វែងរកការពិត* របស់មជ្ឈមណ្ឌលកម្ពុជា ព្រឹត្តិប័ត្រលេខ ១៣ ទំព័រ ៦៥-៦៧។

[54] ការបកប្រែដោយមជ្ឈមណ្ឌលឯកសារកម្ពុជាលើ កំណត់ហេតុនៃសម័យប្រជុំរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០ *ទស្សនាវដ្តីស្វែងរកការពិត* មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១៤ ចុះខែកុម្ភៈ ឆ្នាំ២០០១ ទំព័រ ៤៤ (មានសេចក្តីបញ្ជាក់បន្ថែម)។

"ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"នោះ[55]។ សុខ អាន បានឆ្លើយតបដោយគ្មានស្រពិចស្រពិលថា (១) យុត្តាធិការនេះមិនកម្រិតត្រឹមមេដឹកនាំជាន់ខ្ពស់នោះទេ (២) គ្មានការកំណត់ចំនួនមនុស្សដែលអាចស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក និង (៣) មិនមានបញ្ជីឈ្មោះគោលដៅសក្តានុពលនៃការស៊ើបអង្កេតនោះទេ[56]។ គាត់ក៏បានលើកឡើងច្បាស់លាស់ផងដែរថា ប្រភេទនៃជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" សំដៅលើគោលការណ៍សក្តានុពលច្រើន។ យោងតាមពាក្យពេចន៍របស់គាត់ផ្ទាល់៖

> ប្រសិនបើយើងសួរសំណួរ "តើបុគ្គលណាខ្លះនឹងត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ?" ទាំងអង្គការសហប្រជាជាតិ ឬទាំងក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជា មិនអាចផ្តល់ចម្លើយតបបានទេ។ ពីព្រោះនេះជាភារកិច្ចរបស់តុលាការ៖ អង្គជំនុំជម្រះវិសាមញ្ញ។ បើយើងរៀបរាប់ឈ្មោះមនុស្សសម្រាប់ចោទប្រកាន់កាត់ទោសជំនួសតុលាការ នោះយើងរំលោភអំណាចតុលាការ។ ដូច្នេះ យើងមិនអាចកំណត់ថា បុគ្គល ក, ខ, គ ឬ ឃ ជាបុគ្គលដែលនឹងត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនោះឡើយ។ ដើម្បីជាដំណោះស្រាយ យើងបានកំណត់គោលដៅចំនួនពីរ៖ *មេដឹកនាំជាន់ខ្ពស់ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ នៅពេលពិចារណា *មេដឹកនាំជាន់ខ្ពស់* យើងសំដៅទៅលើបុគ្គលមិនលើសពី ១០ នាក់ ទេ ប៉ុន្តែយើងពុំបញ្ជាក់ឲ្យបានច្បាស់ថា ពួកគេគឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នោះទេ។ នេះជាការងាររបស់សហព្រះរាជអាជ្ញាដែលត្រូវសម្រេចថា តើបុគ្គលណាខ្លះគឺជាមេដឹកនាំជាន់ខ្ពស់។ [...]

[55] ប្រតិចារឹកបកប្រែដោយមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីសម័យប្រជុំលើកទីមួយ នៃនីតិកាលទីបីរបស់រដ្ឋសភាកម្ពុជា ចាប់ពីថ្ងៃទី៤-៥ ខែតុលា ឆ្នាំ២០០៤ ("ប្រតិចារឹកសម័យប្រជុំរដ្ឋសភាជាតិឆ្នាំ២០០៤") ទំព័រ ២២-២៣ ["ឯកឧត្តម លី ធុច៖ ប្រជាជនយើង និងសង្គមស៊ីវិលចង់ស្នើសុំឲ្យ ឯ.ឧ សុខ អាន បញ្ជាក់ឲ្យបានច្បាស់ថា តើបុគ្គលណាជាមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត? តើពួកគេរួមបញ្ចូលប្រធានអង្គភាពអង្គការចាត់តាំងផងដែរឬទេ?] ទំព័រ ៣០-៣១ ["ឯ.ឧ កែវ រ៉េមី៖ តើបុគ្គលណាជាមេដឹកនាំជាន់ខ្ពស់? [...] តើប្រធានភូមិភាគនឹងត្រូវនាំយកមកកាត់ទោសដែរឬទេ? [ឬក៏] ច្បាប់នេះ [កំពុង] ធ្វើឡើងដើម្បីជំនុំជម្រះមេដឹកនាំតែ ៤ ឬ ៥ នាក់តែប៉ុណ្ណោះ? តើបុគ្គលណាផ្សេងទៀតនឹងត្រូវយកមកកាត់ទោស? តើវាមានភាពយុត្តិធម៌ដែរឬទេ ប្រើសិនបើយើងកាត់ទោសតែមនុស្ស ៣-៤ នាក់"? ទំព័រ ៤៦-៤៧ ["ឯ.ឧ អេង ឆៃអ៊ាង៖ ខ្ញុំក៏មិនយល់ច្បាស់អំពី *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត* នោះដែរ។ តើជនទាំងនោះនឹងត្រូវទទួលខុសត្រូវកម្រិតណា? [...] ខ្ញុំចង់ឲ្យតំណាងរដ្ឋាភិបាលបញ្ជាក់ ថា តើជនទាំងនោះត្រូវទទួលខុសត្រូវធំធេងបំផុតត្រឹមកម្រិតណា។ [...] ខ្ញុំចង់ថា កុំឲ្យប្រជាជនមានភាពស្រពិចស្រពិល។ ប្រសិនបើយើងសង្កត់ធ្ងន់តែថ្នាក់ខ្ពស់បំផុតប៉ុណ្ណោះ យើងមានន័យថាជា ប៉ុល ពត ដែលបានស្លាប់បាត់ទៅហើយ"]។

[56] ប្រតិចារឹកសម័យប្រជុំរដ្ឋសភាជាតិឆ្នាំ២០០៤ ទំព័រ ៣០-៣១។ *សូមមើលផងដែរ* ទំព័រ ១៦។

ទោះបីជាយ៉ាងនេះក្តី នៅមានក្រុមគោលដៅទីពីរទៀត។ ពួកគេមិនមែនជាមេដឹកនាំជាន់ខ្ពស់នោះទេ ប៉ុន្តែពួកគេបានប្រព្រឹត្តអំពើឃោរឃៅ។ ហេតុដូច្នេះហើយទើបយើងប្រើពាក្យ *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ គ្មានចំនួនមនុស្សជាក់លាក់នៅក្នុងក្រុមទីពីរ ដែលនឹងត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនោះឡើយ[57]។

28. ច្បាស់ណាស់ថា ការយល់ឃើញរបស់រាជរដ្ឋាភិបាលកម្ពុជាគឺ បុគ្គលប្រភេទនេះមិនគួរត្រូវបានកម្រិតត្រឹមតែ ឌុច នោះទេ។ តាមពិតទៅ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលស្គាល់ថា ការសម្រេចថាបុគ្គលណាខ្លះស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺជាបញ្ហានៃការសម្រេចដោយឯករាជ្យរបស់ចៅក្រមនៅក្នុងតុលាការ។ នៅក្នុងខែមីនា ឆ្នាំ១៩៩៩ គាត់បានជម្រាបទៅលោកអគ្គលេខាធិការ អ.ស.ប ថា៖

> រាជរដ្ឋាភិបាលកម្ពុជាពុំមានអំណាចកំណត់កាតព្វកិច្ចលើសាលាក្តីមានសមត្ថកិច្ចនោះឡើយ [...] បញ្ហាថាតើត្រូវកាត់ទោស តា ម៉ុក តែម្នាក់ឯង ឬមេដឹកនាំខ្មែរក្រហមផ្សេងទៀតដែរឬទេនោះ គឺអាស្រ័យសមត្ថកិច្ចរបស់សាលាក្តីទាំងស្រុង។ រាជរដ្ឋាភិបាលកម្ពុជានឹងមិនដាក់សម្ពាធ ឬជ្រៀតជ្រែក ទោះក្នុងទម្រង់ណាក៏ដោយលើកិច្ចនីតិវិធីទូទៅរបស់តុលាការ ដែលមានភាពឯករាជ្យទាំងស្រុងពីអំណាចនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ[58]។

29. មួយខែក្រោយមក នៅក្នុងជំនួបប្រជុំខែមេសា ឆ្នាំ១៩៩៩ ជាមួយសមាជិកព្រឹទ្ធសភាអាមេរិកលោក John Kerry ដែលបានចូលរួមនៅក្នុងការចរចា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ជូនសមាជិកព្រឹទ្ធសភាលោក John Kerry ថា៖

> ការចោទប្រកាន់ និងការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្សេងទៀត គឺជាសមត្ថកិច្ចរបស់តុលាការតែមួយគត់។ រាជរដ្ឋាភិបាលកម្ពុជាពុំមានសិទ្ធិបញ្ជាឲ្យស្ថាប័នតុលាការធ្វើនេះ ឬធ្វើនោះឡើយ[59]។

---

[57] ប្រតិចារឹកសម័យប្រជុំរដ្ឋសភាជាតិឆ្នាំ២០០៤ ទំព័រ ៥៥-៥៧ (មានសេចក្តីបញ្ជាក់បន្ថែម)។

[58] លិខិតចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ ពីនាយករដ្ឋមន្ត្រីកម្ពុជា ផ្ញើជូនលោកអគ្គលេខាធិការ ឯកសារ អ.ស.ប លេខ A/53/875, S/1999/324 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ ២-៣។ *សូមកត់សម្គាល់*ថា នៅក្នុងកថាខណ្ឌ ៤ លោក ហ៊ុន សែន បានលើកឡើងថា លិខិតនេះត្រូវបានផ្សព្វផ្សាយជាឯកសាររបស់មហាសន្និបាត។

[59] សេចក្តីថ្លែងការណ៍ធ្វើឡើងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៩ ដោយខុទ្ទកាល័យសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជ

### *ខ) អ.ស.ប*

30. អ.ស.ប មានការយល់ឃើញដូចគ្នា។ នៅក្នុងឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញ ចាត់តាំងដោយអគ្គលេខាធិការឲ្យពិនិត្យស្រាវជ្រាវមើលជម្រើសណាខ្លះដែលសមបំផុតក្នុងការស្វែងរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា បានថ្លែងថា៖

> បុគ្គលដែលមិនស្ថិតនៅក្នុងតារាងរចនាសម្ព័ន្ធមេដឹកនាំជាន់ខ្ពស់ អាចដើរតួនាទីសំខាន់នៅក្នុងអំពើឃោរឃៅទាំងនេះ។ ជាពិសេស ចំណុចនេះហាក់ដូចជាត្រឹមត្រូវមែនពាក់ព័ន្ធនឹងមេដឹកនាំមួយចំនួននៅថ្នាក់ភូមិភាគ។ [...] ក្រុមអ្នកជំនាញផ្តល់អនុសាសន៍ថា សាលាក្តីណាក៏ដោយផ្តោតលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុត នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណុចនេះរួមបញ្ចូលទាំងមេដឹកនាំជាន់ខ្ពស់ ដែលទទួលខុសត្រូវលើការបំពារបំពាន ព្រមទាំងជនទាំងឡាយដែលស្ថិតនៅថ្នាក់ក្រោមៗ ដែលត្រូវបានឆ្លើយដាក់ថាជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរទាំងនោះ។ យើងមិនមានបំណងកម្រិតចំនួនលើបុគ្គលបែបនេះ ដែលអាចជាគោលដៅនៃការស៊ើបអង្កេតបានទេ។ ក៏ប៉ុន្តែ យោងតាមក្រុមអ្នកជំនាញ ក្រោយកិច្ចពិគ្រោះយោបល់ និងការស្រាវជ្រាវបង្ហាញថា ចំនួនបុគ្គលដែលត្រូវជំនុំជម្រះអាចស្ថិតនៅក្នុងចន្លោះប្រហែលពី ២០ ទៅ ៣០ នាក់[60]។

---

រដ្ឋាភិបាលកម្ពុជា ឯកសារ អ.ស.ប លេខ A/53/916 ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៩ កថាខណ្ឌ ២។ បន្ថែមលើនេះទៀត "ក្រោយពីទទួលបាននូវការធានាអះអាងបែបនេះពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន រួចមក ព្រឹទ្ធសមាជិក John Kerry បានស្វាគមន៍ចំពោះជំហរវិជ្ជមានរបស់នាយករដ្ឋមន្ត្រីកម្ពុជា"។ *សូមមើលផងដែរ* សារព័ត៌មានអន្តរជាតិ Kyodo *លោក ហ៊ុន សែន សោកស្តាយចំពោះការលើកឡើងពីចំនួនមេដឹកនាំខ្មែរក្រហមដែលត្រូវយកមកកាត់ទោស* ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ [នៅក្នុងកិច្ចសម្ភាសន៍មួយរបស់ប្រព័ន្ធផ្សព្វផ្សាយជប៉ុន៖ "នាយករដ្ឋមន្ត្រីកម្ពុជាលោក ហ៊ុន សែន បានសម្តែងការសោកស្តាយកាលពីថ្ងៃសុក្រនេះដោយបានលើកឡើងថា មេដឹកនាំខ្មែរក្រហម "៤ ទៅ ៥ នាក់" [...]។ គាត់បានមានប្រសាសន៍ថា "ខ្ញុំមិនគួរមានយោបល់ ឬនិយាយពីអ្វីដែលស្ថិតនៅក្នុងព្រំដែនរបស់តុលាការនេះទេ[...]។ លោក ហ៊ុន សែន បានមានប្រសាសន៍ថា អ្នកណាម្នាក់ដែលកំណត់ជាក់លាក់ពីចំនួនមេដឹកនាំដែលត្រូវវិនិច្ឆ័យទោស "គឺខុស ហើយរួមទាំងអ្នកជំនាញច្បាប់របស់ អ.ស.ប ផងដែរ ដែលលើកឡើងថាចន្លោះពី ២០ ទៅ ៣០ នាក់"។ លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា នៅពេលផ្តល់ចំនួនមេដឹកនាំខ្មែរក្រហមជាក់លាក់ "យើងបំពានតុលាការ"]។

[60] របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើងស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ ឯកសារ អ.ស.ប លេខ A/53/850, S/1999/231 ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ("របាយការណ៍ក្រុម

31. អនុសាសន៍ទាំងនេះបង្កើតបានជាមូលដ្ឋាននៃជំហរចរចារបស់ អ.ស.ប នៅពេលនោះ។ លោក David Scheffer បានរម្លឹកនៅក្នុងអត្ថបទមួយបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១១ ដែលពិពណ៌នាលម្អិតអំពីការចូលរួមរបស់គាត់នៅក្នុងការចរចាថា "យើងផ្តោតអារម្មណ៍លើតែមេដឹកនាំជាន់ខ្ពស់ដែលនៅរស់រានមានជីវិត ដែលបង្ហាញថាមានការទទួលខុសត្រូវខ្ពស់ *ព្រមទាំង អ្នកមុខអ្នកការថ្នាក់កំពូលផ្សេងទៀត ដូច ឌុច* ដែលមានតួនាទីដ៏មានឥទ្ធិពលចូលរួមចំណែកនៅក្នុងអំពើឃោរឃៅបែបនេះ"[61]។ គាត់ដឹងច្បាស់ថា "ព្រះរាជអាជ្ញាត្រូវរក្សាឆន្ទានុសិទ្ធិលើការចោទប្រកាន់បុគ្គលណាខ្លះ"[62] ហើយ ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" គឺជា "ក្រុម" បុគ្គល[63]។ ច្បាស់ហើយថា តាមការយល់ឃើញរបស់ អ.ស.ប គឺថា ប្រភេទនេះនឹងមិនកម្រិតត្រឹម ឌុច នោះទេ។

32. នៅត្រឹមខែមីនា ឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានស្នើពាក្យពេចន៍ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលបានពង្រីកប្រភេទនេះលើសពីបំណងរបស់ អ.ស.ប ហើយទាំងលោកអគ្គលេខាធិការ អ.ស.ប កូហ្វី អាណាន់ និងទីប្រឹក្សាច្បាប់របស់ អ.ស.ប លោក ហែន ខូរ៉េល បានសម្តែងការព្រួយបារម្ភជូនរាជរដ្ឋាភិបាលកម្ពុជាថា បច្ចុប្បន្ន ក្រុមនេះមានចំនួនច្រើនពេក។ នៅក្នុងអំឡុងពេលចរចាចុងក្រោយទៅលើចំណុចនេះ រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ពុំបានព្យាយាមធ្វើការកម្រិតឲ្យបានច្បាស់លើប្រភេទនោះត្រឹម ឌុច នោះទេ[64]។ ផ្ទុយទៅវិញ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់ អ.វ.ត.ក ជាមួយនឹងពាក្យពេចន៍ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[65]។ អ្វីដែលគួរឲ្យកត់សម្គាល់ លោក Scheffer បានរម្លឹកឡើងវិញថា៖

---

អ្នកជំនាញ អ.ស.ប") កថាខណ្ឌ ១០៩-១១០ (មានសេចក្តីបញ្ជាក់បន្ថែម)។

[61] ឯកសារ **D378/5.1.205** អត្ថបទរៀបរៀងដោយលោក Scheffer D.J. *ប្រវត្តិចរចាអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក* ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១ ("អត្ថបទរបស់ Scheffer") EN ERN 01595693 (សេចក្តីបញ្ជាក់ត្រូវបានដកចេញ និងបន្ថែម)។ *សូមមើលផងដែរ* EN ERN 01595690-91។

[62] ឯកសារ **D378/5.1.205** អត្ថបទរៀបរៀងដោយលោក Scheffer, EN ERN 01595691។

[63] ឯកសារ **D378/5.1.205** អត្ថបទរៀបរៀងដោយលោក Scheffer, EN ERN 01595692 ["ក្រុមទាំងពីរ គឺក្រុមមេដឹកនាំជាន់ខ្ពស់ និងក្រុមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងឡាយ គឺស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះ។ ខ្ញុំនឹកមិនឃើញថាមានការលើកឡើងណាមួយផ្សេងពីនេះទេ"] EN ERN 01595692, 94 [សំដៅទៅលើ "រូបមន្តបុគ្គលពីរក្រុម"]។

[64] ឯកសារ **D378/5.1.205** អត្ថបទរៀបរៀងដោយលោក Scheffer, EN ERN 01595693-96។

[65] ឯកសារ **D378/5.1.205** អត្ថបទរៀបរៀងដោយលោក Scheffer, EN ERN 01595696។

ក្នុងនាមជាសមាជិកនៃការចរចាអស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំដឹងថា អ្នកចរចារបស់ អ.ស.ប មិនបានសម្បទានចំពោះការបកស្រាយលើពាក្យពេចន៍ស្តីពីយុត្តាធិការបុគ្គល ដោយកម្រិតក្រុមជនសង្ស័យត្រឹមបុគ្គលចំនួន ៥ រូបជាក់លាក់ប៉ុណ្ណោះនោះទេ[66]។

33. ជាការសមហេតុផលក្នុងការសន្មតថា អ្នកបង្កើតច្បាប់កម្ពុជា និងអ្នកចរចា អ.ស.ប បានទទួលស្គាល់និយាមស្តីពីសិទ្ធិមនុស្សជាមូលដ្ឋាន ដែលមាននៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស[67] កតិកាសញ្ញាអន្តរជាតិនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[68] លិខិតុបករណ៍សិទ្ធិមនុស្សប្រចាំតំបន់[69] និងចែងនៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា[70] ថា បុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ ការព្រមព្រៀងថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" យោងតាមអង្គច្បាប់ អាចសំដៅត្រឹមតែ ឌុច ដោយមិនគិតថា ភស្តុតាងបានបង្ហាញអ្វីខ្លះអំពីការទទួលខុសត្រូវរបស់បុគ្គលផ្សេងៗ មិនមែនជាការប្រព្រឹត្តិស្មើគ្នាលើ ឌុច និងបុគ្គលផ្សេងទៀត ហើយរំលោភគោលការណ៍ទាំងនេះ និងកិច្ចការពារនានា។

34. សរុបមក ប្រវត្តិនៃការចរចារបស់ អ.វ.ត.ក បង្ហាញថា ចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប នៅពេលបង្កើតកិច្ចព្រមព្រៀង អ.វ.ត.ក គឺ "ជនទាំងឡាយដែលទទួលខុសត្រូវបំផុត" គឺប្រភេទបើកចំហ ដែលសមាជិកភាពនៅក្នុងក្រុមនេះនឹងត្រូវកំណត់ដោយសហព្រះរាជអាជ្ញា និងចៅក្រមនៃ អ.វ.ត.ក ដោយផ្អែកលើភស្តុតាងទាំងមូល ហើយដោយបំពេញកិច្ចមិនលម្អៀង

---

[66] ឯកសារ **D378/5.1.205** អត្ថបទរៀបរៀងដោយលោក Scheffer, EN ERN 01595698 [សំដៅទៅលើ ឌុច ដែលត្រូវបានផ្តន្ទាទោសរួចមកហើយនៅឆ្នាំ២០១០ ព្រមទាំង នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ដែលត្រូវបានចោទប្រកាន់នាពេលនោះ]។

[67] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ៧។

[68] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិមនុស្ស មាត្រា១៤(១)។

[69] *សូមមើល ឧទាហរណ៍* សេចក្តីប្រកាសរបស់អាមេរិកស្តីពីសិទ្ធិមនុស្ស និងភារកិច្ចរបស់មនុស្ស ដែលអនុម័តដោយសន្និសីទអន្តរជាតិ លើកទី ៩ របស់រដ្ឋនានារបស់អាមេរិក ក្រុង Bogota ឆ្នាំ១៩៤៨ មាត្រា II។ ធម្មនុញ្ញអាហ្វ្រិក (Banjul) ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ដែលទទួលបានការអនុម័តនៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ១៩៨១ និងចូលជាធរមាននៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៨៦ មាត្រា ៣ (១)។ ពិធិសារទី ១២ ចំពោះកតិកាសញ្ញា [អឺរ៉ុប] សម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក្រុងរ៉ូម ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០០ បុព្វកថា។

[70] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ("រដ្ឋធម្មនុញ្ញកម្ពុជា") មាត្រា៣១ [បុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។]។

និងឯករាជ្យ[71]។ ប្រវត្តិនៃការចរចាបង្ហាញច្បាស់ថា គ្មានភាគីណាមួយមានចេតនាបកស្រាយទៅតាមការធ្វើឡើងនៅក្នុងដីកាលើកលែងការចោទប្រកាន់នោះឡើយ។

35. នៅក្រោយពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀង អ.វ.ត.ក ដែលជាសន្ធិសញ្ញាអន្តរជាតិមួយរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ភាគីទាំងសងខាង មានកាតព្វកិច្ចគោរពទៅតាមបទប្បញ្ញត្តិ[72] រួមទាំងវិសាលភាពនៃយុត្តាធិការបុគ្គល បើសិនជាពុំមានការធ្វើវិសោធនកម្ម ដោយអនុលោមតាមមាត្រា២(៣) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក នោះទេ[73]។ មាត្រា ២(៣) ចែងថា "នៅក្នុងករណីចាំបាច់ មានវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មបែបនេះ ត្រូវតែមានការពិគ្រោះយោបល់គ្នាជាមុនរវាងភាគីទាំងពីរ"[74]។ បទប្បញ្ញត្តិនេះចែងច្បាស់ថា ការផ្លាស់ប្តូរគោលនយោបាយមួយពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក (ដែលរួមបញ្ចូលយុត្តាធិការបុគ្គល) ត្រូវទទួលការឯកភាពដោយភាគី *ទាំងសងខាង* ក្រោយការពិភាក្សាមួយដែលមានការចូលរួមរបស់ភាគី *ទាំងសងខាង* ។ មកដល់បច្ចុប្បន្ន ទាំងរាជរដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ ពុំបានព្យាយាម

---

[71] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា៣ (៣) [ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត [...]] ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ[...]]។ ច្បាប់ អ.វ.ត.ក មាត្រា១០*ថ្មី* ។ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៥១ [អំណាចបែកចែកដាច់គ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ]។ មាត្រា១២៨ (មាត្រា១០៩ ចាស់) ["អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។"] ។ មាត្រា១២៩-១៣០ (មាត្រា១១០-១១១ ចាស់)។ ធម្មនុញ្ញសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ បុព្វកថា ១(៧)។ របាយការណ៍ក្រុមអ្នកជំនាញ អ.ស.ប កថាខណ្ឌ៩៧ ["យុត្តិធម៌ត្រឹមត្រូវ និងមិនលម្អៀង តម្រូវឲ្យធ្វើសេចក្តីសម្រេចឯករាជ្យចំពោះការចោទប្រកាន់បុគ្គលទៅជំនុំជម្រះ និងការផ្តន្ទាទោសដោយពុំមានសម្ពាធនយោបាយ"]។ សេចក្តីថ្លែងការណ៍របស់រដ្ឋប៉េកាំងស្តីពីគោលការណ៍ឯករាជ្យភាពនៃតុលាការនៅក្នុងតំបន់ LAWASIA សមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៧ មាត្រា៣(ក), ៤-៥។ ក្រម New Delhi ស្តីពីបទដ្ឋានអប្បបរមានៃឯករាជ្យតុលាការ សមាគមគណៈមេធាវីអន្តរជាតិ ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៨២ មាត្រា១៦។ គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពនៃតុលាការ ដែលអនុម័តដោយសេចក្តីសម្រេចមហាសន្និបាត លេខ៤០/៣២ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងលេខ៤០/១៤៦ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥ កថាខណ្ឌ១-២។

[72] អនុសញ្ញាទីក្រុងវីយែន មាត្រា២៦ ["ការគោរពតាមកិច្ចសន្យា៖ គ្រប់សន្ធិសញ្ញាជាធរមានចងកាតព្វកិច្ចលើភាគី ហើយត្រូវគោរពដោយសុទ្ធចិត្ត"]។ *សូមអានផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា២ (២)។

[73] អនុសញ្ញាទីក្រុងវីយែន មាត្រា៣៩ ["សន្ធិសញ្ញាអាចធ្វើវិសោធនកម្មតាមការព្រមព្រៀងរបស់ភាគី"]។ គោលការណ៍ *គោរពតាមកិច្ចសន្យា* មានន័យក្នុងនោះថា ចាំបាច់ត្រូវធ្វើឡើងជាឯកច្ឆ័ន្ទ។

[74] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា២ (៣)។

ធ្វើវិសោធនកម្មលើបទប្បញ្ញត្តិពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក នោះទេ។ ដូច្នេះ វិសាលភាពនៃយុត្តាធិការបុគ្គល ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក កំណត់និយមន័យយុត្តាធិការបុគ្គលនៃ អ.វ.ត.ក និងគឺជាច្បាប់ដែលអង្គបុរេជំនុំជម្រះ ត្រូវអនុវត្តតាមនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

36. សេចក្តីសន្និដ្ឋានក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា ឌុច គឺជាបុគ្គលម្នាក់គត់ដែលស្ថិតក្នុងប្រភេទនៃ "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" បានបំពានទៅលើកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងជាកំហុសអង្គច្បាប់មួយដែលធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាព។ កំហុសនេះមានអានុភាពលើសេចក្តីសម្រេចដែលថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ។

## ខ. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ដោយខកខានច្រើនដងក្នុងការចេញសេចក្តីសម្រេចដែលមានសំអាងហេតុ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងលទ្ធភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ យឹម ទិត្យ

37. ដីកាសម្រេចលើកលែងចោទប្រកាន់បានខកខានជាច្រើនដងក្នុងការចេញសេចក្តីសម្រេចដែលមានសំអាងហេតុទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងលទ្ធភាពនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ របស់ យឹម ទិត្យ។ ការមិនដាក់បញ្ចូលធាតុផ្សំដ៏សំខាន់ទាំងនេះ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់កំណត់យុត្តាធិការបុគ្គលឲ្យបានសមស្រប ត្រូវចាត់ទុកថាកំហុសអង្គច្បាប់ ដែលកំហុសនីមួយៗ ឬកំហុសទាំងអស់នោះ ធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាព។

### ១. ការគ្មានសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់ទាក់ទងថាតើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តស្ថិតក្នុង យុត្តាធិការនៃ អ.វ.ត.ក និងថាតើ យឹម ទិត្យ ទំនងជាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះដែរឬទេ

38. ដីកាសម្រេចលើកលែងចោទប្រកាន់ មានកំហុសអង្គច្បាប់ ដោយមិនបានពិនិត្យឲ្យបានច្រើនទៅលើភ័ស្តុតាងក្នុងសំណុំរឿង និងមិនមានការសន្និដ្ឋានផ្នែកអង្គហេតុ ដែលបានមកពីការវិភាគលើភ័ស្តុតាងឲ្យបានល្អិតល្អន់។ សូម្បីតែមានការពិនិត្យខ្លះទៅលើភ័ស្តុតាង និងការសន្និដ្ឋានផ្នែកអង្គហេតុតិចតួចក៏ដោយ ក៏ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ដោយ " [...] មិនបានពិចារណាលើការចាត់បទល្មើសទៅតាមអង្គហេតុ និងសរសេរបញ្ចូលនូវទម្រង់នៃការ

ទទួលខុសត្រូវ"[75] នៅពេលសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះ ព្រមទាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០១ និង០០៤/១ និងដីកាសម្រេចច្រានចោលចោទប្រកាន់ សំណុំរឿង០០៣ និង០០៤/២ បានសម្រេចថា ការកំណត់បទចោទលើការសន្និដ្ឋានផ្នែកអង្គហេតុ និងការកំណត់បទចោទលើការប្រព្រឹត្តិទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវ មានភាពចាំបាច់ផ្នែកច្បាប់ ដើម្បីវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ សម្រាប់ការវាយតម្លៃអំពីយុត្តាធិការបុគ្គលនៃ "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត"[76]។ ដោយសារតែដីកាសម្រេចលើកលែងចោទប្រកាន់ខកខានដោយចេតនាក្នុងការមិនផ្តល់សំអាងច្បាប់ដែលតម្រូវឱ្យមានសម្រាប់ការវាយតម្លៃលើយុត្តិធិការបុគ្គលនោះ វាជាកំហុសអង្គច្បាប់ដែលធ្វើឱ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព។

39. ដីកាសម្រេចលើកលែងចោទប្រកាន់បានធ្វើការសន្និដ្ឋានលើផ្នែកអង្គហេតុ (តិចតួច) ទាក់ទងនឹងតួនាទីដែលមានអំណាច និងសិទ្ធិរបស់ យឹម ទិត្យ និងបានធ្វើការសន្និដ្ឋានដាច់ដោយឡែក (តិចតួច) ដែលបង្ហាញពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទីតាំងនានាដែល យឹម ទិត្យ ពិតជាទទួលខុសត្រូវដោយសារតែតួនាទីដែលអំណាច និងសិទ្ធិរបស់គាត់។ ទោះជាយ៉ាងនេះក្តី ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានកំណត់តាមផ្លូវច្បាប់ពីការប្រព្រឹត្តិដែលត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ និងធ្វើការកំណត់ប្រភេទនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះការប្រព្រឹត្តិនោះឡើយ។

---

[75] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤។

[76] <u>អង្គជំនុំជម្រះតុលាការកំពូល</u>៖ សំណុំរឿង០០១-ឯកសារ **F28** សាលដីកាលើបណ្តឹងសាទុក្ខ កថាខណ្ឌ៧១, ៨០។ <u>អង្គជំនុំជម្រះសាលាដំបូង</u>៖ សំណុំរឿង០០១-ឯកសារ **E188** សាលក្រមរបស់ឌុច កថាខណ្ឌ ២២។ សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច កថាខណ្ឌ១១៥។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយ លើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ២៦ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយលើករណី *អ៊ឹម ចែម* ជើងទំព័រ៧៣៥ ["ដោយសារថា ដីកាដំណោះស្រាយនេះលើកលែងការចោទប្រកាន់ ដោយបានផ្អែកតែទៅលើមូលហេតុកង្វះយុត្តាធិការ ...សហចៅក្រមស៊ើបអង្កេតជាតិទទួលស្គាល់ថា ក្រៅពីការបរិយាយពីអង្គហេតុដែលទាក់ទងនឹងការចូលរួមរបស់ជនសង្ស័យ និងភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវបានចោទប្រកាន់ ការកំណត់ប្រភេទបទល្មើសដោយអន្លើៗទៅលើអង្គហេតុទាំងនោះមានភាពចាំបាច់ យ៉ាងហោចណាស់ក៏សម្រាប់ការកំណត់អំពីបញ្ហាថាតើអង្គហេតុទាំងនោះស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក និងអាចនាំទៅរកការកំណត់អំពីភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងក្របខណ្ឌនៃយុត្តាធិការបុគ្គល"]។ សំណុំរឿង០០៤/២-ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន កថាខណ្ឌ៤២៤-៤២៥។ សំណុំរឿង០០៤/២-ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត កថាខណ្ឌ៣ កថាខណ្ឌ៣៦៥-៣៦៧។ *សូមអានផងដែរ* សេចក្តីសម្រេចបញ្ជូនបន្តក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ២៦-២៨។

40. ជាឧទាហរណ៍មួយនៃការសន្និដ្ឋានលើអង្គហេតុដែលពុំមានសំអាងច្បាប់ដែលចាំបាច់ គឺថា ដីកាសម្រេចលើកលែងចោទប្រកាន់យល់ឃើញថា (១) មន្ទីរសន្តិសុខវត្តប្រធាតុ ជាមន្ទីរសន្តិសុខថ្នាក់ស្រុកនៃស្រុកគិរីវង់[77] (២) យឹម ទិត្យ ជាលេខាស្រុកគិរីវង់ ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧[78] (៣) អ្នកទោសនៅទីតាំងនេះ "ត្រូវបានធ្វើទារុណកម្មយ៉ាងទារុណ" រួមទាំងការគ្របក្បាលឲ្យត្រដរខ្យល់ និងការវាយនឹងរំពាត់[79] និង (៤) អ្នកទោសបានស្លាប់នៅមន្ទីរសន្តិសុខដោយសារការសម្លាប់ និងអំពើអមនុស្សធម៌ដែលកើតមាននៅទីនោះ[80]។ ដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់ភ័ស្តុតាងរបស់សាក្សីមួយរូបដែលថា "ករណីដែលមានការសម្លាប់មនុស្សក្នុងចំនួនច្រើននាក់នោះ [កម្មាភិបាលវត្តប្រធាតុ] នឹងត្រូវធ្វើការសុំជំនួយពីថ្នាក់ស្រុកមកជួយ" "គំនរឆ្អឹងមនុស្សយ៉ាងខ្ពស់" ត្រូវបានរកឃើញនៅទីតាំងនោះ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ហើយចំនួនមនុស្សសរុបដែលត្រូវបានសម្លាប់ មានពី៥០០០ ទៅ៦០០០នាក់"[81]។ យ៉ាងណាក៏ដោយ ដីកាសម្រេចលើកលែងចោទប្រកាន់ពុំមានសេចក្តីសន្និដ្ឋានផ្នែកច្បាប់ទាក់ទងថាតើ អង្គហេតុទាំងនេះត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការសម្លាប់រង្គាល ឬអំពើអមនុស្សធម៌ដទៃទៀត ដូចជា ការប្រព្រឹត្តិដោយអមនុស្សធម៌ដែរឬទេ ហើយប្រសិនបើមានសេចក្តីសន្និដ្ឋានដូច្នេះនោះ តើ យឹម ទិត្យ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះដែរឬទេ។

41. ដូចគ្នានេះដែរ ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា នៅស្រុកបាកាន "នៅដើមឆ្នាំ១៩៧៨ [ខ្មែរក្រោម] ទាំងអស់ត្រូវបានសម្លាប់" រួមទាំងកុមារ អ្នកជំងឺ មនុស្សចាស់នៅទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ និងសន្និដ្ឋានថា យឹម ទិត្យ ត្រូវបានប្រកាសថាជាលេខាភូមិភាគពាយ័ព្យ នៅអង្គប្រជុំមួយ នៅបាត់ដំបងក្នុងខែ មីនា ឆ្នាំ ១៩៧៨[82] ដែលបង្ហាញពីអំណាច និងសិទ្ធិតាមព្រឹត្តហេតុរបស់គាត់។ ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា "ការសម្លាប់ខ្មែរក្រោមទ្រង់ទ្រាយធំបានកើតឡើងនៅក្នុងឃុំរំលេច និងខ្នារទទឹង" ហើយ "ជនរងគ្រោះត្រូវបានសម្លាប់និងកប់នៅទីតាំងរណ្តៅសពសេះញ៉ូវ និងព្រៃក្របៅ"[83] ប៉ុន្តែ ពុំបញ្ជាក់ថាតើអង្គហេតុទាំងនេះ

---

[77] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៩០។

[78] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៨៥, ១៨៧,៦៦៧។

[79] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៩៧។

[80] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៩៨។

[81] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៩៨-១៩៩។

[82] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៣៧, ៣២៨។

[83] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣៥៩, ៣៦៧។

ជាអំពើប្រល័យពូជសាសន៍ដែរឬទេ ហើយប្រសិនបើមានការសេចក្ដីសន្និដ្ឋានដូច្នេះនោះ ថាតើ យឹម ទិត្យ ទំនងជាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះដែរឬទេ[84]។

42. ដីកាសម្រេចលើកលែងចោទប្រកាន់ធ្វើការសន្និដ្ឋានស្រដៀងគ្នាទាក់ទងនឹងតួនាទី និងសិទ្ធិអំណាច *តាមនីតិន័យ* និង *តាមព្រឹត្តហេតុ* របស់ យឹម ទិត្យ នៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[85] ព្រមទាំងសំអាងហេតុនានាដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិខាងក្រោមនេះ បានកើតឡើងនៅទីតាំងនានា ដែលយឹម ទិត្យ ទទួលខុសត្រូវ ដោយសារតែតួនាទី និងសិទ្ធិរបស់គាត់[86]។ ឧក្រិដ្ឋកម្មទាំងនេះរួមមាន មនុស្សឃាត[87] ការសម្លាប់រង្គាល[88] ការធ្វើឱ្យទៅជាទាសករ[89] ការ

---

[84] ដីកាសម្រេចលើកលែងចោទប្រកាន់ ធ្វើការសង្កេតដោយអន្លើថា យឹម ទិត្យ មិនត្រូវបានឃើញនៅទីតាំងមួយចំនួនក្នុងចំណោមទីតាំងទាំងនេះទេ។ *សូមអាន ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣៦៣, ៣៧១។ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៣, ៣៦៧។ យ៉ាងច្រើនបំផុតនោះ ការសង្កេតនេះអាចបញ្ជាក់ថា វាគ្រាន់តែមានភាពជាប់ទាក់ទងបន្តិចចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ យឹម ទិត្យ ចំពោះហេតុការណ៍ទាំងនេះប៉ុណ្ណោះ។ ច្បាស់ណាស់ថា យឹម ទិត្យ មិនចាំបាច់មានវត្តមាននៅទីតាំងប្រព្រឹត្តបទឧក្រិដ្ឋទេ ដើម្បីឱ្យគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីនោះ យោងតាមទម្រង់នៃការទទួលខុសត្រូវ ក្រៅពីការប្រព្រឹត្តិដោយផ្ទាល់ ។ ការសង្កេតដែលថា មិនបានឃើញ យឹម ទិត្យ នៅទីតាំងជាក់លាក់ណាមួយ មិនមែនជាការវិភាគដែលមានសំអាងហេតុ ថាតើគាត់ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ក្រោមទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់នៅក្នុងសំណុំរឿងនេះដែរឬទេ ឬក៏មិនមែនបញ្ជាក់ពីកម្រិតនៃការចូលរួមរបសគាត់ទៅក្នុងឧក្រិដ្ឋកម្មទាំងនេះដែរ។ *សូមអានផងដែរ* ខាងលើ ផ្នែក៤ (ច) (៦)។

[85] ភូមិភាគនិរតី៖ ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៨៥, ១៨៧, ៦៦៧, ៦៨០ ។ ភូមិភាគពាយ័ព្យ៖ ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤៧, ១៦១, ១៦៤, ៦៦៩, ៦៧៩ ៦៨០។ ស.ព.អ កត់សម្គាល់ថា ដីកាសម្រេចលើកលែងចោទប្រកាន់ ក៏បានសន្និដ្ឋានថា អ៊ឹម ចែម ក៏ជាសមាជិកមួយរូបនៃគណៈកម្មាធិការតំបន់១៣ ទោះជាបានសម្រេចផ្ទុយពីនេះនៅក្នុងសំណុំរឿង០០៤/១ ក៏ដោយ។ *សូមអាន* ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១០០។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ៣០២។

[86] សេចក្ដីសង្ខេបនៃការសន្និដ្ឋានផ្នែកអង្គហេតុក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ដែលគួរកំណត់ថាជាឧក្រិដ្ឋកម្ម ស្ថិតនៅក្នុង**ឧបសម្ព័ន្ធ ២**។ ស.ព.អ រក្សាជំហរថា ភស្តុតាងក្នុងសំណុំរឿងបង្ហាញថា យឹម ទិត្យ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានពិពណ៌នានៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ រួមមាន អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម ហើយមិនត្រឹមតែឧក្រិដ្ឋកម្មដែលបានលើកឡើងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ។

[87] *សូមអានផងដែរ ឧទា.* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២០៨,២១១-២១២ [មន្ទីរសន្តិសុខក្រាំងតាចាន់], ៣១១-៣១២,៣១៧ [មន្ទីរសន្តិសុខខ្នងគូ], ៣៥៩-៣៦០ [ទីតាំងសម្លាប់មនុស្សទួលសេះញ៉ែរ], ៣៨៨ [មន្ទីរសន្តិសុខវត្តសម្ដេច], ៣៩៨-៤០០ [មន្ទីរសន្តិសុខមនុស្សឃុំកមពង់ព្រៀង រួមមាន ភូមិកាច់រទេះ], ៤១៩, ៤២១-៤២២ [ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង]។

និរទេស[90] ការដាក់ក្នុងមន្ទីរឃុំឃាំង[91] ការធ្វើទារុណកម្ម[92] ការធ្វើទុក្ខបុកម្នេញ (ដោយមូលហេតុនយោបាយ[93] ឬពូជសាសន៍[94]) និងអំពើអមនុស្សធម៌ដទៃទៀត (ការបញ្ជូនចេញដោយបង្ខំ[95]

---

[88] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៥៨-៣៦០ [ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់និយាយថា មានខ្មែរក្រោមច្រើនជាង២០០ (ពីររយ) គ្រួសារ ឬ១០០០ (មួយពាន់) នាក់ ត្រូវបានបញ្ជូនទៅទួលសេះញ៉ូវ] [នៅដើមឆ្នាំ១៩៧៨ ខ្មែរក្រោមទាំងអស់ត្រូវបានសម្លាប់ [...] នៅពេលប្រជុំមួយ គេបានប្រកាសថា ខ្មាំងវៀតណាម៣០០ (បីពាន់) នាក់ ត្រូវបានកម្ទេច]។ ៤១២,៤១៤ [នៅឆ្នាំ១៩៧៨ ប្រជាជនស្វាយរៀង៥០០ (ប្រាំរយ) នាក់ [...] យកដាក់នៅ មន្ទីរសន្តិសុខលេខ០៨ [...] អ្នកស្វាយរៀងត្រូវបានសម្លាប់អស់ក្រោយឃុំខ្លួនបាន៣ (បី) យប់ ហើយមានយប់មួយមនុស្សមួយមន្ទីរត្រូវបានសម្លាប់ចោលទាំងអស់ [...] មុនពេលកងទ័ពវៀតណាមចូលមកដល់ប្រហែល១០ (ដប់) ថ្ងៃ ឬកន្លះខែ អ្នកទោសនៅគុកលេខ០៨ ប្រហែលជា៣០០ (បីរយ) នាក់ទៀត ត្រូវបានសម្លាប់។ ២៤៩-២៥០, ២៥២-២៥៣ [មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន]។

[89] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២៨២, ២៨៣, ២៨៥ ["មានមនុស្សជាច្រើនត្រូវបានគេចាប់បញ្ជូនឱ្យធ្វើការនៅការដ្ឋានទំនប់កង្គូត។ នៅពេលធ្វើការនៅការដ្ឋាន មានក្រុមយោធាដែលប្រដាប់ដោយកាំភ្លើងឈរយាមនៅកន្លែងការដ្ឋាន"។ "ហើយបើអ្នកណាហ៊ាន [តួញត្អែរ] ប្រាកដជាត្រូវគេចាប់បញ្ជូនទៅមន្ទីរឃុំឃាំងបាណន់ ។" "ករណីមានមនុស្សខ្ជិលច្រអូស គេត្រូវធ្វើការរាយការណ៍"], ២៦៩ [សហករណ៍ធិបតី]។

[90] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២១៨ [ទីតាំងសម្លាប់មនុស្សភូមិព្រៃល], ២៣៣ [ទីតាំងសម្លាប់មនុស្សភូមិព្រៃភូមិស្តែង]។

[91] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៨៧ [មន្ទីរសន្តិសុខវត្តប្រធាតុ] កថាខណ្ឌ ១៩៤-១៩៥ [មន្ទីរសន្តិសុខវត្តប្រធាតុ], ២៧៣ [មន្ទីរសន្តិសុខធិបតីនៅសហករណ៍ធិបតី], ៣០៩, ៣១៣ [មន្ទីរសន្តិសុខខ្នងគូ] ។

[92] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៩៧ [អ្នកទោសនៅមន្ទីរសន្តិសុខវត្តប្រធាតុត្រូវគេធ្វើទារុណកម្មយ៉ាងទារុណ] , ៣១១ [នៅមន្ទីរសន្តិសុខខ្នងគូ [អ្នកទោសត្រូវបានគេធ្វើទារុណកម្មជារៀងរាល់ថ្ងៃ]], ៣៤២ [មន្ទីរសន្តិសុខភូមិវាល], ៣៩៧ [ភូមិកំពង់ព្រៀង]។

[93] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌក ២០៧-២០៨ [ខ្មែរក្រោម, សមាជិកអតីតរបប លន់ ណល់ និងប្រជាជន១៧មេសានៅមន្ទីរសន្តិសុខក្រាំងតាចាន់ ], ២៥៧-២៦០ [កម្មាភិបាលពាយ័ព្យ, អ្នកដែលពាក់ព័ន្ធនឹងវៀតណាម, អតីតទាហាន លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេនៅមន្ទីរសន្តិសុខគាស់ក្រឡា], ៤១២ [ប្រជាជនមកពីភូមិភាគបូព៌ា សមជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេនៅគុកលេខ៨], ២៧៩, ២៨៩, ២៨៣-២៨៤ [កម្មាភិបាលភូមិភាគពាយ្យនៅទំនប់កង្គូត], ៣៨៨-៣៨៩ [មន្ទីរសន្តិសុខវត្តសម្តេច], ៤១៩, ៤២១ [ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង]។

[94] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣៥៩, ៣៦៧ [ការសម្លាប់មនុស្សក្រោមទ្រង់ទ្រាយធំបានកើតឡើងនៅក្នុងឃុំរំលេច និងឃុំខ្នារទទឹង ហើយជនរងគ្រោះ [...] កប់នៅទីតាំងរណ្តោះសពសេះញ៉ូវ និងព្រៃកប្បាស]។ ២០៧, ២១២ [មន្ទីរសន្តិសុខក្រាំងតាចាន់] , ២២៨-២២៩ [ទីតាំងសម្លាប់មនុស្សវត្តអង្គុណា] , ៣២៧- ៣២៩ [រោងចក្រស្ករសកំពង់គុល] , ៣៤២ [មន្ទីរសន្តិសុខភូមិវាល]។

ការប្រព្រឹត្តិដោយអមនុស្សធម៌[96] ការរៀបការដោយបង្ខំ[97] ការរំលោភសេពសន្ថវៈ ដោយសារការបង្ខំឱ្យរួមសង្វាស[98] និងការបាត់ខ្លួនដោយបង្ខំ[99]។ លើសពីនេះទៀត ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានពន្យល់ពីមូលហេតុដែលជនរងគ្រោះរាប់ពាន់នាក់ ក្រៅពីអ្នកដែលបាន "ស្លាប់ ឬត្រូវបានសម្លាប់" ពុំត្រូវបានពិចារណានៅក្នុងផ្នែកមានចំណងជើងថា "ចំនួនជនរងគ្រោះ" នោះទេ[100]។

43. ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់បានធ្វើសេចក្ដីសន្និដ្ឋានផ្នែកច្បាប់ដែលតម្រូវឱ្យមានដោយសារតែការសន្និដ្ឋានលើអង្គហេតុ (តិចតួច) នោះ សេចក្តីសន្និដ្ឋានផ្នែកច្បាប់ទាំងនោះ មានអានុភាពលើការកំណត់លើបញ្ហាពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល។ ឧទាហរណ៍ ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់ធ្វើការសន្និដ្ឋានថា យឹម ទិត្យ ទំនងជាទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ឬការសម្លាប់រង្គាល អាចដល់រាប់ពាន់នាក់នោះ ត្រូវមានសេចក្ដីពន្យល់ជាមួយនឹងសំអាងហេតុ ទាក់ទងនឹងមូលហេតុដែល យឹម ទិត្យ មិនស្ថិតនៅក្នុងចំណោម "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះជាធ្វើការសន្និដ្ឋានបែបនេះក៏ដោយ។ ម្យ៉ាងវិញទៀត ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់យល់ឃើញថា អង្គហេតុទាំងនេះមិនបង្ហាញពីការសម្លាប់រង្គាល ឬអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្ត ឬមិន

---

[95] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២០៦ [មន្ទីរសន្តិសុខក្រាំងតាចាន់] , ២៣៣ [ទីតាំងសម្លាប់មនុស្សភូមិព្រៃភូមិស្លែង], ២៤៩-២៥០ [មន្ទីរសន្តិសុខវត្តអង្គសិរីមុនី] ,[ទីតាំងសម្លាប់មនុស្សភូមិព្រេល]។

[96] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣៥០ [មន្ទីរសន្តិសុខស្វាយជ្រំ], ២៤៧-២៤៨ [មន្ទីរសន្តិសុខវត្តអង្គសិរីមុនី], ២៦៩ [សហករណ៍ធិបតី], ២៨៦ [មន្ទីរសន្តិសុខបាណន់], ២៩៦ [មន្ទីរសន្តិសុខវត្តគិរីរម្យ], ៤១៣ [គុកលេខ៨]។

[97] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៦៧៥, ៦៧៩ ["អង្គហេតុមួយចំនួនប៉ុណ្ណោះដែលអះអាងថា យឹម ទិត្យ បានពាក់ព័ន្ធជាមួយការរៀបការដោយបង្ខំនៅស្រុកសំឡូត [...]"។ វាជាព័ត៌មានត្រឹមត្រូវស្រប [...], ៤០៧ [នៅឃុំរាំងកេសី "ត្រូវបានបង្ខំឱ្យរៀបការ"]។

[98] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤០៧ [នៅឃុំរាំងកេសី "មានការប្រកាសទៅកាន់ [...] អ្នកដែលត្រូវរៀបការថា "ត្រូវដើរតាមមាគ៌ាបក្ស មិនមានអ្នកណាអាចប្រកែកបានទេ" ហើយមានយោធាដើរស៊ើបការ], ៣៣១ [នៅរោងចក្រស្ករសកំពង់គល់ "ការរៀបការដោយបង្ខំ [...] មានការនាំទៅបន្ទប់រៀងខ្លួន ដែលមានឈ្លបយាមពេលយប់នៅថ្ងៃរៀបការផង"]។

[99] *សូមអានផងដែរ ឧទាហរណ៍* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២១៩ [ទីតាំងសម្លាប់មនុស្សភូមិព្រេល], ២៣៤ [ទីតាំងសម្លាប់មនុស្សភូមិស្លែង], ២៨៣-២៨៤ [ការដ្ឋានទំនប់កង្កួត], ៣៨០ [មន្ទីរសន្តិសុខវត្តគិរីរម្យ]។

[100] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៥៨៩។

បង្ហាញថា យឹម ទិត្យ ទទួលខុសត្រូវទេនោះ ក៏ត្រូវមានសេចក្តីពន្យល់លម្អិតដែលមានសំអាងហេតុដូចគ្នាដែរទាក់ទងនឹងការសន្និដ្ឋាននោះ។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទប្រកាន់បានជ្រើសរើសវិធីសាស្ត្រមួយដែលគ្រាន់តែវាយតម្លៃលើផ្នែកមួយនៃភស្តុតាងដែលពាក់ព័ន្ធលើប្រធានបទមួយ ដោយមិនបានធ្វើការសេចក្តីសន្និដ្ឋានដែលមានសំអាងហេតុណាមួយឡើយ ហើយបន្ទាប់មកបន្តទៅផ្នែកផ្សេងទៀតដោយប្រើវិធីសាស្ត្រស្រដៀងគ្នាដែលពុំមានសំអាងហេតុ ដែលមានអានុភាពលើការចោទប្រកាន់លើបទល្មើសនីមួយៗនៅក្នុងសំណុំរឿង។ ការគ្មានសំអាងហេតុនេះត្រូវបានចាត់ទុកថាជាកំហុសអង្គច្បាប់ ដែលធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងជាមូលដ្ឋានសំខាន់លើសេចក្តីសម្រេចដែលថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ ទេ។

## ២. ការខកខានមិនបានវាយតម្លៃទៅលើភស្តុតាង និងបង្កើតសំអាងហេតុ ទាក់ទងនឹងតួនាទី និងអំណាច តាមព្រឹត្តហេតុ របស់ យឹម ទិត្យ

44. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយមិនបានពិនិត្យលើតួនាទី និងអំណាច *តាមព្រឹត្តហេតុ* របស់យឹម ទិត្យ នៅក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលរបស់ខ្លួន ទោះបីជា (១) មានការពឹងផ្អែកយ៉ាងខ្លាំងថា ដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤/២ ពឹងផ្អែកលើការមិនមានសិទ្ធិ *តាមព្រឹត្តហេតុ* ក្នុងការធ្វើការសន្និដ្ឋានថា តុលាការមិនមានយុត្តាធិការបុគ្គលលើសំណុំរឿងទាំងនោះ និង (២) ធ្វើការសន្និដ្ឋានដែលបង្ហាញពីសារៈសំខាន់នៃអំណាច *តាមព្រឹត្តហេតុ*។ កំហុសនេះធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាពទេ។

45. ទីមួយ ដីកាសម្រេចលើកលែងចោទប្រកាន់នៃសំណុំរឿង០០៤/២ ពឹងផ្អែកយ៉ាងខ្លាំងទៅលើអង្គហេតុដែលថា ឧក្រិដ្ឋកម្មរបស់ អោ អាន មិនហួសពីអំណាចជាផ្លូវការរបស់គាត់ ក្នុងការឈានទៅការសន្និដ្ឋានរបស់ខ្លួនលើយុត្តាធិការបុគ្គលឡើយ[101]។ ស្រដៀងគ្នានេះដែរ ដីកាសម្រេចលើកលែងចោទប្រកាន់នៃសំណុំរឿង០០៣ បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការអនុវត្តហួសពីអំណាចផ្លូវការ ដោយលើកឡើងថា "បុគ្គលដែលនឹងស្ថិតចូលក្នុងយុត្តាធិការរបស់ អ.វ.ត.ក ពិតជាមានចំនួនតិចតួចបំផុត ដោយសំដៅតែទៅលើ [...] ជនដែលទទួលខុសត្រូវខ្ពស់បំផុតដែលបានចូលរួមយ៉ាងសកម្មក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ [...] *តាមរយៈអំណាច និងឥទ្ធិពលជាក់ស្តែងហួសពី*

[101] សំណុំរឿង០០៤/២-ឯកសារ **D359** ដីកាសម្រេចលើកលែង ចោទប្រកាន់ អោ អាន កថាខណ្ឌ៤៩៤-៥១០។

*អំណាចផ្លូវការដែលមាន*"[102]។ ទោះជា ស.ព.អ មិនយល់ស្របថា យុត្តាធិការ អ.វ.ត.ក កំណត់ត្រឹមតែបុគ្គលដែលប្រើប្រាស់អំណាច និងឥទ្ធិពលជាក់ស្តែង ហួសពីអំណាចផ្លូវការដែលមានក៏ដោយ ក៏ យឹម ទិត្យ ត្រូវបានចាត់ទុកថាជាបុគ្គលបែបនេះហើយ។ ហេតុដូច្នេះ ទោះជាផ្អែកលើទស្សនៈបែបចង្អៀត និងមិនត្រឹមត្រូវ អំពីយុត្តាធិការនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងសំណុំរឿង ០០៤/២ និង០០៣ ក៏ដោយ ក៏ យឹម ទិត្យ ពិតជានៅតែស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរ។

46. ទីពីរ ភ័ស្តុតាងក្នុងសំណុំរឿងនេះបង្ហាញថា អំណាច *តាមព្រឹត្តហេតុ* របស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយព្យ មានលើសពីអំណាចផ្លូវការរបស់គាត់នៅទីនោះឆ្ងាយណាស់ ហើយចំណុចនេះគឺជាចំណុចសំខាន់នៃទឡ្ហីករណ៍របស់អតីត ស.ព.អ នៅក្នុងសេចក្តីសន្និដ្ឋានស្ថាពររបស់គាត់អំពីការទទួលខុសត្រូវរបស់ យឹម ទិត្យ ជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យមួយរូប ដែលលើកឡើងថា៖

> មុនពេលត្រូវបានតែងតាំងជាផ្លូវការជាលេខាតំបន់១ និងជាអនុភូមិភាគពាយ័ព្យ គាត់គឺជាមេដឹកនាំតាមព្រឹត្តន័យដ៏មានឥទ្ធិពល នៅភូមិភាគពាយ័ព្យ។ ក្នុងន័យនេះ យឹម ទិត្យ ស្រដៀងនឹង តាម៉ុក ជាអ្នកឧបត្ថម្ភគាំពារ គឺទោះបីជាតាម៉ុក កំពុងដឹកនាំកាន់កាប់ភូមិភាគពាយ័ព្យដោយកម្មាភិបាលភូមិភាគនិរតីក៏ដោយ ក៏គាត់មិនមានតំណែងផ្លូវការនៅភូមិភាគពាយ័ព្យឡើយ រហូតដល់ រស់ ញឹម ត្រូវបានចាប់ខ្លួន [...] ភ័ស្តុតាងដំបូងបង្អស់អំពីការអនុវត្តតួនាទីរបស់ យឹម ទិត្យ ជាមេដឹកនាំតាមព្រឹត្តន័យដ៏សំខាន់ នៅភូមិភាគពាយ័ព្យ គឺពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ [...][103]។

47. ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានពិនិត្យលើបញ្ហានេះទាល់តែសោះ ដោយផ្តោតទាំងស្រុងតែលើតួនាទីផ្លូវការរបស់ យឹម ទិត្យ ក្នុងការវាយតម្លៃរបស់ខ្លួនលើយុត្តាធិការបុគ្គល[104]។ ប៉ុន្តែ ដូចគ្នានឹង តាម៉ុក ដែរ[105] អំណាចពិតប្រាកដរបស់ យឹម ទិត្យ លើសពីអំណាចផ្លូវការរបស់

---

[102] សំណុំរឿង០០៣-ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត កថាខណ្ឌ៤០៥ (គូសបញ្ជាក់បន្ថែម)។

[103] ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន៦៦នៃវិធានផ្ទៃក្នុង ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ") កថាខណ្ឌ៤៨-៤៩។

[104] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៤៧, ១៦១, ១៦៤, ១៨៥, ១៨៧, ៦៦៧-៦៦៩, ៦៧៩។

[105] ដីកាសម្រេចលើកលែងចោទប្រកាន់ ទទួលស្គាល់ថា "តាម៉ុក មកគ្រប់គ្រងពាយ័ព្យ តាំងពីខែមករាឆ្នាំ១៩៧៧ មុន រស់ ញឹម ត្រូវបានចាប់ខ្លួន។" ហើយជាផ្លូវការ តាម៉ុក ពុំទាន់ក្លាយជាលេខភូមិភាគពាយ័ព្យទេ មុនពេល រស់ ញឹម ត្រូវបានចាប់ខ្លួនប្រហែលមួយឆ្នាំ៦ខែក្រោយមក។ ដីកាសម្រេចលើកលែងចោទប្រកាន់ សន្និដ្ឋានថា ក្នុងអំឡុងពេលនោះ តាម៉ុក បានតែងតាំងកម្មាភិបាលភូមិភាគនិរតីជំនួសកម្មាភិបាលចាស់នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលនៃភូមិភាគពាយ័ព្យ ទោះជាមិនមានសិទ្ធិអំណាច

គាត់ច្រើនណាស់។ ដោយខកខានមិនបានពិចារណាលើអង្គហេតុនេះ ដីកាសម្រេចលើកលែងចោទប្រកាន់ធ្វើការប៉ាន់ស្មានយ៉ាងលឿនលើការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះយុទ្ធនាការឧក្រិដ្ឋកម្មរបស់ ប.ក.ក។

48. ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា យឹម ទិត្យ បានឧទ្ទេសនាមខ្លួនគាត់ជាសមាជិកគណៈកម្មាធិការតំបន់ ១ នៅអង្គប្រជុំមួយ នៅខែ សីហា ឬខែ កញ្ញា ឆ្នាំ ១៩៧៧[106] ក្នុងរយៈពេលប្រហែលជា ៩ ខែ មុនពេលដែលគាត់ត្រូវបានតែងតាំងឲ្យកាន់តួនាទីជាផ្លូវការក្នុងតំបន់នេះ។ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានសន្និដ្ឋានថា នៅអង្គប្រជុំមួយដែលមានកម្មាភិបាលប្រហែល ៨០០ នាក់ ចូលរួមនៅទំនប់កង្កួត មានការប្រកាសថា យឹម ទិត្យ បានមកជួយដឹកនាំតំបន់១ ហើយនៅពេលនោះ យឹម ទិត្យ បាននិយាយអំពីការវាយប្រហារដោយខ្លាំងបង្អប់[107]។ ភ័ស្តុតាងដែលដីកាសម្រេចលើកលែងចោទប្រកាន់ផ្អែកលើ ទាក់ទងនឹងការលើកឡើងនេះ បង្ហាញថា សេចក្តីប្រកាសដែលថា យឹម ទិត្យ នឹងមកជួយដឹកនាំតំបន់ ១ ត្រូវបានធ្វើឡើងដោយ តាប៉ែត លេខាតំបន់ ១ ផ្ទាល់[108] ដូច្នេះ គឺមុនពេល យឹម ទិត្យ មានតួនាទីផ្លូវការណាមួយក្នុងភូមិភាគពាយ័ព្យ (ពីព្រោះ យឹម ទិត្យ មិនត្រូវបានតែងតាំងឲ្យកាន់តំណែងផ្លូវការណាមួយ មុនពេលចាប់ខ្លួន តាប៉ែត ទេ)។

49. ក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យដែលមានឋានានុក្រមគ្រប់គ្រងតឹង[109] ការដែល យឹម ទិត្យ អាចឧទ្ទេសនាមខ្លួនគាត់ជាសាធារណៈថាជាសមាជិកគណៈកម្មាធិការតំបន់ ១ ទោះជាពុំមានតួនាទី

---

ផ្លូវការណាមួយដើម្បីអនុវត្តដូច្នោះក៏ដោយ។ គាត់ក៏បានបញ្ជាឲ្យចាប់ខ្លួនដែលបានអនុវត្តនៅក្នុងភូមិភាគពាយ័ព្យនៅក្នុងអំឡុងពេលនោះ។ ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៣៣, ១៣៩-១៤០,១៤៥, ១៦១, ៦៦៦។

[106] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២៨៩ *ដកស្រង់* ឯកសារ **D219/368** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ចម្លើយទី៥០។ ទោះជានៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២៨៩ លើកឡើងថា "តាទិត្យ បានណែនាំខ្លួនថាគាត់ជាគណៈតំបន់១"។ ភ័ស្តុតាងជាមូលដ្ឋានដែលបានដកស្រង់នោះ ពុំបានលើកឡើងដូច្នេះទេ។

[107] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២៨៩។

[108] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រ១១៣៧ *ដកស្រង់* ឯកសារ **D219/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រី ផាន់ ចម្លើយទី៣ ["តាប៉ែត បានប្រកាសនៅក្នុងអង្គប្រជុំថា តាទិត្យ មកពីភូមិភាគនិរតីមកជួយដឹកនាំពួកយើងនៅក្នុងតំបន់១។ កាលនោះ គឺមានការប្រជុំមួយយ៉ាងធំ ដែលចូលរួមដោយប្រជាជន ប្រធានភូមិ ប្រធានឃុំ ស្រុក ហើយមានមនុស្សទាំងអស់ប្រហែលជា៧០០ទៅ៨០០នាក់។ កាលប្រជុំពេលនោះ ធ្វើឡើងនៅនឹងកន្លែងសាងសង់ទំនប់កង្កួត។"]។

[109] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៩៥, ៩៩, ៦៥៦-៦៦៤, ៦៨០។ *សូមអានផងដែរ* កថាខណ្ឌ ៨០, ៩៤,៩៦, ១០០, ១០៥-១០៦។

ផ្លូវការក្នុងតំបន់នោះ គឺជាចំណុចគួរឲ្យកត់សម្គាល់។ ជាទូទៅ ការបំពានជាសាធារណៈលើបទបញ្ជាផ្លូវការ បណ្ដាលឲ្យមានការចាប់ខ្លួន និងសម្លាប់ចោលភ្លាមៗ ដោយហេតុថា ប.ក.ក មិនអត់ឱនចំពោះអំពើណាមួយដែលបង្ហាញពីការប៉ះបោល ឬការប្រឆាំងឡើយ។ អ្វីដែលចម្លែកដូចគ្នានោះ គឺលេខាតំបន់ ១ ដែលត្រូវបានតែងតាំងដោយត្រឹមត្រូវ បានទទួលស្គាល់ជាផ្លូវការជាបុគ្គលម្នាក់ដែលមិនមានអំណាចជាផ្លូវការ ថា បានមកទីនោះដើម្បី "ជួយដឹកនាំតំបន់ ១"[110]។ ហេតុការណ៍ទាំងនេះបានបង្ហាញថា បទបញ្ជាទូទៅ មិនបានអនុវត្តចំពោះ យឹម ទិត្យ ទេ ពីព្រោះគាត់ស្ថិតក្រោមការការពាររបស់បងថ្លៃរបស់គាត់ គឺ តាម៉ុក[111] ហើយ យឹម ទិត្យ មិនអាចប៉ះពាល់បានឡើយ ពីព្រោះ តាម៉ុក គ្រប់គ្រងភូមិភាគពាយ័ព្យ (ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានដូច្នេះថា គាត់ដូច យឹម ទិត្យដែរ ពុំមានតួនាទីផ្លូវការនៅទីនោះទេ)"[112]។ អ្នកគ្រប់គ្រងតំបន់ ១ បានទទួលការតែងតាំងដោយត្រឹមត្រូវ និងមានទំនាក់ទំនងជាមួយ រស់ ញឹម ដែលបាត់បង់អំណាចជាបណ្ដើរៗនោះ ហើយគាត់ត្រូវទទួលយកការជាន់ឈ្លីលើអំណាចរបស់គាត់ជាសាធារណៈ និងយល់ព្រមប្រគល់អំណាចឲ្យគាត់ "ជួយដឹកនាំតំបន់ ១"[113]។

50. ដូចបានទទួលស្គាល់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ "បានមកធ្វើការគ្រប់គ្រងការដ្ឋានទំនប់កង្ហត នៅក្នុងខែ វិច្ឆិកា ឬ ខែ ធ្នូ ឆ្នាំ ១៩៧៧"[114] ទោះជាគាត់ពុំទាន់មានតួនាទីជាផ្លូវការក្នុងតំបន់ក៏ដោយ។ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានទទួលស្គាល់ភ័ស្តុតាងផ្សេងទៀតដែលបង្ហាញពីសិទ្ធិអំណាច តាមព្រឹត្តហេតុ របស់ យឹម ទិត្យ ដោយកត់សម្គាល់ថា មាន

---

[110] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២៨៩។

[111] *សូមអាន ឧទា.* ឯកសារ **D219/85** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ធីម ចម្លើយទី១២៧ ["តាម៉ុកបងប្រពន្ធតាទិត្យ។"] ឯកសារ **D118/181** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ធីម ចម្លើយទី៨៨ ["តាម៉ុកបងប្រពន្ធតាទិត្យ។"] ឯកសារ **D118/181** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រៀល សន ចម្លើយទី៨៨ ["តាម៉ុកបងប្រពន្ធតាទិត្យ។"] ឯកសារ **D219/956** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចម្លើយទី១៥, ៣៦ ["គាត់ចាប់ខ្សែស្រឡាយតាម៉ុក [...] គាត់អ្នកដើរតាមតាម៉ុកហ្នឹង។ [...] គាត់ចូលមកឃើញដើរតាមតាម៉ុក ដឹងថាខ្សែតាម៉ុកហ្នឹង។"] ឯកសារ **D219/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាន់ ឡួន ចម្លើយទី៩៨៣ ["តែងតែរាយការណ៍ពីនេះពីនោះរវាងគ្នាហើយ ឲ្យដឹងទៅវិញទៅមក។"] ឯកសារ **D118/285** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ធីម ចម្លើយទី១៦ ["ពួកគាត់ទាំងពីរនាក់មានទំនាក់ទំនងគ្នាល្អធម្មតាទេ។"] ឯកសារ **D219/488** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ចម្លើយទី៦៣។ ឯកសារ **D219/844.1.4** គម្រោងលើកកម្ពស់គណនេយ្យភាព មជ្ឈមណ្ឌលឯកសារកម្ពុជា យឹម ទិត្យ ហៅ តា ទិត្យ EN ERN 01336628។

[112] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៣៣។

[113] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២៨៩។

[114] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩០។

សេចក្តីប្រកាសមួយនៅក្នុងអង្គប្រជុំ ក្រោយពេលចាប់ខ្លួន រស់ ញឹម ថា "តាទិត្យ ឡើងជាលេខាតំបន់ និងក្រោយមក គ្រប់គ្រងភូមិភាគពាយ័ព្យផងដែរ"[115] ហើយនៅ "សន្និបាតមួយនៅសាលាសាកលបាត់ដំបង ដែលមានតែកងការពារ និងយោធាចូលរួម [...] បានឧទ្ទេសនាម តាទិត្យជាប្រធានភូមិភាគ"[116]។ អង្គហេតុដែលថា យឹម ទិត្យ ត្រូវបានចាត់ទុក និងឧទ្ទេសនាមថាជាលេខាភូមិភាគពាយ័ព្យ ជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទីនោះ ដោយមិនគិតថាតើ គាត់បានកាន់តំណែងជាផ្លូវការសម្រាប់រយៈពេលមួយដែរឬទេ ពីព្រោះវាបង្ហាញពីកម្រិតនៃអំណាច តាមព្រឹត្តហេតុ របស់គាត់ក្នុងតំបន់នោះ។ ទោះជាគាត់ជាលេខាភូមិភាគជាផ្លូវការ ឬគ្រាន់តែជាអនុលេខាអនុវត្តការងារតាមរយៈការផ្ទេរអំណាចទាំងស្រុងពីតាម៉ុកក៏ដោយនោះ ក៏គាត់មានអំណាចគ្រប់គ្រាន់ដែលចាត់ទុកថាជាលេខាភូមិភាគដែរ។ យ៉ាងហោចណាស់ គាត់គឺជាបុគ្គលមានអំណាចខ្ពស់បំផុតទីពីរនៅក្នុងភូមិភាគពាយ័ព្យ។ ចំណុចនេះមានភាពសំខាន់ណាស់ ដោយហេតុថា សំអាងហេតុក្នុងដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងថា ក្នុងពេលជាមួយគ្នា តាម៉ុក កាន់តំណែងជាលេខាភូមិភាគចំនួន ៣[117] ហើយក្រោយមកចំនួន ៤[118] ដែលលើសពាក់កណ្តាលនៃទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ បន្ថែមពីលើតំណែងរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិម[119]។ ទំហំការងារនេះប្រាកដជាពុំអាចធ្វើបានតែម្នាក់ឯងឡើយ។ ដូច្នេះ មិនសំខាន់ថា យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាភូមិភាគ ឬយ៉ាងណានោះទេ ភស្តុតាងដែលបង្ហាញថា គាត់ត្រូវបានចាត់ទុកដូច្នេះ បង្ហាញយ៉ាងច្បាស់ថា យ៉ាងហោចណាស់ ជារឿយៗ គាត់ត្រូវបំពេញតួនាទីនោះជាកិច្ចការជាក់ស្តែង។

51. ដីកាសម្រេចលើកលែងចោទប្រកាន់ក៏ទទួលស្គាល់ថា សាក្សីជាច្រើនបានថ្លែងថា យឹម ទិត្យ ជាលេខាតំបន់ ១៣ ក្នុងឆ្នាំ ១៩៧៨[120] ប៉ុន្តែ បានច្រានចោលការលើកឡើងនេះដោយមិនត្រឹមត្រូវ

---

[115] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៣៧ (គូសបញ្ជាក់បន្ថែម)។

[116] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៣៧។ *សូមអានផងដែរ* កថាខណ្ឌ ៣២៨។

[117] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៣២, ១៣៧។

[118] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៦៨ ["តាម៉ុកត្រូវបានតែងតាំងជាលេខាភូមិភាគពាយ័ព្យក្នុងពេលដែលគាត់តំណែងជាលេខាភូមិភាគនិរតី។ បន្ទាប់ពីចាប់ខ្លួន សែ តាម៉ុក បានក្លាយជាលេខាបួនភូមិភាគ គឺនិរតី បស្ចិម ពាយ័ព្យ និងឧត្តរថ្មី"]។

[119] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៦៥ ["គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុំម្មុយនីស្តកម្ពុជាមានសមាជិក [...] តាម៉ុក..."]។

[120] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៦៦៨ យោងទៅលើកថាខណ្ឌ ១៧៩ ដកស្រង់ ឯកសារ **D118/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នុត នៅ ទំព័រ៣។ ឯកសារ **D118/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

ដោយពុំផ្អែកលើភ័ស្តុតាង ប៉ុន្តែ ផ្អែកទាំងស្រុងលើមូលហេតុដែលថា គាត់មានឋានៈជាអ្នកមានអំណាចនៅក្នុងភូមិភាគពាយ័ព្យនៅពេលនេះ[121]។ តាមពិតទៅ សាក្សីផ្សេងទៀត ក្រៅពីបុគ្គលដែលដីកាសម្រេចលើកលែងចោទបានកំណត់អត្តសញ្ញាណ បានផ្តល់ភ័ស្តុតាងអំពីវត្តមាន និងអំណាចរបស់ យឹម ទិត្យ នៅក្នុងភូមិភាគនិរតី រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ[122]។

52. ភ័ស្តុតាងនេះ ដែលភាគច្រើនទទួលស្គាល់ដោយដីកាសម្រេចលើកលែងចោទប្រកាន់ គ្រាន់តែជាមួយផ្នែកតូចនៃភ័ស្តុតាងទាំងមូលទាក់ទងនឹងអំណាច និងសិទ្ធិ តាមព្រឹត្តហេតុ របស់ យឹម ទិត្យ តែប៉ុណ្ណោះ[123]។ ក្នុងបរិបទរបបកម្ពុជាប្រជាធិបតេយ្យដែលមានភាពតឹង និងមានការបង្ខិតបង្ខំ

---

ណុប ណាន ទំព័រ៦-៧។ ឯកសារ **D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ទំព័រ២១-២២។ *សូមអានផងដែរ* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ១៧៣ *ដកស្រង់* ឯកសារ **D219/488** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ទំព័រ១០ និងឯកសារ **D118/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នុត នៅ ទំព័រ៣។

[121] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៦៦៨។

[122] ឯកសារ **D118/305** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប ផាន ចម្លើយ១០១ ["ស៖ តើលោកច្បាស់ដែរឬទេ ថាលោកបានឃើញ តាទិត រហូតដល់ចប់របបខ្មែរក្រហម? "] [ "ឆ៖ បាទ ខ្ញុំបានឃើញ។"] ឯកសារ **D219/55** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ចម្លើយ៤២ ["ខ្ញុំបានឃើញតាទិត្យនៅពេលជិតរបបខ្មែរក្រហមដួលរលំ។"] ឯកសារ **D219/189** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹម ឈឿន ចម្លើយ២៧ [ក្នុងអំឡុងពីរបីខែចុងក្រោយ ខ្ញុំមិនបានឃើញគាត់ទេ មុនរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៨។ "ខ្ញុំមិនបានឃើញគាត់ទេ ប៉ុន្តែខ្ញុំដឹងថាគាត់នៅគ្រប់គ្រងស្រុកគិរីវង់។"]

[123] ទាហរណ៍ យឹម ទិត្យ (១) ចូលរួមយ៉ាងសំខាន់ទៅក្នុងគោលនយោបាយប្រឆាំងខ្មាំងរបស់ ប.ក.ក តាមរយៈការកំណត់ អត្តសញ្ញាណ និងការកម្ចាត់អ្នកដែលសន្មតជាខ្មាំងរបស់ ប.ក.ក នៅក្នុងភូមិភាគពាយ័ព្យ។ *សូមអាន* ឯកសារ **D219/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ចម្លើយទី៣, ៥ [យឹម ទិត្យ បាននិយាយក្នុងអង្គប្រជុំក្នុងអំឡុងខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ទៅកាន់ថាមនុស្សទាំងអស់ប្រហែលជា៧០០ទៅ៨០០នាក់ នៅទំនប់កង្ហត ថា "យួន" សេអ៊ីអា និងកាហ្សេបេ កំពុងបង្កប់ខ្លួនក្នុងចំណោមពួកគេ និងបញ្ជាឲ្យរាយការណ៍ព័ត៌មានទាំងអស់អំពីជនសង្ស័យថាខ្មាំងទៅអង្គការលើ"]។ (*កំណត់សម្គាល់៖* សាក្សីបាននិយាយថាអង្គប្រជុំនោះធ្វើឡើងក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ក៏ប៉ុន្តែវាទំនងជាងដែលថាអង្គប្រជុំនោះបានធ្វើឡើងក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ផ្អែកលើមូលហេតុដែលបានលើកឡើងក្នុងឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ៥៨ និង **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ៦៩-៧០ *ដកស្រង់* **D219/982** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចម្លើយទី២៦-៣៣ [យឹម ទិត្យ បានណែនាំឲ្យសមាជិកឃោធោស្រុកគាស់ក្រឡ ស្វែងរក និងសម្លាប់ "សេអ៊ីអា និងយួន" ដែលបណ្តាលឲ្យ "មនុស្សរាប់ពាន់" ត្រូវបានសម្លាប់ក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧])។ (២) បានចូលរួមចំណែកក្នុងគោលនយោបាយពលកម្មដោយបង្ខំរបស់ ប.ក.ក នៅចុងឆ្នាំ១៩៧៦ និង ៦ខែដំបូងក្នុងឆ្នាំ១៩៧៧ នៅពេលដែលគាត់បានចូលរួមក្នុងវគ្គហ្វឹកហ្វឺនមួយសម្រាប់កម្មាភិបាល និងកម្មកររាប់រយនាក់នៅទំនប់កង្ហត និងបានណែនាំឲ្យកម្មករនៅទីនោះប្រឹងប្រែងធ្វើការ។ *សូមអាន* **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ៩៧-១០០ *ដកស្រង់* ឯកសារ **D219/956** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចម្លើយទី១៣-

សកម្មភាពទាំងនេះបង្ហាញពីកម្រិតគួរឲ្យភ្ញាក់ផ្អើលនៃអំណាច តាមព្រឹត្តហេតុ និងការរួចផុតពីបទបញ្ជាទូទៅ។

53. លើសពីនេះទៀត ដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងកថាខណ្ឌស្តីពីសេចក្តីសន្និដ្ឋាន បានកត់សម្គាល់ថា " ដោយឡែក គាត់ [យឹម ទិត្យ] កាន់តួនាទីក្នុងអំឡុងពេលដ៏ខ្លីក្នុងភូមិភាគពាយ័ព្យ"[124] ដែលជាការលើកឡើងយ៉ាងច្បាស់ទៅសេចក្តីសន្និដ្ឋានក្នុងដីកាសម្រេចនេះថា យឹម ទិត្យ កាន់តំណែងជាលេខាតំបន់ ១ និងជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ ពីខែ សីហា ឆ្នាំ ១៩៧៨ រហូតដល់របបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់[125] ដែលមានរយៈពេលតែ ៥ ខែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ការពឹងផ្អែក "យ៉ាងជាក់លាក់" របស់ដីកាសម្រេចលើកលែងចោទប្រកាន់លើអង្គហេតុនេះ មិនសមស្របទាល់តែសោះ ពីព្រោះថា ការតែងតាំង យឹម ទិត្យ ជាផ្លូវការ មានទំនាក់ទំនងតិចតួចបំផុតជាមួយនឹងអំណាចរបស់គាត់ក្នុងការរួមចំណែកក្នុងឧក្រិដ្ឋកម្ម។ យឹម ទិត្យ បានប្រើអំណាច តាមព្រឹត្តហេតុ យ៉ាងច្រើន និងបានចូលរួមក្នុងឧក្រិដ្ឋកម្មនៅក្នុងភូមិភាគពាយ័ព្យមុនពេលត្រូវបានតែងតាំងតំណែងណាមួយជាផ្លូវការនៅទីនោះ។

54. តាមរយៈការបដិសេធសិទ្ធិអំណាច តាមព្រឹត្តហេតុ នេះ ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយខកខានមិនបានពិចារណាលើផ្នែកដ៏សំខាន់បំផុតនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ដែលធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាព និងមានអានុភាពលើសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

---

១៦,២២។ ឯកសារ **D219/981** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចម្លើយទី៣-៥, ១៦-១៧, ៩, ៣៧-៣៨, ៥៨។ ឯកសារ **D219/980** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចម្លើយទី៦៥-៧១។ (៣) បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ តាប៉ែត លេខាតំបន់១នៅពេលនោះ ក្នុងអំឡុងមុនពេលចាប់ខ្លួនប៉ែត និងបានប្រមូលព័ត៌មានអំពីកម្មាភិបាលភូមិភាគពាយ័ព្យ និងអំពីការងារនៅទំនប់កង្ហត ដែលក្នុងបរិបទនោះ ជាព័ត៌មានដែលត្រូវបានប្រើប្រាស់ ដើម្បីអនុវត្តបន្ថែមនូវគោលនយោបាយឧក្រិដ្ឋ។ *សូមអាន* **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ១០១ ដកស្រង់ឯកសារ **D219/368** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជឿង ប៊ុន ចម្លើយទី៣៣-៣៤។ ឯកសារ **D219/980** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជឿង ប៊ុន ចម្លើយទី៦៥-៧១។ ឯកសារ **D219/430** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ចម្លើយទី១៧,១៩។ ឯកសារ **D219/654** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចម្លើយទី៦, ២២-២៣។

[124] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៦៨៣។

[125] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៦៦៩។

## ៣. ការដកទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍មួយចំនួន ដោយមិនត្រឹមត្រូវចេញពីការពិចារណា

55. ដីកាសម្រេចលើកលែងចោទប្រកាន់ មានកំហុសអង្គច្បាប់ ដោយបានដាក់ ទួលម្ទេស ទួលអណ្ដែត និងការរៀបការដោយបង្ខំនៅឃុំកំពង់ព្រៀង នៅក្រៅវិសាលភាពនៃសំណុំរឿង ០០៤។ ដូច្នេះ ហើយ ដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានពិចារណាលើអង្គហេតុទាំងនេះ ដែលជាប់ទាក់ទងនឹងការវាយតម្លៃលើយុត្តាធិការបុគ្គលទេ[126]។ ស.ច.ស បានទទួលអង្គហេតុមកវិនិច្ឆ័យយ៉ាងត្រឹមត្រូវទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ទាំងនេះ[127] ហើយមិនមានសេចក្ដីសម្រេចពី ស.ច.ស ឬអង្គបុរេជំនុំជម្រះ ក្នុងដកការស៊ើបអង្កេតទៅលើអង្គហេតុទាំងនេះទេ[128]។ ដីកាសម្រេច

---

[126] នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ទួលម្ទេស ទួលអណ្ដែត និងការរៀបការដោយបង្ខំនៅស្រុកសង្កែ រួមទាំងការរៀបការដោយបង្ខំនៅឃុំកំពង់ព្រៀង ត្រូវបានដាក់ក្រោមចំណងជើងជាភាសាខ្មែរ "ខ. អង្គហេតុមិនដាក់ឱ្យស្ថិតក្រោមការពិនិត្យ"។ ចំណងជើងនេះត្រូវបានបកប្រែក្នុងសំណៅបកប្រែជាភាសាអង់គ្លេសជាផ្លូវការដែលបានកែសម្រួលថា "2.2 Factual Findings for Dismissal of Charges" ឬអាចបកប្រែប្រសើរជាងនេះជាភាសាអង់គ្លេសថា "2.2 Facts Excluded from the Charges"។ *សូមអាន* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ EN ERN 01628696-97 កថាខណ្ឌ ៥៨៤ និង *បានគូសបញ្ជាក់ឡើងវិញ* នៅកថាខណ្ឌ ៥៨៩, ៦៧៤។ កំណត់សម្គាល់៖ ទោះជាកថាខណ្ឌ ៥៨៤ ក៏បានលើកឡើងអំពីការរៀបការនៅឃុំរាំងកេសី ស្រុកសង្កែ ក៏ដោយ ក៏ដីកាសម្រេចលើកលែងចោទប្រកាន់បានយល់ឃើញថា អង្គហេតុទាំងនេះស្ថិតនៅក្នុងវិសាលភាពសំណុំរឿង០០៤។ *សូមមើល* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ EN ERN 01628695 កថាខណ្ឌ ៤០៦-៤០៧។

[127] *សូមអាន* ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥៤, ៥៧-៥៩ [ទាក់ទងនឹងការបោសសម្អាតនៅភូមិភាគបូព៌ា]។ ឯកសារ **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងតំបន់១ និងខ្មែរក្រោម កថាខណ្ឌ ៥-៨ [ទាក់ទងនឹងស្រុកគាស់ក្រឡ រួមមានការដ្ឋានទួលម្ទេស]។ ឯកសារ **D91** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងការរៀបការដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ និងយេនឌ័រ កថាខណ្ឌ ៤-៦ [ទាក់ទងនឹងការរៀបការដោយបង្ខំនៅស្រុកសង្កែ] កថាខណ្ឌ ១២ [ទាក់ទងនឹងឧក្រិដ្ឋកម្មនៅទំនប់កង្ហត]។ ឯកសារ **D272/1** ចម្លើយតបទៅនឹង ដីកាបញ្ជូន សំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងការរៀបការដោយបង្ខំ កថាខណ្ឌ ៤-៦ [បញ្ជាក់ពីព្រំប្រទល់ស្រុកសង្កែ និងទីតាំងដែលបានដាក់បញ្ចូល]។ អង្គបុរេជំនុំជម្រះ បានសម្រេចថា ស.ច.ស ត្រូវទទួលពិនិត្យ ["ស្ថានភាពជុំវិញការប្រព្រឹត្តដែលលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"]។ *សូមអាន ឧទា.* សំណុំរឿង០០១- ឯកសារ **D99/3/42** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច កថាខណ្ឌ ៣៥។ សំណុំរឿង០០៣- ឯកសារ **D134/1/10** សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ [កោសលុប] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចលើពាក្យសុំរបស់ [មាស មុត] ស្នើឱ្យអង្គជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ, យោបល់របស់ចៅក្រមអន្តរជាតិលើសំណើសុំមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹង [កោសលុប] ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ១៤-១៥។

[128] *សូមអាន* វិធាន៦៦*ស្ទួន* [មានចំណងជើង "ការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ"], វិធាន៧៦ [មានចំណងជើង "បណ្ដឹងសុំមោឃភាពដោយការមិនគោរពវិធានបទប្បញ្ញត្តិ"]។

លើកលែងចោទប្រកាន់បានដកចេញទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ទាំងនេះពីការពិចារណាលើយុត្តាធិការបុគ្គល ដោយសន្និដ្ឋាន ដោយគ្មានសំអាងហេតុគ្រប់គ្រាន់ថា "មិនមានព័ត៌មានច្រើនពាក់ព័ន្ធនឹង យឹម ទិត្យ" [129]។

56. យោងតាមវិធានផ្ទៃក្នុង មានមូលដ្ឋានច្បាប់ចំនួនបី ដើម្បីដកអង្គហេតុពីកិច្ចស៊ើបសួរមួយ ប៉ុន្តែមិនមានមូលដ្ឋានច្បាប់ណាមួយ អាចអនុវត្តបានទេ។ វិធាន៦៦ *ស្ទួន* មិនអាចអនុវត្តបានទេ ពីព្រោះថា វិធាននេះតម្រូវឱ្យ ស.ច.ស (ឬ ស.ច.ស មួយរូប) ជូនដំណឹងដ៏លម្អិតអំពីចេតនារបស់ខ្លួន ដើម្បីដកអង្គហេតុ រួមទាំងថាតើអង្គហេតុដែលនៅសល់ អាចយកមកធ្វើតំណាងចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមបានយ៉ាងដូចម្តេច មុននឹងជូនដំណឹងអំពីការបញ្ចប់នៃកិច្ចស៊ើបសួរ[130]។ វិធាន ៧៦ មិនអាចអនុវត្តបាន ពីព្រោះមិនមានការដាក់ពាក្យសុំធ្វើមោឃភាពទៅកាន់អង្គបុរេជំនុំជម្រះ មុនពេលចេញដីកាដំណោះស្រាយ[131]។ ទោះជាវិធាន៦៧ ចែងអំពីការចេញដីកាសម្រេចលើកលែងចោទប្រកាន់ ប្រសិនបើ *ជាអាទិ៍* "ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ"[132]ក៏ដោយ ក៏ការលើកឡើងក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា "មិនមានព័ត៌មានច្រើនពាក់ព័ន្ធនឹង យឹម ទិត្យ [133]" នោះ គឺជាសំអាងហេតុមិនគ្រប់គ្រាន់ទេ។

57. បន្ថែមពីនេះទៀត អំណះអំណាងក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ផ្ទុយគ្នាពីសំអាងហេតុផ្សេងទៀតនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដែលបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីចាត់ទុកថា ឧក្រិដ្ឋកម្មនៅទីតាំង និងព្រឹត្តិការណ៍ទាំងនេះ ជាប់ពាក់ព័ន្ធនឹង យឹម ទិត្យ។ ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថា (១) ទួលម្ទេស និងទួលអណ្តែត ស្ថិតនៅក្នុង

---

[129] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៧៥។ *សូមអានផងដែរ* កថាខណ្ឌ ៥៨៩ នៃដីកាសម្រេចលើកលែងចោទប្រកាន់ សំណៅជាភាសាខ្មែរ "មិនមានភស្តុតាងច្រើនពាក់ព័ន្ធនឹងជនត្រូវចោទ" ត្រូវបានបកប្រែជាភាសាអង់គ្លេស "insignificant evidence related to the charged person", អាចបកប្រែប្រសើរជាងនេះថា "not much evidence related to the accused"។

[130] វិធាន ៦៦ *ស្ទួន* (២), វិធាន ៦៦ *ស្ទួន* (២)។

[131] ឯកសា **D361/4/1/10** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧ កថាខណ្ឌ ២១។

[132] វិធាន ៦៧ (៣)-(៤)។

[133] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៧៥។ *សូមអានផងដែរ* កថាខណ្ឌ ៥៨៩។.

តំបន់១ ហើយឃុំកំពង់ព្រៀង ស្ថិតនៅក្នុងតំបន់៤[134] (២) យឹម ទិត្យ គឺជាលេខាតំបន់១ ចាប់ពីខែសីហា ឆ្នាំ ១៩៧៨ និងបានក្លាយជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ នៅពេលមួយក្នុងឆ្នាំ ១៩៧៨[135] និង (៣) ទោះជានៅពេលនោះ យឹម ទិត្យ មិនមានតួនាទីផ្លូវការនៅក្នុងភូមិភាគពាយ័ព្យក៏ដោយ ក៏គាត់បានឧទ្ទេសនាមខ្លួនគាត់ថាជាសមាជិកគណៈកម្មាធិការតំបន់ ១ នៅក្នុងអង្គប្រជុំមួយក្នុងខែ សីហា ឬខែ កញ្ញា ឆ្នាំ១៩៧៧[136] ។ ដូច្នេះហើយ សំអាងហេតុទាំងនេះបង្ហាញថា យឹម ទិត្យ មានឋានៈជាអ្នកមានអំណាចលើទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ដែលរងការជំទាស់ក្នុងអំឡុងពេលដែលពាក់ព័ន្ធ។

58. កំហុសអង្គច្បាប់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងការដក ទួលម្ទេស, ទួលអណ្តែត និងការរៀបការដោយបង្ខំក្នុងឃុំកំពង់ព្រៀង ដោយមិនត្រឹមត្រូវ ចេញពីសំណុំរឿង០០៤ បណ្តាលឱ្យមានការខកខានក្នុងការពិចារណាលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងទីតាំងទាំងនេះ នៅពេលធ្វើការវាយតម្លៃយុត្តាធិការបុគ្គល[137]។ កំហុសអង្គច្បាប់នេះ រួមជាមួយកំហុសអង្គច្បាប់ផ្សេងទៀត ធ្វើឱ្យដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាព និងមានអានុភាពលើសេចក្តីសម្រេចដែលថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ។

## ៤. ការមិនបានពិចារណាលើលទ្ធភាពនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះអំពើប្រល័យពូជសាសន៍ក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល

59. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ដោយមិនបានពិចារណាលើលទ្ធភាពនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម ទោះជាបានធ្វើការសន្និដ្ឋានផ្នែកអង្គហេតុដោយលម្អិតដែល (១) បង្ហាញពីការសម្លាប់ខ្មែរក្រោមនៅទីតាំងនានាស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ និង (២) បង្ហាញពីចេតនាជាក់លាក់របស់ យឹម ទិត្យ

---

[134] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៦៤, ៤៨០, ៤៨៦, ៥៨៣-៥៨៤។

[135] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៧៩-៦៨០, ៦៦៩, ១៤៧។ [ទាក់ទងនឹងការកាន់តំណែងតាមនីតិន័យនៅភូមិភាគពាយ័ព្យ] កថាខណ្ឌ ១៤៧, ៦៦៩, ៦៨០, ១៦៤, ១៦១ [ទាក់ទងនឹងការកាន់តំណែងតាមនីតិន័យ នៅតំបន់១]។

[136] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៩ *ដកស្រង់* ឯកសារ **D219/368** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជឿង ប៊ិន ចម្លើយទី៥០។ ទោះជានៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២៨៩ លើកឡើងថា "តាទិត្យ បានណែនាំខ្លួនថាគាត់ជាគណៈតំបន់១"ក៏ដោយ ក៏ភស្តុតាងជាមូលដ្ឋានដែលបានដកស្រង់នោះ ពុំបានលើកឡើងដូច្នេះទេ។

[137] *សូមអាន* **ឧបសម្ព័ន្ធ ២**។

ក្នុងការកម្ទេចខ្មែរក្រោម (ដែលជាផ្នែកមួយនៃក្រុមជនជាតិវៀតណាម) ទាំងស្រុង ឬមួយផ្នែក តាមរយៈការសម្លាប់ ការដាក់ឲ្យស្ថិតក្រោមលក្ខខណ្ឌនៃការរស់នៅដោយមានចេតនាបំផ្លាញ និង ការបង្កឲ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរលើផ្លូវកាយ និងផ្លូវចិត្ត។ ការខកខានដោយមិនត្រឹមត្រូវនេះ ធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាព។

60. ការយោងតែម្តងគត់ទៅលើអំពើប្រល័យពូជសាសន៍នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ គឺការលើកឡើងថា "ខ្មាំង" ដែលត្រូវបានកំណត់គោលដៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាប្រភេទដ៏ទូលាយមួយ ដែលមានភាពខុសគ្នាពី "ជម្លោះពូជសាសន៍" ដែលនាំឲ្យមានអំពើ ប្រល័យពូជសាសន៍នៅក្នុងប្រទេស រ៉វាន់ដា និងជម្លោះ "ជាតិនិយម" ដែលឈានទៅកើតមានអំពើ ប្រល័យពូជសាសន៍នៅអតីតប្រទេសយូហ្គោស្លាវី[138]។ ការលើកឡើងនេះ ផ្ទុយទៅនឹងដីកាដំណោះ ស្រាយសំណុំរឿង ០០២/២ ដែលបានសន្និដ្ឋានថា អំពើប្រល័យពូជសាសន៍ ត្រូវបានប្រព្រឹត្តប្រឆាំង នឹង "បុគ្គលដែលជាសមាជិកនៃក្រុមជនជាតិវៀតណាម[139]"។ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២/២ បានសន្និដ្ឋានថា "ដើមឡើយ បក្សកុម្មុយនីស្តកម្ពុជា បានផ្តោតលើការបណ្តេញចេញរាល់ ប្រជាជនវៀតណាមពីទឹកដីកម្ពុជា[140]" "បុគ្គលដែលជាសមាជិកនៃក្រុមជនជាតិវៀតណាម [...] ត្រូវបានសម្លាប់ដោយមានវិធីសាស្ត្រជាក់លាក់[141]" "ឯកសារនៃការប្រាស្រ័យទាក់ទងមួយចំនួន រវាងភូមិភាគ និងមជ្ឈិម គឺទាក់ទងនឹងការដាក់ឲ្យអនុវត្តគោលនយោបាយនេះ និងបានបង្ហាញពី អត្ថិភាពនៃរបាយការណ៍ស្តីពីការសម្លាប់ប្រជាជនវៀតណាមផងដែរ[142]" "ការសម្លាប់ប្រជាជន ស៊ីវិលវៀតណាម ជាការរៀបចំឡើងនៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិ[143]" ហើយ ប្រជាជនស៊ីវិលវៀតណាម ត្រូវបានកំណត់គោលដៅ និងសម្លាប់ នៅបាត់ដំបង ភូមិភាគពាយ័ព្យ និងតាកែវ ភូមិភាគនិរតី[144]។ ដីកាសម្រេចលើកលែងចោទប្រកាន់ សំណុំរឿង០០២/០២ ក៏បាន លើកឡើងពីការកំណត់គោលដៅលើជនជាតិភាគតិចខ្មែរក្រោម[145] ដោយយោងទៅលើរបាយ

---

[138] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៦៣។

[139] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៤៣-១៣៤៩។

[140] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩៤

[141] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៤៣។

[142] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៤៦។

[143] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨០២។

[144] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨០៣។ *សូមអានផងដែរ* កថាខណ្ឌ ៨០៤ [សន្និដ្ឋានថា ប្រជាជនវៀតណាម ត្រូវបានឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខជាច្រើន ក្នុងនោះមានក្រាំងតាចាន់]។

[145] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៦៨។

ការណ៍ឆ្នាំ ១៩៧៧ ពីស្រុកត្រាំកក់ ក្នុងតំបន់៣១ ដែលស្នើសុំគោលការណ៍ណែនាំស្តីពីការចុះឈ្មោះប្រជាជនខ្មែរក្រោម[146] និងភស្តុតាងដែល ប៉ុល ពត បញ្ជូន "កងទ័ពយើងទៅកម្ពុជាក្រោម [...] ក្នុងបេសកកម្មដើម្បីសម្លាប់ឲ្យបានច្រើនជាអតិបរមានូវបុរស ស្ត្រី និងកុមារ របស់កំពូលយួនដ៏អាក្រក់បំផុតនេះ"[147]។ ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានបញ្ជាក់ពីការផ្លាស់ប្តូរជំហរនេះ ដែលខុសពីជំហរនៅក្នុងដីកាដំណោះស្រាយសំណុំរឿង០០២ ហើយក៏មិនបានពន្យល់លម្អិតថាហេតុដូចម្តេចបានជាខ្មែរក្រោមដែលត្រូវបានចាត់ជា "ខ្មាំង" អាចមិនមែនជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍។

*ក) ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថា ខ្មែរក្រោម ត្រូវបានកំណត់គោលដៅ និងសម្លាប់ពីព្រោះពួកគេ ត្រូវបានចាត់ទុកថាជាជនជាតិវៀតណាម*

61. ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថា ចាប់ពីឆ្នាំ ១៩៧៥ ខ្មែរក្រោម ត្រូវបានបញ្ជូនចេញដោយបង្ខំពីប្រទេសវៀតណាម ត្រូវបានឃុំឃាំងនៅតំបន់ ៣១[148] ហើយក្រោយមក ត្រូវបានសម្លាប់ ដោយយោងតាមគោលនយោបាយ ប.ក.ក[149]។ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានសន្និដ្ឋានថា ប.ក.ក បានកំណត់គោលដៅលើខ្មែរក្រោម និងជនជាតិវៀតណាម ជាមួយគ្នា[150] ដោយពួកគេបានភ្ជាប់ខ្មែរក្រោមទៅនឹងជនជាតិវៀតណាម[151] និងកំណត់ថា ខ្មែរក្រោមជា "យួន[152]" ដែលមាន "ក្បាលយួនខ្លួនខ្មែរ[153]"។ ចុងក្រោយ ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថា ដូចជនជាតិវៀតណាមដែរ ខ្មែរក្រោម ត្រូវបានកំណត់អត្តសញ្ញាណតាមរយៈពណ៌សម្បុរ និងការនិយាយរដឺន[154] និងត្រូវបានកំណត់គោលដៅថាជា "ខ្មាំង" [155]។

---

[146] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០។

[147] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៨។

[148] ដីកាសម្រេចលើកលែងចោទប្រកាន់ សន្និដ្ឋានថា ខ្មែរក្រោម ដែលបានយកពីប្រទេសវៀតណាម ត្រូវបានឃុំឃាំងនៅវត្តព្រៃល នៅចុងឆ្នាំ ១៩៧៨។ *សូមមើល* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៧, ២១៨-២១៩។

[149] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២២១។ *សូមអានផងដែរ* កថាខណ្ឌ ២៣៥-២៣៦, ៣៥៩-៣៦០, ២១៩-២២០, ២៥២, ៤០៥, ៤០៨, ៣៦៦-៣៦៨,២១២, ៣៤៣, ២២៨, ៣៦៧, ២២៩, ៣៦៩។

[150] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៨,៣៤២,៤០៥, ៣២៩, ២៣៥,៣២៨, ៣៥៨។

[151] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៣៥, ៣៥៨, ៣២៨ ។

[152] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៧។

[153] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤២។

[154] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៨។ *សូមអានផងដែរ* កថាខណ្ឌ ២១៩, ៣៥៣។

62. ការខកខានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងការពិចារណាថាអំពើប្រល័យពូជសាសន៍ត្រូវបានអនុវត្តប្រឆាំងនឹងខ្មែរក្រោម ជាការគួរឲ្យកត់សម្គាល់ ដោយហេតុថា សំអាងហេតុនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ផ្ទុះបញ្ចាំងពីសេចក្តីសម្រេចនានា ដែលបានធ្វើឡើងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង សំណុំរឿង០០២/២ ដែលហួសពីវិមតិសង្ស័យ។ អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា ចាប់ពីចុងឆ្នាំ ១៩៧៥ ដល់ចុងឆ្នាំ ១៩៧៦ គោលនយោបាយ ប.ក.ក គឺដើម្បីបណ្តេញប្រជាជនវៀតណាម (ដែលត្រូវបានសំដៅថាជា "យួន" និងត្រូវបានហៅថាជា "ខ្មាំង")[156] ចេញពីប្រទេសកម្ពុជា ជាការដោះដូរជាមួយប្រជាជនខ្មែរក្រោម ដែលរស់នៅក្នុងប្រទេសវៀតណាម (ពួកគេត្រូវបានបញ្ជូនដោយបង្ខំទៅកាន់ទីតាំងនានា រួមមានស្រុកត្រាំកក់ក្នុងតំបន់១៣)[157] និងបានសន្និដ្ឋានថា ក្នុងឆ្នាំ ១៩៧៧ គោលនយោបាយ បានផ្លាស់ប្តូរ ពីការបណ្តេញចេញ ទៅជាការកម្ទេចប្រជាជនស៊ីវិលវៀតណាម តាមរយៈការសម្លាប់[158]។ អង្គជំនុំជម្រះសាលាដំបូងក៏បានសន្និដ្ឋានថា ខ្មែរក្រោម ត្រូវបានប្រព្រឹត្តដាក់ដូចគ្នានឹងជនជាតិវៀតណាមដែរ ពីព្រោះពួកគេមានទំនាក់ទំនងជាមួយជនជាតិវៀតណាម ឬត្រូវបានចាត់ទុកថាជាជនជាតិវៀតណាម[159] និងបានសន្និដ្ឋានថា ខ្មែរក្រោមត្រូវបានកំណត់អត្តសញ្ញាណ តាមរយៈសូរសៀង និងរបៀបនៃការនិយាយរបស់ពួកគេ[160]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ដូចគ្នានឹងជនជាតិ

---

[155] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥២។

[156] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ("សាលក្រមសំណុំរឿង០០២/២"), ផ្នែក១៣.៣.៥.១ [មានចំណងជើង "ការប្រើប្រាស់ពាក្យ "យួន" និង "ខ្មាំង"យួន"]។

[157] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ កថាខណ្ឌ ១១២៥។ *សូមអានផងដែរ* កថាខណ្ឌ៨២៥, ៩៣៨, ១០៧៨, ១១១១, ១១១៩-១១២១។ ផ្នែក១៣.៣.៧ [មានចំណងជើង "ការផ្លាស់ទីលំនៅជនស៊ីវិលវៀតណាម ពីប្រទេសកម្ពុជាទៅកាន់ប្រទេសវៀតណាម"]។

[158] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ ។ ផ្នែក១៣.៣.៨ [មានចំណងជើង "ការសម្លាប់ប្រជាជនស៊ីវិលវៀតណាម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង"]។ ផ្នែក១៣.៣.៩ [មានចំណងជើង "ការសម្លាប់ប្រជាជនស៊ីវិលវៀតណាម នៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង"]។

[159] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ កថាខណ្ឌ ១១២៥, ១១៩២, ២៤៧២, ២៨០២-២៨០៣, ២៨០៦, ២៨៤៦, ៣៣៨៩។

[160] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ កថាខណ្ឌ ១១១៦, ២៨០២។

វៀតណាមដែរ អ្នកដែលជាប់ខ្សែខាងម្ដាយជាខ្មែរក្រោម ត្រូវបានកំណត់គោលដៅ[161] និងសម្លាប់ចោល[162]។

63. លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានផ្សេងៗទាក់ទងនឹងការប្រព្រឹត្តិលើខ្មែរក្រោម ក្នុងតំបន់ដែលជាប់ទាក់ទងនឹងការទទួលខុសត្រូវរបស់ យឹម ទិត្យ។ ឧទាហរណ៍ អង្គជំនុំជម្រះបានសន្និដ្ឋានថា "ទាំងវៀតណាម និងខ្មែរក្រោមជាច្រើននាក់ ត្រូវបានគេកំណត់ថាជាជនជាតិវៀតនាម នៅក្រាំងតាចាន់"[163] "មានការខិតខំប្រឹងប្រែងតាមដាន និងសម្រិតសម្រាំងខ្មែរក្រោម នៅស្រុកត្រាំកក់ ក្នុង ខែ មេសា ឆ្នាំ ១៩៧៧"[164] និងបានសន្និដ្ឋានថា "បញ្ជីឈ្មោះខ្មែរក្រោមត្រូវបានរៀបចំតាមឃុំនានា នៅចុងខែ មេសា ឆ្នាំ ១៩៧៧"[165]។ ទោះជា ស.ច.ស ពុំមានកាតព្វកិច្ចអនុវត្តតាមសេចក្ដីសម្រេចនេះក៏ដោយ ក៏គួរបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើសំអាងហេតុទាំងនេះ ហួសពីវិមតិសង្ស័យ បន្ទាប់ពីបានធ្វើការវាយតម្លៃលើសក្ខីកម្មផ្ទាល់ កំណត់ត្រាពីសម័យនោះ និងភ័ស្ដុតាងផ្សេងទៀត។

*ខ) សំអាងហេតុក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ បង្ហាញពីលទ្ធភាពដែលថា យឹម ទិត្យ បានអនុវត្តគោលនយោបាយក្នុងការកម្ទេចខ្មែរក្រោម ទាំងស្រុង ឬមួយផ្នែក ដោយមានចេតនាជាក់លាក់*

64. ទោះជាមិនបានពិចារណាលើលទ្ធភាពនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះអំពើប្រល័យពូជសាសន៍លើខ្មែរក្រោមក៏ដោយ ក៏ដីកាសម្រេចលើកលែងចោទប្រកាន់មានសំអាងហេតុជាច្រើនដែលបង្ហាញថា ខ្មែរក្រោមទទួលរងការធ្វើបាប និងត្រូវបានសម្លាប់នៅទីតាំងនានា ក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ និងបង្ហាញពីលទ្ធភាពទាក់ទងនឹងចេតនាជាក់លាក់របស់គាត់ក្នុងការកម្ទេចខ្មែរក្រោម។

65. នៅភូមិភាគនិរតី ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋាន *ក្នុងចំណោមចំណុចផ្សេងទៀត* ថា (១) របាយការណ៍ស្ដីពីការចាប់ខ្លួនខ្មែរក្រោមត្រូវបានបញ្ជូនរវាងមន្ទីរឃុំ មន្ទីរស្រុក និងមន្ទីរ

---

[161] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ កថាខណ្ឌ ៣៤២៤។ *សូមមើលផងដែរ* កថាខណ្ឌ ១១២២, ២៨០៣, ផ្នែក ១៣.៣.៦ [មានចំណងជើង "ការកំណត់អត្តសញ្ញាណជនជាតិវៀតណាម និងជាតិពន្ធុជាប់ខ្សែខាងម្ដាយ"]។

[162] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ កថាខណ្ឌ ១២០១, ១១១៧, ១០៨០។ *សូមអានផងដែរ* កថាខណ្ឌ ១០៧៨។

[163] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ កថាខណ្ឌ ២៨០២។

[164] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ កថាខណ្ឌ ២៨០៣។

[165] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/២ កថាខណ្ឌ ២៨០៤។

សន្តិសុខក្រាំងតាចាន់[166] (២) ខ្មែរក្រោមចំនួនប្រហែល ៤០០ គ្រួសារ ត្រូវបានបញ្ជូនចេញ ដោយបង្ខំទៅកាន់វត្តអង្គសិរីមុនី ហើយត្រូវបានសម្លាប់ ពីព្រោះពួកគេត្រូវបានចាត់ទុកថាជាខ្មាំង[167] (៣) ខ្មែរក្រោមជាង ១០០០ នាក់ ត្រូវបានសម្លាប់នៅភូមិព្រៃល[168] ក្នុងនោះមានកុមារខ្មែរក្រោមដែលត្រូវបានចាត់ទុកជា "យួន"[169] (៤) ប្រជាជនដែលមានប្តី ឬប្រពន្ធ ដែលមានទំនាក់ទំនងជាមួយវៀតណាម ក៏ត្រូវបានសម្លាប់ផងដែរ[170] (៥) ក្នុងអំឡុងអង្គប្រជុំនៅវត្តស្លែង ក្នុងឆ្នាំ ១៩៧៨ ខ្មែរក្រោមត្រូវបានពិពណ៌នាថាជា "ក្បាលយួនខ្លួនខ្មែរ" ដែលត្រូវសម្លាប់ចោល ដើម្បីទប់ស្កាត់មិនឱ្យពួកគេភៀសខ្លួនទៅប្រទេសវៀតណាម[171] (៦) ខ្មែរក្រោម ត្រូវបានបញ្ជូនទៅកាន់ក្រាំងតាចាន់ជាបន្តបន្ទាប់ ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨ ហើយភាគច្រើន ត្រូវបានបញ្ជូនទៅទីនោះក្នុងឆ្នាំ ១៩៧៧[172] និង (៧) ខ្មែរក្រោមចំនួនជាង ១០០ នាក់ រួមទាំងកុមារត្រូវបានសម្លាប់ និងបោះចូលក្នុងរណ្តៅនៅក្រាំងតាចាន់[173]។

66. នៅក្នុងភូមិភាគពាយ័ព្យ ដីកាសម្រេចលើកលែងចោទប្រកាន់ បានសន្និដ្ឋាន *ក្នុងចំណោមចំណុចផ្សេងៗទៀត* ថា (១) ការ ប្រឆាំងនឹងជនជាតិវៀតណាម មានសភាពកាន់តែខ្លាំងក្លា នៅអំឡុងពេលដែល យឹម ទិត្យ បានមកដល់ភូមិភាគពាយ័ព្យ[174] (២) ការបោសសម្អាតដែលកំណត់គោលដៅទៅលើអ្នកណាដែលត្រូវបានសង្ស័យថាមានទំនាក់ទំនងជាមួយជនជាតិវៀតណាម ដូចជាប្រជាជនខ្មែរក្រោម[175] (៣) យឹម ទិត្យ បានដឹកនាំអង្គប្រជុំស្តីពីការស្វែងរកខ្មាំងយួន និងបានសន្និដ្ឋានថា ជាលទ្ធផល អ្នកដែលនិយាយភាសាវៀតណាម ឬជាប់សាច់ឈាមជាមួយជនជាតិវៀតណាម ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល[176] (៤) ខ្មែរក្រោមពីរ ឬបីនាក់ ត្រូវបានសម្លាប់

---

[166] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៧។

[167] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥០,២៥២។

[168] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២២០។

[169] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២១៩។

[170] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២១៩។

[171] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៣៥។

[172] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៧។

[173] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៧, ២១២។

[174] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៤។

[175] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៣៥។

[176] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៣។

ស្មើរតែរៀងរាល់ថ្ងៃនៅការដ្ឋានទំនប់កង្កត់[177] (៥) ខ្មែរក្រោម និងជនជាតិវៀតណាម ត្រូវបានចាប់ខ្លួននៅរោងចក្រស្ករសកំពង់គុល ពីព្រោះពួកគេត្រូវបានចាត់ទុកថាមានទំនាក់ទំនងជាមួយ "យួន"។ ពួកគេត្រូវបានកំណត់អត្តសញ្ញាណ ដោយសារសម្បុររបស់ពួកគេ ឬពីព្រោះពួកគេនិយាយខ្មែរមិនច្បាស់[178]។ ពួកគេត្រូវបានដឹកចេញតាមរថយន្តធំ ហើយពេលត្រឡប់មកវិញមិនមានមនុស្សលើរថយន្តទាំងនោះទេ[179] (៦) អ្នកដែលនិយាយខ្មែរមិនច្បាស់ និងមានរូបរាងដូចជនជាតិវៀតណាម ត្រូវបានយកទៅមន្ទីរសន្តិសុខគាស់ក្រឡ[180] (៧) គ្រួសារវៀតណាមទាំងអស់នៅឃុំឈើទាល ស្រុកបាណន់ ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខខ្នងគូ[181] (៨) ខ្មែរក្រោមជាច្រើននាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួនធ្វើទារុណកម្ម និងសួរចម្លើយនៅមន្ទីរសន្តិសុខភូមិវាល ពីព្រោះពួកគេត្រូវបានចាត់ថាជា "ក្បាលយួនខ្លួនខ្មែរ"[182] មុនពេលត្រូវបានសម្លាប់ និងអូសសាកសពរបស់ពួកគេចូលទៅក្នុងរណ្ដៅ[183] (៩) បុរសស្ត្រីដែលជាប្ដីប្រពន្ធរបស់អ្នកដែលត្រូវបានសម្លាប់ ត្រូវបានបង្ខំឱ្យរៀបការម្ដងទៀតនៅព្រៃក្របៅ និងទួលសេះញ៉ូវ[184] (១០) ខ្មែរក្រោមរាប់រយគ្រួសារ និងប្រជាជនដែលត្រូវបានសង្ស័យថាជាខ្មែរក្រោម ឬមានទំនាក់ទំនងជាមួយជនជាតិ វៀតណាម ត្រូវបានបញ្ជូនទៅទួលសេះញ៉ូវ និងត្រូវបានសម្លាប់[185] (១១) នៅក្នុងអង្គប្រជុំមួយនៅ ទួលសេះញ៉ូវ កម្មាភិបាល ប.ក.ក បានប្រកាសថា ខ្មាំងវៀតណាមជាង ៣០០ នាក់ ត្រូវបាន កម្ទេច[186] (១២) ការសម្លាប់រង្គាលខ្មែរក្រោមមកពីឃុំរំលេច និងឃុំខ្នារទទឹង បានធ្វើឡើងនៅព្រៃ ក្របៅ[187] ដែលមានកុមារម្នាក់នៅរស់រានមានជីវិត ពីព្រោះម្ដាយជាខ្មែរ

---

[177] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៧។

[178] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៨។

[179] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៩។

[180] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥៩។

[181] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១០។

[182] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤២។

[183] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤៣។

[184] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦២, ៣៧០។

[185] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៥៨-៣៥៩។

[186] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦០។

[187] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៧។

ប៉ុន្តែឪពុក ដែលជាខ្មែរ ក្រោម ត្រូវបានសម្លាប់[188] និង (១៣) ប្រជាជនរាប់ពាន់ដែលត្រូវបានចាត់ទុកជា "យួន" ត្រូវបានសម្លាប់នៅមុខវត្តរំលេច[189]។

67. ទោះជាមានសំអាងហេតុដ៏ច្រើនសន្ធឹកសន្ធាប់ទាំងនេះ និងមានសំអាងហេតុបញ្ជាក់ពីវិសាលភាពច្បាស់លាស់ ទាក់ទងថាតើខ្មែរក្រោម ត្រូវបានសម្លាប់ដោយវិធីណា និងដោយសារមូលហេតុអ្វីនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ ព្រមទាំងការពាក់ព័ន្ធរបស់ យឹម ទិត្យ ទៅនឹងគោលនយោបាយ ប.ក.ក ក៏ដោយ ក៏ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានពិចារណាទៅលើការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ឬលទ្ធភាពនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះការកំណត់គោលដៅក្នុងការកម្ទេចខ្មែរក្រោមដែរ។ ប្រសិនបើបានពិចារណាដូច្នេះនោះ តាមរយៈការអនុវត្តបទដ្ឋាននៃភស្តុតាងដែលជាប់ទាក់ទងទៅលើការសន្និដ្ឋានលើអង្គហេតុ ដូចបានកត់សម្គាល់ខាងលើនេះ នឹងមានការសន្និដ្ឋានមួយថា យឹម ទិត្យ មានលទ្ធភាពក្នុងការទទួលខុសត្រូវចំពោះចេតនាជាក់លាក់ក្នុងការកម្ទេចខ្មែរក្រោម ទាំងស្រុង ឬមួយផ្នែក។ កំហុសអង្គច្បាប់នេះធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាព និងមានអានុភាពលើសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ៥.ការមិនពិចារណាពីជនរងគ្រោះផ្សេងទៀតក្រៅពីជនទាំងឡាយណាដែលត្រូវបានសម្លាប់ នៅពេលវាយតម្លៃទៅលើយុត្តាធិការបុគ្គល

68. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសផ្នែកអង្គច្បាប់ តាមរយៈការពិចារណាតែទៅលើជនរងគ្រោះដែលបានស្លាប់ដោយសារលក្ខខណ្ឌនៅតាមទីតាំងឧក្រិដ្ឋកម្ម ឬដោយសារការសម្លាប់ដោយចេតនា នៅពេលរៀបរាប់ពីមូលហេតុនៃការធ្វើសេចក្តីសម្រេចពីយុត្តាធិការបុគ្គល[190]។ នេះបង្ហាញថា បើទោះជាសន្និដ្ឋានថា អ្នកទោសត្រូវបានឃុំឃាំងក្នុងលក្ខខណ្ឌដ៏អាក្រក់ និងទទួលរងការធ្វើទារុណកម្ម និងទោះបីជាមានការសន្និដ្ឋានថា ជនរងគ្រោះត្រូវបានធ្វើឲ្យទៅជាទាសករ ឬ

---

[188] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៨។

[189] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧៥។

[190] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៨០ *ដែលដកស្រង់* កថាខណ្ឌ ៥៨៩-៥៩០។ កថាខណ្ឌ ៥៨៩ និង ៥៩០ ដែលត្រូវបានដកស្រង់សម្រាប់ចំនួនជនរងគ្រោះសរុបដោយកថាខណ្ឌ ៦៨០ ផ្តោតតែលើជនរងគ្រោះដែលបានស្លាប់ប៉ុណ្ណោះ។

បង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ក្តី[191] ក៏ដីកាសម្រេចលើកលែងចោទប្រកាន់ពិចារណាតែទៅលើជនរងគ្រោះដែលត្រូវបានសម្លាប់ប៉ុណ្ណោះ នៅពេលវាយតម្លៃពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។ ក្នុងបរិបទនៃការសន្និដ្ឋានក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ការខកខានមិនបានពិចារណាពីព្យសនកម្មរបស់ជនរងគ្រោះផ្សេងទៀត គឺជាកំហុសឆ្គងផ្នែកអង្គច្បាប់ ដែលធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់នេះ វាយតម្លៃខុសពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៤ ដែលបូករួមនឹងកំហុសផ្នែកអង្គច្បាប់ផ្សេងទៀត ធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់នេះគ្មានសុពលភាព និងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ការសន្និដ្ឋានពីយុត្តាធិការបុគ្គល។

69. សរុបសេចក្តីមក ការខកខានផ្នែកអង្គច្បាប់របស់ដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងការធ្វើសេចក្តីសម្រេចសមហេតុផលមួយពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ យឹម ទិត្យ លើឧក្រិដ្ឋកម្មទាំងនោះ ធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងដោយឡែកពីគ្នា ឬជារួម ធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងលើការសម្រេចថា អ.វ.ត.ក គ្មានយុត្តាធិការបុគ្គលគ្រប់គ្រាន់លើ យឹម ទិត្យ ទេនោះ។

---

[191] *សូមមើល* **ឧបសម្ព័ន្ធ ២** [អង្គហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់នៅទីតាំងឧក្រិដ្ឋកម្ម]។ ក្នុងករណីមួយចំនួន ដីកាសម្រេចលើកលែងចោទប្រកាន់រកឃើញថា ឧក្រិដ្ឋកម្មបានកើតឡើង ប៉ុន្តែគ្មានការគូសបញ្ជាក់ពីចំនួនជនរងគ្រោះ។ ក្នុងករណីដែលចំនួនជនរងគ្រោះដែលទទួលរងអំពើឧក្រិដ្ឋក្រៅពីការសម្លាប់រង្គាល អាចរាប់បានក្នុងដីកាសម្រេចលើកលែងចោទប្រកាន់នេះ មានការគណនាចំនួនជនរងគ្រោះប្រមាណ ៥.០០០ នាក់។ *សូមមើល* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៩ [៥៩ នាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់] កថាខណ្ឌ ២៥០ [២.៤០០ នាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់នៅមន្ទីរសន្តិសុខវត្តអង្គសិរីមុនី] កថាខណ្ឌ ៣០០ [២០០ នាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់នៅមន្ទីរសន្តិសុខបាណន់] កថាខណ្ឌ ៣២៣ [៤ នាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់ ឬបាត់ខ្លួននៅរោងចក្រស្ករសកំពង់គុល] កថាខណ្ឌ ៣៣៧ [៧៦ នាក់ត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ក្នុងស្រុកសំឡូត] កថាខណ្ឌ ៣៥០ [២.០៨០ នាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់នៅមន្ទីរសន្តិសុខស្វាយជ្រុំ] កថាខណ្ឌ ៣៦៦ [៦០ នាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់នៅមន្ទីរសន្តិសុខភ្នំវាល] កថាខណ្ឌ ៣៨៨-៣៨៩ [៣០០ នាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់នៅមន្ទីរសន្តិសុខវត្តសម្តេច] និងកថាខណ្ឌ ៤០៧ និង ៥៨៧ [២៨៦ នាក់ត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ក្នុងឃុំរាំងកេសី]។ តួលេខមួយចំនួនក្នុងចំណោមតួលេខទាំងនេះ ត្រូវបានកំណត់ដោយប្រើប្រាស់វិធីសាស្ត្រយកកម្រិតអប្បបរមារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការគណនាចំនួនជនរងគ្រោះ។ *សូមមើល* ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១-១៤៥។

## គ. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសផ្នែកអង្គច្បាប់ តាមរយៈការពិចារណាពីបញ្ជារបស់ថ្នាក់លើ និងការបង្ខិតបង្ខំ នៅពេលវាយតម្លៃលើយុត្តាធិការបុគ្គល

70. ដីកាលើកលែងចោទប្រកាន់មានកំហុសផ្នែកអង្គច្បាប់ តាមរយៈការពឹងផ្អែកលើបញ្ជារបស់ថ្នាក់លើ និងការបង្ខិតបង្ខំ ដែលធ្វើឲ្យដីកានេះគ្មានសុពលភាព និងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ការសន្និដ្ឋានថា យឹម ទិត្យ ស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។

### ១. ការពឹងផ្អែកលើបញ្ជារបស់ថ្នាក់លើក្នុងការវិភាគពីយុត្តាធិការបុគ្គល

71. ដីកាលើកលែងចោទប្រកាន់មានកំហុសផ្នែកអង្គច្បាប់ តាមរយៈការពឹងផ្អែកលើបញ្ជារបស់ថ្នាក់លើក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល។ ក្នុងផ្នែកចុងក្រោយស្ដីពីយុត្តាធិការបុគ្គល មានការសន្និដ្ឋានថា យឹម ទិត្យ ត្រូវទទួលបញ្ជារបស់ថ្នាក់លើ[192]។ ដីកាសម្រេចលើកលែងចោទប្រកាន់ លើកឡើងថា ជនរងគ្រោះដែលត្រូវបានសម្លាប់ក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ គឺជា "លទ្ធផលនៃការអនុវត្តគោលនយោបាយបង្ក្រាបដែល យឹម ទិត្យ គ្មានសិទ្ធិអំណាចចាត់ចែង ក្រៅតែពីការគោរពតាមមាគ៌ាបក្ស"[193] និងបញ្ជាក់ថា ក្នុងការចូលរួមរបស់ យឹម ទិត្យ "ក្នុងទីតាំងបទល្មើស" គាត់ "គ្មានគំនិតផ្ដួចផ្ដើម" ហើយថា "វាជាការចូលរួមអនុវត្តការងារតាមគោលនយោបាយបក្សដែលត្រូវតែគោរព និងធ្វើតាម"[194]។ ដូចការរៀបរាប់លម្អិតខាងក្រោម ការពិចារណាពីបញ្ជារបស់ថ្នាក់លើ នៅពេលវាយតម្លៃលើយុត្តាធិការបុគ្គល គឺជាការរំលោភច្បាប់ អ.វ.ត.ក។ កំហុសនេះបានធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព។

72. ក្នុងសំណុំរឿង ០០១ នៅពេលពិចារណាពីទឡ្ហីករណ៍របស់ ឌុច ដែលថា គួរតែមាន "ការវាយតម្លៃដោយប្រៀបធៀបពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" ដើម្បីកំណត់ថាតើគាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នៃជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណានោះ[195] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា គោល

---

[192] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ ERN 01619236 ["ជំពូក ៧ សំអាងហេតុ និងសេចក្ដីសន្និដ្ឋានបញ្ហាយុត្តាធិការបុគ្គលលើ យឹម ទិត្យ និងការបិទបញ្ចប់សំណុំរឿង ០០៤ ទាំងមូល"]។ *សូមមើលផងដែរ* កថាខណ្ឌ ៦៥៦-៦៥៧ [ក្នុងការពិភាក្សាទូទៅស្ដីពីយុត្តាធិការបុគ្គល ដីកាសម្រេចលើកលែងចោទប្រកាន់រកឃើញថា កម្មាភិបាលគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តតាម "បញ្ជាទាំងអស់" ពី "ថ្នាក់លើ"]។

[193] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៨០។

[194] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៨៣។

[195] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦២។

ការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌពាក់ព័ន្ធនឹងបញ្ហារបស់ថ្នាក់លើ អាចអនុវត្តបានចំពោះការវាយតម្លៃលើជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" និងយល់ថា ការដាក់បន្ទុកលើបញ្ហារបស់ថ្នាក់លើក្នុងការវិភាគពីយុត្តាធិការនឹង "ផ្ទុយនឹងបទប្បញ្ញត្តិនានាដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក" ៖

> "សញ្ញាណនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលយកមកប្រៀបធៀបគ្នានេះ គឺផ្ទុយទៅនឹងមាត្រា ២៩ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា "តួនាទី ឬឋានៈរបស់ជនសង្ស័យ មិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ"។ បទប្បញ្ញត្តិនេះក៏បញ្ជាក់យ៉ាងច្បាស់ផងដែរអំពីគោលការណ៍ដែលថា បញ្ហារបស់ថ្នាក់លើ មិនបង្កើតបានជាមធ្យោបាយការពារឱ្យរួចផុតពីឧក្រិដ្ឋកម្ម ដូចមានចែងក្នុងជំពូក២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឡើយ។ ជាការពិត ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង ត្រូវចាប់ផ្តើមធ្វើការវាយតម្លៃដោយប្រៀបធៀបពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ *ការធ្វើបែបនេះគឺមានន័យស្មើនឹងការបង្កើតឱ្យមានមធ្យោបាយការពារ ដោយប្រយោលដោយមូលហេតុបញ្ហារបស់ថ្នាក់លើ ហើយនឹងផ្ទុយបទប្បញ្ញត្តិនានាដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមទាំងក្នុងមាត្រា ២៩ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផងដែរ*[196] ។

73. ការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលបង្ហាញថា នៅពេលកំណត់ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅកម្ពុជាប្រជាធិបតេយ្យ ក្នុងបរិបទនៃយុត្តាធិការបុគ្គល បញ្ហារបស់ថ្នាក់លើមិនគួរត្រូវបានពិចារណានោះទេ ព្រោះថា ការធ្វើដូច្នេះនឹងធ្វើឱ្យមានការការពារបញ្ហារបស់ថ្នាក់លើតាមវិធីមួយផ្សេងទៀត។ ការដែលដីកាសម្រេចលើកលែងចោទប្រកាន់ពឹងផ្អែកយ៉ាងខ្លាំងលើបញ្ហារបស់ថ្នាក់លើថាជាកត្តាសម្រាលការទទួលខុសត្រូវរបស់ យឹម ទិត្យ មិនស៊ីសង្វាក់គ្នានឹងការសន្និដ្ឋានរបស់តុលាការឡើយ។

---

[196] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ដូចកថា*ខណ្ឌ ៦២ (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម *ដូច*កថាខណ្ឌ ៥២៧។ សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ("សាលក្រមសំណុំរឿង ០០២/០១") កថាខណ្ឌ ៧០២ ["ការទទួលខុសត្រូវអាចកើតមាននៅពេលជនជាប់ចោទចេញបញ្ជា ឬផ្ទេរការបញ្ជា ដែលរួមទាំងតាមរយៈអន្តរការីផងដែរ"]។

74. មូលដ្ឋានសំអាងផ្លូវច្បាប់អន្តរជាតិ ច្បាប់របស់ អ.វ.ត.ក និងច្បាប់របស់កម្ពុជា ពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ គាំទ្រដល់គោលការណ៍ទូទៅដែលបានកំណត់ក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះយុត្តាធិការបុគ្គល។ ប្រការសំខាន់ត្រូវធ្វើយ៉ាងណាឱ្យជនបង្កទទួលខុសត្រូវ ដោយមិនគិតពីបញ្ជារបស់ថ្នាក់លើឡើយ។ យ៉ាងហោចណាស់ចាប់តាំងពីមានធម្មនុញ្ញទីក្រុងឡុង ដែលបានបង្កើតតុលាការយោធាអន្តរជាតិ (“IMT”) នៅនូរាំប៊ឺក[197] មានការកំណត់ច្បាស់ថា នៅក្រោមច្បាប់ទម្លាប់អន្តរជាតិ អ្នកដែលធ្វើតាមបញ្ជាថ្នាក់លើ នៅតែមានការទទួលខុសត្រូវព្រហ្មទណ្ឌដែលចំពោះឧក្រិដ្ឋកម្មអន្តរជាតិណាមួយដែលខ្លួនបានប្រព្រឹត្ត[198]។ តុលាការយោធាអន្តរជាតិ

---

[197] ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ - ឧបសម្ព័ន្ធភ្ជាប់ ទៅនឹងកិច្ចព្រមព្រៀងសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមធំៗរបស់អាកហ្សិសអឺរ៉ុប ទីក្រុងឡុង ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥, 82 UNTS 279, មាត្រា ៨ [“ប្រការដែលចុងចោទបានធ្វើតាមបញ្ជារបស់រដ្ឋាភិបាលរបស់គាត់ ឬរបស់ថ្នាក់លើ មិនត្រូវឱ្យគាត់រួចខ្លួនពីការទទួលខុសត្រូវឡើយ ប៉ុន្តែគាត់អាចត្រូវបានពិចារណាក្នុងការសម្រាលពីការផ្តន្ទាទោស បើសិនជាតុលាការសម្រេចថា យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ”]។

[198] *សូមមើលជាឧទាហរណ៍* ច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ ១០ ការផ្តន្ទាទោសជនដែលមានពិរុទ្ធចំពោះឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥ មាត្រា II (៤) (ខ) [“ប្រការដែលជនណាម្នាក់បានធ្វើតាមបញ្ជារបស់រដ្ឋាភិបាលរបស់គាត់ ឬរបស់ថ្នាក់លើណាម្នាក់ មិនអាចឱ្យគាត់គេចផុតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មណាមួយបានឡើយ ប៉ុន្តែអាចត្រូវបានពិចារណាក្នុងការសម្រាល”]។ ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ មាត្រា ៦។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ ដែលបានធ្វើបច្ចុប្បន្នភាពនៅខែកញ្ញា ឆ្នាំ២០០៩ មាត្រា ៧ (៤) [“ប្រការដែលជនជាប់ចោទណាម្នាក់ បានធ្វើតាមបញ្ជារបស់រដ្ឋាភិបាលណាមួយ ឬរបស់ថ្នាក់លើណាម្នាក់ មិនត្រូវឱ្យគាត់គេចផុតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មណាមួយឡើយ ប៉ុន្តែអាចត្រូវបានពិចារណាក្នុងការសម្រាលក្នុងការផ្តន្ទាទោស ប្រសិនបើតុលារអន្តរជាតិនោះកំណត់ថា យុត្តិធម៌តម្រូវដូច្នេះ”]។ ច្បាប់លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ មាត្រា ៦(៤)។ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ដែលបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសៀរ៉ាឡេអូន ស្តីពីការបង្កើតឱ្យមានតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ហ្វ្រីថោន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ (“ច្បាប់លក្ខន្តិកៈ SCSL”) មាត្រា ៦(៤)។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ ១៧៥៧ ឧបសម្ព័ន្ធ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់លីបង់ ឯកសារអង្គការសហប្រជាជាតិ S/RES/1757 ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ មាត្រា ៣(៣)។ *សហរដ្ឋអាមេរិក ទល់នឹង List et al.,* មតិយោបល់ និងសាលក្រម ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៤៨ សវនាការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធានូរាំប៊ឺកក្រោមច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ ១០ (“TWC”) ភាគ XI ទំព័រ ១២៣៦-១២៣៧។ សាលដីកាក្នុងរឿងក្តី *Sainovic* កថាខណ្ឌ ១៦៦១។ *សូមមើលបន្ថែម* សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៧៦ [“ថ្នាក់ក្រោមជាអន្តរការីដែលស្ថិតក្នុងខ្សែសង្វាក់នៃការបញ្ជា ដែលជាអ្នកបញ្ជូនបញ្ជាបន្តទៅចារី ក៏អាចនឹងត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះការបញ្ជាដែលនាំឱ្យមានការប្រព្រឹត្តបទល្មើសនោះដែរ ឱ្យតែជននោះមានស្ថានភាពផ្លូវអារម្មណ៍ដូចលក្ខខណ្ឌតម្រូវ”] *ដោយបានតម្កល់* ក្នុងសាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩។ សាលក្រមក្នុងរឿងក្តី *Kupreskic* កថាខណ្ឌ ៨៦២។ សាលក្រមក្នុងរឿងក្តី *Milutinovic* កថាខណ្ឌ ៨៧។

លើកឡើងថា "បញ្ជារបស់ថ្នាក់លើ រួមទាំងបញ្ជាដែលដាក់លើទាហាន មិនអាចត្រូវបានចាត់ទុកថាជាស្ថានសម្រាលទោសបានទេ ក្នុងករណីដែលឧក្រិដ្ឋកម្មបង្កភាពភ័យរន្ធត់ និងមានទំហំធំធេងត្រូវបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ ដោយគ្មានមេត្តា និងគ្មានការដោះសារ ឬការសំអាងផ្នែកយោធានោះទេ"[199]។

75. ស្រដៀងគ្នានេះដែរ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[200] និងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[201] សុទ្ធតែកំណត់ថា បញ្ជាខុសច្បាប់ពីថ្នាក់លើ មិនបានជួយសម្រាលដល់ជនសង្ស័យណាម្នាក់ពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយ។ បើសិនជាបញ្ជានោះ ជាបញ្ជាខុសច្បាប់ជាក់ស្តែង ដូចជាបញ្ជាឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[202] មិនអាចឲ្យជនត្រូវចោទទាមទារការបន្ធូរបន្ថយការកាត់ទោសនោះទេ[203]។ នៅចំពោះមុខបញ្ជាខុសច្បាប់ កាតព្វកិច្ចគឺ

[199] *សហរដ្ឋអាមេរិក និងគូកន ទល់នឹង Goring និងគូកន* សាលក្រម ចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ សវនាការកាត់សេចក្តីលើឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ ភាគ I ទំព័រ ២៨០-២៨១។ *សូមមើលផងដែរ* ទំ.៣២៥ ["និយាយឱ្យខ្លី ការការពារខ្លួនរបស់ Alfred Jodl's គឺជាទ្រឹស្តីនៃ "បញ្ជាថ្នាក់លើ" ដែលត្រូវបានហាមឃាត់ដោយមាត្រា ៨ នៃធម្មនុញ្ញនេះថាជាការការពារខ្លួន។ គ្មានអ្វីដែលអាចជួយសម្រាលបានទេ។ ដោយសារវាមិនមែនជាលក្ខខណ្ឌតម្រូវចំពោះទាហានណាម្នាក់ ការចូលរួមក្នុងឧក្រិដ្ឋកម្មដូច្នេះ មិនអាចឱ្យគាត់យកធ្វើជាខែលសម្រាប់ជាលក្ខខណ្ឌតម្រូវបែបទេវកថាក្នុងការការពារខ្លួន ថាជាអ្វីមួយដែលទាហានត្រូវតែគោរព ទោះបីក្នុងតម្លៃណាក៏ដោយដើម្បីធ្វើជាលេសនៃការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះបានឡើយ"]។

[200] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៩(៤) ["ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ"]។ *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ **E188** សាលដីកា *ឌុច* កថាខណ្ឌ ៥៥២ ["ការប្រព្រឹត្តិទៅតាមបញ្ជារបស់ថ្នាក់លើ មិនបង្កើតបានជាការការពារខ្លួនស្របច្បាប់ ចំពោះការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាមឡើយ"]។

[201] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ មាត្រា ១០០ ["ក្នុងករណីដែលសេចក្តីបង្គាប់ជាអនិត្យានុកូល ហើយអ្នកបញ្ជាជាអាជ្ញាធរធម្មានុរូបនោះ ចៅក្រមត្រូវថ្លឹងមើលតាមការគួរពីការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌរបស់ភ្នាក់ងារអនុវត្តបញ្ជានោះ" (ការបកប្រែក្រៅផ្លូវការ)]។

[202] *សូមមើលជាឧទាហរណ៍* លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ២១៨៧ UNTS 90 មាត្រា ៣៣ (២)។

[203] *សហរដ្ឋអាមេរិក ទល់នឹង Ohlendorf និងគូកន* មតិយោបល់ និងសាលក្រម ចុះថ្ងៃទី៨-៩ ខែមេសា ឆ្នាំ១៩៤៨ ("សាលក្រម Einsatzgruppen") TWC ភាគ IV ទំព័រ ៤៧០-៤៧១ ["ទាហាន [...] មិនសង្ឃឹមថានឹងឆ្លើយតប ដូចផ្នែកណាមួយនៃគ្រឿងម៉ាស៊ីននោះដែរ។ មានជំនឿខុសមួយដែលគេតែងតែប្រើយ៉ាងទូលំទូលាយនោះគឺថា ទាហានតែងតែគោរពតាមអ្វីៗគ្រប់យ៉ាងដែលមន្ត្រីថ្នាក់លើរបស់ខ្លួនបញ្ជាឱ្យគាត់ធ្វើអ្វីមួយ [...] អ្នកក្រោមបង្គាប់មានកាតព្វកិច្ចគោរពតែបញ្ជាត្រឹមត្រូវរបស់ថ្នាក់លើរបស់ខ្លួនប៉ុណ្ណោះ ហើយបើសិនជាគាត់ទទួលយកបញ្ជាឧក្រិដ្ឋ និងអនុវត្តបញ្ជានោះដោយមានគំនិតរបស់ខ្លួនឯងផ្ទាល់ គាត់

ត្រូវមិនគោរពតាម មិនមែនអនុវត្តតាមទេ[204]។ ដូច្នេះ បើសិនជាជនជាប់ចោទធ្វើសកម្មភាពដោយផ្អែកលើបញ្ជាខុសច្បាប់ជាក់ស្តែង ចំណុចនេះមិនប៉ះពាល់ដល់ការវាយតម្លៃអំពីកម្រិតនៃការទទួលខុសត្រូវ ឬយុត្តាធិការបុគ្គលរបស់គាត់នោះទេ។

76. ប្រសិនបើភាពសមហេតុផលនៃដីកាសម្រេចលើកលែងការចោទប្រកាន់ ស្តីពីបញ្ជារបស់ថ្នាក់លើពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល ត្រូវបានទទួលយកក្នុងករណីពីមុនៗរបស់ អ.វ.ត.ក ប្រាកដជាគ្មានជនណាម្នាក់ត្រូវបានស៊ើបអង្កេត ឬជំនុំជម្រះទោសឡើយ។ ឌុច, ខៀវ សំផន, និង នួន ជា ដែលត្រូវបានកាត់ទោស និងផ្តន្ទាទោសនៅ អ.វ.ត.ក សុទ្ធតែបានអះអាង ឬប្រហែលជា បានអះអាងថាពួកគេគ្រាន់តែអនុវត្តតាមបញ្ជា ហើយថា ប៉ុល ពត គឺជាថ្នាក់លើរបស់ពួកគេ និងមិនត្រាប្រណីចំពោះអ្នកប្រឆាំងឡើយ។ ឧទាហរណ៍ ឌុច និយាយថា "អំណាចរបស់ខ្ញុំគឺធ្វើការផ្សព្វផ្សាយសេចក្តី

---

មិនអាចយកបញ្ជារបស់ថ្នាក់លើធ្វើជាលេសដើម្បីសម្រាលដល់បទល្មើសរបស់ខ្លួនឡើយ។ បើសិនជាប្រភេទនៃសកម្មភាពដែលបានបញ្ជាក់ជាក់ស្តែង វាហួសពីវិសាលភាពនៃសិទ្ធិអំណាចរបស់ថ្នាក់លើ នោះអ្នកក្រោមបង្គាប់មិនអាចយកភាពមិនដឹងមិនលឺធ្វើជាលេសចំពោះឧក្រិដ្ឋភាពនៃបញ្ជានោះឡើយ"]។ *សូមមើលផងដែរ សហរដ្ឋអាមេរិក ទល់នឹង Milch* សាលក្រម ចុះថ្ងៃទី១៦-១៧ ខែមេសា ឆ្នាំ១៩៤៧ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ច្បាប់ស្តីពីសវនាការឧក្រិដ្ឋជនសង្គ្រាម ("LRTWC)" ភាគ VII ទំព័រ ៤០-៤២, ៦៥ [តុលាការយោធាសហរដ្ឋអាមេរិក បានទាត់ចោលសំណើរសុំអភ័យទោសដែលយកមូលហេតុបញ្ជាថ្នាក់លើធ្វើជាលេសដើម្បីសម្រាលទោស ពីព្រោះចុងចោទ *ត្រូវតែបានដឹងថា* បញ្ជាទាំងនោះដែលមានការពាក់ព័ន្ធនឹងការប្រព្រឹត្តិការធ្វើទុក្ខបុកម្នេញ និងភេរវកម្ម ជាអំពើអនុត្យានុកូល]។ *Buck និងគូកន* តុលាការយោធាអង់គ្លេស Wuppertal (ចុះថ្ងៃទី៦-១០ ខែឧសភា ឆ្នាំ១៩៤៦) ដែលបានរាយការណ៍នៅក្នុង LRTWC ភាគ V ទំព័រ ៤២-៤៣ ["ចៅក្រមការពារបានថ្លែងថាតាមគោលការណ៍បញ្ជាថ្នាក់លើមិនអាចការពារខ្លួនចំពោះបទចោទព្រហ្មទណ្ឌណាមួយឡើយ [...] ចៅក្រមបញ្ចេញទស្សនៈឱ្យឃើញថា ជនជាប់ចោទនឹងមានពិរុទ្ធ បើសិនជាគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមតាមបញ្ជារបស់ថ្នាក់លើ ទីមួយ បើសិនជាបញ្ជានោះ *អនីត្យានុកូលជាក់ស្តែង* ទីពីរ បើសិនជាជនជាប់ចោទ *បានដឹងថាបញ្ជានោះអនីត្យានុកូល* ឬទីបី បើសិនជា*គាត់គោងតែដឹងថា បញ្ជានោះអនីត្យានុកូល បើសិនជាគាត់បានពិចារណាលើកាលៈទេសៈផ្សេងៗពេលបញ្ជានោះត្រូវបានផ្តល់"]* (សេចក្តីបញ្ជាក់ដើម)។ *Golkel និងគូកន* តុលាការយោធាអង់គ្លេស Wuppertal អាល្លឺម៉ង់ ចុះថ្ងៃទី១៥-២១ ខែឧសភា ឆ្នាំ១៩៤៦ (រឿងក្តី *Golkel*) ដែលបានរាយការណ៍នៅក្នុង LRTWC ភាគ V ទំព័រ ៥១។

[204] សាលដីកាក្នុងរឿងក្តី *Mrksic & Sljivancanin* កំណត់សម្គាល់ជើងទំព័រ ៣៣១។ មតិយោបល់របស់ Cassese ក្នុងសាលដីកានៃរឿងក្តី *Erdemovic* កថាខណ្ឌ ១៥។ សាលដីកាតុលាការកំពូល ឆ្នាំ១៩៨៦ ក្នុងរឿងក្តី *Erdemovic* កថាខណ្ឌ ១៨។ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ទិន្នន័យច្បាប់ទម្លាប់មនុស្សធម៌អន្តរជាតិ វិធាន ១៥៤ ៖ អាចរកបាននៅក្នុង https://ihl-databases.icrc.org/customary-ihl/eng/docs/v1_rul_rule154។

សម្រេចពីថ្នាក់លើ" ហើយថា "គាត់មិនអនុវត្តទៅតាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួនឡើយ" ហើយថ្នាក់លើរបស់គាត់មិនអនុញ្ញាតឲ្យគាត់ដោះលែងអ្នកទោសណាម្នាក់ចេញពីមន្ទីរ ស-២១ នោះទេ[205]។

77. កំហុសផ្នែកអង្គច្បាប់ក្នុងការពឹងផ្អែកលើបញ្ជារបស់ថ្នាក់លើ បានធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងប៉ះពាល់យ៉ាងខ្លាំងដល់ការសន្និដ្ឋានពីយុត្តាធិការបុគ្គល។

## ២. ការពឹងផ្អែកលើការបង្ខិតបង្ខំក្នុងការវិភាគពីយុត្តាធិការបុគ្គល

78. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសផ្នែកអង្គច្បាប់បន្ថែមទៀត តាមរយៈការពឹងផ្អែកលើការបង្ខិតបង្ខំ នៅពេលវាយតម្លៃលើយុត្តាធិការបុគ្គល។ ការសន្និដ្ឋានដែលបញ្ជាក់ថា យឹម ទិត្យ ត្រូវអនុវត្តតាមបញ្ជារបស់ថ្នាក់លើ ផ្អែកទៅលើមូលដ្ឋានថា ការភ័យខ្លាចចំពោះជីវិតខ្លួនឯងគឺត្រូវតែជាមូលហេតុចាំបាច់ដែលធ្វើឱ្យ យឹម ទិត្យ បានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ ដោយសារបុគ្គលដែលមិនគោរពតាមរបបកម្ពុជាប្រជាធិបតេយ្យ នឹងត្រូវទទួលទណ្ឌកម្ម[206]។ ក្នុងការពិភាក្សាជាទូទៅស្តីពីយុត្តាធិការបុគ្គល[207] ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងថា ថ្នាក់ក្រោមត្រូវអនុវត្តតាមបញ្ជា ពុំនោះទេនឹង "ត្រូវចាប់យកសម្លាប់ចោលភ្លាមៗ" ហើយថា "ឲ្យតែមិនគោរពតាមគោលនយោបាយរបស់អង្គការ បើទោះបីជាកម្មាភិបាលថ្នាក់ណាក៏ត្រូវក្លាយជាមុខសញ្ញានៃការបោសសម្អាតដែរ"[208]។ ទោះបីជាអង្គហេតុបញ្ជាក់ថា កត្តាដែលអាចសម្រាលស្ថានទោស ដូចជា ការបង្ខិតបង្ខំ ត្រូវតែបង្ហាញឡើងដោយមេធាវីការពារក្តី[209] និងមិនត្រូវបាន

---

[205] ឯកសារ **D 6.1.1067** កំណត់ហេតុនៃការសួរចម្លើយ ឌុច ERN 00146659។ សំណុំរឿង ០០១-ឯកសារ **F14** សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២៥។ ឯកសារ **D6.1.1058** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ERN 00177602។

[206] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៧១ ["យឹម ទិត្យ ស្ថិតនៅក្រោមលេខាភូមិភាគដ៏មានឥទ្ធិពលគឺ តាម៉ុក និង រស់ ញឹម "] កថាខណ្ឌ ៦៨០, ៦៨៣។ ពាក់ព័ន្ធនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ *សូមមើល* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១១២, ៩៩, ១៣០។

[207] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ ERN 01619210 [ជំពូក ៦ ច្បាប់ជាធរមាន ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៅ អ.វ.ត.ក]។ *សូមមើលផងដែរ* កថាខណ្ឌ ៩៥, ៩៩។

[208] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៥៧, ៦៥៩។ *សូមមើលផងដែរ* កថាខណ្ឌ ៩៥, ៩៩, ៦៦៤, ៦៦១-៦៦៣។

[209] សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧០។ សំណុំរឿង ០០២-ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៥២។

សន្មតថាមានអត្ថិភាពដោយអង្គហេតុក្តី ក៏លទ្ធផលរកឃើញរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា យឹម ទិត្យ អនុវត្តក្រោមការបង្ខិតបង្ខំ មិនគួរជាផ្នែកមួយនៃការវាយតម្លៃលើយុត្តាធិការបុគ្គលក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ។ ប្រសិនបើមានការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើសំណុំរឿងនេះ ភស្តុតាងនឹងបង្ហាញថា លក្ខណវិនិច្ឆ័យផ្លូវច្បាប់សម្រាប់ការបង្ខិតបង្ខំ ដើម្បីក្លាយជាកត្តាសម្រាលស្ថានទោសដែលមានសុពលភាពពាក់ព័ន្ធនឹង យឹម ទិត្យ មិនអាចទទួលយកបានឡើយ។ ផ្ទុយទៅវិញ ភស្តុតាងបង្ហាញថា យឹម ទិត្យ បានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តក្នុងផែនការឧក្រិដ្ឋកម្មរួម។ ការពិចារណាដោយមិនត្រឹមត្រូវពីការបង្ខិតបង្ខំ ធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាពទេ។

79. យោងតាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក ការបង្ខិតបង្ខំត្រូវមានការបង្ហាញថា បុគ្គលណាម្នាក់ប្រឈមនឹងការគំរាមកំហែងយ៉ាងខ្លាំង ដែលការគំរាមកំហែងនោះគឺជាហេតុផលសំអាងនៃសកម្មភាពរបស់គាត់ ហើយថា ការគំរាមកំហែងនោះមិនមែនបណ្តាលមកពីគោលនយោបាយដែលជនជាប់ចោទខ្លួនឯងបានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តទេ[210]។ ដីកាសម្រេចលើកលែងចោទប្រកាន់គ្មានភស្តុតាងសំអាងក្នុងសំណុំរឿងនេះដែលបំពេញលក្ខណវិនិច្ឆ័យផ្នែកអង្គច្បាប់ទាំងនេះឡើយ។

80. ក្រៅពីនេះ ដីកាសម្រេចលើកលែងចោទប្រកាន់នេះមិនបានពិចារណាពីអង្គហេតុដែលថា យឹម ទិត្យ មិនបានធ្វើអ្វីមួយដើម្បីផ្តាច់ខ្លួនចេញពីការប្រព្រឹត្តិអំពើឧក្រិដ្ឋនោះទេ។ បើទោះជាដីកាសម្រេចលើកលែងចោទប្រកាន់នេះសន្និដ្ឋានថា កម្មាភិបាលខ្មែរក្រហមមួយចំនួនបានឈប់រួមចំណែកក្នុងសកម្មភាពឧក្រិដ្ឋរបស់ ប.ក.ក តាមរយៈការរត់គេចខ្លួនទៅប្រទេសវៀតណាម ឬការលាក់ខ្លួន

---

[210] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៥៣, ៥៥៧-៥៥៨។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច កថាខណ្ឌ ៣៦៤។ *សូមមើលផងដែរ* មតិយោបល់របស់ Cassese ក្នុងសាលក្រម *Erdemovic កថាខណ្ឌ ១៦, ១៧* ["យោងតាមច្បាប់យុត្តិសាស្ត្រស្តីពីច្បាប់មនុស្សធម៌អន្តរជាតិ ការបង្ខិតបង្ខំ ឬភាពចាំបាច់ មិនអាចជាលេសដើម្បីគេចពីការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌសម្រាប់ជនដែលមានបំណងចង់បានការការពារខ្លួនដូច្នេះឡើយ ប្រសិនបើបុគ្គលរូបនោះបានជ្រើសរើសដោយសេរី និងដោយស្ម័គ្រចិត្ត ដើម្បីចូលជាសមាជិកនៃអង្គភាព អង្គការ ឬក្រុមណាមួយ ដែលស្ថាប័ននោះមានចេតនាធ្វើសកម្មភាពផ្សេងៗដែលផ្ទុយពីច្បាប់មនុស្សធម៌អន្តរជាតិ"] កថាខណ្ឌ ៤១, ៥០ [ដូចបានបញ្ជាក់អះអាងដោយទស្សនៈរបស់ចៅក្រម Stephen នៅត្រង់កថាខណ្ឌ ៦៨ ក្នុងសាលក្រម *Erdemovic*]។ សាលដីកាតុលាការកំពូល ឆ្នាំ១៩៩៦ ក្នុងរឿងក្តី *Erdemovic* កថាខណ្ឌ ១៨។ សាលក្រមក្នុងរឿងក្តី *Einsatzgruppen* ទំព័រ ៤៨០-៤៨១។ *សហរដ្ឋអាមេរិក ទល់នឹង Milch* សាលក្រម ចុះថ្ងៃទី១៦-១៧ ខែមេសា ឆ្នាំ១៩៤៧, TWC, ភាគ II ទំព័រ ៧៩១។

ក្នុងព្រៃក្តី[211] ក៏ដីកានេះមិនបានពិចារណាពីអង្គហេតុដែលថា យឹម ទិត្យ ដែលមានមូលដ្ឋាននៅឆ្ងាយពីទីស្នាក់ការរបស់ ប.ក.ក នាទីក្រុងភ្នំពេញ និងស្ថិតនៅជិតព្រំដែនប្រទេសថៃ មានលទ្ធភាពច្រើន (ខុសពី ឌុច) ក្នុងការរត់គេចខ្លួនពីរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើគាត់ចង់។ ការធ្វើឲ្យដីកាសម្រេចលើកលែងចោទប្រកាន់នេះសន្និដ្ឋានដោយប្រសិទ្ធភាពថា យឹម ទិត្យ គ្មានជម្រើសអ្វីក្រៅពីសម្លាប់ និងធ្វើឲ្យប្រជាជនកម្ពុជារាប់ពាន់អ្នកក្លាយជាទាសករ ក្រោមអំណាចរបស់គាត់ដើម្បីសង្គ្រោះជីវិតខ្លួនឯង គឺជាការបដិសេធចោលសកម្មភាពផ្សេងទៀតដែល យឹម ទិត្យ អាចធ្វើឡើងក្នុងអំឡុងរបបនេះ។

81. ដូចដែលមានរៀបរាប់ក្នុងសេចក្តីលម្អិតខាងក្រោម ផ្ទុយទៅវិញ ភស្តុតាងចំពោះសំណុំរឿងនេះបង្ហាញថា យឹម ទិត្យ មានបំណងពិតប្រាកដក្នុងការចូលរួមក្នុងផែនការឧក្រិដ្ឋកម្មរួម និងមានឆន្ទៈ និងចំណាប់អារម្មណ៍ក្នុងការចូលរួមក្នុងផែនការនោះ។ និយាយបែបផ្សេងមានន័យថា សកម្មភាពឧក្រិដ្ឋកម្មរបស់ យឹម ទិត្យ មិនមែនជាលទ្ធផលនៃការភ័យខ្លាចការដាក់ទោសទណ្ឌនោះទេ។ អំពើរបស់គាត់បានចូលរួមចំណែកដល់ការបង្កើត និងការរក្សារបបកម្ពុជាប្រជាធិតេយ្យដែលមានការបង្ខិតបង្ខំ[212]។

82. ភស្តុតាងចំពោះសំណុំរឿងនេះដែលបង្ហាញថា ការចូលរួមដោយឆន្ទៈរបស់ យឹម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្មរួម បង្ហាញថា គាត់មានគោលការណ៍ និងចេតនាដូចគ្នាទៅនឹងថ្នាក់លើរបស់គាត់។ ឧទាហរណ៍ ភស្តុតាងបង្ហាញថា យឹម ទិត្យ បានទៅទស្សនកិច្ចមន្ទីរសន្តិសុខវត្តព្រះធាតុ ដើម្បីសួរចម្លើយអ្នកជាប់ឃុំដោយផ្ទាល់យ៉ាងហោចណាស់ចំនួនពីរលើក[213] ពោលគឺជា កិច្ចការមួយដែល

[211] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៦ ["ការបោសសម្អាតបានបណ្តាលឲ្យមានការបែកបាក់ផ្ទៃក្នុងរបស់ ប.ក.ក ដោយអតីតកម្មាភិបាលខ្មែរក្រហមខ្លះបានរត់ទៅវៀតណាម ហើយអ្នកខ្លះទៀតបានរត់ចូលព្រៃ"]។

[212] លក្ខណៈបង្ខិតបង្ខំនៃរបបកម្ពុជាប្រជាធិបតេយ្យ យ៉ាងច្រើន ត្រូវបានកំណត់ជាស្ថានសម្រាលក្នុងកម្រិតតិចតួច។ *សូមមើល* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច កថាខណ្ឌ ៣៦៤, ៣៧១-៣៧៣។ *សូមមើលផងដែរ ឧទាហរណ៍* សាលដីកាកាត់ទោសសំណុំរឿង *Tadić* កថាខណ្ឌ ៤៨ [ផ្តល់ទម្ងន់ហួសហេតុទៅលើកត្តាពាក់ព័ន្ធ នៅពេលការធ្វើសេចក្តីសម្រេចឆន្ទានុសិទ្ធិមួយ អាចធ្វើឲ្យមានកំហុស]។ យោងដល់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង *Mejakić* កថាខណ្ឌ ១០។

[213] ឯកសារ **D118/22** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ឆ. ១៦ ["តា ទិត្យ [...] មក [...] វត្តព្រះធាតុ។ ខ្ញុំដឹងរឿងនេះដោយសារខ្ញុំបានឮពួកឈ្លប និង តា ទិត្យ សួរចម្លើយអ្នកទោស"]។ ឯកសារ **D219/110** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ. ៣ ["ខ្ញុំធ្លាប់ឃើញ តា ទិត្យ សួរចម្លើយអ្នកទោសចំនួនពីរដង។ លើកទី១ គឺគាត់សួរចម្លើយអ្នកទោសជាមួយនឹង យាយ បូ ហើយលើកទី២ គឺគាត់សួរចម្លើយអ្នកទោសតែម្នាក់ឯងទេ"]។ ឆ.៤។ ឯកសារ **D219/346** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ. ២៦, ៤៧-២៩។

ហួសពីការទទួលខុសត្រូវរបស់គាត់ក្នុងនាមជាលេខាស្រុក ឬអនុលេខាស្រុក។ នៅក្នុងមួយលើក ក្នុងចំណោមទាំងពីរលើកនោះ គាត់បានចូលរួមដោយផ្ទាល់ក្នុងការប៉ុនប៉ងកំណត់អត្តសញ្ញាណ "ខ្មាំង" បន្ថែមទៀត តាមរយៈការសួរអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសទាំងនោះថា "អ្នកឯងមកពីណា? មានគ្នាប៉ុន្មាននាក់នៅក្នុងក្រុមអ្នកឯង? ហើយតើហេតុអីបានជាអ្នកឯងចង់រត់? ហើយរត់ទៅទីណា?"[214]។ នៅពេលមួយផ្សេងទៀត យឹម ទិត្យ មានវត្តមាននៅវត្តព្រះធាតុ នៅពេលអ្នកទោសមួយក្រុមត្រូវបានសម្លាប់ ហើយប្រម៉ាត់របស់ពួកគេត្រូវបានគេវះយកចេញ[215]។ នៅពេលនោះ បុគ្គលិកគុកបានប្រគល់សរីរាង្គដែលបានវះយកចេញទាំងនេះទៅឲ្យ យឹម ទិត្យ និងកម្មាភិបាលម្នាក់ទៀត ដែលបានបើករថយន្តចេញទៅជាមួយសរីរាង្គទាំងនោះ[216]។

83. ទាំងនេះមិនមែនជាសកម្មភាពរបស់មន្ត្រីដែលខ្លាច ដែលបានបញ្ចប់ការងារក្នុងព្រឹត្តិការណ៍នានាដែលហួសពីការគ្រប់គ្រងរបស់គាត់ និងដែលត្រូវបានបង្ខំឲ្យដើរស្របតាមយុទ្ធនាការនៃភាពភ័យខ្លាច ដែលគាត់មិនព្រមព្រៀងជាមួយនោះទេ។ ផ្ទុយមកវិញ សកម្មភាពទាំងនេះបង្ហាញថា យឹម ទិត្យ បានយល់ព្រមតាមការប្រមាថរបស់ថ្នាក់លើរបស់គាត់ចំពោះជីវិត និងសេចក្ដីថ្លៃថ្នូររបស់ "ខ្មាំង" របស់ ប.ក.ក និងការប្ដេជ្ញាចិត្តកម្ទេចពួកគេ។

---

[214] ឯកសារ **D219/110** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទន់ ស៊ូន ឆ. ៦។ *សូមមើលផងដែរ* ឯកសារ ឯកសារ **D219/346** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទន់ ស៊ូន ឆ. ៥៤-៥៦។

[215] ឯកសារ **D219/326** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហោ យ៉ន ឆ.៣២ [ស៖ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ គេវះយកកប្រមាត់នៅចំពោះមុខ តា ទិត្យ តែម្ដងឬ? ឆ.៣២៖ គេយកអ្នកទោសទៅវះនៅចម្ងាយប្រហែល ៥០ម៉ែត្រពីគុក រួចហើយគេយកប្រមាត់មកឲ្យ តា ទិត្យ គាត់នៅក្នុងឡាន]។ ឆ.៣៣-៣៦។ ឯកសារ **D118/155** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២២-២៦, ៣៤-៣៥។ ឯកសារ **D105/6** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១២-១៤ (ស.ព.អ កត់សម្គាល់ថា កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីនេះត្រូវបានធ្វើឡើងស្របតាមដីកាចាត់ឲ្យស៊ើបសួរជំនួសមួយដែលត្រូវបានចេញដោយ និងនៅក្នុងអំឡុងរយៈពេលកាន់តំណែងរបស់ ស.ច.ស.អ បម្រុង Kasper-Ansermet ហើយដូច្នេះធ្លាក់ចូលទៅក្នុងប្រភេទភស្តុតាងដែលដីកាលើកលែងចោទប្រកាន់ បានបង្ហាញថា នឹងមិនមានការពិចារណា។ *សូមមើល* ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៥០។ ទោះជាយ៉ាងណា ការបដិសេធមិនពិចារណាភស្តុតាងដែលត្រូវបានប្រមូលដោយ ស.ច.ស.អ បម្រុង គឺជាកំហុសផ្នែកអង្គច្បាប់ ពីព្រោះមាត្រា ២៦ នៃច្បាប់ស្ដីពី អ.វ.ត.ក ចែងថា "ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ")។ ឯកសារ **D1.3.11.18** បទសម្ភាសន៍ជាមួយ ហោ យ៉ន EN ERN 00217607។

[216] ឯកសារ **D118/155** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២៦ ["បាទ តា ទិត្យ ក៏នៅទីនោះដែរ ហើយប្រមាត់ត្រូវបានពួកគេដាក់ឡានយកចេញទៅ"]។

84. ចំណុចនេះបង្ហាញឱ្យឃើញបន្ថែមទៀតតាមរយៈវិធីដែលគ្មានមេត្តា ដែល យឹម ទិត្យ បានពិភាក្សាអំពីការស្លាប់ដែលអាចកើតមាន។ ដោយជជែកអំពីផលិតកម្មកប្បាសនៅការដ្ឋានមួយ យឹម ទិត្យ បាននិយាយថា "បើដាំកប្បាសមិនបាន! ដង្កូវស៊ីកប្បាស ដង្កូវនឹងស៊ីមនុស្សទៀត"[217] ដែលជាការបញ្ជូនទៅសម្លាប់ជាធម្មតាចំពោះអ្នកទាំងឡាយណាដែលបរាជ័យក្នុងការសម្រេចបានគោលដៅកសិកម្ម។ ជាថ្មីម្តងទៀត នេះមិនមែនជាភាសារបស់ជនរងគ្រោះដ៏ភ័យខ្លាចម្នាក់ដែលដើរស្របតាមផែនការដោយសារគាត់មិនមានជម្រើសផ្សេងទៀតនោះទេ។ វាជាភាសារបស់មនុស្សម្នាក់ដែលរីករាយនឹងការអនុវត្តអំណាចទៅលើអ្នកដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។

85. ការអនុវត្តគោលនយោបាយរបស់ ប.ក.ក ដោយការតាំងចិត្តរបស់ យឹម ទិត្យ បានបន្តកើតមានរហូតដល់ថ្ងៃចុងក្រោយនៃរបបនេះ។ ខណៈដែលខ្មែរក្រហមបានរត់ភៀសខ្លួនមុនពេលកងកម្លាំងរបស់វៀតណាមចូលមកដល់នៅខែធ្នូ ឆ្នាំ១៩៧៨ យឹម ទិត្យ បានបញ្ជាឱ្យសម្លាប់អ្នកទោសទាំងអស់ដែលនៅសល់នៅមន្ទីរសន្តិសុខវត្តបាយដំរាំ ហើយបញ្ជាទាំងនេះត្រូវបានអនុវត្តដោយអ្នកនៅក្រោមបង្គាប់របស់គាត់[218]។ យឹម ទិត្យ បានបញ្ជាឱ្យប្រព្រឹត្តភាពឃោរឃៅនេះ ខណៈដែលអំណាចរបស់កម្ពុជាប្រជាធិបតេយ្យកំពុងដួលរលំ និងនៅពេលដែលអំណាចបង្ខិតបង្ខំរបស់របបនេះស្ថិតក្នុងការធ្លាក់ចុះខ្សោយខ្លាំងបំផុតរបស់ខ្លួន។ បើទោះជាស្ថិតក្នុងស្ថានភាពនេះក៏ដោយ ក៏គាត់បានបន្តអនុវត្តដោយការតាំងចិត្តនូវគោលនយោបាយឧក្រិដ្ឋកម្មរបស់ ប.ក.ក រហូតដល់ចុងបញ្ចប់នៃរបបនេះ។

---

[217] ឯកសារ **D219/64** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.៣០ ["ខ្ញុំឮគេនិយាយថា តា ទិត្យ បានបញ្ជាទៅ តា គី ថា 'បើដាំកប្បាសមិនបាន! ដង្កូវស៊ីកប្បាស់ ដង្កូវនឹងស៊ីមនុស្សទៀត'"]។ ដីកាសម្រេចលើកលែងចោទប្រកាន់ បានចាត់ទុកចម្លើយនេះថាបានមកពី "កម្មាភិបាលថ្នាក់លើ" នៅភូមិភាគពាយ័ព្យ ប៉ុន្តែភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ការលើកឡើងនេះបានមកពី យឹម ទិត្យ។ *សូមមើល* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៨។

[218] ឯកសារ **D219/533** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ិន ឆ.១០៤, ១០៨ ["ពេលដែលវា [...] ដឹកវាទៅលើហើយ អ្នកទោសទាំងនោះសុទ្ធតែវាយកទៅសម្លាប់ចោលទាំងអស់។ ពេលដែលប្រជាជនបរទេះជូនពួកវាទៅលើហើយ ពុំមានអ្នកទោសនៅក្នុងវត្តបាយដំរាំ ឬផ្ទះចែជូ ទៀតទេ។ អ្នកទោស [...] គឺសម្លាប់ដោយកងឈ្លបរបស់និរតី របស់ តា ណេន ក្រោមការដឹកនាំរបស់ តា ទិត្យ"]។

86. សូម្បីបន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យក្តី យឹម ទិត្យ បានបន្តរស់នៅជាមួយមេដឹកនាំខ្មែរក្រហមផ្សេងទៀត និងអនុវត្តសិទ្ធិអំណាចក្នុងឋានានុក្រមរបស់ខ្មែរក្រហម ដែលជាការបង្ហាញយ៉ាងច្បាស់ថា គាត់មិនធ្លាប់បានចោលគោលដៅ និងគោលនយោបាយរបស់របបនេះឡើយ[219]។

87. ប្រសិនបើវិធីសាស្ត្រស្តីពីការបង្ខិតបង្ខំរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវបានអនុវត្តក្នុងសំណុំរឿងរបស់ អ.វ.ត.ក ក្នុងកន្លងមកនោះ គ្មានបុគ្គលណាម្នាក់ត្រូវបានស៊ើបអង្កេត ឬកាត់ទោសឡើយ។ ឌុច, ខៀវ សំផន និង នួន ជា ដែលអ្នកទាំងអស់នេះត្រូវបានកាត់ទោស និងផ្តន្ទាទោសនៅ អ.វ.ត.ក បានអះអាងថា ពួកគេភ័យខ្លាចចំពោះសុវត្ថិភាពរបស់ពួកគេ ប្រសិនបើពួកគេមិនបានគោរពតាម។ ខៀវ សំផន បានអះអាងថា គាត់មិនមានអំណាចធ្វើសេចក្តីសម្រេចចិត្តឡើយ[220] ហើយគាត់មិនបានឯកភាពទៅនឹងផ្នែកមួយចំនួននៃគោលនយោបាយរបស់ ប.ក.ក ទេ

[219] ឯកសារ **D123/1/5.41** បទសម្ភាសន៍ជាមួយ ឡុង សុឃី (ហៅ ឡុង រដ្ឋា) របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ERN 00931544-00931545 ["ក្នុងរង្វង់៧៩ នឹង គឺផ្លាស់កន្លែងចល័តម៉ង។ [...] អង្គភាពធ្លាប់នៅសំឡូតជាមួយ អ៊ុំ ទិត្យ នឹង។ [...] ខ្ញុំនៅផ្ទាល់ម៉ង ក្រោយមកខ្ញុំនៅពេទ្យផ្ទាល់គាត់។ [...] មុខសញ្ញានឹងទាំងអស់។ [...] ទាំងកងទ័ពទាំងប្រជាជន"] ERN 00931548 ["ដានីៈ ចឹងកាលមឹងនៅពី ៧៩ ដល់ ៨២ ជាមួយ តា ទិត្យ? រដ្ឋាៈ ចា៎]។ ឯកសារ **D123/2/1.27a** បទសម្ភាសន៍ជាមួយ ទឹម ភួន របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១១ ERN 00957762 ["សាក្សីគឺជាក្មួយប្រុសរបស់ យឹម ទិត្យ ដែលបានរត់គេចខ្លួនទៅកាន់សំឡូតក្នុងឆ្នាំ១៩៧៩ៈ "ដានីៈ កាលហ្នុង អ្នកគ្រប់គ្រងនៅសំឡូតពីណាគេ? ភួនៈ តា ទិត្យ"] ហើយ *ត្រូវបានសង្ខេបនៅ* ឯកសារ **D65.1.3** គម្រោងជំរុញឱ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាៈ ឡេង អាន & យឹម ទិត្យ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១១ EN ERN 00704584។ ឯកសារ **D219/844.1.4** គម្រោងជំរុញឱ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាៈ យឹម ទិត្យ ហៅ តា ទិត្យ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ EN ERN 01530127 [មានមូលដ្ឋានលើកំណត់សម្គាល់បទសម្ភាសរបស់អ្នកស្រាវជ្រាវជាមួយក្មួយប្រុសរបស់ យឹម ទិត្យ ឈ្មោះ ងឹម នឿនៈ ក្រោយឆ្នាំ១៩៧៩ នឿន [...] បានផ្លាស់ទៅនៅសំឡូត ជាទីកន្លែងដែល តា ទិត្យ ជាអភិបាលស្រុកសំឡូត"]។ ឯកសារ **D219/952** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម អេម ឆ.៨៥-៨៦, ១០១, ១០៦។ ឯកសារ **D219/665** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ឆ.១៨។ ឯកសារ **D219/380** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុក សុផាត ឆ.៣០។ ឯកសារ **D219/117** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុប សឹង ឆ.១៩៥, ១៩៧, ២០០។ ឯកសារ **D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.១០៦។ *សូមមើលផងដែរ* ឯកសារ **D219/931** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សឿន ឆ.៦៧, ៦៩, ERN 01395021-01395022។ ឯកសារ **D219/551** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ឃ្លី ឆ.៧១, ១៦០, ១៦៦។ ឯកសារ **D219/774** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សេង ឆ.១០៣, ១០៥, ១១៣។ ឯកសារ **D219/518** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ឆ.៦២-៦៣។

[220] ឯកសារ **D6.1.1259** ចម្លើយរបស់ ខៀវ សំផន (SOAS/HRW) ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥ ERN 00078213។ ឯកសារ **D1.3.36.1** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ខៀវ សំផន ERN 00156619។ ឯកសារ **D6.1.1036** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ខៀវ សំផន ERN 00156678។

ប៉ុន្តែលោកថ្លែងថា "ខ្ញុំមិនអាចនៅរស់រានមានជីវិតបានទេ ប្រសិនបើខ្ញុំហ៊ានលើកឡើងពីការជំទាស់ណាមួយនោះ"[221]។ ឌុច បាននិយាយថា គាត់មានការតក់ស្លុត និងភ័យខ្លាចចំពោះជីវិតរបស់គាត់[222]។ សូម្បី នួន ជា ក៏បានប្រាប់អ្នកសរសេរប្រវត្តិរូបរបស់គាត់ផងដែរថា គាត់ភ័យខ្លាចគេហៅគាត់ថាជាខ្មាំង បន្ទាប់ពីកម្មាភិបាលធំៗជាច្រើនត្រូវបានគេយកទៅដាក់គុក និងដាក់ទណ្ឌកម្ម[223]។

88. កំហុសផ្នែកអង្គច្បាប់ក្នុងការពឹងផ្អែកលើការបង្ខិតបង្ខំ បានធ្វើឱ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការសន្និដ្ឋានពីយុត្តាធិការបុគ្គល។

## ៣. ការពិចារណាលើបញ្ជាថ្នាក់លើ និងការបង្ខិតបង្ខំ តាមរបៀបផ្សេងគ្នា ក្នុងសំណុំរឿង ០០១ និង ០០៤

89. សេចក្តីសម្រេចលើអង្គហេតុ និងអង្គច្បាប់ក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ ផ្តល់ការអះអាងផ្ទុយគ្នាស្រលះអំពីគោលការណ៍នៅក្នុងដីកាលើកលែងចោទប្រកាន់ដែលថា ការអនុវត្តតាមបញ្ជារបស់ថ្នាក់លើ និងការបង្ខិតបង្ខំ ធ្វើឱ្យបុគ្គលរួចផុតពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ ដោយហេតុថា បញ្ជារបស់ថ្នាក់លើ និងការបង្ខិតបង្ខំ មិនបានដក ឌុច ចេញពីប្រភេទ "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយត្រឹមត្រូវ គេមិនអាចធ្វើដូច្នេះបានជាមួយ យឹម ទិត្យ ឡើយ។ ការអះអាងថា យឹម ទិត្យ មិនស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដោយសារតែគាត់អនុវត្តតាមបញ្ជា និងមានហេតុផលពីការភ័យខ្លាចចំពោះលទ្ធផលនៃការប្រកែកណាមួយ ខណៈដែល ឌុច ស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ទោះបីជាគាត់ស្ថិតក្រោមការទទួលបញ្ជាពីថ្នាក់លើ និងការបង្ខិតបង្ខំ ជាការប្រកាន់យកការអនុវត្តច្បាប់ផ្សេងគ្នាតាមទំនើងចិត្ត ចំពោះបុគ្គលដែលស្ថិតក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា។ ទោះជាយ៉ាងនេះក្តី ដីកាលើកលែងចោទប្រកាន់ពុំបានផ្តល់ការពន្យល់ណាមួយអំពីការចាកចេញពីសំណុំរឿង ០០១ ឡើយ។

90. ទាក់ទងនឹងបញ្ជារបស់ថ្នាក់លើ ក្នុងសំណុំរឿង ០០១ ស.ច.ស រកឃើញថា ឌុច បានទទួលបញ្ជាជាក់លាក់ពីថ្នាក់លើរបស់គាត់ ទាក់ទងនឹងផ្នែកជាច្រើន រួមទាំង (១) ការដកស្រង់ និងខ្លឹមសារ

---

[221] ឯកសារ **D6.1.1036** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ខៀវ សំផន ERN 00156678។ *សូមមើលផងដែរ* ឯកសារ **D1.3.36.1** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ខៀវ សំផន EN ERN 00156949។

[222] សំណុំរឿង ០០១ ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ១៦៩-១៧០។

[223] ឯកសារ **D219/370.1.7**, G. Chon & T. Sambath *នៅពីក្រោយវាលពិឃាត* EN ERN 00757519 (ទំព័រ ៨១ ផ្នែកខាងក្រោម)។

នៃចម្លើយសារភាពជាក់លាក់[224] (២) របបអាហារដែលត្រូវផ្ដល់ឲ្យអ្នកទោស[225] (៣) ការប្រើទារុណកម្មទៅលើអ្នកទោសជាក់លាក់[226] (៤) នីតិវិធីរដ្ឋបាលច្បាស់លាស់ដែលត្រូវអនុវត្តពេលសម្លាប់អ្នកទោស[227] និង (៥) របៀបនៃការសម្លាប់ និងការកប់សពអ្នកទោសសំខាន់ៗមួយចំនួន[228]។ ស.ច.ស ក៏បានរកឃើញដែរថា ឌុច មានឥទ្ធិពលមានកម្រិតលើការចាប់ខ្លួន[229]។ គាត់មិនអាចប្រកែកមិនទទួលអ្នកទោសដែលត្រូវបានបញ្ជូនមកឲ្យគាត់ទេ ហើយគាត់ក៏មិនអាចដោះលែងបានដែរ[230]។ ឌុច ពុំមានសេរីភាពក្នុងការធ្វើសេចក្ដីសន្និដ្ឋានក្រោយការស៊ើបអង្កេតថា បុគ្គលណាម្នាក់ពុំមានកំហុស[231] ហើយគាត់ពុំមានឆន្ទានុសិទ្ធិមិនសម្លាប់អ្នកទោសណាម្នាក់ដែលត្រូវបានបញ្ជូនមកឲ្យគាត់ ហើយឱកាសធំបំផុតដែលមេដឹកនាំផ្ដល់ឲ្យគាត់ គឺសិទ្ធិរក្សាទុកជីវិតអ្នកទោសដែលមានជំនាញខ្លះសម្រាប់ធ្វើការក្នុងរយៈពេលជាក់លាក់មួយ[232]។ ស.ច.ស បានរកឃើញយ៉ាងជាក់ច្បាស់ថា "តួនាទីចម្បងរបស់មន្ទីរ ស-២១ *គឺដើម្បីអនុវត្តមាគ៌ានយោបាយបក្ស* ពាក់ព័ន្ធនឹងខ្មាំង"[233]។

91. ការពិនិត្យលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ និងភស្តុតាងក្នុងសំណុំរឿង ០០៤ បង្ហាញថា យឹម ទិត្យ មានឆន្ទានុសិទ្ធិ *ច្រើនជាង* ឆ្ងាយ ពីរបៀបដែលគាត់អនុវត្តបញ្ជាជាង ឌុច។ ខណៈដែល យឹម ទិត្យ មានភារកិច្ចអនុវត្តគោលនយោបាយខ្មាំងក្នុងជួរ និងក្រៅជួរ របស់ ប.ក.ក ពុំមានភ័ស្តុតាង ឬមានភ័ស្តុតាងតិចតួច បង្ហាញថា គាត់បានទទួលបញ្ជាឲ្យចាប់ខ្លួន ឬសម្លាប់បុគ្គលជាក់លាក់។ ខុសពី ឌុច ដែលគ្រាន់តែទទួលអ្នកទោសដែលត្រូវបានគេបញ្ជូនមកឲ្យគាត់ និងមានសិទ្ធិតិចតួច ឬពុំមានសិទ្ធិសោះក្នុងការដោះលែងអ្នកទោសទាំងនោះដែលគាត់ទទួលបញ្ជាឲ្យ

---

[224] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៤៤។

[225] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៦៨។

[226] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៨៥, ៩៩។

[227] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ១០៧។

[228] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ១២២។

[229] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៣៣, ៥១-៥២។

[230] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៥៣, ៣១។

[231] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៤៤។

[232] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ ឌុច កថាខណ្ឌ ៣១, ១១១។

[233] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៣១ (គូសបញ្ជាក់បន្ថែម)។

សម្លាប់ យឹម ទិត្យ *ពិតជា* មានអំណាចដោះលែងអ្នកទោសនៅក្រោមការគ្រប់គ្រងរបស់គាត់ ប្រសិនបើគាត់សម្រេចធ្វើដូច្នោះ ដូចដែលដីកាលើកលែងចោទប្រកាន់បានទទួលស្គាល់[234]។

92. មានភស្តុតាងតិចតួច ឬពុំមានភ័ស្តុតាងទាល់តែសោះដែលថា យឹម ទិត្យ ខុសពី ឌុច "ត្រូវស្ថិតនៅក្រោមការតាមដានជាប្រចាំ"[235] ដោយថ្នាក់លើរបស់គាត់ឡើយ។ ផ្ទុយទៅវិញ ភ័ស្តុតាងបង្ហាញថា តា ម៉ុក បានធ្វើការប្រកាសជាសាធារណៈថា "បើអត់ពីអញទៅ តា ទិត្យ ជាអ្នកទទួលខុសត្រូវភូមិភាគ [ពាយ័ព្យ] បន្ទាប់"[236] ដែលជាការបង្ហាញច្បាស់ក្រឡែតពីការផ្ទេរ អំណាចទាំងស្រុងរបស់ តា ម៉ុក។ ជាការពិត ដោយ តាម៉ុក ទទួលខុសត្រូវលើភូមិភាគចំនួនបី ឬបួន ក្នុងពេលដំណាលគ្នា នៅខណៈដែលគាត់ជាសមាជិកគណៈអចិន្ត្រៃយ៍[237] តា ម៉ុក មិនអាចគ្រប់គ្រងពេញទៅលើ យឹម ទិត្យ ដូចដែល នួន ជា និងគណៈអចិន្ត្រៃយ៍គ្រប់គ្រងឌុចពេញនោះឡើយ។

93. បន្ថែមលើនេះទៀត នៅពេលធ្វើការបដិសេធចម្លើយរបស់ ឌុច ស្តីពីបញ្ជារបស់ថ្នាក់លើ ក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឌុច "បានដឹងថាបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឲ្យប្រព្រឹត្តបទល្មើសទាំងនោះគឺខុសច្បាប់"[238]។ យឹម ទិត្យ ក៏បានដឹងថា គាត់បានចូលរួមក្នុងឧក្រិដ្ឋកម្មគួរឲ្យរន្ធត់ តាមរយៈ ការអនុវត្តបញ្ជាដោយខុសច្បាប់ច្បាស់ក្រឡែត ដោយបង្ខំប្រជាជនឲ្យធ្វើការ បង្ខំឲ្យរៀបការ និងការចាប់ខ្លួន ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម និង ការធ្វើទុក្ខបុកម្នេញ និង/ឬ ការសម្លាប់ខ្មាំងដែលត្រូវបានសន្មតដោយពុំមានមូលដ្ឋានច្បាប់សមហេតុផល និងដោយពុំមាននីតិវិធីត្រឹមត្រូវណាមួយ។ ដីកាលើក

---

[234] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ២០១, ៦៧៦។ *សូមមើលផងដែរ* ឯកសារ **D219/369** កំណត់ហេតុស្តាប់ចម្លើយ ហុក ចន ឆ.១០៣-១១០ [ពិភាក្សាអំពីបញ្ជារបស់ យឹម ទិត្យ ឲ្យដោះលែងអ្នកទោសនៅវត្តព្រះធាតុ]។ ឯកសារ **D219/430** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២១ ["ពួកគេទាំងអស់ត្រូវបានយកទៅសម្លាប់ លើកលែងតែ តា សាម៉ន ចេញ ដែល តា ទិត្យ ទុកឲ្យរស់"]។

[235] សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ១៧០។

[236] ឯកសារ **D118/150** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ឆ.៦១ (គូសបញ្ជាក់បន្ថែម)។ ឯកសារ **D118/222** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ឆ.១៤។

[237] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ៦៥ ["គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាមាន [...] តា ម៉ុក"] ១៦៨ ["តា ម៉ុក ត្រូវបានតែងតាំងជាលេខាភូមិភាគពាយ័ព្យ ក្នុងពេលដែលគាត់កំពុងកាន់តំណែងជាលេខាភូមិភាគនិរតី។ បន្ទាប់ពីចាប់ខ្លួន សែ នៅក្រោយថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៨ តា ម៉ុក បានក្លាយជាលេខាបួនភូមិភាគគឺ និរតី បស្ចិម ពាយ័ព្យ និងឧត្តរថ្មី"។] ១៣២, ១៣៧។

[238] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៥២។

លែងចោទប្រកាន់ពុំបានរកឃើញ ហើយក៏ពុំមានភ័ស្តុតាងបង្ហាញថា យឹម ទិត្យ ព្យាយាមប្រកែកបញ្ហារបស់ថ្នាក់លើឡើយ[239]។

94. ទាក់ទងនឹងការបង្ខិតបង្ខំ ទោះបីដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ ពុំបានរកឃើញផ្នែកអង្គច្បាប់ណាមួយអំពីអត្ថិភាពនៃការបង្ខិតបង្ខំ ការរកឃើញអង្គហេតុណាមួយ ពាក់ព័ន្ធនឹងការភ័យខ្លាចរបស់ ឌុច ពុំបានរារាំងការរកឃើញដ៏ត្រឹមត្រូវដែលថា ឌុច ស្ថិតនៅក្នុងប្រភេទ "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត"។ ស.ច.ស បានដកស្រង់សម្ភារៈភ័ស្តុតាងដែល ឌុច ថ្លែងថា គាត់ "ត្រូវតែទទួលការចាត់តាំងទាំងអស់ដោយខានមិនបាន" និង "តក់ស្លុតចំពោះជីវិតរបស់ខ្ញុំ"[240] និងថា ប្រសិនបើគាត់លះបង់តួនាទីរបស់គាត់ មានន័យថា គាត់ និងគ្រួសាររបស់គាត់ "ត្រូវស្លាប់"[241]។ ខណៈដែលភ័ស្តុតាងពាក់ព័ន្ធនឹង ឌុច ក៏ខកខានបំពេញលក្ខខណ្ឌច្បាប់សម្រាប់ការបង្ខិតបង្ខំ ដោយសារតែការគ្មានការគំរាមកំហែងដែលត្រូវកើតឡើង ភ័ស្តុតាងដែល ស.ច.ស បង្ហាញនៅក្នុងសំណុំរឿង ០០១ បង្ហាញថា ឌុច បានទទួលរងប្រភេទសម្ពាធដូចគ្នាទៅនឹង យឹម ទិត្យ តែទោះជាយ៉ាងនេះក្តី ស.ច.ស មិនបានយល់ថា នេះជាកត្តារារាំងដល់ការរកឃើញដ៏ត្រឹមត្រូវនៃយុត្តាធិការបុគ្គលពាក់ព័ន្ធនឹង ឌុច ឡើយ។

95. ជាសេចក្តីសន្និដ្ឋាន ដីកាលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយអនុញ្ញាតការទទួលបញ្ជាពីថ្នាក់លើជាការការពារផ្លូវច្បាប់ នៅក្នុងការពិចារណាលើយុត្តាធិការបុគ្គល ដែលផ្ទុយទៅនឹងយុត្តិសាស្ត្រ អ.វ.ត.ក និងមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងរកឃើញដោយមិនច្បាស់អំពីអត្ថិភាពនៃការបង្ខិតបង្ខំ ទោះបីជាមិនបានបំពេញលក្ខណវិនិច្ឆ័យផ្នែកច្បាប់ និងទោះបីជាភស្តុតាងនៅក្នុងសំណុំរឿងបង្ហាញផ្ទុយពីនេះក្តី។ កំហុសទាំងនេះនាំឲ្យមោឃភាពដីកា

---

239 អ.ជ.ស.ជ បានរកឃើញដូចគ្នាអំពី ឌុច "ជនជាប់ចោទ [...] មិនបានលើកឡើងអំពីការមិនគោរពតាមបញ្ជាណាមួយឡើយ"។ *សូមមើល* សំណុំរឿង០០១-ឯកសារ **E188** ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៥៥។

240 ឯកសារ **D1.3.29.2** (ពីមុនសំណុំរឿង០០១-ឯកសារ **D21**) កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ERN 00146678 ដែលត្រូវបានយោងក្នុងសំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ១៦៩ (ជើងទំព័រ៥០១, ៥០៣)។

241 ឯកសារ **D6.1.1064** (ពីមុនសំណុំរឿង០០១-ឯកសារ **D73**) កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច EN ERN 00209177 ដែលត្រូវបានយោងក្នុងសំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយ ឌុច កថាខណ្ឌ ១៦៩ (ជើងទំព័រ៥០២)។ ដោយសារតែមុខតំណែងរបស់ ឌុច ជាប់ពាក់ព័ន្ធខ្លាំងទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ចំណុចនេះបង្កើតបានជាភ័ស្តុតាងដែលថា ឌុច បានជឿថា ប្រសិនបើគាត់ឈប់សម្លាប់មនុស្ស រូបគាត់ និងក្រុមគ្រួសាររបស់គាត់នឹងត្រូវសម្លាប់។

លើកលែងចោទប្រកាន់ ហើយទោះបីជាដោយឯកឯង ឬជារួមគ្នី ជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្ដីសម្រេចដែលថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ។

## ឃ. ដីកាលើកលែងការចោទប្រកាន់មានកំហុសនៅក្នុងការពិចារណាលើទម្រង់នៃការចូលរួម និងភាពនៅជិតឧក្រិដ្ឋកម្មរបស់ យឹម ទិត្យ នៅពេលកំណត់លើកម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត

96. ដីកាលើកលែងការចោទប្រកាន់មានកំហុសអង្គច្បាប់ដោយផ្តោតទាំងស្រុងលើ "ការចូលរួមផ្ទាល់" និង ភាពនៅជិតការប្រព្រឹត្តឧក្រិដ្ឋកម្ម និងការបដិសេធពិចារណាលើទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ ជាពិសេស សហឧក្រិដ្ឋកម្មរួម។ កំហុសទាំងនេះនាំឲ្យសេចក្ដីសម្រេចគ្មានសុពលភាព ហើយជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្ដីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

### ១. ការផ្តល់ទម្ងន់ជ្រុលហួសលើ "ការចូលរួមផ្ទាល់" នៅក្នុង និងភាពនៅជិតឧក្រិដ្ឋកម្ម នៅក្នុងការវិភាគលើយុត្តាធិការបុគ្គល

97. ដីកាលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយធ្វើការអះអាងថា "លក្ខណវិនិច្ឆ័យសម្រាប់អ្នកទទួលខុសត្រូវខ្ពស់បំផុត" [...] ផ្តោតជាចម្បងលើការចូលរួមជាក់ស្តែង និងដោយផ្ទាល់ ដោយមិនគិតអំពីតួនាទី[242]។ កំហុសក្នុងដីកាលើកលែងចោទប្រកាន់ដែលផ្តោតលើការចូលរួមផ្ទាល់ ដែលដីកានេះមិនបានកំណត់និយមន័យ ប៉ុន្តែមានកំហុសក្នុងការប្រៀបធៀបស្មើគ្នាទៅនឹងការចូលរួមផ្ទាល់ និងដោយមិនរាប់បញ្ចូលដោយចេតនាពីការពិចារណាលើទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ គឺជាកំហុសអង្គច្បាប់ដែលនាំឲ្យដីកាលើកលែងចោទប្រកាន់គ្មានសុពលភាព។

98. នៅពេលធ្វើការវាយតម្លៃលើការចូលរួម និងសិទ្ធិអំណាចរបស់ យឹម ទិត្យ នៅតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗ ការអះអាងដដែលៗនៅក្នុងដីកាលើកលែងចោទប្រកាន់ដែលថា យឹម ទិត្យ មិនមានវត្តមានផ្ទាល់នៅតាមទីតាំងឧក្រិដ្ឋកម្មនានា[243] មិនបានចូលរួមដោយសកម្មនៅក្នុង ឬផ្តួចផ្តើមការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ ហើយជាលទ្ធផល "ចំនួនជនរងគ្រោះទាំងនេះមិនមែនជាលទ្ធផលនៃអំពើឧក្រិដ្ឋកម្មផ្ទាល់របស់[244] យឹម ទិត្យ ទេ" មានវិការៈផ្លូវច្បាប់ និងភាពសមហេតុសមផល។

---

[242] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៨៣។ *សូមមើលផងដែរ* កថាខណ្ឌ ៦៣៦, ៦៣៨, ៦៨២។

[243] *សូមមើលឧទាហរណ៍* ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៤០១ [ឃុំកំពង់ព្រៀង] ៤៧៩ [ទួលម្ទេស] ៣៣២ [រោចក្រសួរសកំពង់គល់] ៣៤៤ [មន្ទីរសន្តិសុខភូមិវាល] ២៧៥ [សហករណ៍ធិបតី]។

[244] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៨៣, ៦៨០។

ដោយហេតុថា ការប្រព្រឹត្តិបទឧក្រិដ្ឋផ្ទាល់ គឺជាទម្រង់នៃការទទួលខុសត្រូវតែមួយគត់ដែលតម្រូវឲ្យមានការចូលរួមផ្ទាល់ និងភាពនៅជិត ដីកាលើកលែងចោទប្រកាន់មានកំហុសច្បាស់ក្រឡែតក្នុងការប្រៀបធៀបស្មើគ្នានៃការចូលរួមផ្ទាល់ ទៅនឹងការប្រព្រឹត្តិបទឧក្រិដ្ឋផ្ទាល់។ ប្រភេទ "នៃការទទួលខុសត្រូវខ្ពស់បំផុត" ដូចមានចែងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលកិច្ចព្រមព្រៀង និងច្បាប់ទាំងពីរនេះ រួមទាំងចេតនារបស់រាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ជាប្រភេទចំហ ដែលសមាជិកភាពអាចត្រូវបានកំណត់តែមួយគត់ដោយសហព្រះរាជអាជ្ញា និងចៅក្រម អ.វ.ត.ក ដោយផ្អែកលើភ័ស្តុតាងទាំងមូល[245]។ ដូចត្រូវបានសម្រេចយ៉ាងត្រឹមត្រូវនៅក្នុងដីកាដំណោះស្រាយមុនៗ "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ត្រូវតែធ្វើការកំណត់ឲ្យបានច្បាស់លាស់ដោយយោងទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ ឬជនត្រូវចោទ ដោយពិចារណាទៅលើកត្តាផ្សេងៗមួយចំនួន[246] ដោយពុំមានកត្តាណាមួយតម្រូវឲ្យមានភាពនៅជិតផ្ទាល់នឹងឧក្រិដ្ឋកម្ម ឬការប្រព្រឹត្តិបទឧក្រិដ្ឋផ្ទាល់នោះទេ[247]។

99. ទង្វើដែលរួមចំណែកដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មអន្តរជាតិអាចជា និងសម្រាប់ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ជាញឹកញាប់ ត្រូវបានផ្តាច់ចេញតាមលក្ខណៈភូមិសាស្ត្រ និងបណ្តោះអាសន្នពី អំពើផ្ទាល់នៃការប្រព្រឹត្តិនោះ។ មានការកំណត់យ៉ាងច្បាស់នៅក្នុងយុត្តិសាស្ត្របន្ទាប់ពីការជំនុំជម្រះក្រោយសង្គ្រាមលោកលើកទី ២ ថា ដើម្បីរកឃើញការទទួលខុសត្រូវតាមរយៈទម្រង់ណាមួយនៃការទទួលខុសត្រូវដូចមានចែងក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក លើកលែងតែការប្រព្រឹត្តិបទ

---

[245] *សូមមើលយោងខាងលើ* ផ្នែក IV(ក)(៣)។

[246] សំណុំរឿង ០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ *អ៊ឹម ចែម* កថាខណ្ឌ ៣៨-៤១ ជើងទំព័រ ៧៣៥។ សំណុំរឿង ០០៣-ឯកសារ **D266** ដីកាដំណោះស្រាយ *មាស មុត* កថាខណ្ឌ ៣, ៣៦៥-៣៦៧។ សំណុំរឿង០០៤/២ -ឯកសារ **D359** ដីកាដំណោះស្រាយ *អោ អាន* កថាខណ្ឌ ៤២៤-៤២៥។ *យោងខាងលើ* ផ្នែក III(ខ)។

[247] កត្តាមួយក្នុងចំណោមកត្តានានាដែលត្រូវពិចារណាក្នុងការវិភាគលើកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទនោះគឺកម្រិតនៃការចូលរួមរបស់គាត់ក្នុងឧក្រិដ្ឋកម្ម។ ខណៈដែល "ការចូលរួម" មិនមែនជាពាក្យមានន័យពិសេសក្នុងបរិបទណាមួយនោះ វាមិនកំណត់ត្រឹមតែ ការចូលរួម*ផ្ទាល់* នោះទេ ហើយជាញឹកញាប់ត្រូវបានគេប្រើយោងទៅលើរាល់ទម្រង់ទាំងអស់នៃការទទួលខុសត្រូវក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក។ *សូមមើលឧទាហរណ៍* សាលដីកា *Kayishema & Ruzindana* កថាខណ្ឌ ១៨៥។ សាលក្រម *Musema* កថាខណ្ឌ ១១៤។ សាលក្រម *Kamuhanda* កថាខណ្ឌ៥៨៨។ សាលដីកា *Delalić* កថាខណ្ឌ ៣៥១។

ឧក្រិដ្ឋផ្ទាល់ ការមានវត្តមានផ្ទាល់នៅទីតាំងឧក្រិដ្ឋកម្មពុំមែនជាលក្ខខណ្ឌតម្រូវទេ[248]។ ចំណុចនេះក៏ត្រូវបានទទួលស្គាល់សម្រាប់ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម[249] ដែលនៅក្នុងនោះ ការចូលរួមនៅក្នុងគោលបំណងរួមមិនចាំបាច់ឲ្យមាន សូម្បីតែការពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[250] ហើយអ្នកចូលរួមអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយអ្នកប្រព្រឹត្ត ផ្ទាល់

---

[248] *សូមមើលឧទាហរណ៍* សាលក្រម *Tadić* កថាខណ្ឌ ៦៧៩ [“ការចូលរួមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនតម្រូវឲ្យមានវត្តមានរូបវ័ន្តជាក់ស្តែង ឬជំនួយរូបវ័ន្តទំនងជាត្រូវបានទទួលយកយ៉ាងត្រឹមត្រូវនៅក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម Nürnberg”] ៦៩១ *ដកស្រង់* រឿងក្តី *Golkel* ទំព័រ ៥៣ [“វាច្បាស់ថា ពាក្យពេចន៍ទាំងនោះ [“ពាក់ព័ន្ធក្នុងការសម្លាប់”] មិនមានន័យថាមនុស្សម្នាក់ពិតជាមានវត្តមាននៅទីតាំងបាញ់ប្រហារទេ”] និង *ការជំនុំជម្រះ Max Wielen និង ១៧ នាក់ផ្សេងទៀត* តុលាការយោធាចក្រភពអង់គ្លេស Hamburg ប្រទេសអាល្លឺម៉ង់ ចុះថ្ងៃទី១ ខែកក្កដា-៣ កញ្ញា ឆ្នាំ១៩៤៧ ត្រូវបានរាយការណ៍ក្នុង LRTWC, វ៉ុល XI ទំព័រ៤៣-៤៤, ៤៦ [“តាមរយៈការសន្និដ្ឋានថា ជនជាប់ចោទ Schimmel និង Gmeiner មានពិរុទ្ធភាព តុលាការបានបញ្ជាក់ថា “ការជាប់ពាក់ព័ន្ធក្នុងការសម្លាប់” មិនចាំបាច់តម្រូវឲ្យមានវត្តមានជនជាប់ចោទនៅទីតាំងឧក្រិដ្ឋកម្មនោះទេ ដោយសារតែទាំង Schimmel និង Gmeiner បានផ្តល់ការណែនាំទៅកាន់ថ្នាក់ក្រោមរបស់ខ្លួន តែមិនមានវត្តមាននៅកន្លែងបាញ់ប្រហារ។” (ដកស្រង់ពីទំព័រ ៤៦)]។ *Gustav Becker, Wilhelm Weber និង ១៨នាក់ផ្សេងទៀត* តុលាការយោធាអចិន្ត្រៃយ៍ប្រចាំនៅទីក្រុងលីយ៉ុង ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤៧, LRTWC, វ៉ុល VII, ទំព័រ៦៧, ៧០ [ជនជាប់ចោទលើកលែងតែម្នាក់ចេញ បានចាប់ខ្លួនជនជាតិបារាំងជាច្រើននាក់ ក្នុងដែនដីដែលគ្រប់គ្រងដោយប្រទេសបារាំង ដែលជាផលវិបាកត្រូវបាននិរទេសទៅកាន់ជំរុំប្រមូលផ្តុំនៅក្នុងប្រទេសអាល្លឺម៉ង់ ដែលជាទីដែលបីនាក់ក្នុងចំណោមពួកគេបានស្លាប់ដោយការធ្វើបាប។ ពួកគេត្រូវបានរកឃើញថាមានពិរុទ្ធភាពដោយសារការបណ្តាលឲ្យមានការស្លាប់ជនស៊ីវិលបារាំងនៅក្នុងប្រទេសអាល្លឺម៉ង់ តាមរយៈការចូលរួមចំណែក និងការជួយទំនុកបម្រុងការនិរទេសជនស៊ីវិលទាំងនោះ។]។ សាលក្រម *Kayishema & Ruzindana* កថាខណ្ឌ២០០ [“មិនត្រូវបានសន្និដ្ឋានជាមុនទេថា ជនជាប់ចោទត្រូវតែមានវត្តមាននៅកន្លែងឧក្រិដ្ឋកម្ម ហើយមិនមែនថាការចូលរួមចំណែករបស់គាត់ត្រូវតែផ្ទាល់នោះទេ។”]

[249] *សូមមើលឧទាហរណ៍* សាលដីកា *Krnojelac* កថាខណ្ឌ ៨១ [“អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពិចារណាថា វត្តមានរបស់អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនៅពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងដោយជនល្មើសដើម មិនចាំបាច់ឡើយ”]។ សាលដីកា *Kvočka* កថាខណ្ឌ ១១២។ សាលដីកា *Simba* កថាខណ្ឌ ២៩៦។ សាលដីកា *Karemera & Ngirumpatse* កថាខណ្ឌ ១៥៣ [“មិនចាំបាច់ទេថាតើ Ngirumpatse ស្ថិតនៅក្រៅប្រទេស ឬយ៉ាងណា ខណៈដែលអំពើឧក្រិដ្ឋមួយចំនួនត្រូវបានប្រព្រឹត្តឡើង។ អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមមិនតម្រូវឲ្យមានវត្តមានផ្ទាល់ នៅពេល និងនៅទីកន្លែងដែលឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្តឡើយ”]។ សាលក្រម *Bagilishema* កថាខណ្ឌ៣៣។

[250] សំណុំរឿង០០២-ឯកសារ **E313** សាក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៦៩៣។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥០៨។ សាលដីកា *Tadić* កថាខណ្ឌ ២២៧, ២២៩។ សាលដីកា *Šainović* កថាខណ្ឌ ៩៨៥។ សាលដីកា *Prlić* កថាខណ្ឌ១៤១០, ១៨៨០។ សាលដីកា *Sesay* កថាខណ្ឌ ៦១១។

ដែលពុំមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម[251]។ ស្រដៀងគ្នានេះដែរ ទៅតាមលក្ខណៈជា មូលដ្ឋាន មិនមានលក្ខខណ្ឌចំពោះការប្រព្រឹត្តិផ្ទាល់ ឬវត្តមានផ្ទាល់ សម្រាប់ការទទួលខុសត្រូវ ព្រហ្មទណ្ឌ តាមរយៈការរៀបចំផែនការ ការញុះញង់ និងការបញ្ជា[252] ឬ ការជួយ និងជំរុញ[253] ឬ ការទទួលខុសត្រូវរបស់ថ្នាក់លើ[254]។

100. ដើម្បីកំណត់ថា ការចូលរួមផ្ទាល់ ដែលដីកាលើកលែងចោទប្រកាន់កំណត់ច្បាស់លាស់ថាជា ការប្រព្រឹត្តិផ្ទាល់ គឺជាទម្រង់តែមួយគត់នៃទម្រង់នៃការទទួលខុសត្រូវ ដែលនឹងធ្វើឱ្យ ជនសង្ស័យ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នឹងរារាំងការចោទប្រកាន់បុគ្គលសឹងតែគ្រប់រូប លើកលែងតែ បុគ្គលដែលជាឧបករណ៍នៅថ្នាក់ទាបបំផុតនៃរបបឧក្រិដ្ឋ ដូចជា របបកម្ពុជាប្រជាធិបតេយ្យ។ ផ្អែកលើលក្ខណៈរួមនៃឧក្រិដ្ឋកម្មអន្តរជាតិ កម្រិតនៃការទទួលខុសត្រូវ ជាទូទៅ មានការកើនឡើង ខណៈដែលភាពនៅជិតនឹងការប្រព្រឹត្តិផ្ទាល់ មានការថយចុះ។ ឧត្តមសេនីយ៍ដែលបានរៀបចំ ផែនការសម្លាប់ទ្រង់ទ្រាយធំ ត្រូវបានយល់ថាមានការទទួលខុសត្រូវច្រើនជាងទាហានតូចតាច ដែលបានអនុវត្តផែនការនោះ[255]។ ដូច្នេះ ការផ្តោតលើការប្រព្រឹត្តិផ្ទាល់ និងភាពនៅជិតផ្ទាល់ នៅ

[251] សំណុំរឿង០០២-ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៤០។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២២៥។ សាលដីកា *Prlić* កថាខណ្ឌ ១៩៨៨។ សាលដីកា *Brđanin* កថាខណ្ឌ ៤១០-៤១៤, ៤១៨, ៤៣០។ សាលដីកា *Đorđević* កថាខណ្ឌ ១៦៥។ សាលដីកា *Sesay* កថាខណ្ឌ ៣៩៨-៤០០។

[252] សាលដីកា *Boškoski & Tarčulovski* កថាខណ្ឌ ១៣២ ["អង្គជំនុំជម្រះសាលាឧទ្ធរណ៍រំលឹកថា វត្តមានរបស់ជនជាប់ចោទ នៅកន្លែងឧក្រិដ្ឋកម្មមិនមែនជាធាតុផ្សំចាំបាច់នៃការរៀបចំផែនការ ការញុះញង់ និងការបញ្ជាទេ"]។ សម្រាប់ការញុះញង់ *សូមមើលផងដែរ* សាលដីកា *Nahimana* កថាខណ្ឌ ៦៦០។ សាលដីកា *Nyiramasuhuko* កថាខណ្ឌ ៣៣២៧។ សម្រាប់ការបញ្ជា *សូមមើលផងដែរ* សាលដីកា *D. Milošević* កថាខណ្ឌ ២៩០។

[253] ករណីលើកលែងមួយនោះគឺករណីអ្នកមើលដោយពេញចិត្ត។ *សូមមើល ឧទាហរណ៍* សាលដីកា *Lukić & Lukić* កថាខណ្ឌ ៤២៥ ["អង្គជំនុំជម្រះសាលាឧទ្ធរណ៍កត់សម្គាល់ថា វត្តមានផ្ទាល់របស់អ្នកជួយ និងអ្នកជំរុញ នៅ ឬនៅក្បែរកន្លែងឧក្រិដ្ឋកម្ម អាចជាកត្តាពាក់ព័ន្ធក្នុងករណី ការជួយ និងការជំរុញតាមការព្រមព្រៀងតុណ្ហីភាព។ លើសពីនេះទៀត ធាតុផ្សំសត្យានុម័ត នៃការជួយ និងការជំរុញអាចត្រូវបានបំពេញពីចម្ងាយ"]។ សាលដីកា *Ntagerura* កថាខណ្ឌ ៣៧២។ សាលក្រម *Akayesu* កថាខណ្ឌ ៤៨៤។ សាលក្រម *Rutaganda* កថាខណ្ឌ ៤៣។ សាលក្រម *Brima* កថាខណ្ឌ ៧៧៥។

[254] សាលដីកា *Karemera & Ngirumpatse* កថាខណ្ឌ ២៥៩ ["ចងចាំថា វត្តមានមិនចាំបាច់ទេសម្រាប់ការទទួលខុសត្រូវ របស់ថ្នាក់លើ អនុលោមតាមមាត្រា ៦(៣) នៃលក្ខន្តិកៈ"]។

[255] *សូមមើល* សាលដីកា *Tadić* កថាខណ្ឌ ១៩១ ["ភាគច្រើនឧក្រិដ្ឋកម្មទាំងអស់នេះមិនបណ្តាលមកពីទំនោរឧក្រិដ្ឋរបស់ បុគ្គលតែឯងនោះទេ ប៉ុន្តែបង្កើតបានជាការស្តែងចេញឱ្យឃើញនូវភាពឧក្រិដ្ឋជាសមូហភាព៖ ឧក្រិដ្ឋកម្មជាញឹកញាប់ត្រូវបាន ធ្វើឡើងដោយក្រុមបុគ្គលដែលធ្វើស្របតាមការរៀបចំផែនការឧក្រិដ្ឋរួម។ ទោះបីជាមានតែសមាជិកខ្លះនៃក្រុមនោះ អាចប្រព្រឹត្ត អំពើឧក្រិដ្ឋដោយផ្ទាល់ [...] ការចូលរួម និងការរួមចំណែករបស់សមាជិកផ្សេងទៀតនៃក្រុមនោះ ជាញឹកញាប់ មានសារៈសំខាន់

ក្នុងការកំណត់ថា បុគ្គលណាទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងការរៀបចំភាពសាហាវឃោរឃៅទ្រង់ទ្រាយធំ ខកខានក្នុងការចាប់យកលក្ខណៈ និងយន្តការនៅខាងក្រោយឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបំផុត។

101. លើសពីនេះទៅទៀត ជំហរដែលត្រូវបានប្រកាន់យកនៅក្នុងដីកាលើកលែងចោទប្រកាន់[256] ក៏មានលក្ខណៈខុសគ្នាផងដែរទៅនឹងការសម្រេចលើយុត្តាធិការបុគ្គលនៅក្នុងសំណុំរឿង ០០២។ នៅក្នុងសំណុំរឿង ០០២ ស.ច.ស បានរកឃើញថា នួន ជា ខៀវ សំផន អៀង សារី និង អៀង ធារិទ្ធ មិនត្រឹមតែជាមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះទេ ក៏ប៉ុន្តែ ក៏ស្ថិតនៅក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដោយសារតែ "ការចូលរួមផ្ទាល់របស់ពួកគេនៅក្នុងការអនុវត្តគោលបំណងរួមរបស់ ប.ក.ក តាមរយៈមធ្យោបាយឧក្រិដ្ឋ"[257]។ ស.ច.ស ពុំបានរកឃើញថា នួន ជា ខៀវ សំផន អៀង សារី ឬ អៀង ធារិទ្ធ បានចូលរួមផ្ទាល់ក្នុងឧក្រិដ្ឋកម្មណាមួយ ហើយក៏ពុំបានរកឃើញថា ការទទួលខុសត្រូវរបស់ពួកគេត្រូវបានរកឃើញតែឯកឯង ដោយផ្អែកលើវត្តមាននៅទីតាំងឧក្រិដ្ឋកម្មណាមួយដែលត្រូវបានស៊ើបអង្កេតនោះដែរ[258]។

102. ចុងក្រោយ ដីកាលើកលែងចោទប្រកាន់បានមើលរំលងយុត្តិសាស្ត្រផ្ទុយនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត។ ពុំមានដីកាសម្រេចរបស់ចៅក្រមនៅតុលាការ ICTY ណាមួយ ដែលបុគ្គលម្នាក់ត្រូវបានបញ្ជាក់ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ផ្តល់ទម្ងន់សំខាន់លើភាពនៅជិតនឹងឧក្រិដ្ឋកម្ម ឬការចូលរួមផ្ទាល់ឡើយ[259]។ លើសពីនេះទៀត តុលាការ ICTY បានផ្តន្ទាទោស

---

ក្នុងការជួយដល់ការប្រព្រឹត្តិបទល្មើសបែបនោះ។ ដូច្នេះ ភាពធ្ងន់ធ្ងរបែបសីលធម៌នៃការចូលរួមបែបនោះ ជាញឹកញាប់ មិនតិចឬតាមពិតនោះ មិនខុស ពីការចូលរួមរបស់អ្នកដែលបានអនុវត្តអំពើនោះដោយផ្ទាល់ឡើយ"]។

[256] *សូមមើលយោងខាងលើ* កថាខណ្ឌ ៩៧។ *សូមមើលផងដែរ* សំណុំរឿង០០៣-ឯកសារ **D266** ដីកាដំណោះស្រាយ *មាស មុត* កថាខណ្ឌ ៣៦៨ ["មេដឹកនាំដែលពុំបានចូលរួមអ្វីជាដុំកំភួននៅក្នុងសកម្មភាពល្មើសនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចស្ថិតនៅក្រៅក្របខណ្ឌនៃយុត្តាធិការរបស់តុលាការ ដោយហេតុថា បុគ្គលនោះពុំមែនជាអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតទេ។"]។

[257] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៧-១៣២៨។

[258] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២១-១៥៦៣។ *សូមមើលផងដែរ* កថាខណ្ឌ ៨៦២-៩៩៣ (នួន ជា) ៩៩៤-១១២៥ (អៀង សារី) ១១២៦-១២០០ (ខៀវ សំផន) ១២០១-១២៩៥ (អៀង ធីរិទ្ធ)។

[259] សេចក្តីសម្រេចកំណត់សមត្ថកិច្ចរឿងក្តី *D. Milošević* កថាខណ្ឌ ២១-២៣។ [ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីបានសម្រេចថា Milošević ស្ថិតនៅក្នុងចំណោមជន "ជាន់ខ្ពស់បំផុត" ពីព្រោះថា (i) គាត់បានកាន់មុខតំណែងអធិន្ត្រៃយ៍ជាមេបញ្ជាការ SRK ក្នុងរយៈពេលជាយូរអង្វែង ដែលជាកងកម្លាំងមានទាហាន ១៨ ០០០ នាក់។ (ii) មានតែមេបញ្ជាការយោធាថ្នាក់លើតែមួយគត់ដែលនៅពីលើ និង (iii) គាត់ដើរតួនាទីដឹកនាំយ៉ាងច្បាស់ ឧទាហរណ៍ ការចូលរួមកិច្ចចរចា]។ សាលដីកា *Lukić*

Zdravko Tolimir ឱ្យជាប់ពន្ធនាគារមួយជីវិតពីបទប្រល័យពូជសាសន៍[260] ចំពោះការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម ក្នុងការសម្លាប់បុរស និងកុមារា មកពី ស្រេប្រេនីកា ទោះបី Tolimir បានទទួលបញ្ជាផ្ទាល់ពី Ratko Mladić និងពុំដែលមានវត្តមាននៅក្នុងអំឡុងពេលប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះ[261]។

103. សំណុំរឿង *Taylor* នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន ("SCSL") ប្រហែលជាឧទាហរណ៍គួរឱ្យទាក់ទាញអារម្មណ៍បំផុតបង្ហាញពីកំហុសនៅក្នុងវិធីសាស្ត្ររបស់ដីកាលើកលែងចោទប្រកាន់។ មាត្រា ១(១) នៃលក្ខន្តិកៈតុលាការ SCSL កម្រិតយុត្តាធិការបុគ្គលរបស់តុលាការត្រឹម "ជនដែលមាន*ការទទួលខុសត្រូវបំផុត*" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនៅក្នុងប្រទេសសេរ៉ាលីអូន[262]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL បានផ្តន្ទាទោសអតីតប្រមុខរដ្ឋលីបេរីយ៉ា ដែលមិនដែលឈានជើងចូលប្រទេសសេរ៉ាលីអូនបន្តិចណាសោះ[263] ចំពោះបទ ជួយ និងជំរុញ និងការរៀបចំផែនការឧក្រិដ្ឋកម្មនៅទីនោះ និងបានកាត់ទោស

---

កថាខណ្ឌ ២១-២៣ [អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបដិសេធសេចក្តីសម្រេចកំណត់សមត្ថកិច្ចរឿងក្តី *Lukić & Lukić* ដែលបានសម្រេចបញ្ជូនរឿងក្តីនេះទៅអាជ្ញាធរបូស្នៀ ដោយយល់ឃើញថា ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី បានសង្កត់ធ្ងន់ហួសហេតុលើវិសាលភាពភូមិសាស្ត្រមានកំណត់នៃអំពើរបស់ជនជាប់ចោទ ហើយមិនបានវាយតម្លៃកម្រិតនៃការចូលរួមរបស់គាត់ក្នុងនាមជា "មេដឹកនាំ និងជាអ្នករៀបចំម្នាក់នៃឧក្រិដ្ឋកម្មទាំងនេះ"។]។ សេចក្តីសម្រេចកំណត់សមត្ថកិច្ចរឿងក្តី *Delić* កថាខណ្ឌ ២០-២៥ [ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីបានរកឃើញថា ជនជាប់ចោទស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ដោយសារតែតំណែងយោធាជាន់ខ្ពស់របស់គាត់ និងតួនាទីរបស់គាត់នៅក្នុងការរៀបចំផែនការ ណែនាំ និងតាមដានប្រតិបត្តិការយោធា។ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីបានកត់សម្គាល់ថា ជនជាប់ចោទ មិនត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដោយការប្រព្រឹត្តដោយផ្ទាល់ទេ ហើយបានបញ្ជាក់យ៉ាងច្បាស់ថា ក្រុមប្រឹក្សា "មិនជឿតាមអយ្យការដែលថា "ភាពនៅឆ្ងាយ" របស់ជនជាប់ចោទពីបទល្មើសទាំងនោះ កាត់បន្ថយកម្រិតនៃការទទួលខុសត្រូវរបស់គាត់ដែលត្រូវបានចោទប្រកាន់ រហូតដល់កម្រិតមួយដែលធ្វើឱ្យរឿងក្តីនេះសមបញ្ជូនទៅទេ"។]។

[260] សាលដីកា *Tolimir* កថាខណ្ឌ ៦៤៨ [អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសន្និដ្ឋានថា ការពិចារណាអំពីការផ្តន្ទាទោស Tolimir ចំពោះអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តតាមរយៈការសម្លាប់បុរស និងក្មេងប្រុសមកពីស្រេប្រេនីកា និងតាមរយៈការបង្កឱ្យមានការឈឺចាប់លើរាងកាយ ឬព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរលើជាជនមូស្លីមបូស្នៀ នៅស្រេប្រេនីកា តែឯងនោះ កម្រិតនៃការទទួលខុសត្រូវ Tolimir ត្រូវទទួលការដាក់ទោសអស់មួយជីវិត ដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង។]។

[261] សាលក្រម *Tolimir* កថាខណ្ឌ ៩១៥-៩១៦, ១០៩៦, ១០៩៩, ១១០១, ១១០៣-១១០៤, ១១០៩-១១១០, ១១២៩, ១២៤២។

[262] លក្ខន្តិកៈតុលាការ SCSL មាត្រា ១(១) (គូសបញ្ជាក់បន្ថែម)។

[263] សាលដីកា *Taylor* កថាខណ្ឌ ៩៨ ["ខណៈដែលលោក Taylor មិនដែលជាន់ជើងលើទឹកដីសេរ៉ាឡេអូន ប៉ុន្តែស្នាមជើងដ៏ធ្ងន់របស់គាត់មាននៅទីនោះ ហើយអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា ដែនសមត្ថកិច្ចនៅក្រៅប្រទេសនៃអំពើឧក្រិដ្ឋរបស់គាត់គឺជាកត្តាស្ថានទម្ងន់មួយ"]។

គាត់ឲ្យជាប់ពន្ធនាគាររយៈពេល ៥០ ឆ្នាំ[264] ហើយការកាត់ទោសនេះត្រូវបានតម្កល់ដោយសាលាឧទ្ធរណ៍[265]។

104. ការយកចិត្តទុកដាក់ដោយមិនត្រឹមត្រូវនៅក្នុងដីកាលើកលែងចោទប្រកាន់លើការចូលរួមផ្ទាល់ និងការខកខានពិចារណាលើទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ ផ្ទុយទៅនឹងយុត្តិសាស្ត្រអន្តរជាតិ និងយុត្តិសាស្ត្រ អ.វ.ត.ក។ កំហុសអង្គច្បាប់នេះនាំឲ្យដីកាលើកលែងចោទប្រកាន់គ្មានសុពលភាព និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្ដីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ២. ការខកខានពិចារណាលើការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម នៅពេលធ្វើការវាយតម្លៃលើយុត្តាធិការបុគ្គល

105. ដីកាលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយបដិសេធការពិចារណាលើសហឧក្រិដ្ឋកម្មរួម (ឬទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ)[266] នៅពេលធ្វើការវាយតម្លៃយុត្តាធិការបុគ្គល[267]។ ចំណុចនេះផ្ទុយទៅនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០១ ដែលដីកានេះបានទទួលស្គាល់ថា ការចូលរួមក្នុងសហឧក្រិដ្ឋកម្ម បង្កើតបានជាការប្រព្រឹត្តិ អនុលោមតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[268] និងបានយោងលើទស្សនៈរបស់អង្គបុរេជំនុំជម្រះដែលថែងថា ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមគ្របដណ្ដប់លើស្ថានភាពដែលជនត្រូវចោទអាច *មានលក្ខណៈពីចំងាយពីការរួមប្រព្រឹត្តជាក់ស្ដែងនៃអំពើពិរុទ្ធនៃបទឧក្រិដ្ឋ ផ្សេងពីស្ថានភាពដែលអាចមើលឃើញ តាមរយៈការចូលរួមផ្ទាល់ដែលត្រូវបានកំណត់លក្ខខណ្ឌ យោងតាមច្បាប់នៅថ្នាក់ជាតិ*[269]។

106. ទោះជាយ៉ាងនេះក្ដី ផ្អែកលើការរកឃើញអង្គហេតុមានកម្រិតនៅក្នុងដីកាលើកលែងចោទប្រកាន់ គេអាចធ្វើការសន្និដ្ឋានដូចតទៅ (១) មានពហុបុគ្គលនៅក្នុង បកក ដែលបានឯកភាពលើគោល

---

[264] សាលក្រម *Taylor* ផ្នែកសម្រេចសេចក្ដី កថាខណ្ឌ ៦៩៩៤។ សាលក្រមកំណត់ទោស *Taylor* ផ្នែកសម្រេចសេចក្ដី ទំព័រ ៤០។

[265] សាលដីកា *Taylor* ផ្នែកសម្រេចសេចក្ដី ទំព័រ ៣០៥។

[266] ឯកសា **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៤។

[267] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៨៣។

[268] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ *អ៊ឹម ចែម* កថាខណ្ឌ៩០។

[269] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ *អ៊ឹម ចែម* កថាខណ្ឌ១០១ (គូសបញ្ជាក់ក្នុងច្បាប់ដើម) *ដកស្រង់* សំណុំរឿង០០២-ឯកសារ **D97/15/9** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ១០១។

បំណងឧក្រិដ្ឋរួម ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនេះ (២) យឹម ទិត្យ ទំនងជាបានចូលរួម និងបានរួមចំណែកយ៉ាងសំខាន់ក្នុងគោលបំណងឧក្រិដ្ឋកម្មរួម និង (៣) យឹម ទិត្យ ទំនងជាមានចេតនាចូលរួមនៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួម និងមានចេតនាសម្រាប់ឧក្រិដ្ឋកម្មនីមួយៗដែលពាក់ព័ន្ធនៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួម និងបានដឹងពីប្រព័ន្ធនៃការធ្វើបាបដែលបានរៀបចំ និងចេតនាដើម្បីបន្តប្រព័ន្ធនេះ។ ទោះបីជាមានការរកឃើញយ៉ាងទូលំទូលាយដែលបង្កើតបានជាធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម ដីកាលើកលែងចោទប្រកាន់មានកំហុសដោយពុំបានរកឃើញថា យឹម ទិត្យ ទំនងជាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្រោមទម្រង់នៃការទទួលខុសត្រូវនេះ។ កំហុសអង្គច្បាប់ដោយមិនពិចារណាលើការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមនាំឲ្យអស់សុពលភាពដីកាលើកលែងចោទប្រកាន់។

### *ក) ដីកាលើកលែងចោទប្រកាន់បានរកឃើញថា បកក បានអនុវត្តគោលនយោបាយឧក្រិដ្ឋនៅទូទាំងប្រទេសកម្ពុជា*

107. គោលនយោបាយ បកក ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងការចូលរួមរបស់ពហុបុគ្គល[270]។ ដីកាលើកលែងចោទប្រកាន់បានរកឃើញថា គោលនយោបាយដូចតទៅនេះមានអត្ថិភាព។ ដំបូងប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង និងទីប្រជុំជន ទៅទីជនបទ[271]។ ប្រជាជនទាំងនេះរួមទាំងប្រជាជន និងកម្មាភិបាលនៅក្នុងភូមិភាគនិរតីដែលត្រូវបានគេបញ្ជូនទៅភូមិភាគពាយ័ព្យ ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧[272]។

108. ទីពីរ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការតាមការដ្ឋាន ព្រែក ទំនប់ ប្រឡាយ អាងទឹក និងគម្រោងដទៃទៀត[273]។ ពុំមានម្ហូបអាហារគ្រប់គ្រាន់សម្រាប់អ្នកធ្វើការ ហើយពួកគេជាច្រើនបានស្លាប់ដោយសារភាពអត់ឃ្លាន[274]។

109. ទីបី បកក បានកំណត់គោលដៅមនុស្សគ្រប់រូបដែលពួកគេចាត់ទុកថាជា ខ្មាំង[275] ដោយបានបង្កើតមន្ទីរសន្តិសុខចំនួន ១៩៦ សម្រាប់ការឃុំឃាំង និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ នៅទូទាំង

---

[270] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៥៧, ៥៨, ៦៣៩។

[271] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៥៩, ៧៦, ៨២-៨៧។

[272] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៨៦។

[273] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៥៩, ៦៦, ៧៦, ៨៤, ៦៤៤។

[274] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧។

[275] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៩១-១០០, ១២៨-១៥៧, ៦៥៤។

ប្រទេសកម្ពុជា[276]។ គោលនយោបាយនេះបានកំណត់គោលដៅចំពោះអតីតសមាជិកនៃរបប សាធារណរដ្ឋ ខ្មែរក្រោម និងប្រជាជនដែលគេសង្ស័យថាមានទំនាក់ទំនងជាមួយវៀតណាម កម្មាភិបាលពាយ័ព្យ អ្នកដែលត្រូវបានគេចាត់ទុកថាជានាយទុន សក្តិភូមិ ឬបញ្ញវ័ន្ត[277] ប្រជាជនដែលត្រូវបានគេចាត់ទុកថា មិនដើរតាមគោលនយោបាយ បកក[278] និងសូម្បីតែអ្នកដែលប្រព្រឹត្តកំហុសតិចតួច ដូចជា ធ្វើឲ្យបាក់ស្លាបព្រា ឬលួចបូតស្រូវ[279]។

110. ទីបួន ប្រជាជនត្រូវបានបង្ខំឲ្យរៀបការដោយ បកក[280]។ បុរស និងស្ត្រីដែលមានឋានៈនយោបាយដូចគ្នា ត្រូវបានបង្ខំឲ្យរៀបការ និងរួមភេទ ដើម្បីបង្កើនចំនួនប្រជាជន និងមានចំនួនកម្មករ និងប្រជាជនច្រើនជាងមុនដើម្បីការពាររបបកម្ពុជាប្រជាធិបតេយ្យ[281]។

111. ទីប្រាំ សាសនាទាំងអស់ត្រូវបានហាមឃាត់[282]។ ព្រះសង្ឃពុទ្ធសាសនាត្រូវបានចាប់ផ្សឹកដោយបង្ខំ វត្តអារាមត្រូវបានកម្ទេច ហើយព្រះវិហារត្រូវបានក្លាយជាកន្លែងឃុំឃាំង ទីតាំងសម្លាប់មនុស្ស រោងបាយ និងកន្លែងចញ្ចឹមសត្វ[283]។

112. ដីកាលើកលែងចោទប្រកាន់បានរកឃើញថា គោលនយោបាយ បកក ទាំងនេះ ត្រូវបានផ្សព្វផ្សាយដល់ប្រជាជនទូទាំងប្រទេស តាមរយៈកិច្ចប្រជុំតាមថ្នាក់នីមួយៗ[284] និងត្រូវបានអនុវត្តនៅទូទាំងប្រទេស ពីថ្នាក់លើដល់ថ្នាក់ក្រោមនៃខ្សែសង្វាក់បញ្ជារបស់ខ្មែរក្រហម[285]។ កម្មាភិបាលនៅថ្នាក់ឃុំត្រូវរាយការណ៍ទៅស្រុក ស្រុកទៅតំបន់ និងតំបន់ទៅភូមិភាគ[286]។ បន្ថែមលើនេះ មាន

---

[276] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៩៤, ១០០។

[277] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៣, ៩១, ១៣៥។

[278] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៨១, ៩៥, ៦៥៧។

[279] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៧៦, ៦៤៨។

[280] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៧៦, ៨៨-៩០, ៦៥២។

[281] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៨៨-៨៩។

[282] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៧២។ ការធ្វើទុក្ខបុកម្នេញផ្នែកសាសនាមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង004 ទេ។ ទោះជាយ៉ាងនេះក្តី ការរកឃើញរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា ឧក្រិដ្ឋកម្មទាំងនេះបានកើតឡើងក្នុងតំបន់ស្ថិតក្រោមសិទ្ធិអំណាចរបស់ យឹម ទិត្យ គឺពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។

[283] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៧២។

[284] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៤, ១០៩, ៦៤១, ៦៥៨។

[285] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១១០, ១២៦, ១២៨-១២៩, ១៤១, ១៥៨-១៦០, ៦៥៦, ៦៦៤-៦៦៥។

[286] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ១២៧។

ប្រព័ន្ធនៃការតាមដានបុគ្គលនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់[287] ដែលអនុញ្ញាតឱ្យ កម្មាភិបាលថ្នាក់លើធានាថា គោលនយោបាយត្រូវបានអនុវត្តដោយកម្មាភិបាលថ្នាក់ក្រោម[288]។

*ខ) ការរកឃើញនៅក្នុងដីកាលើកលែងចោទប្រកាន់ បង្ហាញថា យឹម ទិត្យ ទំនងបានចូលរួមក្នុង និងបានរួមចំណែកយ៉ាងសំខាន់ដល់គោលបំណងឧក្រិដ្ឋរួម*

113. ដីកាលើកលែងចោទប្រកាន់បានរកឃើញថា យឹម ទិត្យ ជាអនុលេខា និងក្រោយមកជាលេខាស្រុកគិរីវង់[289] ប្រហែលជានៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៧[290] ជាលេខាតំបន់១៣ ប្រហែលជានៅក្នុងខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧៧[291] បានធ្វើការណែនាំខ្លួនគាត់ថាជាសមាជិកគណៈតំបន់១ នៅក្នុងខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧៧[292] ត្រូវបានតែងតាំងជាផ្លូវការជាលេខាតំបន់១ ពីខែសីហា ឆ្នាំ១៩៧៨ រហូតដល់ចុងបញ្ចប់នៃរបបខ្មែរក្រហម[293] និងបានធ្វើជាសមាជិកគណៈភូមិភាគពាយ័ព្យ នៅពេលណាមួយក្នុងឆ្នាំ១៩៧៨[294]។ បន្ថែមពីលើនេះ ដីកាលើកលែងចោទប្រកាន់បានទទួលស្គាល់ ប៉ុន្តែ បានខកខានក្នុងការវាយតម្លៃសមស្របលើភស្តុតាងសាក្សីដែលថា យឹម ទិត្យ មានតួនាទីជាលេខាតំបន់១៣ ក្នុងឆ្នាំ១៩៧៨ រហូតដល់ចុងបញ្ចប់នៃរបបគ្រប់គ្រង[295] និងថា យឹម ទិត្យ ត្រូវបានចាត់ទុកថាជាលេខាភូមិភាគពាយ័ព្យ[296]។ នៅក្នុងតួនាទីផ្សេងៗទាំងនេះ យឹម ទិត្យ

---

[287] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៨០, ៦៦១។

[288] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១០៤។

[289] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៨៥, ១៨៧។

[290] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ១៨៥, ៦៦៧, ៦៨០។

[291] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៦៨, ៦៨០។ ស.ព.អ កត់សម្គាល់ថា ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានរកឃើញផងដែរថា អ៊ុម ចែម គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិកនានារបស់តំបន់ ១៣ ទោះបីជាបានសម្រេចផ្ទុយពីនេះនៅក្នុងសំណុំរឿង០០៤/១។ *សូមមើល* ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១០០។ សំណុំរឿង០០៤-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣០២។

[292] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៨៩។ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ ចែងក្នុងកថាខណ្ឌ ២៨៩ ថា "តា ទិត្យ បានណែនាំខ្លួនថា គាត់ជាគណៈតំបន់ ១" ភស្តុតាងជាមូលដ្ឋានដែលដីកានេះបានយោងមិនបានលើកឡើងអំពីចំណុចនេះទេ។

[293] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧, ១៦១, ១៦៤, ៦៦៩, ៦៨០។

[294] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧, ១៦១, ៥២៦, ៦៦៩, ៦៧៩-៦៨០។

[295] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៧៣-១៧៥, ៦៦៨។

[296] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧, ៣២៨។

បានអនុវត្តគោលបំណងរួមពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅតាមតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ ដីកាលើកលែងចោទប្រកាន់បានរកឃើញចំណុចខាងក្រោម ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ។

114. <u>ការជម្លៀសដោយបង្ខំ៖</u> មានប្រជាជនចំនួនរាប់រយគ្រួសារ រួមទាំងសមាជិកនៃអតីតរបប លន់ នល់ និងខ្មែរក្រោម ត្រូវបានបង្ខំឱ្យចាកចេញពីទីក្រុងភ្នំពេញ និងខេត្តតាកែវ ទៅរស់នៅក្នុងភូមិសំភ្លី[297]។ ប្រជាជនត្រូវបានបង្ខំឱ្យធ្វើដំណើរដោយថ្មើរជើងរាប់សិបថ្ងៃ[298] មុននឹងត្រូវបានបែងចែកជាក្រុម និងចាត់តាំងឱ្យធ្វើការ[299]។ ខ្មែរក្រោមក៏ត្រូវបានបង្ខំឱ្យចាកចេញពីកម្ពុជាក្រោមទៅរស់នៅក្នុងភូមិស្លែង[300]។

115. <u>ការធ្វើការដោយបង្ខំ៖</u> កម្មាភិបាលនៅក្នុងភូមិស្លែង បានរៀបចំកិច្ចប្រជុំដោយចាត់ចែងប្រជាជនឱ្យទៅភ្ជួរស្រែ និងស្ទូងស្រូវ[301] ប្រជាជនត្រូវបានបង្ខំឱ្យធ្វើការទាំងយប់ថ្ងៃ ដោយគ្មានការសម្រាក *ដូចជា* ការងារលើកភ្លឺស្រែ និងធ្វើជី នៅក្នុងភូមិសំភ្លី ហើយត្រូវបានកម្មាភិបាលប្រាប់ឱ្យប្តេជ្ញាផលិតស្រូវប្រាំតោនក្នុងមួយហិកតា[302] ប្រជាជនក្នុងសហករណ៍ធិបតី ត្រូវស្ទូងស្រូវ លើកភ្លឺស្រែ និងច្រូតស្រូវ ដោយមិនមានពេលសម្រាក គ្មានអាហារគ្រប់គ្រាន់ និងគ្មានថ្នាំព្យាបាល[303] ប្រជាជនរាប់ពាន់នាក់ រួមទាំងកុមារ ត្រូវធ្វើការក្រោមការគ្រប់គ្រងដោយប្រដាប់អាវុធនៅទំនប់កង្កួត ហើយអ្នកដែលត្រូវបានគេចាត់ទុកថា "ខ្ជិល" ត្រូវបានរាយការណ៍ទៅថ្នាក់លើ និងមានកម្មករជាច្រើនដែលស្លាប់ដោយសារការអត់ឃ្លាន[304] អ្នកទោសនៅមន្ទីរសន្តិសុខបាណន់ ត្រូវសែងសាកសពអ្នកទោសដែលត្រូវបានគេសម្លាប់ និងកប់សាកសពទាំងនោះ[305] អ្នកទោសនៅមន្ទីរសន្តិសុខខ្នងគូត្រូវបានបង្ខំឱ្យធ្វើការដោយមានរបបអាហារមិនគ្រប់គ្រាន់ដែលនាំឱ្យពួកគេមួយចំនួនដាច់ចិត្តហូប

---

[297] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៥៩។

[298] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៥៦។

[299] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៥៧។

[300] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៣។

[301] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៣២។

[302] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៥៧-២៥៨។

[303] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៦៩។

[304] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៨២-២៨៣, ២៨៦។

[305] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៣។

សំបកដំឡូងដែលត្រូវបានគេបោះចោល[306] អ្នកជាប់ឃុំនៅមន្ទីរ ៨ ត្រូវធ្វើការ ១១ម៉ោងក្នុងមួយថ្ងៃ ដោយមិនមានពេលសម្រាក និងពេលយប់ត្រូវបានគេដាក់ខ្នោះជើង[307] កម្មករបានស្លាប់ដោយសារភាពអត់ឃ្លាន និងកង្វះថ្នាំសង្កូវនៅមន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ និងឃុំវាំងកេសី[308] អ្នកជាប់ឃុំនៅវត្តអង្គុណ ត្រូវបានបង្ខំឲ្យជីកប្រឡាយ[309] ហើយកម្មករនៅរោងចក្រស្ករស កំពង់គល់ ពេលខ្លះត្រូវធ្វើការពេលមួយយប់ដើម្បីសម្រេចបានផែនការផលិតស្ករស បីទៅប្រាំតោន របស់ បកក[310]។

116. <u>ការកំណត់គោលដៅក្រុម និងការសម្លាប់ខ្មាំង៖</u> មានកិច្ចប្រជុំនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលមានការប្រកាសអំពីប្រភេទប្រជាជនដែលត្រូវសម្លាប់ រួមទាំងអ្នកដែលមានជាប់ទាក់ទងជាមួយរបប លន់ នល់[311] ខណៈដែលអ្នកចូលរួមប្រជុំនៅវត្តស្លែង ត្រូវបានគេប្រាប់ថា ខ្មែរក្រោមមាន "ក្បាលយួនខ្លួនខ្មែរ" ហើយត្រូវតែសម្លាប់[312]។ ការណែនាំបែបនេះត្រូវបានអនុវត្ត។ ឧទាហរណ៍ អតីតមន្ត្រីនៃរបប លន់ នល់ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់[313] មន្ទីរសន្តិសុខវត្តសម្តេច[314] មន្ទីរសន្តិសុខគាស់ក្រឡ[315] មន្ទីរសន្តិសុខបាណន់[316] និងមន្ទីរសន្តិសុខខ្នង

---

[306] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២។

[307] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៤១៣។

[308] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៨, ៤០៣។ ស.ព.អ មិនបានប្ដឹងទៅ ស.ច.ស នូវឧក្រិដ្ឋកម្មនៃពលកម្មដោយបង្ខំនៅក្នុងឃុំវាំងកេសីទេ។ ទោះជាយ៉ាងនេះក្ដី ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ថា ឧក្រិដ្ឋកម្មទាំងអស់នេះបានកើតឡើងក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ គឺពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។

[309] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២២៦។

[310] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣២៥។ ស.ព.អ មិនបានប្ដឹងទៅ ស.ច.ស អំពីឧក្រិដ្ឋកម្មនៃពលកម្មដោយបង្ខំនៅក្នុងរោងចក្រស្ករសកំពង់គល់ទេ។ ទោះជាយ៉ាងនេះក្ដី ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ថា ឧក្រិដ្ឋកម្មទាំងអស់នេះបានកើតឡើងក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ គឺពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។

[311] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២០៨។

[312] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៥។

[313] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២០៧។

[314] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៨។

[315] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៥៧។

[316] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៩៧។

គូ[317]។ ខ្មែរក្រោមត្រូវបានចាប់ខ្លួននិងឃុំនៅវត្តព្រះធាតុ[318] ត្រូវបានបាត់ខ្លួនពីវត្តអង្គសិរីមុនី[319] និងរោងចក្រស្ករស កំពង់គល់[320] និងត្រូវបានសម្លាប់នៅវត្តស្លែង[321] ទំនប់កង្ហត[322] និងមន្ទីរសន្តិសុខភូមិវាល។[323] គ្រួសារ និងកូនៗរបស់ខ្មែរក្រោម ក៏ត្រូវបានសម្លាប់នៅក្រាំងតាចាន់[324] ទួលសេះញ៉ូវ[325] វត្តអង្គសិរីមុនី[326] និងព្រៃក្របៅ[327]។ លើសពីនេះទៀត រណ្តៅសពរួមរបស់ខ្មែរក្រោមត្រូវបានរកឃើញនៅភូមិព្រាល[328] និងវត្តអង្គុណា[329]។

117. ការមកដល់ភូមិភាគពាយ័ព្យរបស់កម្មាភិបាលភូមិភាគនិរតី នាំឲ្យមានការបោសសម្អាតកម្មាភិបាលពាយ័ព្យ ពីថ្នាក់ភូមិឡើងទៅ[330]។ ឧទាហរណ៍ កម្មាភិបាលពាយ័ព្យត្រូវបានចោទសថាជាជនក្បត់ និងត្រូវបានជំនួសដោយកម្មាភិបាលនិរតី នៅមន្ទីរសន្តិសុខវត្តគិរីរម្យ[331] កម្មាភិបាលពាយ័ព្យបានបាត់ខ្លួន និងជំនួសដោយកម្មាភិបាលនិរតីនៅសហករណ៍ធិបតី[332] កម្មាភិបាលពាយ័ព្យចំនួនដ៏ច្រើនត្រូវបានចាប់ខ្លួនយកទៅ ស្ទើរតែរាងរាល់យប់ ក្រោយពីការមកដល់របស់កម្មាភិបាលនិរតីនៅទំនប់កង្ហត[333] កម្មាភិបាលពាយ័ព្យបានក្លាយជាអ្នកទោសនៅមន្ទីរសន្តិសុខខ្នងគូ[334] ហើយ

---

[317] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៩។

[318] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៩៤។

[319] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៥២។

[320] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៨-២៣៩។

[321] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៦។

[322] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៨៧។

[323] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៤២-៣៤៣។

[324] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២១២។

[325] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៥៨-៣៥៩។

[326] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៥២។

[327] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៧។

[328] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២២០-២២១។

[329] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២២៨-២២៩។

[330] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣។

[331] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨០។

[332] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៦៦។

[333] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៧៩, ២៨៣-២៨៤។

[334] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១០។

កម្មាភិបាលពាយ័ព្យទាំងអស់ត្រូវបានចាប់ខ្លួន ចង និងបណ្ដើរចេញទៅសម្លាប់នៅវត្តសម្ដេច មិនយូរប៉ុន្មានក្រោយពីការមកដល់របស់កម្មាភិបាលនិរតី[335]។

118. ការរកឃើញផ្សេងទៀតក៏បានបង្ហាញពីរបៀបដែលបុគ្គលដទៃទៀតត្រូវបានចាត់ទុកជា "ខ្មាំង"។ ឧទាហរណ៍ អ្នកដែលបានប្រព្រឹត្ត "កំហុសសីលធម៌" ឬលួចអាហារ ត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខបាណន់[336] នៅទំនប់កង្ហត កម្មករដែលឈឺញឹកញាប់ ត្រូវបានចាត់ទុកថាជាខ្មាំង អ្នកដែលត្រូវបានគេរកឃើញថាបានលួចទៅសួរសុខទុក្ខគ្រួសារ ត្រូវបានសម្លាប់ ហើយយុវជនដែលនិយាយជាមួយក្មេងស្រី ត្រូវបានសម្លាប់ដោយសារបានប្រព្រឹត្ត "កំហុសសីលធម៌"[337]។ បន្ថែមលើនេះ នរណាម្នាក់ដែលត្រូវបានចាត់ទុកថាមាន "កំហុស" នៅភូមិស្ដែង[338] ឬនៅវត្តគិរីរម្យ ត្រូវបានសម្លាប់[339]។

119. <u>ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖</u> យឹម ទិត្យ និង តា ម៉ុក បានមើលការខុសត្រូវលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកសំឡូត ដោយ យឹម ទិត្យ បានប្រាប់អ្នកដែលទើបបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ឱ្យស្រលាញ់គ្នា និងរួមរស់ជាមួយគ្នា[340]។ ប្ដីប្រពន្ធត្រូវបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ និងត្រូវបានឈ្លបតាមដាន នៅរោងចក្រស្ករស កំពង់គល់[341] ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតមានឡើងនៅឃុំរាំងកេសី[342] និងបុរសពោះម៉ាយ និងស្ត្រីមេម៉ាយ ដែល ប្រពន្ធ

---

[335] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៩។

[336] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៩៧។

[337] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៨៥, ២៨៧។

[338] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៦។

[339] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨២។

[340] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣៩។

[341] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣១។ ស.ច.ស.អ មិនបានទទួលយកថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅរោងចក្រស្ករសកំពង់គល់ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០៤ ទេ *សូមមើល* ឯកសារ **D341/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងរោងចក្រស្ករសនៅកំពង់គល់ និងសាក្សី ឡុង សុខឃី ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧។ ទោះជាយ៉ាងនេះក្តី ការរកឃើញរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា ឧក្រិដ្ឋកម្មទាំងអស់នេះបានកើតឡើងក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ គឺពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។

[342] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៤០៧។

ឬប្តីជាខ្មែរក្រោមត្រូវបានគេសម្លាប់ ត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាថ្មី នៅទួលសេះញ៉ូវ[343] និងព្រៃក្របៅ[344]។

120. <u>ការហាមឃាត់សាសនា៖</u>[345] ព្រះសង្ឃត្រូវបានបង្ខំឲ្យចាកចេញពីវត្តអារាម ទៅវត្តព្រៃល និងត្រូវបានផ្សឹក[346]។ បន្ទាប់មកទៀត ព្រះសង្ឃក្មេងៗត្រូវបានគេឲ្យទៅធ្វើទ័ព ហើយចៅអធិការត្រូវបញ្ជូនទៅគោកព្រិច[347]។ លើសពីនេះទៀត វត្តអារាមត្រូវបានប្រមាថតាមរយៈការប្រើប្រាស់ជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដែលរួមមាន មន្ទីរសន្តិសុខវត្តព្រះធាតុ ទីតាំងសម្លាប់មនុស្សវត្តអង្គុណ ទីតាំងសម្លាប់មនុស្សវត្តអង្គសិរីមុនី មន្ទីរសន្តិសុខគាស់ក្រឡ មន្ទីរសន្តិសុខធិបតី ទីតាំងសម្លាប់មនុស្សវត្តចាន់រង្សី មន្ទីរសន្តិសុខវត្តគិរីរម្យ មន្ទីរសន្តិសុខវត្តសម្តេច មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ និងវត្តវាំងកេសី។

*គ) ការរកឃើញនានារបស់ដីកាសម្រេចលើកលែងចោទប្រកាន់បង្ហាញពីលទ្ធភាពដែលថា យឹម ទិត្យ មានចេតនាចូលរួមចំណែកយ៉ាងសំខាន់ក្នុងផែនការឧក្រិដ្ឋរួម មានចេតនាឲ្យមានឧក្រិដ្ឋកម្ម និងបានដឹងអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ*

121. យឹម ទិត្យ បានប្រាប់ប្រធានភូមិ ឃុំ និងស្រុកអំពីការវាយប្រហារដោយ "ខ្មាំងបង្កប់" នៅក្នុងអង្គប្រជុំមួយនៅទំនប់កង្ហត[348] បានប្រាប់កម្មាភិបាលក្នុងភូមិភាគពាយ័ព្យឲ្យស្វែងរក "ខ្មាំងយួន" ឬអ្នកទាំងឡាយណាដែលបានចូលរួមជាមួយវៀតណាម ដែលជាលទ្ធផល នាំឲ្យអ្នកដែលនិយាយភាសាវៀតណាម ឬមានគ្រួសារជាជនជាតិវៀតណាមត្រូវបានចាប់ខ្លួន និងសម្លាប់ចោល[349] បាននិយាយនៅក្នុងការប្រជុំមួយក្នុងខេត្តបាត់ដំបងថា កម្មាភិបាលភូមិភាគនិរតីបានមកការពាររោង

---

[343] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦២។ ស.ព.អ មិនបានប្តឹងទៅ ស.ច.ស អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទួលសេះញ៉ូវទេ។ ទោះជាយ៉ាងនេះក្តី ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ថា ឧក្រិដ្ឋកម្មទាំងអស់នេះបានកើតឡើងក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ គឺពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។

[344] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៩។

[345] ការធ្វើទុក្ខបុកម្នេញផ្នែកសាសនាមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿប្រឆាំងនឹង យឹម ទិត្យ ទេ។ ទោះជាយ៉ាងនេះក្តី ការរកឃើញរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលថា ឧក្រិដ្ឋកម្មទាំអអស់នេះបានកើតមានឡើងក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ គឺពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។

[346] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២១៨។

[347] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២១៨។

[348] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៨៩។

[349] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៣។

ចក្រស្តរសកំពង់គល់ពីយួន[350] បានប្រាប់ប្រជាជនដែលត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ក្នុងស្រុកសំឡូតឲ្យខិតខំធ្វើការដើម្បីបង្កើនផលិតផលកសិកម្ម[351] និងបានប្រាប់អ្នកនៅទំនប់កង្ហតឲ្យបន្តប្រឹងប្រែងធ្វើការក្នុងការកសាងទំនប់ និងការដាំដុះស្រូវ និងដើម្បីការពារកុំឲ្យខ្មាំងវាយប្រហារ *ស្ហម្បីតែ* នៅពេលដែលរបបនោះជិតដួលរលំទៅហើយ[352]។

122. ជាងនេះទៀត ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា បុគ្គលិកវត្តប្រធាតុ ត្រូវរាយការណ៍ទៅកាន់គណៈស្រុកគិរីវង់ (ដែលជា យឹម ទិត្យ[353]) មុនពេលចេញបញ្ជាឲ្យចាប់ខ្លួន និងឃុំខ្លួន[354] អាជ្ញាធរស្រុកគិរីវង់នឹងបញ្ជូនបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួន និងដែលត្រូវបញ្ជូនទៅកាន់វត្តប្រធាតុមកឲ្យថ្នាក់ឃុំ[355] ហើយបានស្នើសុំជំនួយពីថ្នាក់ស្រុកគិរីវង់ នៅពេលដែលមានចំនួនមនុស្សច្រើនត្រូវសម្លាប់[356]។ ស្រដៀងគ្នានេះដែរ របាយការណ៍អំពីការចាប់ខ្លួនត្រូវបញ្ជូនពីស្រុកត្រាំកក់ទៅកាន់គណៈតំបន់ ១៣ (នៅពេលដែល យឹម ទិត្យ ជាលេខាតំបន់ ១៣[357]) ដែលបន្ទាប់មកបានបញ្ជូនសេចក្តីណែនាំបន្តទៅកាន់មន្ទីរសន្តិសុខក្រាំងតាចាន់[358] ហើយមន្ត្រីគុកក្រាំងតាចាន់ ជាញឹកញាប់ រាយការណ៍ទៅកាន់តំបន់ ១៣ ឬ អង្គការ អំពីអ្នកទាំងឡាយណាដែលត្រូវបានកម្ទេច[359]។

123. សហឧក្រិដ្ឋកម្មរួមគឺជាមធ្យោបាយស្នូលនៃការទទួលខុសត្រូវជាបុគ្គលនៅ អ.វ.ត.ក[360] ហើយអតីត ស.ព.អ បានធ្វើការសន្និដ្ឋានយ៉ាងទូលំទូលាយអំពីការទទួលខុសត្រូវរបស់ យឹម ទិត្យ

---

[350] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣២។

[351] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣៩។

[352] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៩១។

[353] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៨៥។

[354] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៩២។

[355] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៩៥។

[356] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៩៨។

[357] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៦៨។

[358] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២១៣។

[359] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២១១។

[360] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥១៤-៥១៧។ សំណុំរឿង០០២-ឯកសារ **E313** សំណារឿង០០២/០១ កថាខណ្ឌ ៨៦១-៨៧៧, ៩៦០-៩៩៦។ សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១១៦-៤១៧៥, ៤២៥៥-៤៣០៧។

អនុលោមតាមសហឧក្រិដ្ឋកម្មរួមនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់[361]។ ទោះជាយ៉ាងនេះក្ដី ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបាន សូម្បីតែពិចារណាអំពីលទ្ធភាពនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ក្រោមសហឧក្រិដ្ឋកម្មរួម ទោះបីជាការរកឃើញជាច្រើនបង្ហាញឱ្យឃើញថា ធាតុផ្សំរបស់សហឧក្រិដ្ឋកម្មរួមត្រូវបានបង្ហាញ។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទប្រកាន់ផ្អែកលើរចនាសម្ព័ន្ធឋានានុក្រមរបស់ ប.ក.ក និងរបៀបដែលគោលនយោបាយត្រូវបានផ្សព្វផ្សាយ និងអនុវត្តយ៉ាងស៊ីចង្វាក់ ដើម្បីដោះឱ្យ យឹម ទិត្យ រួចផុតពីការទទួលខុសត្រូវទាំងខុសឆ្គង តាមរយៈការលើកឡើងថា យឹម ទិត្យ មិនមានជម្រើសណាក្រៅពីទទួលយកការណែនាំ និងការអនុវត្តគោលនយោបាយទាំងនោះ[362]។ កំហុសអង្គច្បាប់នេះបាននាំឱ្យ ដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្ដីសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតនៅក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។

124. សរុបមក កំហុសអង្គច្បាប់របស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលផ្ដោតទាំងស្រុងតែទៅលើការចូលរួមប្រព្រឹត្តដោយផ្ទាល់ និងភាពកៀកកិតទៅនឹងឧក្រិដ្ឋកម្ម ហើយបដិសេធដោយចេតនាមិនពិចារណាអំពីសហឧក្រិដ្ឋកម្មរួម (និងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត) បានធ្វើឱ្យសេចក្ដីសម្រេចរបស់ខ្លួនគ្មានសុពលភាព និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្ដីសន្និដ្ឋានអំពីយុត្តាធិការបុគ្គល។

## ខ. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុស ដោយបានការធ្វើការសន្និដ្ឋានផ្នែកអង្គហេតុដែលនាំឱ្យមានការខុសឆ្គងរបស់តុលាការ

125. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុជាច្រើន ដែលកំហុសតែមួយ ឬរួមបញ្ចូលគ្នា បង្កើតបានជាការខុសឆ្គងរបស់តុលាការ និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃយុត្តាធិការបុគ្គល។

### ១. ការរកឃើញថា មានតែគណៈកម្មាធិការ ប.ក.ក មួយចំនួនប៉ុណ្ណោះ មានសិទ្ធិអំណាចធ្វើការសម្រេចចិត្តអំពីការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

*ក) សេចក្ដីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦*

[361] ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១០៩២-១១១៨។

[362] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៨០, ៦៨៣។

126. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសផ្នែកអង្គហេតុ តាមរយៈការសន្និដ្ឋានថា មានមនុស្សប្រហែល ១៣រូប បានធ្វើការសម្រេចទាំងអស់អំពីអ្នកដែលត្រូវសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ក្នុងរយៈពេលស្ទើរតែបួនឆ្នាំនេះ[363]។ ដីកាសម្រេចលើកលែងចោទប្រកាន់បានពឹងផ្អែកខ្លាំងលើអង្គហេតុដែលថា យឹម ទិត្យ "មិនមែនស្ថិតក្នុងចំណោមបុគ្គលជាង ១៣ រូប ដែលមានសិទ្ធិកម្ទេច រួមមាន លេខាភូមិភាគ ដូចជា តា ម៉ុក តាមសេចក្តីសម្រេច [គណៈកម្មាធិការមជ្ឈិម] ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ឡើយ" ដើម្បីដកគាត់ចេញពីយុត្តាធិការរបស់ អ.វ.ត.ក[364]។ ការពឹងផ្អែកលើកំហុសអង្គហេតុនេះបានធ្វើឲ្យមានការខុសឆ្គោយរបស់តុលាការ។

127. ដីកាសម្រេចលើកលែងចោទប្រកាន់ផ្អែកការសន្និដ្ឋានអង្គហេតុខុសនេះលើពាក្យពេចន៍នៃសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ និងផ្នែកមួយនៃសក្ខីកម្មរបស់ឌុច។ ដីកាសម្រេចលើកលែងចោទប្រកាន់បានលើកឡើងថា៖

> តាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្សនៅឆ្នាំ ១៩៧៦ គោលនយោបាយបោសសម្អាតត្រូវបានដាក់ចេញ ដែលពាក់ព័ន្ធសិទ្ធិសម្រេចកម្ទេចក្នុង និងក្រៅបក្ស ដោយបានចែងយ៉ាងជាក់លាក់ថា "*បើនៅក្នុងក្របខណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមជ្ឈិមសម្រេច តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច*"។ ទន្ទឹមនឹងនោះដែរ អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច កន្លងមកបានបកស្រាយទាក់ទិននឹងសេចក្តីសម្រេចនាឆ្នាំ១៩៧៦ នេះដែរថា "*អ្នកដែលមានសិទ្ធិនៅមូលដ្ឋានមិនមែនអចិន្ត្រៃយ៍ភាគទាំងមូលនោះទេ ... លេខាភាគមានសិទ្ធិសម្រេចកម្ទេចអ្នកណាត្រូវកម្ទេចអ្នកនោះ លេខាភូមិភាគទុកឲ្យអ្នកណារស់គឺ អ្នកនោះរស់ ដូច្នេះអំណាចនៅលើលេខាភាគ*"[365]។

128. ការលើកឡើងរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា "បុគ្គលជាង ១៣រូប ដែលមានសិទ្ធិកម្ទេច រួមមានលេខាភូមិភាគ ដូចជា តា ម៉ុក តាមរយៈសេចក្តីសម្រេចថ្ងៃទី ៣០ ខែមីនា

---

[363] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧១។

[364] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧១។

[365] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៩២ (គូសបញ្ជាក់ក្នុងច្បាប់ដើម)។ "មនុស្សជាង ១៣នាក់" ដែលដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានខុសដែលមានសិទ្ធិអំណាចបញ្ជាឲ្យសម្លាប់មនុស្សនោះ គឺជាលេខាភូមិភាគ គណៈអចិន្ត្រៃយ៍ និងអាចជាសេនាធិការ។

ឆ្នាំ១៩៧៦”[366] ផ្អែកទាំងស្រុងទៅលើតែការបកស្រាយរបស់ ឌុច អំពីសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដើម្បីសន្និដ្ឋានថា ពាក់ព័ន្ធទៅនឹង “ថ្នាក់មូលដ្ឋាន” សិទ្ធិអំណាចទាំងអស់ក្នុងការបញ្ជាឲ្យសម្លាប់គឺស្ថិតនៅលើលេខាភូមិភាគ (ដោយមន្ត្រីដែលបានកំណត់ឈ្មោះផ្សេងទៀត មានសិទ្ធិអំណាចចេញបញ្ជាឲ្យសម្លាប់ក្នុងមជ្ឈិមបក្ស តំបន់ឯករាជ្យ ឬនៅក្នុងកងកម្លាំងប្រដាប់អាវុធ)។

129. ភាសាធម្មតានៃសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ផ្ទុយទៅនឹងការបកស្រាយនេះ ដោយសេចក្តីសម្រេចនេះលើកឡើងថា សិទ្ធិកម្ទេចមនុស្សនៅមូលដ្ឋានជារបស់ “គណៈកម្មាធិការអចិន្ត្រៃយ៍ភាគ” [367] (ឬ “សមាជិកអចិន្ត្រៃយ៍ភាគ” ដូចដែលត្រូវបានបកប្រែនៅក្នុងដីកាស្រេចលើកលែងចោទប្រកាន់)។ ចំណុចនេះអាចបញ្ចូល យឹម ទិត្យ យ៉ាងហោចណាស់ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៨ នៅកំឡុងពេលនៃការចាប់ខ្លួន តា ប៉ែត និង រស់ ញឹម នៅពេលដែល យឹម ទិត្យ បានក្លាយជាអនុលេខាភូមិភាគពាយ័ព្យ[368] (ឬ សូម្បីតែនៅក្នុងការរកឃើញមិនត្រឹមត្រូវរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ[369])។

130. ការបកស្រាយរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ផ្ទុយទៅនឹងការវិភាគពីមុនៗអំពីអនុភាពនៃឯកសារនេះ។ ដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ បានទទួលស្គាល់ពាក្យពេចន៍នៃសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នេះ ប៉ុន្តែក្រោយមកបានសន្និដ្ឋានថា៖

> ក្នុងការអនុវត្ត មានការលេចឡើងដែលថាតំបន់ចេញសេចក្តីសម្រេច “កម្ទេច” ឬត្រួតពិនិត្យសេចក្តីសម្រេចកម្ទេចនៅតាមថ្នាក់ស្រុក។ នៅកន្លែងផ្សេងទៀត ស្រុកហាក់បីដូចជាធ្វើការសម្រេចបៀបនេះ ដោយកម្មាភិបាលរបស់ខ្លួនដោយផ្ទាល់។ ម្យ៉ាងវិញទៀត គណៈមជ្ឈិម យ៉ាងហោចណាស់បានផ្ទេរអំណាចនេះទៅសហករណ៍មួយ ចំនួន។ ការដែលថាសហករណ៍មួយចំនួនមានអំណាច “កម្ទេច” ត្រូវបានបង្ហាញ ភស្តុតាងដោយសក្ខីកម្មរបស់សាក្សីនានា របាយការណ៍សារព័ត៌មានផ្លូវការ និងសារទូរលេខ។ បន្ថែមពី

[366] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧១។

[367] ឯកសារ **D1.3.19.1** សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ERN 00003136។

[368] *សូមមើលយោងខាងក្រោម* ផ្នែក IV(ង)(៣)។

[369] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៦៦, ៦៨០។

នេះទៀត កម្មាភិបាលនៅតាមសហករណ៍មួយចំនួនបានបញ្ជូនអ្នក ទោសទៅមន្ទីរសន្តិសុខថ្នាក់ស្រុកដើម្បីសម្លាប់ ដូចជាករណីនៅក្នុងស្រុកត្រាំកក់ ជាឧទាហរណ៍[370]។

131. ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានពន្យល់អំពីមូលដ្ឋានដែលខ្លួនបានបោះបង់ចោលការវិភាគដ៏មានអត្ថន័យល្អិតល្អន់ និងប្រុងប្រយ័ត្នពីមុនអំពីអនុភាពនៃសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដើម្បីទទួលយកការបកស្រាយរបស់ ឌុច នោះទេ។ ខណៈដែល ឌុច គឺជាអ្នកសង្កេតដ៏យកចិត្តទុកដាក់លើការងាររបស់ ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យនោះ គាត់បានទទួលស្គាល់ថា គាត់មិនដែលបានឃើញសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នេះទេ រហូតទាល់តែគាត់បានចូលមើលតាមរយៈសំណុំរឿង អ.វ.ត.ក ក្រោយពេលការចាប់ខ្លួនគាត់[371]។ បន្ថែមពីលើនេះ ឌុច មិនធ្លាប់បម្រើការនៅថ្នាក់ "មូលដ្ឋាន" ទេ ហើយដូច្នេះ មិនមានចំណេះដឹងផ្ទាល់អំពីរបៀបដែលសេចក្តីសម្រេចកម្ទេចត្រូវបានធ្វើឡើងនៅទីនោះទេ។

132. លើសពីនេះទៀត បញ្ហាសាមញ្ញៗនៃភាពជាក់ស្តែង និងបញ្ហាភស្តុភារ អាចធ្វើឲ្យមិនអាចទៅរួចសម្រាប់មនុស្សតែម្នាក់ ជា លេខានៃភូមិភាគមួយ ក្នុងការមានសិទ្ធិអំណាចសម្រេចយ៉ាងជាក់លាក់ថាតើអ្នកណាគួរត្រូវសម្លាប់ និងអ្នកណាគួរទុកនៅក្នុងដែនដីទាំងមូលរបស់ភូមិភាគមួយ។ ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា មានជនរងគ្រោះជាង ២៥.០០០ នាក់ ត្រូវបានសម្លាប់ដោយចេតនា នៅក្នុងទីតាំងឧក្រិដ្ឋកម្មស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០៤ តែប៉ុណ្ណោះ[372] ហើយមនុស្សជាង ៥០.០០០ នាក់ ត្រូវបានសម្លាប់ ប្រសិនបើទីតាំងឧក្រិដ្ឋកម្មដែលត្រូវបាន

---

[370] សំណុំរឿង០០២- ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៨៦ (យោងខាងក្នុងត្រូវបានលុប)។

[371] ឯកសារ **D118/103.3** សេចក្តីសន្និដ្ឋានស្តាពរជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ កថាខណ្ឌ ៣៥ ["ឯកសារ ថ្ងៃ ៣០.៣.៧៦ ខ្ញុំទើបតែឃើញនៅ អវតក នេះ។"]។

[372] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ១៩៩ [៥០០០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តព្រះធាតុ] ២១២ [១២៧ នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់] ២២០ [១០០០ នាក់ត្រូវបានសម្លាប់នៅទីតាំងសម្លាប់មនុស្សភូមិព្រាល] ២៥៣ [៤០០០ នាក់ ទីតាំងសម្លាប់មនុស្សត្រូវបានសម្លាប់នៅព្រៃសុខុន] ២៦១ [២០០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខកាស់ក្រឡ] ២៧៣ [១០០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខធិបតី] ២៨៧ [៧៣០ នាក់ត្រូវបានសម្លាប់នៅការដ្ឋានទំនប់កង្ហត] ៣២៨-៣២៩ [៣០ នាក់ត្រូវបានសម្លាប់នៅរោចក្រស្គរសកំពង់គុល] ៣១៤-៣១៥ [៩០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខខ្នងគូ] ៣៥៩-៣៦០ [៣០០០ ទៅ ៤០០០ នាក់ត្រូវបានសម្លាប់នៅទីតាំងសម្លាប់មនុស្សទួលសេះញ៉ៀវ] ៣៦៧ និង ៣៦៩ [២២០០ នាក់ត្រូវបានសម្លាប់នៅទីតាំងសម្លាប់មនុស្សព្រៃក្របៅ] ៣៧៥ [៣០០ នាក់ត្រូវបានសម្លាប់នៅទីតាំងសម្លាប់មនុស្សវត្តចាន់វាំងស្សី] ៣៨៣ [២០០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តគិរីរម្យ] ៣៨៩ [១០០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តសម្តេច] ៤០០ [៥០០០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តកាច់រទេះ] ៤០៨ [១ នាក់ត្រូវបានសម្លាប់នៅឃុំវាំងកេសី] ៤១៦ [២០០០ នាក់ត្រូវបានសម្លាប់នៅគុកលេខ ៨] ៤២១ [២០០០ នាក់ត្រូវបានសម្លាប់នៅទីតាំងសម្លាប់

ដកចេញត្រូវបានរាប់បញ្ចូលក្នុងចំនួនសរុប[373]។ ទស្សនៈដែលថា តា ម៉ុក និង រស់ ញឹម បានដឹងអំពីករណីពាក់ព័ន្ធទៅនឹងបុគ្គលនីមួយៗទាំងនេះ ហើយក្រោយមកបានសម្រេចលើមូលដ្ឋានជាបុគ្គល ថាតើម្នាក់ៗគួរត្រូវសម្លាប់ឬយ៉ាងណានោះ ពិតជាមិនសមហេតុផលទាល់តែសោះ។ ចំណុចនេះពិតជាពិសេសចំពោះ តា ម៉ុក ដែលដូចដែលដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញ ចុងក្រោយបានទៅគ្រប់គ្រងបី ឬបួន ភូមិភាគ ខណៈដែលកំពុងបម្រើការនៅគណៈអចិន្ត្រៃយ៍ផងនោះ[374]។ ការរកឃើញរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា លេខាភូមិភាគគឺជាអ្នកធ្វើការសម្រេចតែម្នាក់គត់ ពិតជាបង្កប់ន័យថា តា ម៉ុក បានធ្វើការសម្រេច *ទាំងអស់* អំពីអ្នកដែលត្រូវសម្លាប់នៅក្នុងតំបន់ដែលលាតសន្ធឹងពាក់កណ្ដាលនៃប្រទេសកម្ពុជា។ ដោយសារតែទំហំនៃការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មាននរណាម្នាក់ធ្វើការតែឯងអាចធ្វើរឿងនេះបានឡើយ សូម្បីតែគាត់មិនមានការទទួលខុសត្រូវណាផ្សេងទៀតក៏ដោយ។ តាមរយៈទស្សនៈតក្កវិជ្ជា វាច្បាស់ណាស់ ហើយភ័ស្តុតាងក៏បង្ហាញដែរ[375] ថា មេដឹកនាំភូមិភាគ បញ្ជូន

---

មនុស្សវាលបាក់ជញ្ជីង]។ ចំនួនជនរងគ្រោះដ៏ច្រើននេះមិនរួមបញ្ចូលការរកឃើញដែលមិនអាចកម្រិតចំនួនបានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់អំពីជនរងគ្រោះដែលត្រូវបានសម្លាប់ "ជាច្រើន" នៅតាមទីតាំងសម្លាប់មនុស្សនានា៖ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៥ ["ខ្មែរក្រហមដឹកប្រជាជនខ្មែរក្រោមជាច្រើនរទេះសេះ [...] យកទៅសម្លាប់ក្នុងព្រៃក្នុងភូមិស្លែង"] ៣០២ ["មានប្រជាជនជាច្រើននាក់ត្រូវបាន [...] សម្លាប់ចោលនៅមន្ទីរសន្តិសុខបាណន់។"]។

[373] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៥៨៩-៥៩០, ៦៨០។ ទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានដកចេញសុទ្ធតែស្ថិតនៅក្នុងភូមិភាគពាយ័ព្យ និងនិរតីទាំងអស់ ដែលមានន័យថា នៅក្នុងការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ មានតែ តា ម៉ុក និង រស់ ញឹម គឺជាមនុស្សមានអំណាចបញ្ជាឲ្យមានការសម្លាប់ណាមួយក្នុងចំណោមការសម្លាប់ទាំងអស់នេះ។

[374] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៥, ១៦៨, ១៣២, ១៣៧។

[375] *សូមមើលឧទាហរណ៍* ឯកសារ **D219/120** កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ យុត ឆ.១៩, ២៨, ២៩ [នៅក្នុងភូមិភាគកណ្ដាល សាក្សីគឺជាលេខាស្រុក ដែលបានទទួលបញ្ជាពីលេខាតំបន់របស់គាត់ឲ្យកំណត់អត្តសញ្ញាណ ចាប់ខ្លួន និងកម្ទេចប្រភេទខ្មាំងជាក់លាក់។ សាក្សីបានបញ្ជាមេឃុំរបស់គាត់ឲ្យ "កំណត់ទៅតាមកម្រិតធ្ងន់ធ្ងរ" របស់ខ្មាំងទាំងនោះ។ បន្ទាប់មក សាក្សី "ពិនិត្យពិចារណាលើករណីនីមួយៗ [...] ថាតើអ្នកណាអាចទុកបាន អ្នកណាទុកមិនបាន"។ ឯកសារ **D6.1.796** កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ERN 00410186-87 [អំពីឯកសារ **D219/702.1.40** លិខិតកម្ពុជាប្រជាធិបតេយ្យពីកម្មាភិបាលម្នាក់ ដែលជាអនុលេខាភូមិភាគ និងលេខាតំបន់ ដែលជូនដំណឹងដល់អង្គការអំពីអ្នកដែលត្រូវបញ្ជូនទៅអង្គការ។ ឌុចបានសង្កេតមើលចំណារលើលិខិតនោះ "ស-២១ហើយ""]។ នៅទំនប់កង្ហត ស.ព.អ សន្និដ្ឋានថា មិនមានលទ្ធភាពសមហេតុផលដែលថា ក្នុងពេលរវាង យឹម ទិត្យ កំពុងពិនិត្យមើលទីតាំងនោះ និងពេលដែលកម្មករបាត់ខ្លួន ឬត្រូវបានសម្លាប់ភ្លាមៗបន្ទាប់ពីការត្រួតពិនិត្យ យឹម ទិត្យ ផ្សព្វផ្សាយព័ត៏មានទាក់ទងនឹងកម្មករ "ខ្ជិល" ទៅកាន់ តា ម៉ុក ហើយ តា ម៉ុក ធ្វើការសម្រេចជាលក្ខណៈបុគ្គលលើជោគវាសនារបស់កម្មករម្នាក់ៗ ហើយទំនាក់ទំនងត្រឡប់មកកាន់ យឹម ទិត្យ វិញ ដែលបន្ទាប់មកបញ្ជូនវាបន្តទៅកាន់កម្មាភិបាលពាក់ព័ន្ធនៅទំនប់នោះទេ។ ការណ៍នេះ ពិតជាមិនអាចធ្វើបានទេ ប្រសិនបើ តា ម៉ុក នៅកន្លែងណាមួយលើកលែងនៅក្នុងភូមិភាគពាយ័ព្យនៅពេលវេលាពាក់ព័ន្ធនោះ។ *សូមមើល* ឯកសារ **D219/46** កំណត់ហេតុស្ដាប់ចម្លើយ សោម

*គោលនយោបាយ* ទាក់ទងនឹងប្រភេទខ្មាំងដែលត្រូវកម្ទេច ទៅកាន់មេដឹកនាំថ្នាក់តំបន់ ដែលបន្ទាប់មកជាញឹកញាប់បញ្ជូនគោលការណ៍ណែនាំគោលនយោបាយទាំងនោះចុះមកក្រោមបន្តទៀត និងថា សេចក្តីសម្រេចជាក់ស្តែងជាច្រើនអំពីអ្នកដែលត្រូវសម្លាប់ត្រូវបានធ្វើឡើងដោយកម្មាភិបាលថ្នាក់ទាបល្មម អនុលោមសិទ្ធិអំណាចដែលបានប្រគល់ជូន។

133. ប្រហែលការពន្យល់ល្អបំផុតអំពីអង្គហេតុដែលថា សិទ្ធិកម្ទេចមិនត្រូវបានកំណត់ត្រឹមលេខាភូមិភាគនោះ គឺភស្តុតាងដ៏សំខាន់អំពីកម្មាភិបាលដែលមានឋានៈនៅក្នុងឋានានុក្រម *ទាប* ជាង យឹម ទិត្យ ដែលបានអនុវត្តឆន្ទានុសិទ្ធិទាក់ទងនឹងអ្នកដែលត្រូវសម្លាប់។ ភស្តុតាងនេះបញ្ជាក់ច្បាស់ថា សូម្បីតែកម្មាភិបាលនៅថ្នាក់ភូមិ សហករណ៍ ឃុំ ឬកងចល័ត មានសិទ្ធិអំណាចសម្រេចថា មនុស្សណាត្រូវស្ថិតនៅក្នុងប្រភេទខ្មាំង ដែលត្រូវបានកំណត់ដោយថ្នាក់ដឹកនាំ និងហេតុដូច្នេះ ត្រូវសម្លាប់ចោល[376]។ គួរឲ្យភ្ញាក់ផ្អើល ស.ច.ស បានសន្និដ្ឋានយ៉ាងច្បាស់នៅក្នុងដីកាដំណោះស្រាយសំណុំ

---

វណ្ណា ឆ.៤១, ៤៤ ["បើឃើញមុខ តា ទិត្យ នៅពេលថ្ងៃ យប់ឡើងគឺនឹងមានបាត់ខ្លួនមនុស្សហើយ។ [...] បើឃើញ តា ទិត្យ មកគឺដឹងតែបាត់មនុស្សហើយ។"]។ ឯកសារ **D219/797** កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.២១៨-២១៩។ សំណុំរឿងមានភស្តុតាងបន្ថែមទៀតជាច្រើនអំពី យឹម ទិត្យ ចេញបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ចោល។ ខណៈដែលភស្តុតាងនេះមិនជាចាំបាច់រារាំងដល់លទ្ធភាពដែលថា ការផ្តល់បញ្ជាណាមួយដែលមានប្រភពចេញមកពីថ្នាក់លើ បរិមាណនៃបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ទាំងនោះ បង្ហាញអំពីភាពមិនដំណើរការនៃប្រព័ន្ធមួយដែលក្នុងនោះកម្មាភិបាលថ្នាក់កណ្តាល និងថ្នាក់ទាបមិនមានអំណាចធ្វើការសម្រេចដោយខ្លួនឯងនៅក្នុងទម្រង់គោលនយោបាយដ៏ទូលំទូលាយ ដែលកំណត់ដោយមជ្ឈិមបក្ស។ *សូមមើលឧទាហរណ៍* ឯកសារ **D34.1.10** បទសម្ភាសន៍ ហេង ទារ *ហៅ* ប៉ែត ដោយ ស្ទីវ ហេឌើ ERN 00964055-56 (*សូមមើលផងដែរ* ឯកសារ **D1.3.11.15** បទសម្ភាសន៍ ហេង ទារ *ហៅ* ប៉ែត ដោយ ស្ទីវ ហេឌើ ERN 00388312)។ ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេន ឆ.១៩០-១៩១។ ឯកសារ **D219/85** កំណត់ហេតុស្តាប់ចម្លើយ វី ផាន់ ឆ.៣, ៥។ ឯកសារ **D118/209** កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ុល) ហឿន ឆ.១៣៩, ១៤១, ១៤៣, ១៤៥-១៤៦។ ឯកសារ **D219/533** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០៤, ១០៨។ ឯកសារ **D118/86** កំណត់ហេតុស្តាប់ចម្លើយ ញឹក លី ឆ.៥។ ឯកសារ **D219/19** កំណត់ហេតុស្តាប់ចម្លើយ សាន់ ឡូន ឆ.៨៧៣។ ឯកសារ **D219/34** កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ុល) ហឿន ឆ.៣៣។ ឯកសារ **D6.1.1105** Ben Kiernan, *របប ប៉ុល ពត* ERN 00637644-45 (*សូមមើលផងដែរ* ឯកសារ **D219/726.1.1** កំណត់សម្គាល់បទសម្ភាសន៍ Ben Kiernan ជាមួយ ង៉ោល ERN 01339959, 61-62)។ *សូមមើលផងដែរ* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤១៩, ៤២០ iii, ៤២១។

[376] *សូមមើលឧទាហរណ៍* ឯកសារ **D118/245** កំណត់ហេតុស្តាប់ចម្លើយ ជួន ថន ឆ.១៧ [ទាក់ទងនឹងសាក្សីដែលជាកម្មាភិបាលថ្នាក់ទាប ទទួលបន្ទុកកងចល័តតូចមួយ]។ ឯកសារ **D219/85** កំណត់ហេតុស្តាប់ចម្លើយ វី ផាន់ ឆ.៧ [អំពីភូមិ និងប្រធានកង]។ ឯកសារ **D118/96** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ឆ.៣៥ [ទាក់ទងនឹងសាក្សីដែលជាសមាជិកគណៈសហករណ៍]។ *សូមមើលផងដែរ* ឯកសារ **D219/982** កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៨ [ទាក់ទងនឹងមេបញ្ជាការយោធាក្នុងស្រុកមួយ]។ ឯកសារ **D118/243** កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.១៤-១៥ [ទាក់ទងនឹង

រឿង ០០៤/១ ថា អ៊ឹម ចែម ដែលបានប្រតិបត្តិសិទ្ធិអំណាចនៅថ្នាក់ស្រុក និងថ្នាក់តំបន់ បានបញ្ជាឱ្យសម្លាប់មនុស្ស[377]។ ដីកាសម្រេចលើកលែងចោទប្រកាន់នេះមិនមានការពន្យល់ណាទាល់តែសោះអំពីមូលហេតុដែលខ្លួនជំទាស់ទៅនឹងការសម្រេចពីមុននេះ។

134. ការបកស្រាយមិនសមហេតុផលរបស់ដីកាសម្រេចលើកលែងចោទប្រកាន់អំពីសេចក្ដីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ផ្ទុយពីការពិត ឯកសារ និងការវិភាគពីមុនផ្ទាល់របស់ដីកាសម្រេចលើកលែងចោទប្រកាន់។ ការសន្និដ្ឋានដែលថា មានតែលេខាភូមិភាគមានសិទ្ធិអំណាចសម្រេចថាតើអ្នកណាត្រូវកម្ទេចនៅថ្នាក់មូលដ្ឋាន គឺជាកំហុសអង្គហេតុដែលបណ្ដាលឱ្យមានការខុសឆ្គងរបស់តុលាការ។

135. សូម្បីតែសន្មត *ជាទឡ្ហីករណ៍* ថា មានតែលេខាភូមិភាគមានសិទ្ធិអំណាចសម្រេចថានរណាត្រូវកម្ទេចក៏ដោយ ក៏ភ័ស្តុតាងបង្ហាញថា តា ម៉ុក បានផ្ទេរអំណាចរបស់គាត់ក្នុងនាមជាលេខាភូមិភាគពាយ័ព្យមកឱ្យ យឹម ទិត្យ ដែលនៅតែដាក់ យឹម ទិត្យ ស្ថិតក្នុងក្រុមដែលមានអំណាចកម្ទេច។ តា ម៉ុក មានការទទួលខុសត្រូវច្រើននៅខាងក្រៅភូមិភាគពាយ័ព្យ ដែលជាចាំបាច់តម្រូវឱ្យគាត់អវត្តមានជាញឹកញាប់ពីតំបន់។ ចំណុចអស់ទាំងនេះរួមបញ្ចូលទាំងការដឹកនាំកម្លាំងប្រយុទ្ធប្រឆាំងនឹងវៀតណាម និងការធ្វើជាគណៈកម្មាធិការភូមិភាគផ្សេងទៀត និងគណៈកម្មាធិការអចិន្ត្រៃយ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[378]។ មិនចម្លែកទេ ចំណុចនេះតម្រូវឱ្យគាត់ផ្ទេរអំណាចរបស់គាត់ឱ្យ យឹម ទិត្យ ក្នុងពេលគាត់អវត្តមាន។ ហែម មឿន បានស្ដាប់ឮពូរបស់គាត់ តា ម៉ុក ប្រកាសនៅក្នុងខេត្តបាត់ដំបងថា ""បើអស់ពីអញទៅ តាទិតជាអ្នក *ទទួលខុសត្រូវ* ភូមិភាគផ្ទាល់""[379]។ ហែម មឿន បានធ្វើការយ៉ាងជិតស្និទ្ធនឹង តា ម៉ុក និងបាននិយាយថា គាត់បានដឹងថា

---

ជំនួយការរបស់ យឹម ទិត្យ ឈ្មោះ នីម]។ ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពរ របស់ ស.ព.អ កថាខណ្ឌ ៥៧, ៥៩, ៦៣, ៦៩។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៥១៣, ៥២០ iii។

[377] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ *អ៊ឹម ចែម* កថាខណ្ឌ ៣០៩ ["អ៊ឹម ចែម ចូលរួមចំណែកដល់ផែនការ [របស់ ប.ក.ក] នេះ តាមរយៈការគ្រប់គ្រងលើការដ្ឋាន និងមន្ទីរសន្តិសុខ និងតាមរយៈការចេញបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់ ដែលបញ្ជានេះត្រូវបានអនុវត្តដោយកងឈ្លបដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់។"]។

[378] *សូមមើល*ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពរ របស់ ស.ព.អ កថាខណ្ឌ ៤៥, ១១៤ (និងភ័ស្តុតាងដែលបានយោងខាងក្នុង)។

[379] ឯកសារ **D118/150** កំណត់ហេតុស្ដាប់ចម្លើយ ហែម មឿន ឆ.៦១ (គូសបញ្ជាក់បន្ថែម)។ ឯកសារ **D118/222** កំណត់ហេតុស្ដាប់ចម្លើយ ហែម មឿន ឆ.១៤។ *សូមមើលផងដែរ*ឯកសារ **D219/853** កំណត់ហេតុស្ដាប់ចម្លើយ ចាន់ វិចិត្រ ឆ.៥០-៥១ [សាក្សីគឺជាអតីតនីសារតំបន់ ១៣៖ "សៈ តាមលោកនិយាយ តា ម៉ុក ហើយពេល តា ម៉ុក អត់នៅ តា ទិត្យ គាត់ជាអ្នកចាត់ចែងកម្លាំងទ័ព ចង់ដឹងថា តើកម្លាំងទ័ពដែលគាត់ចាត់ចែង ជាទ័ពរបស់ថ្នាក់ណា? [...] ឆ.៥០៖ ទ័ពភូមិភាគ។

"នៅបាត់ដំបងគឺមានតែ តា ទិត្យ ប៉ុណ្ណោះដែលធំជាងគេបន្ទាប់ពី តា ម៉ុក" ពីព្រោះ (i) "តា ទិត្យ បាននាំយកកម្លាំងទាហាន*របស់ខ្លួនឯង*ពីតាកែវមក*ជាមួយ* តា ម៉ុក" និង (ii) នៅពេលយាមផ្លូវទៅកាន់កន្លែងប្រជុំ គាត់បានសង្កេតឃើញក្នុងពេលអវត្តមាន តា ម៉ុក ថា "តា ទិត្យ ធ្លាប់បានហៅ*មេៗយោធា*ទៅប្រជុំ" [380]។ ឈាន ប៊ិា ដែលជានីរសារ និងជាអង្គរក្សរបស់ តា ប៉ែត បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា តា ប៉ែត បានបង្ហាញគាត់នូវឯកសារពីមជ្ឈិម ដែលបានតែងតាំង យឹម ទិត្យ "ឲ្យគាត់គ្រប់គ្រងភូមិភាគពាយ័ព្យនេះ"[381]។ នីរសារម្នាក់ទៀត នៅក្នុងតំបន់ ១៣ បាននិយាយថា "តា ម៉ុក [...] មិនដែលប្រគល់ឲ្យអ្នកណាទេ គឺមានតែ តា ទិត្យ"[382]។ ការផ្ទេររបស់ តា ម៉ុក នូវអំណាចរបស់គាត់ក្នុងភូមិភាគពាយ័ព្យគឺត្រូវបានបញ្ជាក់ដោយសាក្សីច្រើននាក់ទៀត[383]។ ដូច្នេះ ស្ងម្បីតែតាមទស្សនៈដ៏មានកម្រិតមិនសមហេតុផលនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ អំពីសិទ្ធិអំណាចដែលត្រូវបានផ្តល់ជូនដោយសេចក្តីសម្រេចថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៧៦ ក៏ដោយ ក៏ យឹម ទិត្យ នៅតែស្ថិតនៅក្នុងក្រុមអ្នកដែលមានអំណាចធ្វើការសម្រេចអំពីការសម្លាប់ដោយផ្អែកលើការផ្ទេរអំណាចរបស់ តា ម៉ុក។

ឆ៖ យើងចង់ដឹងពីសន្តិសុខផ្ទៃក្នុង តើក្រោមការក្តាប់របស់ តា ម៉ុក ឬ តា ទិត្យ ទេ? ឆ.៥១៖ ក្រោម តា ម៉ុក តែពេលអត់ តា ម៉ុកទៅ ប្រហែលជាមានប្រជុំឲ្យ តា ទិត្យ ជំនួស។"] ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពរ របស់ ស.ព.អ កថាខណ្ឌ ៤៥។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨៣, ៩៩៤។

[380] ឯកសារ **D118/150** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ឆ.៩, ១៧, ៦០-៦១ (គូសបញ្ជាក់បន្ថែម)។ ឯកសារ **D118/222** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ឆ.១៤។

[381] ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ិា ឆ.១៣ ["តា ប៉ែត គាត់ចូលរួមប្រជុំនោះ ហើយនៅពេលដែលខ្ញុំបើកឡានជូនគាត់ត្រឡប់មកវិញ គាត់ប្រាប់ខ្ញុំថា តា ទិត មកប្រកាស និងបង្ហាញឯកសារពីមជ្ឈិមតែងតាំងឲ្យគាត់គ្រប់គ្រងភូមិភាគពាយ័ព្យនេះ"]។

[382] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយ ចាន់ វិចិត្រ ឆ.១៤៤។

[383] ឯកសារ **D118/108** កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១៧ ["ខ្ញុំស្គាល់ពីឈ្មោះ តា ទិត ព្រោះគេឲ្យកងការពារទៅចូលរួមសន្និបាតនៅសាលាសកលបាត់ដំបង ក្នុងក្រុងបាត់ដំបង ហើយគេឧទ្ទេសនាមថា តា ទិត ជាប្រធានភូមិភាគពាយ័ព្យ។"] និង*បានបញ្ជាក់*នៅក្នុង ឯកសារ **D219/649** កំណត់ហេតុស្តាប់ចម្លើយ ឆ.៣៧។ ឯកសារ **D219/64** កំណត់ហេតុស្តាប់ចម្លើយ ពៅ គឿន ឆ.២៨-២៩ [អតីតប្រធានកម្មករនៅសហករណ៍ធិបតី៖ "តា ទិត្យ ក៏គ្រប់គ្រងភូមិភាគពាយ័ព្យផងដែរ។ មានការប្រជុំ ហើយអ្នកដែលនៅក្រោម តា ទិត្យ បាននិយាយថា [...] "សមមិត្ត ទិត្យ ជាអ្នកគ្រប់គ្រងនៅខេត្តបាត់ដំបង។ [...]""]។ ឯកសារ **D1.3.27.5** Masato Matsushita និង Stephen Heder, *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅតាមព្រំដែនកម្ពុជា-ថៃ* ឆ្នាំ១៩៨០ ERN 00324732 [បទសម្ភាសន៍លេខ ១៨]។ *សូមមើលផងដែរ* ឯកសារ **D118/69** កំណត់ហេតុស្តាប់ចម្លើយ នួន មួន ឆ.១៤, ១៦។ ឯកសារ **D20** កំណត់ហេតុស្តាប់ចម្លើយ ហាន ធី ERN 00699643។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨៣។

## *ខ) កម្មាភិបាលយោធា ក្នុងអំឡុងពេលបោសសម្អាត*

136. លើសពីនេះទៀត ដីកាសម្រេចលើកលែងចោទប្រកាន់មានភាពផ្ទុយទាំងស្រុងទៅនឹងទស្សនៈដែលថា មានតែមនុស្សប្រមាណ ១៣រូប ប៉ុណ្ណោះ រួមទាំងលេខាភូមិភាគ មានសិទ្ធិអំណាចធ្វើការសម្រេចអំពីការសម្លាប់ តាមរយៈការសន្និដ្ឋានថា ក្នុង "យុទ្ធនាការបោសសម្អាតនេះ កម្មាភិបាលស៊ីវិលគ្មានសិទ្ធិសម្លាប់មនុស្សទេ តែផ្ទុយទៅវិញ យោធាទើបមានសិទ្ធិសម្លាប់មនុស្ស"[384]។ ការអះអាងនេះផ្អែកលើកំហុសអង្គហេតុដែលបណ្ដាលឱ្យមានការខុសឆ្គងរបស់តុលាការ ដែលធ្វើឱ្យដីកាលើកលែងចោទប្រកាន់ធ្វើការវាយតម្លៃទាបលើកម្រិតនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ដោយផ្អែកលើភស្តុតាងរបស់សាក្សីតែម្នាក់ និងខកខានមិនបានទទួលស្គាល់ កុំថាឡើយការវិភាគលើភស្តុតាងនៅក្នុងសំណុំរឿងរបស់សាក្សីផ្សេងទៀតជាច្រើនដែលបង្ហាញថា កម្មាភិបាលស៊ីវិលក៏សម្លាប់កម្មាភិបាល[385] និងប្រជាជនធម្មតាផងដែរ[386] នៅក្នុងភូមិភាគពាយ័ព្យ ដូចគ្នានឹង យឹម ទិត្យ

[384] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១ ["ក្នុងយុទ្ធនាការបោសសម្អាតនេះ កម្មាភិបាលស៊ីវិលគ្មានសិទ្ធិសម្លាប់មនុស្សទេ តែផ្ទុយទៅវិញ យោធាទើបមានសិទ្ធិសម្លាប់មនុស្ស"]។ ដីកាសម្រេចលើកលែងចោទប្រកាន់ប្រើពាក្យ "បោសសម្អាត" ដើម្បីមានន័យ *ជាអាទិ៍*ថា "សម្លាប់"។ *សូមមើល* ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១២៩-១៣០។

[385] *សូមមើលឧទាហរណ៍* ឯកសារ **D219/242** កំណត់ហេតុស្ដាប់ចម្លើយ អប់ ច្រឹង *ហៅ* រ៉ន ឆ.២៤ [សាក្សីគឺជាទាហានកងតូចក្នុងឃុំមួយក្នុងស្រុកបាកាន តំបន់ ២៖ "នៅពេលដែល បិណ [លេខាតំបន់ ២ មកពីភូមិភាគនិរតី] មកដល់ទីនេះ បិណ បានចាប់មេកងវរៈយកទៅសម្លាប់ចោល"]។ ឯកសារ **D219/223** កំណត់ហេតុស្ដាប់ចម្លើយ នួន រិន ឆ.៣០ [សាក្សីគឺជាកម្មករកងចល័តក្នុងតំបន់ ២៖ "ក្នុងអំឡុងពេលដែល បិណ នៅគ្រប់គ្រង បានធ្វើការចាប់ និងសម្លាប់កម្មាភិបាលមូលដ្ឋាននៅពោធិ៍សាត់ [...] ថ្នាក់ភូមិ ឃុំ ស្រុក កងវរៈជាដើម"]។ ឯកសារ **D118/238** កំណត់ហេតុស្ដាប់ចម្លើយ កុល សែត *ហៅ* កែវ សែត ឆ.៥៨ [សាក្សីគឺជាឈ្លប និងក្រោយមកជាកសិករក្នុងស្រុកបាកាន៖ "ពេលដែល យាយ រឹម [ស្ថិតក្នុងគណៈស្រុកបាកាន] មកដល់គឺគាត់បានយកកម្មាភិបាលខ្មែរក្រហមចាស់ៗទៅដាក់គុក និងសម្លាប់ចោល ហើយយកអ្នកថ្មីមកដាក់ជំនួសវិញម្ដង។"]។ ឯកសារ **D219/188** កំណត់ហេតុស្ដាប់ចម្លើយ ថាន ឃន ឆ.៨៨។ ឯកសារ **D134/3** កំណត់ហេតុស្ដាប់ចម្លើយ សាត ឆាង ឆ.២៨ (*សូមមើលផងដែរ* ឯកសារ **D6.1.618** បទសម្ភាសន៍ SOAS ជាមួយ សាត ឆាង ERN 00721704)។

[386] *សូមមើលឧទាហរណ៍* ឯកសារ **D219/46** កំណត់ហេតុស្ដាប់ចម្លើយ សោម វណ្ណា ឆ.៥៣-៥៤ [ដើមបណ្ដឹងរដ្ឋប្បវេណីជាកម្មករកងចល័តក្នុងតំបន់ ៤ នៅពេលដែលគាត់បានឃើញ "នៅវត្តវាំងកេសី [...] តាឡឹក និង យាយចាន់ បានបាញ់រះប្រជាជនតែម្ដង ហើយក៏បាញ់ត្រូវ តា ស៊ើង ស្លាប់។ ពេលនោះមានជនរងគ្រោះដែលរបួសជាច្រើន [...] តា ឡឹក និងយាយ ចាន់ ជាអ្នកប្រមូលយកទៅសម្លាប់ចោល។"] (*សូមមើលផងដែរ* ឯកសារ **D219/312** កំណត់ហេតុស្ដាប់ចម្លើយ ប៉ង់ ថៃ ឆ.១២។ ឯកសារ **D219/939** កំណត់ហេតុស្ដាប់ចម្លើយ សេក មន្ថា ឆ.២៥។ ឯកសារ **D5/85** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោយ យ៉ែម ERN 00562463។ ឯកសារ **D219/866** កំណត់ហេតុស្ដាប់ចម្លើយ ឡើយ ម៉ុន ឆ.៤១, ៤៧, ៤៩។ ឯកសារ **D219/257** កំណត់ហេតុស្ដាប់ចម្លើយ សេក ជោត ឆ..៧)។ ឯកសារ **D118/4** កំណត់ហេតុស្ដាប់ចម្លើយ កន ចឹក ឆ.៣០-៣១។

ដែរ[387]។ ដីកានេះក៏បានមើលរំលងផងដែរថា លេខាភូមិភាគមិនស្ថិតនៅក្រោមសិទ្ធិអំណាចរបស់កងទ័ពបដិវត្តកម្ពុជា ឬ សេនាធិការ[388] និងថា តា ម៉ុក ដែលដីកាសម្រេចលើកលែងចោទប្រកាន់បានកំណត់ (យ៉ាងត្រឹមត្រូវ) ពីការទទួលខុសត្រូវដ៏ធំធេងចំពោះការបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យនោះ[389] គឺជាជនស៊ីវិល។

---

[387] សម្រាប់ជនរងគ្រោះដែលជាទាហាន ឬកម្មាភិបាល *សូមមើល ឧទាហរណ៍* ឯកសារ **D34.1.10** បទសម្ភាសន៍ ហេង ទារ *ហៅ* ប៉ែត ដោយ Steve Heder ERN 00964055 [“ទិត្យ ហ្នឹងវាបញ្ជា ៗ ឱ្យកងទ័ពហ្នឹងសម្លាប់តែម្តង។ សម្លាប់ហ្នឹងបើនិយាយទៅ វាកងទ័ពនៅខាងពាយ័ព្យទិសហ្នឹងដែរ។”]។ ឯកសារ **D20** កំណត់ហេតុស្តាប់ចម្លើយ ហាន ធី ERN 00699643 [សាក្សីគឺជាមេឃុំក្នុងតំបន់ ១៖ “ផែនការសម្លាប់នៅពេលនោះពីពួកខ្មែរក្រហមគ្នាឯង [កម្មាភិបាល] […] ជាបញ្ជាថ្នាក់លើដូច្នេះថ្នាក់លើមានតែ តា ទិត្យ”] (*សូមមើលផងដែរ* ឯកសារ **D105/8** កំណត់ហេតុស្តាប់ចម្លើយ ហាន ធី ឆ.១២។ ឯកសារ **D118/271** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ឆ.២៩)។ ឯកសារ **D6.1.1105** Ben Kiernan *របប ប៉ុល ពត* ERN 00637645-46 [ក្នុងបទសម្ភាសន៍ក្នុងខែសីហា ឆ្នាំ១៩៨០ ង៉ោល ដែលជាអតីតមេឃុំរាមអណ្តើក ស្រុកគិរីវង់ បាននិយាយថា “បទបញ្ជាតែងតែចេញមកពីប្រធានស្រុកម្នាក់ឈ្មោះ ទិត ដែលណែនាំឱ្យ ង៉ោល ចាប់ប្រជាជនយកទៅឱ្យកងកម្លាំងសន្តិសុខស្រុក។ អ្នកដែលត្រូវ […] សម្លាប់ក្នុងឆ្នាំ ១៩៧៦ រួមទាំងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលហ្វឹកហាត់នៅហាណូយ”] (*សូមមើលផងដែរ* ឯកសារ **D219/726.1.1** កំណត់សម្គាល់របស់ Ben Kiernan ពីបទសម្ភាសន៍ជាមួយ ង៉ោល ERN 01339959, 61-62)។ *សូមមើលផងដែរ* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤២១។ ឯកសារ **D378/2** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ៣៤។ សម្រាប់ជនរងគ្រោះធម្មតា *សូមមើលឧទាហរណ៍* ឯកសារ **D219/982** កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៦-៣៣ [សាក្សីគឺជាប្រធានកងតូចក្នុងស្រុកគាស់ក្រឡ និងបានឃើញ អន ដែលជាបញ្ជាការយោធា “សម្លាប់ ហើយចាប់យកទៅសម្លាប់”។ នៅពេលដែលគាត់សួរ អន “មិត្តឯងធ្វើឃាតករសម្លាប់ប្រជាជន អ្នកណាចាត់តាំងមក […] គាត់ថា ឈ្មោះ ទិត្យ ហ្នឹង” “រាប់ពាន់នាក់” ត្រូវបានសម្លាប់។]។ ឯកសារ **D219/263** កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.៣៣-៣៥, ៤១-៤២, ៤៧-៤៩, ៥៨ (*សូមមើលផងដែរ* ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ឆ.៧-៨។ ឯកសារ **D219/233** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ឆ.២២-២៤)។ ឯកសារ **D118/209** កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ុល) ហឿន ឆ.១៣៨, ១៤៣, ១៤៦។ ឯកសារ **D219/533** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ុន ឆ.១០៨។ ឯកសារ **D6.1.1105** Ben Kiernan *របប ប៉ុល ពត* ERN 00637644-45 (*សូមមើលផងដែរ* ឯកសារ **D219/726.1.1** កំណត់សម្គាល់របស់ Ben Kiernan ពីបទសម្ភាសន៍ជាមួយ ង៉ោល ERN 01339959, 61-62)។ *សូមមើលផងដែរ* ឯកសារ **D378/2** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ៣៤, ៦៩, ៧១, ៧៣។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤១៣, ៤២១, ៦៧៩។

[388] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២, ៦៧១, ៩២។ *សូមមើលផងដែរ* ឯកសារ **D1.3.15.1** របាយការណ៍វិភាគជាលាយលក្ខណ៍អក្សររបស់ Craig C. Etcheson កថាខណ្ឌ ៧ [ភូមិនៅក្រោមគណៈកម្មាធិការអចិន្ត្រៃយ៍], ១២ [លក្ខន្តិកៈ ប.ក.ក ថ្លែងថា កងទ័ពបដិវត្តកម្ពុជា ជារបស់មជ្ឈិម] ១០៤ [រចនាសម្ព័ន្ធយោធា និងនយោបាយបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ] កថាខណ្ឌ ៦៧, ៤៩-៥០។

[389] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ១៣៩-១៤០។

137. មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុមានហេតុផលណាអាចខកខានក្នុងការសន្និដ្ឋានថា (i) មនុស្ស ប្រមាណជាង ១៣ រូប មានអំណាចធ្វើការសម្រេចលើការសម្លាប់ ផ្អែកលើភ័ស្តុតាងទាំងអស់នៅក្នុងសំណុំរឿងនេះ និង (ii) កម្មាភិបាលស៊ីវិលមានអំណាចសម្លាប់ក្នុងអំឡុងពេលបោសសម្អាតនៅភូមិភាគពាយ័ព្យ។ កំហុសអង្គហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់នេះបាននាំឱ្យមានការខុសឆ្គោយរបស់តុលាការ និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ២. ការរកឃើញថា យឹម ទិត្យ អាចមានមុខនាទីក្នុងភូមិភាគមួយ ក្នុងរយៈពេលណាមួយ

138. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុ ដោយការច្រានចោលភ័ស្តុតាងដែលថា យឹម ទិត្យ បានបន្តកាន់មុខនាទីជាលេខាតំបន់ ១៣ មកទល់ចុងឆ្នាំ១៩៧៨ លើមូលដ្ឋានដែលថា "សាក្សីជាច្រើនបានអះអាងថា ក្រុមកម្មាភិបាលនៃភូមិភាគនិរតីនៅក្នុងនោះមាន យឹម ទិត្យ បានចាកចេញទៅកាន់ភូមិភាគពាយ័ព្យក្នុងពាក់កណ្តាលឆ្នាំ ១៩៧៧ រួចទៅហើយ"[390]។ ចំណុចនេះបង្កើតបានជាការរកឃើញដោយប្រយោលថា យឹម ទិត្យ មិនអាចកាន់មុខនាទីពីរក្នុងពេលតែមួយ ទាំងនៅក្នុងភូមិភាគពាយ័ព្យ និងទាំងនៅក្នុងភូមិភាគនិរតីបានឡើយ។ ប៉ុន្តែ នៅក្នុងកថាខណ្ឌបន្ទាប់ ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថា តា ម៉ុក បានធ្វើការជាលេខាបួនភូមិភាគក្នុងពេលតែមួយ ដែលរួមគ្នាគ្របដណ្តប់ស្ទើតែពាក់កណ្តាលនៃទឹកដីរបស់របបកម្ពុជាប្រជាធិបតេយ្យទាំងមូល បន្ថែមលើការរកឃើញពីមុនរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា តា ម៉ុក គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍[391]។ ដោយហេតុថា តា ម៉ុក គឺជាអ្នកគាំទ្រ និងអ្នកការពាររបស់ យឹម ទិត្យ[392] និងថា ក្នុននាមជាប្អូនប្រុសសាច់ថ្លៃរបស់គាត់ យឹម ទិត្យ គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែល តា ម៉ុក ទុកចិត្តបំផុត វាមិនត្រឹមតែអាចទៅរួចនោះទេ ប៉ុន្តែថែមទាំងទំនងថា តា ម៉ុក បានចាត់តាំងឱ្យ យឹម ទិត្យ មានមុខនាទីច្រើនក្នុងភូមិភាគជាច្រើនក្នុងពេលដំណាលគ្នា ដូចគ្នានឹង តា ម៉ុក ខ្លួនគាត់បានធ្វើដែរ។ មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុមានហេតុផលណាធ្វើការវិភាគខុសអំពីកម្រិតនៃការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់ យឹម ទិត្យ

---

[390] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ៦៦៨។

[391] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ៦៦៩, ៦៥។

[392] *សូមមើល* ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ៩, ១១, ៤៥។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣២៧, ៣៤៨-៣៥០, ៩៩៤។

ឡើយ។ កំហុសអង្គហេតុនេះបាននាំឲ្យមានការខុសឆ្គោយរបស់តុលាការ និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្ដីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ៣. ការរកឃើញដែលថា តួនាទីតែមួយគត់របស់ យឹម ទិត្យ នៅថ្នាក់ភូមិភាគពាយ័ព្យ គឺត្រឹមថ្នាក់សមាជិកគណៈកម្មាធិការ

139. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុ ដោយការសន្និដ្ឋានថា តួនាទីរបស់ យឹម ទិត្យ នៅថ្នាក់ភូមិភាគពាយ័ព្យគឺជាសមាជិកគណៈកម្មាធិការ មិនមែនជាអនុលេខាទេ[393]។ ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានដកស្រង់ភ័ស្តុតាងណាសម្រាប់ការសន្និដ្ឋាននេះ ហើយភ័ស្តុតាងដ៏មានទម្ងន់ច្រើនលើសលុបដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះបង្ហាញថា យឹម ទិត្យ (យ៉ាងហោចណាស់) គឺជាអនុលេខាភូមិភាគពាយ័ព្យ មិនមែនគ្រាន់តែជាសមាជិកគណៈកម្មាធិការនោះទេ[394]។ ការសន្និដ្ឋានផ្នែកអង្គហេតុមិនសមហេតុផលនេះ បានបណ្ដាលឲ្យដីកាសម្រេចលើក

---

[393] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៦៦, ៦៨០។

[394] ឯកសារ **D118/108** កំណត់ហេតុស្ដាប់ចម្លើយ លឹម ទីម ឆ.១៦-១៨ ["ខ្ញុំស្គាល់តា ទិត គាត់នៅកាន់ភូមិភាគពាយ័ព្យ។ [...] ខ្ញុំស្គាល់ពីឈ្មោះ តា ទិត ព្រោះគេឲ្យកងការពារទៅចូលរួមសន្និបាតនៅសាលាសកលបាត់ដំបង ក្នុងក្រុងបាត់ដំបង ហើយគេឧទ្ទេសនាមថា តា ទិត ជាប្រធានភូមិភាគពាយ័ព្យ។ ខ្ញុំដឹងថា តា ទិត មកបាត់ដំបង នេះមុន តា ម៉ុក, តា ទិត មកប្រហែលជាមួយឆ្នាំមុនវៀតណាមចូល។ [...] ប្រហែលជាពាក់កណ្ដាលឆ្នាំ ១៩៧៨ [...] គេឧទ្ទេសនាមឈ្មោះ តា ទិត ថាជាគណៈភូមិភាគពាយ័ព្យ។ [...] តា រស់ ញឹម និង តា កន គេចាប់ក្រោយគេ គឺគេចាប់ពួកគាត់ប្រហែលជា៥ ទៅ៦ខែ មុនវៀតណាមចូល។"] ឆ.២៧ ["សៈ ពេលលោកទៅសន្និបាតនៅបាត់ដំបង តើតា ញឹម មានវត្តមាននៅទីនោះដែរ ឬទេ? ឆ.២៧៖ មិនមានទេ មានតែ តា ទិត ដែលធំជាងគេ។"]។ ឯកសារ **D118/271** កំណត់ហេតុស្ដាប់ចម្លើយ ឈាង ប៊ា ឆ.៣៤ ["គេចាប់ខ្លួន តា ញឹម មុនគេ ហើយប្រហែលជា ៥ខែក្រោយមក គេចាប់ខ្លួន តា កី។ តា ទិត និង តា ម៉ុក ឡើងគ្រប់គ្រងជំនួស។"]។ ឯកសារ **D118/150** កំណត់ហេតុស្ដាប់ចម្លើយ ហែម មឿន ឆ.៥៩-៦១, ៦៥ ["តា ទិត និង តា ប៊ិត គឺជាកូនចៅរបស់ តា ម៉ុក។ [...] នៅបាត់ដំបងគឺមានតែ តា ទិត ប៉ុណ្ណោះដែលធំជាងគេបន្ទាប់ពី តា ម៉ុក។ ប្រសិនបើ តា ម៉ុក មិននៅ តា ទិត ជាអ្នកទទួលខុសត្រូវភូមិភាគពាយ័ព្យ។ [...] តា ម៉ុកបានប្រកាសប្រាប់យោធាថា 'បើអស់ពីអញទៅ តា ទិត ជាអ្នកទទួលខុសត្រូវភូមិភាគផ្ទាល់។' [...] ខ្ញុំធ្លាប់ជួប តា ទិត ដំបូងប្រហែលចុងឆ្នាំ ១៩៧៧ ឬដើម ១៩៧៨ នៅបាត់ដំបង ប៉ុន្តែខ្ញុំមិនច្បាស់នោះទេ ព្រោះយូរឆ្នាំណាស់មកហើយ។"] (*សូមមើលផងដែរ*ឯកសារ **D118/222** កំណត់ហេតុស្ដាប់ចម្លើយ ហែម មឿន ឆ.១៤)។ ឯកសារ **D118/69** កំណត់ហេតុស្ដាប់ចម្លើយ នួន មួន ឆ.១៤, ១៦-១៧ ["ឆ.១៤៖ [...] តា ទិត ក្លាយជាអនុប្រធានភូមិភាគពាយ័ព្យរបស់ តា ម៉ុក ទទួលបន្ទុកតំបន់ ១។ [...] សៈ តើហេតុអ្វីទើបលោកដឹងថា តា ទិត ជាអនុភូមិភាគពាយ័ព្យ? ឆ.១៦៖ ព្រោះកាលនោះអ្នកដែលធំមកពីភូមិភាគនិរតីមានតែពីរនាក់ទេ តា ម៉ុក និង តា ទិត ហើយមិនមានអ្នកណាផ្សេងទៀតទេ។ សៈ តើគេដែលប្រកាសថា តា ទិត ក្លាយជាអនុភូមិភាគដែរឬទេ? ឆ.១៧៖ គេមិនដែលប្រកាសទេ ខ្ញុំដឹងតាមរយៈប្រជាជន និងកម្មាភិបាលនិរតីដែលគ្រប់គ្រងសហករណ៍ និងសហជីព។"]។ ឯកសារ **D219/917** កំណត់ហេតុស្ដាប់ចម្លើយ ដៃ ទូច ឆ.១១, ១៣, ១៥ ["ឮពេលនៅដូនទាវ បាត់ដំបង ឮតែ [យឹម ទិត្យ] [...] ខ្ញុំឮតែគេនិយាយ ពេលប្រជុំកម្មករ។ [...] [តាឬ] គ្រាន់តែថា តា ទិត្យ

លែងចោទប្រកាន់មានកំហុសក្នុងការវាយតម្លៃរបស់ខ្លួនលើកម្រិតនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហមនៅក្នុងភូមិភាគពាយ័ព្យ។ ផ្អែកលើភ័ស្តុតាងទាំងអស់មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុមានហេតុផលណា អាចខកខានមិនបានរកឃើញថា យឹម ទិត្យ យ៉ាងហោចណាស់គឺជាអនុលេខាភូមិភាគពាយ័ព្យនោះទេ។ កំហុសផ្នែកអង្គហេតុនេះ រួមជាមួយនឹងកំហុសអង្គហេតុផ្សេងៗទៀត បាននាំឲ្យមានការខុសឆ្គោយរបស់តុលាការ និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ៤. ការរកឃើញដែលថា យឹម ទិត្យ មិនមានអ្នកក្រោមបង្គាប់

140. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុ និងផ្ទុយគ្នាទាំងស្រុងទៅនឹងភ័ស្តុតាងដែលមាន ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់ ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ និងការរកឃើញរបស់ខ្លួនផ្ទាល់ នៅពេលដែលដីកានេះបានសន្និដ្ឋានថា យឹម ទិត្យ "មិនមានអ្នកក្រោមបង្គាប់ជាក់លាក់"[395]។ ការរកឃើញមិនមានហេតុផលនេះត្រូវបានធ្វើឡើងនៅក្នុងផ្នែកនៃដីកាសម្រេចលើកលែងចោទប្រកាន់ ដែលដោះស្រាយជាពិសេសអំពីយុត្តាធិការបុគ្គលលើ យឹម ទិត្យ

---

ប្រធានភូមិភាគ។"]។ ឯកសារ **D105/8** កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.២៧ ["ជួបលើកទីពីរ គាត់ [យឹម ទិត្យ] ឲ្យខ្ញុំប្រជុំប្រជាជននៅឃុំកន្ទឺ២ ដើម្បីទម្លាក់ តា ប៉ែត ចេញពីដំណែងភូមិភាគពាយ័ព្យ ហើយ តា ទិត្យ ឡើងជាលេខាភូមិភាគវិញ។"]។ ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.១០ ERN 00960664 ["ស៖ លោកនិយាយថា តា ទិត ជាដៃស្តាំរបស់ តា ម៉ុក ដែលកាន់ភូមិភាគពាយ័ព្យ តើលោកចង់មានន័យថា តា ទិត ក៏មានតួនាទីនៅភូមិភាគពាយ័ព្យដែរ ឬយ៉ាងណា? ឆ.១០៖ បាទ! តា ទិត គាត់ក៏មានតួនាទីថ្នាក់ភូមិភាគដែរ។"] ឆ.១៣ ["តា ប៉ែត គាត់ចូលរួមប្រជុំនោះ ហើយនៅពេលដែលខ្ញុំបើកឡានជូនគាត់ត្រឡប់មកវិញ គាត់ប្រាប់ខ្ញុំថា តា ទិត មកប្រកាស និងបង្ហាញឯកសារពីមជ្ឈិមតែងតាំងឲ្យគាត់មកគ្រប់គ្រងភូមិភាគពាយ័ព្យនេះ។"]។ ឯកសារ **D1.3.27.5** Masato Matsushita និង Stephen Heder, *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅតាមព្រំដែនកម្ពុជា-ថៃ* ឆ្នាំ ១៩៨០ ERN 00324732។ ឯកសារ **D123/2/1.1a** បទសម្ភាសន៍ គុប ស៊ើង ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00957635។ ឯកសារ **D219/34** កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ុល) ហឿន ឆ.៤៣ ["ខ្ញុំបានឃើញបញ្ជីឈ្មោះនោះ ដែលមាន តា ទិត្យ ទៅគ្រប់គ្រងនៅខេត្តបាត់ដំបង"]។ *សូមមើលផងដែរ* ឯកសារ **D118/63** កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.២៩-៣០។ ឯកសារ **D105/4** កំណត់ហេតុស្តាប់ចម្លើយ ហ៊ុយ ក្រឹម ឆ.២០។ ឯកសារ **D118/75** កំណត់ហេតុស្តាប់ចម្លើយ ហ៊ុយ ក្រឹម ឆ.២៥។ ឯកសារ **D219/835** កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.៩១។ ឯកសារ **D123/1/1.4a** បទសម្ភាសន៍ ញឹក លី *ហៅ* គឹម ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00057703។ ឯកសារ **D1.3.11.53** បទសម្ភាសន៍ តេន ជឹម ដោយ SOAS ERN 00217753-54។ ឯកសារ **D118/65** កំណត់ហេតុស្តាប់ចម្លើយ ជឹម ចាន់ធឿន ឆ.២៨។ ឯកសារ **D219/117** កំណត់ហេតុស្តាប់ចម្លើយ គុប សឹង ឆ.៧៨-៧៩។ ឯកសារ **D219/515** កំណត់ហេតុស្តាប់ចម្លើយ ឆីណ ឈួយ ឆ.៣០, ៤៧, ៥៧។ ឯកសារ **D219/268** កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៤៣, ៤៨។ ឯកសារ **D219/373** កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៨៩-៩០, ១១៧។

[395] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៨២។

ដែលបានបង្ហាញពីសារៈសំខាន់របស់វាចំពោះសេចក្ដីសន្និដ្ឋានមិនត្រឹមត្រូវលើយុត្តាធិការ។ កំហុសផ្នែកអង្គហេតុនេះបាននាំឱ្យមានការខុសឆ្គោយរបស់តុលាការ។

141. ដូចបានពិភាក្សាខាងលើ ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញយ៉ាងច្បាស់ថា យឹម ទិត្យ បានបម្រើការជា (i) អនុលេខាស្រុកគិរីវង់ (ii) លេខាស្រុកគិរីវង់ (iii) លេខាតំបន់ ១៣ (iv) លេខាតំបន់ ១ និង (v) សមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ[396]។ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានរកឃើញថា "រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល [របស់កម្ពុជាប្រជាធិបតេយ្យ] មានតាមឋានានុក្រមពីលើទៅក្រោម ដូចជា ភូមិភាគ តំបន់ ស្រុក ឃុំ ភូមិ ក្រុម និងកង"[397] រកឃើញថា "គោលនយោបាយបក្ស [...] ត្រូវបានចូលរួមធ្វើការផ្សព្វផ្សាយឱ្យដល់ប្រជាជននៅទូទាំងផ្ទៃប្រទេស តាមរយៈការប្រជុំគ្រប់កម្រិតចាប់ពីថ្នាក់លើចុះទៅថ្នាក់ក្រោម តាមឋានានុក្រមនៃការដឹកនាំពីមជ្ឈិម ភូមិភាគ តំបន់ស្វយ័ត តំបន់ ស្រុក ឃុំ ភូមិ និងសហករណ៍ជាដើម"[398] និងថា "ឃុំនានាត្រូវរាយការណ៍ត្រឡប់ទៅគណៈស្រុក គណៈស្រុកត្រូវរាយការណ៍ជាបន្តទៅគណៈតំបន់។ គណៈតំបន់មានកាតព្វកិច្ចត្រូវរាយការណ៍ជាបន្តទៅគណៈភូមិភាគ"[399]។ ក្នុងការធ្វើការសន្និដ្ឋានទាំងនេះ ដីកាសម្រេចលើកលែងចោទប្រកាន់បានពឹងផ្អែកជាពិសេសលើ[400] របាយការណ៍វិភាគ ដែលលើកឡើងថា "ថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជានៅថ្នាក់តំបន់ មានអំណាចទូលំទូលាយទៅលើបញ្ហាបុគ្គលិក និងបញ្ហាអង្គការចាត់តាំង សន្តិសុខ និងសេដ្ឋកិច្ច ក្នុងតំបន់រៀងៗខ្លួន"[401] និងមានការសន្និដ្ឋានតាមបែបប្រៀបធៀបទាក់ទងនឹងមេដឹកនាំថ្នាក់ស្រុក និងថ្នាក់ភូមិភាគ[402]។

142. ការសន្និដ្ឋានទាំងនេះស្របទៅនឹងលក្ខន្តិកៈ ប.ក.ក ដែលចែងថា គណៈតំបន់ត្រូវ "ចុះជាប់ស្រុកសាខា និងមូលដ្ឋានជាក់ស្ដែងរបស់សាខា [...] ដើម្បីដឹកនាំការអនុវត្តភារកិច្ច ក្នុងមហាជន និងផ្ទៃក្នុង" និង "ក្ដាប់អង្គការស្រុក អង្គការសាខា កម្មាភិបាល បក្ខជន និងអង្គការស្នូលទាំងអស់

[396] *សូមមើលយោងខាងលើ* កថាខណ្ឌ ៤២។

[397] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៨។

[398] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៤។

[399] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១២៧។

[400] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១២៧ ជើងទំព័រ ៣៦២។

[401] ឯកសារ **D1.3.15.1** របាយការណ៍វិភាគជាលាយលក្ខណ៍អក្សររបស់ Craig C. Etcheson កថាខណ្ឌ ៥៨។

[402] ឯកសារ **D1.3.15.1** របាយការណ៍វិភាគជាលាយលក្ខណ៍អក្សររបស់ Craig C. Etcheson កថាខណ្ឌ ៤១-៤៤, ៧៥។

ក្នុងតំបន់ ខាងប្រវត្តិរូប ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង"[403]។ បទប្បញ្ញត្តិស្រដៀងគ្នានេះត្រូវអនុវត្តចំពោះភូមិភាគ និងស្រុកនានា[404]។

143. ផ្អែកតាមការសន្និដ្ឋានផ្ទាល់របស់ដីកាសម្រេចលើកលែងចោទប្រកាន់ និងក្នុងពេលគ្មានភស្តុតាងផ្ទុយ មិនមានអ្នកវិនិច្ឆ័យអង្គហេតុមានហេតុផលណា អាចខកខានក្នុងការសន្និដ្ឋានថា យឹម ទិត្យ មានអ្នកក្រោមបង្គាប់នោះឡើយ។

144. ហេតុដូច្នេះ ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់បានអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់ និងបានពិចារណាគ្រប់ជ្រុងជ្រោយលើភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងនេះ វាពិតជាបានកំណត់អត្តសញ្ញាណអ្នកក្រោមបង្គាប់ជាក់លាក់របស់ យឹម ទិត្យ។ ឈឿង ប៊ិន បានពិភាក្សាអំពីការប្រជុំមួយដែលគាត់បានចូលរួមថា "រួមមាន តា ទិត្យ *និងអ្នកក្រោមឱវាទរបស់គាត់* ដូចជាតាគាន់ (មេកង) វ៉ាត, តែម, រ៉ន, រ៉ុម, តាខូវ"[405]។ ក្នុងការពិភាក្សាអំពីទំនប់កង្គួត សាក្សីម្នាក់ផ្សេងទៀតបាននិយាយថា "តា ទិត្យ ហ្នឹងឯងនៅកង្គួត [...] ខ្ញុំឃើញម្តង។ ក្រោយមក [...] *ឃើញតែកូនចៅគាត់ដូចជា មេកង*"[406]។ ណុប ធីម បានផ្តល់ភស្តុតាងថា ក្នុងនាមជាអនុលេខាស្រុកសំឡូតគាត់គឺជាអ្នកក្រោមបង្គាប់របស់ យឹម ទិត្យ[407]។ មានសាក្សីជាច្រើនបានបញ្ជាក់ថា តានីម គឺជាអ្នកក្រោមបង្គាប់ថ្នាក់ខ្ពស់របស់ យឹម ទិត្យ ក្នុងតំបន់១[408]។ សាក្សីផ្សេងទៀត បានថ្លែងថា យឹម

---

[403] ឯកសារ **D1.3.20.1** លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា មាត្រា ១៦(១), (៣) ERN 00053030-31។

[404] ឯកសារ **D1.3.20.1** លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា មាត្រា ១៣(១), ៣, ១៩(១), ៣ ERN 00053029, 00053032។

[405] ឯកសារ **D219/368** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ិន ឆ.៩០ [សាក្សីបានចូលរួមប្រជុំនៅចុងឆ្នាំ១៩៧៨ នៅឃុំបាយដំរាំ៖ "កិច្ចប្រជុំនោះ រួមមាន តា ទិត្យ និងអ្នកក្រោមឱវាទរបស់គាត់ដូចជា តា គាន់ (មេកង) វ៉ាត, តែម, រ៉ន, រ៉ុម, តា ខូវ"] (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ឆ.១១៤ ["ខ្ញុំបានឃើញ តា ទិត្យ ទៅមកៗ នៅឯទំនប់កង្គួត [...]។ គាត់បានបញ្ជូនកូនចៅរបស់គាត់ ដូចជា តែម, វ៉ាត, រ៉ន, រ៉ុម និង ឈា ព្រមទាំងកូនចៅដទៃទៀត មកការដ្ឋានទំនប់នេះ ក្នុងខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧។"]។

[406] ឯកសារ **D219/943** កំណត់ហេតុស្តាប់ចម្លើយ ឡុម លិន ឆ.១២-១៣ (គូសបញ្ជាក់បន្ថែម)។

[407] ឯកសារ **D123/2/2.17a** បទសម្ភាសន៍ ណុប ធីម ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00733838។ ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.៣១។

[408] ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ឆ.៧ [សាក្សីគឺជាអង្គរក្ស និងនិរសាររបស់ តា ប៉ែត៖ "អនុរបស់ តា ទិត ឈ្មោះ តា នីម។ តា នីម និង តា ទិត មកស្នាក់នៅទំនប់កង្គួត ហើយ តា ទិត និង តា នីម ចាប់មនុស្ស [...] ទៅបាញ់ចោលមិនតិចទេ។ [...] តា ទិត និង តា នីម មកកាន់តំបន់ ១ នេះ។"]។ ឯកសារ **D219/904** កំណត់ហេតុស្តាប់ចម្លើយ យឹម គួញ ឆ.៨២ ["ប្តីខ្ញុំ [នីម] ទៅជួបរាយការណ៍នៅផ្ទះ តា ទិត្យ"] (*សម្គាល់៖* សាក្សីមិនដឹងអំពីតួនាទីជាន់ខ្ពស់របស់ប្តីគាត់នៅក្នុង

ទិត្យ បានចេញបញ្ជាសម្លាប់ទៅកាន់កម្មាភិបាលឃោធាស្រុកគាស់ក្រឡម្នាក់ ឈ្មោះ អន និងកម្មាភិបាលម្នាក់ទៀត ឈ្មោះ តាសាម៉ន[409]។ ទាហានម្នាក់បានផ្តល់ភ័ស្តុតាងថា "តាទិត បានយក *កម្លាំងទាហានរបស់ខ្លួនឯង* ពីតាកែវមកជាមួយ តា ម៉ុក។"[410] ដីកាសម្រេចលើកលែងចោទប្រកាន់ហាក់ដូចជាទទួលយកភ័ស្តុតាងថា "តា ទិត្យ *នាំកម្លាំងដោយផ្ទាល់* មកពិនិត្យមើលស្ថានភាពនៅរោងចក្រកំពង់គុល ព្រមទាំងចាត់តាំងឈ្មោះ យ៉ាន ឲ្យគ្រប់គ្រងរោងចក្រ"[411]។

145. ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា យឹម ទិត្យ មិនមានអ្នកក្រោមបង្គាប់ច្បាស់លាស់ ពិតជាមិនសមហេតុផលទេ។ សារៈសំខាន់របស់វានៅក្នុងផ្នែកនៃសេចក្តីសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់បង្ហាញថា កំហុសអង្គហេតុនេះបាននាំឲ្យមានការខុសឆ្គងរបស់តុលាការ និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ៥. ការរកឃើញដែលថា ការសម្លាប់បានធ្លាក់ចុះក្រោយសេចក្តីប្រកាសរបស់ ខៀវ សំផន ដែលត្រូវបានអះអាងនៅពាក់កណ្តាលឆ្នាំ ១៩៧៨

146. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុ ដោយការអះអាងថា ខៀវ សំផន បានប្រកាស "ការលើកលែងការសម្លាប់ដែលចង់មិនចង់នាំឲ្យមានថមថយនូវការបង្ក្រាប" នៅពេល

---

ប.ក.ក ទេ *សូមមើល* ឯកសារ **D219/904** កំណត់ហេតុស្តាប់ចម្លើយ យឹម គួញ ឆ.១១៣)។ ឯកសារ **D219/263** កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.៥៤, ៥៦, ៥៨។ ឯកសារ **D219/894** កំណត់ហេតុស្តាប់ចម្លើយ កៅ ពន ឆ.១៩, ២២។

[409] អន៖ ឯកសារ **D219/982** កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៨-២៩ [សាក្សីគឺជាអតីតប្រធានកងតូចនៅស្រុកគាស់ក្រឡ និងបានឃើញ អន ដែលជាបញ្ជាការឃោធា "សម្លាប់ ឃើញចាប់យកទៅសម្លាប់"]។ នៅពេលដែលគាត់សួរ អន ថា "មិត្តឯងធ្វើឃាតករសម្លាប់ប្រជាជនហ្នឹង អ្នកណាចាត់តាំងមក។ [...] គាត់ថា ឈ្មោះ តា ទិត្យ ហ្នឹង។"]។ *សូមមើលផងដែរ* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤១៣។ ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦៩។ សាម៉ន៖ ឯកសារ **D219/368** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ុន ឆ.១៤១ [សាក្សីគឺជាពលករនៅទំនប់កង្កួត ដែលមេបញ្ជាការរបស់គាត់បានប្រាប់គាត់ថា យឹម ទិត្យ បានបញ្ជាឲ្យសម្លាប់៖ "មេកងរបស់ខ្ញុំបានរត់គេចខ្លួនហើយ តា សាម៉ន បានដេញសម្លាប់ពួកគាត់តាមបញ្ជារបស់ តា ទិត្យ។"] (*សូមមើលផងដែរ* ឯកសារ **D219/465** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ុន ឆ.៣៥។ ឯកសារ **D219/533** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ុន ឆ.២២០)។ ឯកសារ **D219/689** កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧២។

[410] ឯកសារ **D118/150** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ឆ.៦០ [សាក្សីគឺជាទាហានដែលធ្វើការស្និទ្ធនឹង តា ម៉ុក៖ "តាទិត បានយកកម្លាំងទាហានរបស់ខ្លួនឯងពីតាកែវមកជាមួយ តា ម៉ុក។"] (គូសបញ្ជាក់បន្ថែម)។

[411] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣២ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ យោងខាងក្រោម* ផ្នែក IV(ច)(២)។

ដែល យឹម ទិត្យ បានក្លាយជាលេខាតំបន់១ និងជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ[412]។ ការអះអាងខុសនេះមាននៅក្នុងផ្នែក "សំអាងហេតុ និងសេចក្តីសន្និដ្ឋានបញ្ហាយុត្តាធិការបុគ្គល" នៃដីកាសម្រេចលើកលែងចោទប្រកាន់ និងត្រូវបានអះអាងដើម្បីកាត់បន្ថយចំនួនសម្លាប់ ដែល យឹម ទិត្យ ទំនងជាទទួលខុសត្រូវ។ កំហុសអង្គហេតុនេះ រួមជាមួយនឹងកំហុសអង្គហេតុផ្សេងទៀត បាននាំឲ្យមានការខុសឆ្គោយរបស់តុលាការ។

147. ដីកាសម្រេចលើកលែងចោទប្រកាន់ *មិន* បានដកស្រង់ភស្តុតាងណាមួយពីសំណុំរឿង ០០៤ ដើម្បីគាំទ្រការអះអាងនេះទេ និងមិនបានយោងទៅលើឯកសារណាមួយដែល ខៀវ សំផន បានធ្វើសេចក្តីប្រកាសអំពីការបញ្ឈប់ការសម្លាប់ឡើយ។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទប្រកាន់នេះ បានផ្អែក *ទាំងស្រុង* លើការអះអាងនៅក្នុងកថាខណ្ឌ ៥០៨ នៃដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងសំណុំរឿង ០០៤/២ ទៅវិញ[413]។ ហើយ ដីកាសម្រេចលើកលែងចោទប្រកាន់នៃសំណុំរឿង ០០៤/២ *មិន* មានការយោងសំអាងណាមួយទៅសេចក្តីថ្លែងដែលបានអះអាងរបស់ ខៀវ សំផន នេះទេ។

148. លើសពីនេះទៀត ការលើកឡើងដោយមិនត្រឹមត្រូវនេះផ្ទុយទៅនឹងការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលបានបង្ហាញពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ឧទាហរណ៍ ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា (i) កម្មាភិបាលភូមិភាគនិរតីបានមកកាន់តែច្រើនឡើងៗ ដើម្បីបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ នៅពាក់កណ្តាលឆ្នាំ១៩៧៨[414] (ii) ការចាប់ខ្លួនមានសភាពកាន់តែច្រើនឡើងនៅពេលកម្មាភិបាលភូមិភានិរតីបានមកដល់[415] (iii) ការតស៊ូប្រឆាំងនឹងវៀតណាមកាន់តែខ្លាំងឡើងៗនៅក្នុងភូមិភាគពាយ័ព្យ ចាប់ពីពេលដែល យឹម ទិត្យ បានមកដល់រហូតដល់ចុងបញ្ចប់នៃរបបនេះ[416] (iv) កម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានប្រកាសថាជាជនក្បត់ជាតិ ដោយកម្មាភិបាលភូមិភាគនិរតី នៅវត្តគិរីរម្យនៅពាក់កណ្តាលឆ្នាំ ១៩៧៨ និងក្រោយមកត្រូវបានចាប់ខ្លួន និងជំនួស[417] (v) ការសម្លាប់បានកើនឡើង "យ៉ាងខ្លាំង" នៅមន្ទីរសន្តិសុខវត្ត

---

[412] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៨០។

[413] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រ ២៥០៦។

[414] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១។

[415] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣។

[416] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤។

[417] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨០។

បាណន់នៅពាក់កណ្ដាលឆ្នាំ ១៩៧៨[418] (vi) វត្តគាស់ក្រឡាត្រូវបានប្រើជាមន្ទីរសន្តិសុខ *ក្រោយពេល* ការមកដល់នៃកម្មាភិបាលភូមិភាគនិរតី[419] (vii) វត្តសម្ដេចបានចាប់ផ្ដើមប្រើជាកន្លែងឃុំខ្លួន និងសម្លាប់មនុស្សនៅពាក់កណ្ដាលឆ្នាំ ១៩៧៨[420] និងបន្ទាប់មក កម្មាភិបាលភូមិភាគពាយ័ព្យទាំងអស់ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់[421] (viii) អ្នកទោសស្ទើរតែទាំងអស់នៅក្នុងមន្ទីរសន្តិសុខធិបតីបានស្លាប់នៅចុងឆ្នាំ ១៩៧៨[422] (ix) ការចាប់ខ្លួនមានសភាពញឹកញាប់ជាងមុននៅរោងចក្រស្កសកំពង់គុលក្រោយឆ្នាំ ១៩៧៨[423] និង (x) កម្មាភិបាលភូមិភាគនិរតីបានចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យនៅក្នុងឃុំកំពង់ព្រៀង *ក្រោយ* ពាក់កណ្ដាលឆ្នាំ ១៩៧៨[424]។

149. ការសន្និដ្ឋាន *ជាទទ្បីករណ៍* ថា ដីកាសម្រេចលើកលែងចោទប្រកាន់បានផ្អែកលើឯកសារគណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ ដែលអះអាងអំពីការលើកលែងទោសដល់ជនទាំងឡាយណាដែលត្រូវបានចោទថាជាបណ្ដាញ សេ.អ៊ី.អា និង កា.ហ្សេ.បេ[425] ការអះអាងនេះនៅតែមិនត្រឹមត្រូវ។ ដីកាដំណោះស្រាយសំណុំរឿង០០២ បានកត់សម្គាល់ថា ឯកសារនេះ "ហាក់ចែងអំពីការអប់រំកែប្រែ ចំពោះអ្នកដែលបានចូលរួម សេ.អ៊ី.អា (CIA) កា.ហ្សេ.បេ (KGB) និងភ្នាក់ងារវៀតណាមមុនខែកក្កដា ឆ្នាំ១៩៧៨ ប៉ុន្តែសេចក្ដីណែនាំនេះបង្គាប់ឲ្យបក្ស និងប្រជាជនកម្ពុជាលុបបំបាត់ខ្សែបណ្ដាញទាំងឡាយដែលបន្តប្រឆាំងនឹងបក្ស ចាប់ពីខែកក្កដា ឆ្នាំ១៩៧៨ តទៅ"[426]។ ហើយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រមសំណុំរឿង០០២/០២ របស់ខ្លួនបានកត់សម្គាល់ថា "បញ្ជីឈ្មោះអ្នកជាប់ឃុំរបស់មន្ទីរ ស-២១ បញ្ជាក់ថា ការចាប់ខ្លួនបានបន្តនៅទូទាំងប្រទេស [...] ក្រោយខែមិថុនា ឆ្នាំ១៩៧៨ រហូតដល់ចុងរបប"[427]។

---

[418] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៤។

[419] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៥៥។

[420] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៦។

[421] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៩។

[422] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ២៧៣។

[423] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៦។

[424] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៩។

[425] ឯកសារ **D6.1.473** សេចក្ដីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីសកម្ពុជា អំពីគោលនយោបាយរបស់បក្ស ចុះខែមិថុនា ឆ្នាំ១៩៧៨។

[426] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៩១៩។

[427] សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ១៤៦៨។

150. ដីកាសម្រេចលើកលែងចោទប្រកាន់ផ្អែកលើការលើកឡើងដែលគ្មានការសំអាង ដែលផ្ទុយទៅនឹងការសន្និដ្ឋានផ្ទាល់របស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលបង្កើតបានជាកំហុសអង្គហេតុដែលរួមគ្នាជាមួយកំហុសអង្គហេតុផ្សេងទៀត នាំឱ្យមានការខុសឆ្គោយរបស់តុលាការ។ ជាងនេះទៀត ការសន្និដ្ឋានខុសរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលថា យឹម ទិត្យ មានការទទួលខុសត្រូវតិចតួចចំពោះការសម្លាប់ទាំងនេះ ដោយសំអាងលើការលើកឡើងដែលគ្មានការគាំទ្រនេះ រួមជាមួយនឹងកំហុសអង្គហេតុផ្សេងទៀត នាំឱ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។

151. សរុបមក ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុជាច្រើន ដាច់ដោយឡែក ឬរួមបញ្ចូលគ្នា នាំឱ្យមានការខុសឆ្គោយរបស់តុលាការ និងនាំឱ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។

## ច. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយផ្តល់ទម្ងន់លើអង្គហេតុដែលមានភាពពាក់ព័ន្ធតិចតួច

152. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយការផ្តល់ទម្ងន់ណាមួយ ឬទម្ងន់ច្រើនហួសទៅលើអង្គហេតុជាច្រើនដែលមានភាពពាក់ព័ន្ធតិចតួច នៅពេលធ្វើសេចក្តីសម្រេចរបស់ខ្លួនលើយុត្តាធិការបុគ្គល។ កំហុសអង្គច្បាប់នេះ តែឯង ឬ រួមបញ្ចូលគ្នា នាំឱ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងនាំឱ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

### ១. ការរកឃើញថា យឹម ទិត្យ មិនមែនជាសមាជិកម្នាក់នៃសភាតំណាងប្រជាជន

153. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយការផ្តល់ទម្ងន់ណាមួយទៅលើអង្គហេតុដែលថា យឹម ទិត្យ មិនមែនជាសមាជិកសភាតំណាងប្រជាជន នៅពេលធ្វើការវាយតម្លៃលើយុត្តាធិការ[428] ទោះបីជាបានរកឃើញពីមុនមកថា សភានេះគ្រាន់តែជាស្ថាប័ននិមិត្តរូប ដែលបានជួបប្រជុំតែម្តងគត់ និង "ហាក់ដូចជាគ្មានសិទ្ធិអំណាចអ្វីទាំងអស់ ពីព្រោះថា អ្វីៗទាំងអស់ត្រូវ

[428] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧០។

ស្ថិតនៅក្រោមអំណាចនៃការដឹកនាំរបស់បក្ស"[429]។ អង្គហេតុដែលថា យឹម ទិត្យ មិនមែនជាសមាជិកនៃស្ថាប័នខ្សែបន្ទាត់មិនច្បាស់លាស់ និងគ្មានអំណាចនេះ មិនបាននិយាយអ្វីទាំងអស់អំពីកម្រិតនៃការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ កំហុសនេះ រួមជាមួយនឹងកំហុសអង្គច្បាប់ផ្សេងទៀត បាននាំឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព។

154. លើសពីនេះទៀត ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ក្នុងសំណុំរឿង ០០៤/១ ស.ច.ស បានខកខានមិនបានពិចារណាថា អ៊ឹម ចែម ធ្លាប់ជាសមាជិកសភាតំណាងប្រជាជន[430]។ ការយោងរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ទៅ យឹម ទិត្យ ថាមិនមែនជាសមាជិកនៃស្ថាប័នដូចគ្នានេះ ដូច្នេះបានបង្ហាញពីវិធីសាស្ត្រមិនស៊ីសង្វាក់គ្នាចំពោះកត្តានេះ ដោយការវាយតម្លៃថាមានពាក់ព័ន្ធក្នុងពេលមួយ និងបដិសេធក្នុងពេលមួយផ្សេងទៀត។

155. កំហុសអង្គច្បាប់ដែលផ្តល់ទម្ងន់ទៅ យឹម ទិត្យ ថា មិនមែនជាសមាជិកសភាតំណាងប្រជាជន រួមជាមួយនឹងកំហុសអង្គច្បាប់ផ្សេងទៀត បាននាំឲ្យដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាព និងនាំឲ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

### ២. ការសន្និដ្ឋានថា យឹម ទិត្យ មិនមានតួនាទីក្នុងកងទ័ព

156. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ដោយការផ្តល់ទម្ងន់ច្រើនហួសទៅលើអង្គហេតុដែលថា យឹម ទិត្យ គ្មានតួនាទីក្នុងកងទ័ព[431]។ ភស្តុតាងបង្ហាញថា ជាទូទៅ គណៈកម្មាធិការភូមិភាគ និងតំបន់ "បញ្ជាអង្គភាពប្រដាប់អាវុធ" និង "ការទទួលបន្ទុកទូទៅ" លើគ្រប់បញ្ហាទាំងអស់នៅក្នុងយុត្តាធិការរបស់ខ្លួនទោះបីជាទាហាន ឬជនស៊ីវិលក៏ដោយ"[432]។ ក៏មានភស្តុតាងសំខាន់ៗបញ្ជាក់ថា យឹម ទិត្យ មានសិទ្ធិអំណាចជាពិសេសលើកងកម្លាំងយោធា និងបានចេញបញ្ជាទៅកាន់កងកម្លាំងយោធានៅក្នុងតំបន់ដែលគាត់សកម្ម។ ក្មួយប្រុសរបស់ តា ម៉ុក បានថ្លែងថា

---

[429] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១២៤។ *សូមមើលផងដែរ* កថាខណ្ឌ ១១៩-១២៥។

[430] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់របស់ចៅក្រមអន្តរជាតិ កាថខណ្ឌ ៣០២។

[431] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧០ [យឹម ទិត្យ "គ្មានតួនាទីអ្វីក្នុងកងទ័ព។"]។

[432] ឯកសារ **D1.3.15.1** របាយការណ៍វិភាគជាលាយលក្ខណ៍អក្សររបស់ Craig C. Etcheson កថាខណ្ឌ ៦៧, ៤៩-៥០។

យឹម ទិត្យ បានកោះហៅមេដឹកនាំយោធាមកប្រជុំនៅសកលវិទ្យាល័យបាត់ដំបង[433]។ អតីតលេខាស្រុកបវិល (ក្នុងតំបន់ ៣) បានថ្លែងថា យឹម ទិត្យ ទទួលខុសត្រូវយោធាតំបន់ ៣[434]។ កម្មករកងចល័តម្នាក់ក្នុងស្រុកសង្កែ (ក្នុងតំបន់ ១) បានថ្លែងថា យឹម ទិត្យ ទទួលខុសត្រូវលើយោធានៅទីនោះ[435]។ អតីតប្រធានកងអនុសេនាតូចក្នុងស្រុកគាស់ក្រឡ (ក្នុងតំបន់ ១) បានផ្ដល់ភ័ស្តុតាងថា យឹម ទិត្យ បានចេញបញ្ជាសម្លាប់ទៅកាន់បញ្ជាការយោធាកងធំស្រុកគាស់ក្រឡ និងថា មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់ដោយសារតែបញ្ជាទាំងនោះ[436]។ ទាហានថ្នាក់ភូមិភាគម្នាក់បាននិយាយថា "តាទិត នាំកម្លាំងរបស់គាត់ដោយផ្ទាល់" មកពិនិត្យមើលស្ថានភាពរោងចក្រស្ករសកំពង់គុល (ក្នុងតំបន់ ១)[437]។ តាមពិត ដីកាដំណោះស្រាយសំណុំរឿង០០២ បានទទួលស្គាល់ថា កម្មាភិបាល

---

[433] ឯកសារ **D118/150** កំណត់ហេតុស្ដាប់ចម្លើយ ហែម មឿន ឆ.៦១ [សាក្សីគឺជាក្មួយប្រុសរបស់ តា ម៉ុក និងបានធ្វើដំណើរយ៉ាងច្រើនជាមួយ តា ម៉ុក៖ "តា ម៉ុក បានប្រកាសប្រាប់យោធាថា "បើអស់ពីអញទៅ តា ទិត ជាអ្នកទទួលខុសត្រូវភូមិភាគបន្ទាប់"។ តា ទិត ធ្លាប់បានហៅមេៗយោធាទៅប្រជុំនៅបាត់ដំបងនៅបរិវេណសាលាសកល។"]។

[434] ឯកសារ **D219/294** កំណត់ហេតុស្ដាប់ចម្លើយ មូល អេង ឆ.៣៦ [លេខាស្រុកបវិល] ឆ.១៩០-១៩៣ ["ស៖ អ៊ីចឹង តើដូចជា យឹម ទិត ដែលគាត់ជាគណ:តំបន់ គាត់មានសិទ្ធិអំណាចក្នុងការបញ្ជូនយោធា ដើម្បីឱ្យចាប់ខ្លួន ឬក៏មានសិទ្ធបញ្ជូនទ័ពមកដោះស្រាយបញ្ហាសន្តិសុខដែរឬទេ? ឆ.១៩០៖ បាទ គាត់មានសិទ្ធិ។ គណ:តំបន់ណាក៏មានសិទ្ធិធ្វើដូច្នេះដែរ។ ឆ៖ អ៊ីចឹង លោកចង់និយាយថា គណ:តំបន់ មានសិទ្ធគ្រប់គ្រងលើយោធាតំបន់ទៀត ឬ? ឆ.១៩១៖ បាទ គេមានសិទ្ធិលើយោធាតំបន់។ [...] ឆ.១៩២៖ នៅតំបន់ ៣ គឺមានកងអនុសេនាធំ ដែលមានទាហានប្រហែល ១២០នាក់។ ស៖ អ៊ីចឹង តើតំបន់មួយៗនៅក្នុងភូមិភាគហ្នឹង សុទ្ធតែមានកងអនុសេនាធំមួយៗទាំងអស់ឬ? ឆ.១៩៣៖ បាទ មានអ៊ីចឹងគ្រប់កន្លែង។ ទោះអ៊ីចឹងក៏ដោយ ប៉ុន្តែ តា ម៉ុក មានសិទ្ធិបញ្ជាលើយោធាទាំងអស់ ហើយគាត់ដាក់បញ្ជាទៅថ្នាក់ខេត្ត ឱ្យគ្រប់គ្រងលើយោធាជំនួសគាត់។"]។

[435] ឯកសារ **D219/538** កំណត់ហេតុស្ដាប់ចម្លើយ សឿន ម៉ត ឆ.២០. ៣៨, ៥៦ [សឿន ម៉ត គឺជាកម្មករកងចល័តក្នុងស្រុកសង្កែ៖ "ឆ.២០៖ [...] តា ទិត្យ ជាអ្នកគ្រប់គ្រងខាងទ័ព [...] ឆ.៣៨៖ [...] ប្រជាជនគ្រប់គ្នាស្គាល់ឈ្មោះ តា ទិត្យ ជាមេទ័ពខ្លាំង។ [...] ឆ.៥៦៖ មេភូមិ មេកង បាននិយាយលើកឡើងអំពីកងទ័ពរបស់ តា ទិត្យ ដូច្នេះ ហើយទើបខ្ញុំដឹងថាគាត់ជាមេទ័ព។"]។

[436] ឯកសារ **D219/982** កំណត់ហេតុស្ដាប់ចម្លើយ សៅ ជាប់ ឆ.២៦-៣៣ [សាក្សីគឺជាអតីតប្រធានកងតូចក្នុងស្រុកគាស់ក្រឡ និងបានឃើញ អន ដែលជាមេបញ្ជាការយោធា "សម្លាប់ ហើយចាប់យកទៅសម្លាប់"។ នៅពេលដែលគាត់សួរ អន "មិត្តឯងធ្វើឃាតករសម្លាប់ប្រជាជន អ្នកណាចាត់តាំងមក [...] គាត់ថា ឈ្មោះ ទិត្យ ហ្នឹង" "រាប់ពាន់នាក់" ត្រូវបានសម្លាប់។]។

[437] ឯកសារ **D118/106** កំណត់ហេតុស្ដាប់ចម្លើយ ហួន ជឿម ឆ.១២ ["យោធាភូមិភាគប្រាប់ខ្ញុំថា តា ទិត នាំកម្លាំងរបស់គាត់ដោយផ្ទាល់ គាត់មកមើលស្ថានការណ៍នៅរោងចក្រស្ករសកំពង់គល់ [...] តា ទិត បានចាត់តាំង នារី យ៉ាន មកពីនិរតីឱ្យកាន់ក្ដាប់កន្លែងរោងចក្រស្ករសនោះជំនួសវិញ។"] (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ឯកសារ **D381** ដីកាដំណោះស្រាយកថាខណ្ឌ ៣៣២។

ស៊ីវិលអាចគ្រប់គ្រងលើកងទ័ព[438]។ ដោយហេតុថា យឹម ទិត្យ មានសិទ្ធិអំណាចលើកម្លាំងយោធាពាក់ព័ន្ធទៅនឹងតំបន់ប្រតិបត្តិការរបស់គាត់ និងឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់នោះ អង្គហេតុដែលថាគាត់មិនមានតួនាទីនៅក្នុងកងទ័ពមជ្ឈិម (កងទ័ពបដិវត្តកម្ពុជា) មានភាពពាក់ព័ន្ធតិចបំផុតទៅនឹងការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ កំហុសអង្គច្បាប់នេះ រួមជាមួយនឹងកំហុសអង្គច្បាប់នានាផ្សេងទៀត បាននាំឱ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងនាំឱ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ៣. ការសន្និដ្ឋានដែលថា យឹម ទិត្យ មិនជាប់ពាក់ព័ន្ធក្នុងការរៀបចំការផ្ទេរកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ

157. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយផ្តល់ទម្ងន់ណាមួយទៅលើការសន្និដ្ឋានថា យឹម ទិត្យ មិនជាប់ពាក់ព័ន្ធក្នុងការរៀបចំការផ្ទេរកម្មាភិបាលភូមិភាគនិរតី ទៅកាន់ភូមិភាគពាយ័ព្យ និងថា ការរៀបចំទាំងអស់នេះផ្ទុយទៅវិញត្រូវបានធ្វើឡើងដោយ តា ម៉ុក នៅពេលវាយតម្លៃលើយុត្តាធិការបុគ្គល[439]។ ចំណុចនេះក៏មិនពាក់ព័ន្ធទៅនឹងការពិចារណាជារួមចំពោះថាតើ យឹម ទិត្យ ស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណា។ អង្គហេតុដែលថា យឹម ទិត្យ មិនបានចូលរួមក្នុងការរៀបចំការផ្ទេរនេះ មិនផ្លាស់ប្តូរអង្គហេតុដែលថា គាត់បានចូលរួមក្នុងឧក្រិដ្ឋកម្មនានាតាមវិធីជាច្រើនអនេកផ្សេងទៀត និងកាន់តែធ្ងន់ធ្ងរទៅទៀត។ កំហុសអង្គច្បាប់នេះ រួមជាមួយនឹងកំហុសអង្គច្បាប់ផ្សេងទៀត បាននាំឱ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងនាំឱ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

---

[438] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣ ["ទ័ពរបស់ភូមិភាគ [...] គឺជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋបាលភូមិភាគ"] ១៣៥ ["កងឈ្លប [...] ត្រូវបានគេហៅឱ្យបំពេញការងារសន្តិសុខរដ្ឋបាលស៊ីវិល។"]។ *សូមមើលផងដែរ* ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧ ["តា វ៉ាញ លេខាតំបន់១ ជាមេបញ្ជាការយោធាតំបន់"] ១៦៤។

[439] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០។

## ៤. ការសន្និដ្ឋានដែលថា ការបោសសម្អាតបានចាប់ផ្តើមមួយផ្នែករួចទៅហើយ និងទីតាំងឧក្រិដ្ឋកម្មខ្លះបានដំណើរការរួចហើយមុនការមកដល់ភូមិភាគពាយ័ព្យរបស់ យឹម ទិត្យ

158. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយការផ្តល់ទម្ងន់ណាមួយទៅលើអង្គហេតុដែលថា ទីតាំងខ្លះក្នុងចំណោមទីតាំងទាំងឡាយ ដែល យឹម ទិត្យ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម បានកើតឡើងរួចហើយមុនពេលគាត់មកដល់ភូមិភាគពាយ័ព្យ និងថា ផ្នែកខ្លះនៃការបោសសំអាតបានចាប់ផ្តើមអនុវត្តមុនការមកដល់របស់ យឹម ទិត្យ[440]។ ជាថ្មីម្តងទៀត យ៉ាងច្រើនបំផុតនោះ ចំណុចនេះមានភាពពាក់ព័ន្ធតិចតួចបំផុត។ អ្វីដែលសំខាន់នោះគឺអង្គហេតុដែលថា យឹម ទិត្យ បានបន្តអនុវត្តយ៉ាងសាទរ និងបានបង្កើនកម្លាំងនៃគោលនយោបាយបោសសម្អាត ក្រោយការមកដល់របស់គាត់ក្នុងភូមិភាគពាយ័ព្យ។ កំហុសអង្គច្បាប់នេះ រួមជាមួយនឹងកំហុសអង្គច្បាប់ផ្សេងទៀត បាននាំឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងនាំឲ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ៥. ការសន្និដ្ឋានដែលថា មានកម្មាភិបាលប្រមាណ ១០០ នាក់ ដែលបានបម្រើការនៅថ្នាក់តំបន់ និងថ្នាក់ភូមិភាគ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

159. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយការផ្អែកសេចក្តីសន្និដ្ឋានលើយុត្តាធិការរបស់ខ្លួនលើអង្គហេតុដែលថា យឹម ទិត្យ ស្ថិតក្នុង "ចំណោមមនុស្សយ៉ាងតិច ១០០ រូបក្នុងកម្រិតភូមិភាគ ឬតំបន់[441]" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា ចំណុចនេះមានន័យថា យឹម ទិត្យ មិនសំខាន់ទេ ហើយដូច្នេះមិនបំពេញតាមលក្ខខណ្ឌតម្រូវផ្អែកយុត្តាធិការរបស់ អ.វ.ត.ក ទេ។ វិធីសាស្ត្រនេះខកខានមិនបានឲ្យតម្លៃលើភាពខុសគ្នាយ៉ាងខ្លាំងនៃអំណាចក្នុងចំណោមមនុស្សទាំង ១០០ នាក់ទាំងនេះ (ទោះជាយ៉ាងនេះក្តី ជាចំនួនដែលមិនមានភស្តុតាងយោងបញ្ជាក់) និងថា យឹម ទិត្យ ស្ថិតក្នុងចំណោមអ្នកមានអំណាចបំផុត។ ខណៈដែលកម្មាភិបាលផ្សេងទៀតត្រូវបានបោសសម្អាត ចាប់ខ្លួន និងសម្លាប់ យឹម ទិត្យ ត្រូវបានតម្លើងតួនាទីកាន់តែសំខាន់ជាងមុន និងបានអនុវត្តអំណាចកាន់តែខ្លាំងជាងមុន។ ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ថា កម្មាភិបាលទាំងនេះទទួលខុសត្រូវដូចគ្នាចំពោះឧក្រិដ្ឋកម្មនានានៃរបបកម្ពុជាប្រជាធិបតេយ្យ មិនសមហេតុផលឡើយ។ កំហុសអង្គច្បាប់នេះ រួមជាមួយ

[440] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥, ៦៧៣។

[441] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧១។

នឹងកំហុសអង្គច្បាប់ផ្សេងទៀត បាននាំឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងនាំឲ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្ដីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

## ៦. ការសន្និដ្ឋានដែលថា សាក្សីមួយចំនួនមិនបានឮអំពី យឹម ទិត្យ

160. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយការផ្ដល់ទម្ងន់ណាមួយទៅលើអង្គហេតុដែលថា សាក្សីមួយចំនួនមិនបានឮអំពី យឹម ទិត្យ[442]។ កំហុសនេះ រួមជាមួយនឹងកំហុសអង្គច្បាប់ផ្សេងទៀត បាននាំឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព។

161. ដោយមិនបានធ្វើការវិភាគអំពីថាតើ សាក្សីនីមួយៗក្នុងចំណោមសាក្សីទាំងអស់នោះ អាចស្ថិតក្នុងតួនាទីស្គាល់ ឬឮអំពី យឹម ទិត្យ ឬយ៉ាងណា ការផ្អែកលើរបស់ដីកាសម្រេចលើកលែងចោទប្រកាន់លើការរកឃើញនេះតែឯង មិនសមហេតុផល ជាពិសេស ដោយសារតែវាក៏បានរកឃើញថា "សាក្សីចំនួនប្រហែល ២៤រូប បានអះអាងថាស្គាល់ តា ទិត្យ"[443]។ ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា ការសម្ងាត់គឺជាគោលការណ៍ប្រតិបត្តិមួយក្នុងចំណោមគោលការណ៍ប្រតិបត្តិនានានៃផែនការឧក្រិដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យ "ការបោសសម្អាតមិនត្រូវប្រកាសឲ្យដឹងទេ ដោយសារជារឿងសម្ងាត់"[444] ហើយប្រព័ន្ធប្រាស្រ័យទំនាក់ទំនង និងខ្សែសង្វាក់នៃការបញ្ជាត្រូវបានកំណត់ថ្នាក់ដោយ "គោលការណ៍រក្សាការសម្ងាត់ជាប់មកជាមួយ ដែលជាទូទៅពុំអនុញ្ញាត ឬយ៉ាងហោចណាស់ពុំលើកទឹកចិត្ត [...] ដល់ការផ្លាស់ប្ដូរព័ត៌មានយុទ្ធសាស្ត្រ និងប្រតិបត្តិ តាមលក្ខណៈសមភាពនៃខ្សែទទឹងទៅតាមថ្នាក់ក្រោមៗនៃការដឹកនាំថ្នាក់លើ"[445]។ តាមពិត របបនោះមានភាពសម្ងាត់ខ្លាំង ដែលមនុស្សតិចបំផុតបានឮអំពី ប៉ុល ពត ខ្លួនគាត់ផ្ទាល់រហូតដល់ឆ្នាំ ១៩៧៧ ប៉ុន្តែ អង្គហេតុនេះមិនបានធ្វើឲ្យ ប៉ុល ពត ទទួលខុសត្រូវតិចជាងមុនណា

---

[442] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧២, ៦៧៦។

[443] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៧២។ វាមិនច្បាស់លាស់ថាតើ ដីកាសម្រេចលើកលែងចោទប្រកាន់មានន័យដូចម្ដេចចំពោះពាក្យថា "បានស្គាល់" យឹម ទិត្យ ប៉ុន្តែយ៉ាងហោចណាស់សាក្សី ៥០នាក់ បានឮអំពី យឹម ទិត្យ ផ្អែកតាមបទពិសោធន៍ផ្ទាល់របស់ពួកគេ ឬការដឹងពីបុគ្គលផ្សេងទៀត។ *សូមមើល* **ឧបសម្ព័ន្ធ** ៣។

[444] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២។

[445] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៦៥។

មួយចំពោះឧក្រិដ្ឋកម្មរបស់របបនោះឡើយ[446]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានក្នុងសំណុំរឿង ០០២/០១ ថា៖

> ក្នុងករណីខ្លះ ប្រជាជនធម្មតាអាចដឹងព័ត៌មានតិចតួចប៉ុណ្ណោះអំពីរចនាសម្ព័ន្ធថ្នាក់ដឹកនាំ ដោយពួកគាត់ត្រូវបានគេតម្រូវឱ្យអនុវត្តតាម ដោយមិនត្រូវសាកសួរអំពីការសម្រេចនានារបស់ "អង្គការ" ដែលជាស្ថាប័នអនាមិក ដែលត្រូវបានគេមើលឃើញថាមានអំណាចត្រួតត្រាសង្គមទាំងមូលនោះទេ។ កម្មាភិបាលថ្នាក់ក្រោមពេលខ្លះគ្រាន់តែយល់ដឹងតិចតួចអំពីការរៀបចំចាត់ចែងអំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ[447]។

162. ស្រដៀងគ្នានេះ នៅក្នុងសំណុំរឿងនេះ គោលការណ៍នៃការសម្ងាត់ ពន្យល់ពីមូលហេតុដែលថាមិនមែនសាក្សីគ្រប់គ្នានៅក្នុងសំណុំរឿងនេះបានឮអំពី យឹម ទិត្យ ឡើយ។ ប៉ុន្តែ នៅពេលដែលភស្តុតាងត្រូវបានវាយតម្លៃជារួមដោយយកចិត្តទុកដាក់អំពីវិសាលភាពនៃការដឹងរបស់សាក្សីម្នាក់ៗ ដោយពិចារណាទៅលើអ្វីដែលសាក្សីត្រូវបានរំពឹងថាបានដឹងនោះ រូបភាពនៃអំណាច និង តួនាទីរបស់ យឹម ទិត្យ មានលក្ខណៈច្បាស់លាស់។ សាក្សីដែលត្រូវបានរំពឹងទុកថាស្គាល់ ឬដឹងអំពី យឹម ទិត្យ ជាទូទៅពិតជាបានដឹង ឬស្គាល់ដូច្នោះមែន។ អ្នកដែលមិនត្រូវបានរំពឹងទុកថាបានស្គាល់គាត់ពេលខ្លះមិនបានស្គាល់គាត់ទេ។ ដោយយោងទៅលើការសន្និដ្ឋានផ្ទាល់របស់ដីកាសម្រេចលើកលែងចោទប្រកាន់អំពីការសម្ងាត់ វាគឺជាកំហុសមួយក្នុងការផ្តល់ទម្ងន់ទៅលើអង្គហេតុសាមញ្ញដែលថាសាក្សីមួយចំនួនមិនបានដឹងអំពី យឹម ទិត្យ ក្នុងការវាយតម្លៃលើយុត្តាធិការ។ កំហុសអង្គច្បាប់នេះបាននាំឱ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងនាំឱ្យមានផលប៉ះពាល់ ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

163. សរុបមក ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយការផ្តល់ទម្ងន់ណាមួយ ឬការផ្តល់ទម្ងន់ច្រើនហួសទៅលើអង្គហេតុជាច្រើនដែលមានភាពពាក់ព័ន្ធតិចតួច។ កំហុសអង្គច្បាប់ទាំងអស់នេះ តែឯង ឬរួមបញ្ចូលគ្នា បាននាំឱ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព និងនាំឱ្យមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានរបស់ខ្លួនថា យឹម ទិត្យ ស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។

---

[446] ឯកសារ **D6.1.596** David P. Chandler, *បងធំលេខ ១ ឆ្នាំ ១៩៩៩* EN ERN 00392916។ ឯកសារ **D219/370.1.70** Gina Chon និង ថេត សម្បត្តិ *នៅពីក្រោយវាលពិឃាត* ឆ្នាំ ២០១០ EN ERN 00757527។

[447] សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៩៩។

## V. ផលវិបាកផ្នែកច្បាប់នៃដីកាដំណោះស្រាយខ្វែងគ្នា

164. ដោយយោងទៅលើសំអាងហេតុនានាដែលបានរៀបរាប់នៅក្នុងបណ្ដឹងឧទ្ធរណ៍នេះ ស.ព.អ សន្និដ្ឋានថា ការរកឃើញរបស់ដីកាសម្រេចលើកលែងចោទប្រកាន់លើយុត្តាធិការបុគ្គល គួរត្រូវបានបដិសេធចោល។ ប្រសិនបើបណ្ដឹងឧទ្ធរណ៍នេះត្រូវបានតម្កល់ ច្បាស់ណាស់ថា សំណុំរឿងនេះគួរត្រូវបញ្ជូនទៅកាន់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ការជំនុំជម្រះ ដោយឈរលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង យឹម ទិត្យ។ ទោះជាយ៉ាងនេះក្ដី ស.ព.អ កត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះក៏ត្រូវប្ដឹងឧទ្ធណ៍ដោយ យឹម ទិត្យ និង ស.ព.ជ ផងដែរ។ ស.ព.អ កត់សម្គាល់ថា អាចមានសេណារីយ៉ូពីរ ដែលក្នុងនោះ សូម្បីតែក្រោយពេលដែលអង្គបុរេជំនុំជម្រះសម្រេចលើបណ្ដឹងឧទ្ធរណ៍ទាំងអស់ក្នុងរឿងក្ដីនេះ ដីកាដំណោះស្រាយដែលខ្វែងគ្នាទាំងពីរនឹងនៅតែមានអនុភាព។ សេណារីយ៉ូទីមួយអាចកើតឡើង ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកសម្លេងភាគច្រើនដែលតម្រូវដោយកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និង វិធានផ្ទៃក្នុង សម្រាប់សេចក្ដីសម្រេចរបស់ខ្លួន។ សេណារីយ៉ូទីពីរនឹងកើតឡើង ប្រសិនបើអង្គបុរេជំនុំជម្រះធ្វើការសម្រេចបដិសេធបណ្ដឹងឧទ្ធរណ៍ទាំងអស់ ដោយសន្និដ្ឋានថាទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់បានប្រព្រឹត្តតាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតរៀងខ្លួន។ ដូចបានពន្យល់ខាងក្រោម ប្រសិនបើស្ថានភាពណាមួយកើតឡើង បទប្បញ្ញត្តិពាក់ព័ន្ធនៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា រឿងក្ដីនេះត្រូវបន្តទៅជំនុំជម្រះលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ចំណុចនេះស្របគ្នាទៅនឹងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ។

165. វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចែងថា៖

> សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤(បួន)រូបយ៉ាងតិច។ សេចក្ដីសម្រេចនេះត្រូវបិទផ្លូវតវ៉ា ។ ប្រសិនបើសំឡេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖
>
> ក- ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ ។

ខ-ក្នុងករណីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសំឡេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

166. វិធាន ១ (២) នៃវិធានផ្ទៃក្នុងចែងបន្ថែមទៀតថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះ ចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ" ។ ដូច្នេះ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងអនុវត្តចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចេញដោយ ស.ច.ស តែម្នាក់ដូចគ្នានឹងករណីបច្ចុប្បន្ននេះ។ ដូច្នេះ វិធាន ៧៧(១៣)(ខ) បញ្ជាក់ច្បាស់ថា ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសេចក្ដីសម្រេចសំឡេងភាគច្រើន នៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ទេនោះ រឿងក្ដីប្រឆាំងនឹង យឹម ទិត្យ នឹងត្រូវបញ្ជូនទៅជំនុំជម្រះ។

167. ការសន្មត *ជាទម្លាក់ករណ៍* ថា ពាក្យពេចន៍ "ដីកា" ក្នុងវិធាន៧៧(១៣)(ក) នៃវិធានផ្ទៃក្នុងរួមបញ្ចូលដីកាសម្រេចលើកលែងចោទប្រកាន់[448] វិធាន ៧៧(១៣)(ខ) គឺជា *គោលការណ៍នៃការបកស្រាយច្បាប់* ទាក់ទងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងហេតុដូច្នេះ មានសារៈសំខាន់ជាងពាក្យពេចន៍ទូទៅរបស់វិធាន ៧៧(១៣)(ក)។ "ដីកាសម្រេចលើកលែងចោទប្រកាន់" និង "ដីកាដំណោះស្រាយ" ដូចគ្នានឹង "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" គឺជាពាក្យដែលបានកំណត់និយមន័យនៅក្នុងវិធានផ្ទៃក្នុង[449]។ ប្រសិនបើអ្នកធ្វើសេចក្ដីព្រៀងវិធានផ្ទៃក្នុងមានបំណងដោះស្រាយយ៉ាង

---

[448] ស.ព.អ កត់សម្គាល់ថា សំណៅជាភាសាបារាំងនៃវិធាន ៧៧(១៣) និង ៧៧(១៣)(ក) អានថា៖ "Lorsque la majorité requise n'est pas atteinte, la Chambre préliminaire est présumée avoir rendu une décision s'interprétant comme suit: a) Concernant un appel contre une ordonnance ou une requête en annulation d'un acte d'instruction, *autre que l'ordonnance de clôture*, l'ordonnance ou l'acte d'instruction demeure" ដូច្នេះបានដកដីកាសម្រេចលើកលែងចោទប្រកាន់ចេញពីព្រំដែននៃវិធាន ៧៧(១៣)(ក)។ សំណៅជាភាសាខ្មែរ ដូចគ្នានឹងភាសាអង់គ្លេសដែរ សំដៅលើ "ដីកា ឬកិច្ចស៊ើបសួរ *ដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ*" ទុកឲ្យដីកាសម្រេចលើកលែងចោទប្រកាន់ស្ថិតក្នុងវិសាលភាពនៃវិធាននោះ។ ក្នុងសំណុំរឿង០០៤/១ ក្នុងករណីដែល អ.ប.ជ មិនអាចធ្វើសេចក្ដីសម្រេចដោយសំឡេងភាគច្រើនបានលើបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ ក្នុងសំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ *អ៊ឹម ចែម* (ដីកាសម្រេចលើកលែងចោទប្រកាន់) អ.ប.ជ ជាឯកច្ឆន្ទ ("ប្រកាសថា ដីកាដំណោះស្រាយ (សំអាងហេតុ) លើកលែងចោទប្រឆាំងនឹង អ៊ឹម ចែម ត្រូវបានតម្កល់ទុក" ស្របតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង។ *សូមមើល* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍ របស់ *អ៊ឹម ចែម* ប្រឆាំងនឹងដីកាដំណោះស្រាយ ទំព័រ ៣៩ (ការសម្រេចជាឯកច្ឆន្ទ)។

[449] វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ៨៣-៨៤។

ជាក់លាក់លើផលប៉ះពាល់នៃការបរាជ័យរបស់អង្គបុរេជំនុំជម្រះក្នុងការបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់នោះ ពួកគាត់អាចធ្វើដូច្នោះបាន។ ហេតុដូច្នេះ សូម្បីក្នុងករណីដែលដីកាសម្រេចលើកលែងចោទប្រកាន់ដែលប្ដឹងឧទ្ធរណ៍មិនបានជោគជ័យ "ត្រូវបានតម្កល់" ជាកំណត់ត្រាមួយនៃការអនុវត្តឆន្ទានុសិទ្ធិឯករាជ្យរបស់ ស.ច.ស និងការសម្រេចមិនចូលរួមក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងបញ្ជាក់អំពីជម្រើសគោលនយោបាយថា ក្នុងករណីមានដីកាដំណោះស្រាយខ្វែងគ្នា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ហើយរឿងក្តីត្រូវតែជំនុំជម្រះ។ ចំណុចនេះត្រូវបានបង្ហាញដោយវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ដែលចែងថា "អង្គជំនុំជម្រះសាលាដំបូង*ត្រូវ*ទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"[450]។

168. យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់លើការបកស្រាយនេះ អំពីនីតិវិធីជាធរមាននៅពេលដែលមានដីកាដំណោះស្រាយខ្វែងគ្នា។ សាលដីកាបណ្តឹងសាទុក្ខសំណុំរឿង ០០១ សម្រេចថា៖

> ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា ដីកាសហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[451]។

169. ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលប្រើឃ្លា "ការស៊ើបអង្កេតត្រូវបន្ត" ដោយសារតែវាត្រូវបានដកស្រង់ផ្ទាល់ចេញពីច្បាប់ អ.វ.ត.ក ក៏ដោយ ក៏ការបកស្រាយសមហេតុផលតែមួយគត់នៃឃ្លា

---

[450] គូសបញ្ជាក់បន្ថែម។

[451] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ខុច* កថាខណ្ឌ ៦៥ *យោង* ច្បាប់ អ.វ.ត.ក មាត្រា ២៣*ថ្មី*។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។ ខណៈដែលការសន្និដ្ឋាននេះកើតចេញមកពីការពិភាក្សាអំពីសេណារីយ៉ោ ដែលថា ស.ច.ស ម្នាក់ ឬទាំងពីរនាក់ បានបញ្ជូនបញ្ហានៃការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាដំណោះស្រាយខ្វែងគ្នា ទៅកាន់ អ.ប.ជ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង លទ្ធផលជាសំខាន់អាចអនុវត្តបានដូចគ្នាចំពោះស្ថានភាពបច្ចុប្បន្ន ដោយ អ.ប.ជ បានទទួលយកបណ្តឹងឧទ្ធរណ៍របស់ភាគីនានា ដោយសារតែលក្ខណៈដែល អ.ប.ជ ត្រូវបានប្ដឹងអំពីបញ្ហាដូចគ្នា គឺថាតើចៅក្រមណាម្នាក់មានកំហុសក្នុងការចេញដីកាលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួននោះមិនពាក់ព័ន្ធឡើយ។

នេះគឺថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរបន្តទៅជំនុំជម្រះ។ មិនមានន័យណាផ្សេងទៀត ដែលអ្វីមួយអាច "បន្ត" នៅដំណាក់កាលដែលអង្គជំនុំជម្រះតុលាការកំពូលបានកំពុងពិភាក្សាឡើយ *គឺថា* នៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ខ្វែងគ្នា ត្រូវបានចេញ ហើយដីកាទាំងពីរត្រូវបានជំទាស់មិនជោគជ័យនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍។ ដោយហេតុថា វិធានផ្ទៃក្នុងកំណត់និយមន័យ "ដំណាក់កាលសវនាការ" ថា "សំដៅទៅលើកាលបរិច្ឆេទចាប់ពីពេលដែលអង្គជំនុំជម្រះទទួលបានសំណុំរឿង"[452] ការប្រកាសរបស់អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ខ្លួនបានចាត់ទុក "ការស៊ើបអង្កេត" នៅតែបន្តរហូតដល់ពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអាចកើតឡើងអនុលោមតាមវិធាន ៧៧(១៣)(ខ) ឬ ៧៩(១) នៃវិធានផ្ទៃក្នុង។

170. អង្គបុរេជំនុំជម្រះបានបកស្រាយពាក្យ "ការស៊ើបអង្កេត" ស្របទៅនឹងទស្សនៈនេះដែរ។ នៅក្នុងសំណុំរឿង ០០២ ក្នុងករណីដែល ស.ច.ស "ស្ថិតក្នុងការជាប់គាំងផ្នែកនីតិវិធី"[453] អង្គបុរេជំនុំជម្រះបានសម្រេចថា៖

> សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះទេ នៅពេលខ្លួនមិនព្រមព្រៀងគ្នាលើបញ្ហាណាមួយដែលនៅចំពោះមុខ ហើយក្នុងករណីនេះ សេចក្ដីសម្រេចនោះគឺថា "ការស៊ើបអង្កេតត្រូវតែបន្ត" ស្របទៅនឹងវិធីសាស្ត្រ ដែលសហចៅក្រមស៊ើបអង្កេតបានយកមកអនុវត្តនៅក្នុងករណីបច្ចុប្បន្ននេះ។[454]

171. "វិធីសាស្ត្រ" ដែលបានរៀបរាប់នេះ គឺត្រូវបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ[455]។ ដូច្នេះ អង្គបុរេជំនុំជម្រះបានបកស្រាយឃ្លា "ការស៊ើបអង្កេតត្រូវបន្ត" ដែលដូចអង្គជំនុំជម្រះតុលាការកំពូលដែរ ថារួមបញ្ចូលទាំងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅអង្គជំនុំជម្រះសាលាដំបូង។

---

[452] វិធានផ្ទៃក្នុង សន្ទានុក្រម ទំព័រ ៨៥។

[453] សំណុំរឿង០០២-ឯកសារ **D427/1/30** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧២។

[454] សំណុំរឿង០០២-ឯកសារ **D427/1/30** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤។

[455] សំណុំរឿង០០២-ឯកសារ **D427/1/30** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤។

172. លទ្ធផលនេះស្របគ្នាទៅនឹងស្មារតី និងរចនាសម្ព័ន្ធនៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និង វិធានផ្ទៃក្នុង។ ទាំងអស់នេះប្រកាន់ខ្ជាប់នូវគោលការណ៍ដែលថា ស.ច.ស (និងសហព្រះរាជអាជ្ញា) អាចបំពេញកិច្ចដោយឯករាជ្យ ដើម្បីបន្តកិច្ចដំណើរការនីតិវិធីទៅមុខ និងជាគោលនយោបាយជា ប្រយោជន៍ដល់កិច្ចដំណើរការនីតិវិធី ដើម្បីបន្តទៅមុខ ក្នុងករណីមិនអាចដោះស្រាយការខ្វែង យោបល់គ្នាបាន[456]។ ឋានៈស្មើគ្នារបស់ ស.ច.ស និងអាណត្តិការងារឯករាជ្យរបស់ពួកគាត់ត្រូវ បានបញ្ជាក់ដោយការទទួលស្គាល់ម្តងហើយម្តងទៀតនៅក្នុងអត្ថបទជាមូលដ្ឋានរបស់តុលាការនេះ ដែលថា ស.ច.ស អាចខ្វែងយោបល់គ្នាពីដំណើរការទៅមុខនៃកិច្ចដំណើរការនីតិវិធី។ ឧទាហរណ៍ មាត្រា (៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក បានប្រមើលពីស្ថានភាពដែល ស.ច.ស "មិនអាចទទួល បានការឯកភាពគ្នាជាឯកច្ឆ័ន្ទ" បានកំណត់ថា "ការស៊ើបអង្កេតត្រូវបន្ត" លើកលែងតែ ការខ្វែង យោបល់នោះមិនត្រូវបានប្តឹងទៅអង្គបុរេជំនុំជម្រះតាមត្រា ៧ ដែលបានចែងថា ប្រសិន បើសំឡេង ភាគច្រើនលើសលប់របស់អង្គបុរេជំនុំជម្រះមិនអាចដោះស្រាយការខ្វែងយោបល់គ្នារវាង ស.ច.ស បាន ដូច្នេះ "ការស៊ើបអង្កេត ឬការចោទប្រកាន់ត្រូវបន្ត"។ ដំណើរការនេះត្រូវបានរៀបចំឡើងវិញ នៅក្នុងមាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក។ វិធាន ៧២ និង ៧៧ នៃវិធានផ្ទៃក្នុង និងមាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក បញ្ជាក់ច្បាស់ថា ស.ច.ស *មិនត្រូវបានតម្រូវឱ្យ* បញ្ជូនបញ្ហាខ្វែងយោបល់ ទៅឱ្យអង្គបុរេជំនុំជម្រះដោះស្រាយទេ។ ដូច្នេះ ខណៈដែលការប្រើប្រាស់យន្តការដើម្បីដោះស្រាយ វិវាទគឺជាឆន្ទានុសិទ្ធិ កិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងកំណត់ស្របគ្នាថា ដំណើរការតុលាការ*ត្រូវ*បន្តទៅមុខ ក្នុងករណីដែល ស.ច.ស (ឬសហព្រះរាជអាជ្ញា) មិនអាច ឯកភាពគ្នាបាន ខណៈកំពុងបំពេញកិច្ច ក្នុងសមត្ថកិច្ចឯករាជ្យរបស់ពួកគាត់។ អង្គបុរេជំនុំជម្រះ បានតម្កល់គោលការណ៍នេះជាច្រើនដង[457]។

---

[456] *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤), ៦(៤), ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២០*ថ្មី*។ វិធាន ៧១-៧២, ៧៧ (១៣) នៃវិធានផ្ទៃក្នុង។

[457] *សូមមើល ឧទាហរណ៍* ឯកសារ **D1/1.3** ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហ ព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១៦, ២៦, ៤៥។ សំណុំរឿង ០០២-ឯកសារ **D427/1/30** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤-២៧៦។ ឯកសារ **A122/6.1/2** សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អ៊ឹម ចែម សុំផ្អាកការអនុវត្តដីកាកោះរបស់គាត់ ឱ្យមកបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៤។ ឯកសារ **D306/17.1/1/6.1.8** សេចក្តីសម្រេចលើ [កោសលុប] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ជនសង្ស័យពាក់ព័ន្ធនឹង ដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៦។ ឯកសារ **D212/1/2/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

173. ក្របខណ្ឌការងារនេះអនុវត្តចំពោះការចេញដីកាដំណោះស្រាយខ្វែងគ្នា។ ការសន្និដ្ឋានផ្សេងពីនេះនឹងធ្វើឲ្យប៉ះពាល់ដល់បទប្បញ្ញត្តិជាច្រើនពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាង ស.ច.ស ដូច្នេះនាំឲ្យដាក់កម្រិតដោយមិនត្រឹមត្រូវលើការអនុវត្តឯករាជ្យភាពរបស់ ស.ច.ស ម្នាក់ៗ និងមិនស្របទៅនឹងវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យ ស.ច.ស ចេញដីកាដំណោះស្រាយ "ចោទប្រកាន់ និងបញ្ជូនរឿងទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"។ ដូចដែលបានកត់សម្គាល់រួចមកហើយ វិធាន ១(២) នៃវិធានផ្ទៃក្នុង ចែងសំដៅទៅ ស.ច.ស "ទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ"។ អានរួមគ្នា វិធានផ្ទៃក្នុងប្រមើលពីស្ថានភាព ដែលក្នុងនោះ ស.ច.ស ម្នាក់ៗចេញដីកាដំណោះស្រាយ ដីកាមួយក្នុងចំណោមដីកាទាំងនោះ គឺត្រូវចោទប្រកាន់ និងមួយទៀតត្រូវលើកលែងចោទប្រកាន់។

174. ដូច្នេះ នៅក្នុងស្ថានភាពបច្ចុប្បន្នដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ប្រហាក់ប្រហែលគ្នាពី ស.ច.ស មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ផ្តល់ការណែនាំច្បាស់លាស់ចំពោះអ្វីត្រូវធ្វើ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចដោះស្រាយភាពមិនស្របគ្នារវាង ស.ច.ស បាន។ មាត្រានេះចែងថា "ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត"[458]។ ចាតើមានការចាត់ទុកថាការផ្ទេរដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ទៅអង្គជំនុំជម្រះសាលាដំបូង ជាផ្នែកមួយនៃការស៊ើបអង្កេត ដូចដែលអង្គជំនុំជម្រះតុលាការកំពូល និងអង្គបុរេជំនុំជម្រះបានសម្រេច ឬជាផ្នែកមួយនៃការចោទប្រកាន់ ឬយ៉ាងណានោះ ច្បាស់ណាស់ថា ប្រសិនបើអង្គបុរេជំនុំជម្រះខកខានមិនអាចបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើនលើសលប់នោះ អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលសំណុំរឿង ហើយរឿងក្តីនេះត្រូវបន្តទៅជំនុំជម្រះ។

---

អំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ៧។ ឯកសារ **D208/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ១១។

[458] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ ចំណុចនេះក៏ឆ្លុះបញ្ចាំងផងដែរអំពីការយល់របស់អ្នកចរចាម្នាក់ដ៏សំខាន់ក្នុងចំណោមអ្នកចរចានានារបស់ អ.ស.ប លើកិច្ចព្រមព្រៀង អ.វ.ត.ក គឺ លោក David Scheffer ដែលបានថ្លែងថា តាមវិធានស្តីពីសំឡេងលើសលុប "វិធីតែមួយគត់ដែលការចោទប្រកាន់ ឬការស៊ើបអង្កេតត្រូវបានឈប់ ប្រសិនបើ អង្គបុរេជំនុំជម្រះសម្រេចដោយសំឡេងលើសលប់ថា វាគួរបញ្ចប់។" *សូមមើល* David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទីបី វ៉ុល III ឆ្នាំ២០០៨ ទំព័រ ២៤៦។

175. ជាចុងក្រោយ លទ្ធផលនេះក៏ត្រូវបានកំណត់ដោយគោលបំណងដ៏សំខាន់នៃការបញ្ចប់និទណ្ឌភាពផងដែរ។ ដីកាសម្រេចកលើកលែងចោទប្រកាន់បានទទួលស្គាល់ថា "គោលបំណងដ៏ពិតប្រាកដនៃការបង្កើត អ.វ.ត.ក នេះឡើង គឺដើម្បីលុបបំបាត់វប្បធម៌និទណ្ឌភាពបទល្មើសអន្តរជាតិ"[459]។ ចំពោះរឿងក្តីមួយមិនអាចបន្តទៅមុខបាន ទោះបីជាមានអត្ថិភាព និងប្រសិទ្ធភាពបន្តនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងអស់រយៈពេលជាច្រើនឆ្នាំប្រឆាំងនឹងជនរងគ្រោះរាប់សិបពាន់នាក់ក្តី គឺជាការមាក់ងាយលើទស្សនៈនៃការទទួលខុសត្រូវ។ លើសពីនេះទៀត ដំណើរការរឿងក្តីបន្តទៅជំនុំជម្រះធ្វើឲ្យគោលបំណងដ៏សំខាន់នេះមានតុល្យភាពសមស្របជាមួយនឹងសិទ្ធិរបស់ជនត្រូវចោទ ដោយសារតែការជំនុំជម្រះនឹងផ្តល់ឲ្យជននោះនូវរាល់សិទ្ធិទាំងអស់ដែលគាត់ត្រូវមាន រួមទាំង សិទ្ធិទទួលបានសវនាការត្រឹមត្រូវនៅចំពោះមុខតុលាការមិនលម្អៀង ដោយចៅក្រមឯករាជ្យ សិទ្ធិដេញដោលភស្តុតាង និងត្រួតពិនិត្យសាក្សី សិទ្ធិទទួលបានការតំណាងដោយមេធាវីការពារក្តី និងលក្ខខណ្ឌតម្រូវចុងក្រោយដែលថា ភាគីចោទប្រកាន់ត្រូវតែបញ្ជាក់ភស្តុតាងរឿងក្តីរបស់ខ្លួនឲ្យហួសពីវិមតិសង្ស័យ។

## VI. សេចក្តីសន្និដ្ឋាន

176. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើន ដែល ដាច់ដោយឡែកពីគ្នា ឬរួមគ្នា បានធ្វើឲ្យសេចក្តីសម្រេចគ្មានសុពលភាព និង/ឬនាំឲ្យមានការខុសឆ្គោយរបស់តុលាការ និងមានផលប៉ះពាល់ដែលជាការកំណត់មូលដ្ឋានគ្រឹះនៃសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល។ ការកាត់បន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ យឹម ទិត្យ ដោយមិនត្រឹមត្រូវរបស់ដីកាសម្រេចលើកលែងចោទប្រកាន់នេះ ដែលបណ្តាលមកពីការបកស្រាយខុសលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ការខកខានជាច្រើនដងក្នុងការចេញសេចក្តីសម្រេចមានសំអាងហេតុទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើង និងការទទួលខុសត្រូវដែលអាចមានរបស់ យឹម ទិត្យ ការសំអាងមិនត្រឹមត្រូវទៅការបញ្ជា និងការបង្ខិតបង្ខំរបស់ថ្នាក់លើ ការផ្តល់ទម្ងន់ធ្ងន់ហួសទៅលើ "ការចូលរួមដោយផ្ទាល់" ក្នុងឧក្រិដ្ឋកម្ម និងភាពកៀកកិតទៅនឹងឧក្រិដ្ឋកម្ម ខណៈដែលបដិសេធ

---

[459] ឯកសារ **D381** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៣៦។ ស.ព.អ ទទួលស្គាល់ថា ស.ច.ស ទាំងពីរបានសម្រេចថា ដោយសារតែបញ្ហានិទណ្ឌភាពត្រូវបានប្រមើលមើលយ៉ាងច្បាស់ និងមានគោលបំណងនៅពេលបង្កើត អ.វ.ត.ក អត្ថិភាពនៃបញ្ហានេះមិនអាចជាកត្តាដែលមានឥទ្ធិពលដល់ការសន្និដ្ឋានអំពីយុត្តាធិការឡើយ។ ប៉ុន្តែ នោះគឺជាបញ្ហាដោយឡែកពីអ្វីដែលត្រូវកើតឡើងក្នុងស្ថានភាពដែល ស.ច.ស បានឈានដល់ការសម្រេចខ្វែងគ្នាលើបញ្ហាយុត្តាធិការបុគ្គល ហើយទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងទាំងដីកាសម្រេចលើកលែងចោទប្រកាន់ នៅតែមានអនុភាពបន្ទាប់ពីបណ្តឹងឧទ្ធរណ៍។ សំណុំរឿង ០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ *អ៊ឹម ចែម* កថាខណ្ឌ ២៦-៣៦។

មិនពិចារណាលើទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ កំហុសអង្គហេតុជាច្រើនផ្សេងទៀតលើបញ្ហានានាដែលសំខាន់ក្នុងការវិភាគអំពីយុត្តាធិការបុគ្គល និងការពិចារណាមិនសមស្របលើកត្តានានាដែលមានភាពពាក់ព័ន្ធតិចតួច។ កំហុសទាំងនេះបានបណ្តាលឲ្យមានការសន្និដ្ឋានខុសយ៉ាងច្បាស់ក្រឡែតថា យឹម ទិត្យ មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះ។

177. ផ្អែកលើមូលហេតុដែលបានរៀបរាប់ខាងលើ ស.ព.អ ស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធការលើកលែងចោទប្រកាន់ ដោយយោងទៅលើការសន្និដ្ឋានខុសរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា យឹម ទិត្យ មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក និងសុំឲ្យបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ | លោកស្រី Brenda J. HOLLIS សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |